# គណៈធម្មយាត្រាបំពេញបុណ្យ
# ដែនដីពុទ្ធភូមិ

## ឥណ្ឌា ~ នេប៉ាល់



ប្រមូលរៀបរៀងដោយ


ធម្មានន្ទ
វ៉ាន់ ចាន់សារ៉េន






# គណៈធម្មយាត្រាបំពេញបុណ្យ
# ដែនដីពុទ្ធភូមិ

*រៀបរៀងដោយ*

*ធម្មានន្ទ វ៉ាន់ ចាន់សាវ៉ែន*

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*
*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*
*ព.ស.២៥៥៧*
*គ.ស.២០១៣*

| | |
|---|---|
| ឈ្មោះសៀវភៅ | គណៈធម្មយាត្រាបំពេញបុណ្យ |
| | ដែនដីពុទ្ធភូមិ |
| រៀបរៀងដោយ | ធម្មានន្ទ វ៉ាន់ ចាន់សាវ៉ែន |
| អ្នកមានឧបការៈ | ព្រះគ្រូទេវសត្ថា ពឿយ មេត្តា |
| | ប្រធានគណៈធម្មយាត្រាដែនដីព្រះពុទ្ធភូមិ |
| | ឧបាសក សំ សុផល ប្រធានហេរញ្ញិក |
| | ពុទ្ធិកបណ្ឌិតសភា |
| | លោក រស់ សេរីវណ្ណាត សមាជិក |
| កាលបរិច្ឆេទ | ព.ស. ២៥៥៧ គ.ស.២០១៣ |
| ការផ្សាយ | ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា |
| | នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |



# អតីតព្រះមហាវីរក្សត្រ ព្រះបាទ នរោត្តម សីហនុ
# ទ្រង់ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍
# ទ្រង់បានសាងផ្នួសជាបព្វជិតក្នុងព្រះពុទ្ធសាសនា

"ព្រះសមណគោតម ដែលជាម្ចាស់សាសនា ទ្រង់បានប្រទានឱសថ គឺព្រះសទ្ធម្ម ស្រោចស្រង់មនុស្សលោក ដែលមានរោគខាងកិលេសតណ្ហា ឲ្យសះជាបាន សមគួរតាមនិស្ស័យ ។ ព្រះអង្គជាមហាសាស្តាក្នុងលោក មានព្រះញាណខ្ពស់បំផុត ទីងរកសាស្តាដទៃស្មើគ្មាន" ។

ព្រះបន្ទូល **ព្រះករុណា ព្រះបាទនរោត្តម សីហនុ**

នៅថ្ងៃទី ២០ ខែ ឧសភា ១៩៥៨ ក្នុងឱកាសសម្ពោធទស្សនាវដ្តីពុទ្ធិកសិក្សា



ព្រះករុណា ព្រះបាទ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ទ្រង់ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍

**ទីឃាយុកោ ហោតុ មហារាជ**

**សូមមហារាជ ទ្រង់ព្រះចម្រើន**

*ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*

*ជំពូកទី ២ មាត្រា ៤៣ ចែងថា*

*ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ*

# សំវេជនីយដ្ឋាន
# ស្ថានទីដ៏អស្ចារ្យ ៤ កន្លែង



អគ្គោហមស្មិ លោកស្ស, ជេដ្ឋោហមស្មិ លោកស្ស,
សេដ្ឋោហមស្មិ លោកស្ស,អយមន្តិមា ជាតិ,
នត្ថិទានិ បុនព្ភវោ ។



កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ
ឧបសុស្សតុ និស្សេសំ សរីរេ មំសលោហិតំ។
ន ត្វេវាហំ សម្មាសម្ពោធឹ អប្បត្វា ឥមំ បល្លង្កំ
ភិន្ទិស្សាមិ។



ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ
លោកានុកម្បាយ អត្ថាយ ហិតាយ
សុខាយ ទេវមនុស្សានំ។



ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា
អប្បមាទេន សម្បាទេថ។

## សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត អភិធជមហារដ្ឋគុរុ
## អគ្គមហាបណ្ឌិត និងជាបណ្ឌិតអក្សរសាស្រ្តខ្មែរ
## បាននិមន្តមកក្រាបថ្វាយបង្គំ ស្ថានទីពោធិបល្លង្ក និងគល់ពោធិព្រឹក
## ដែលព្រះសម្ពុទ្ធជាម្ចាស់នៃយើងទ្រង់ត្រាស់ដឹង
## ក្នុងស្រុកគយា រដ្ឋពិហារ ប្រទេសឥណ្ឌា



ប្រសិនបើព្រះតេជគុណឬញាតិញោមទាំងក្នុង និងក្រៅប្រទេស មានបំណងចង់មក ទស្សនា ក្រាបថ្វាយបង្គំចំពោះព្រះបរមសម្ពុទ្ធ ឬ ជួយឧបត្ថម្ភកសាងវត្តខ្មែរនៅដែនដីពុទ្ធភូមិឥណ្ឌា និងនេប៉ាល់ សូម មេត្តាទំនាក់ទំនងតាម រយៈលេខទូរស័ព្ទ និងអាសយដ្ឋានដូចបាន ប្រគេន និងជូនខាងក្រោម ៖



**ព្រះទេវសត្ថា ពឿយ មេត្តា** ព្រះចៅអធិការវត្តខ្មែរទាំង ៦ និងជាប្រធានសមាគមសមណសិស្ស និងនិស្សិតខ្មែរប្រចាំប្រទេសឥណ្ឌា

*ទូរស័ព្ទ* (0091) 9971178336

E_mail mettapoeuy@yahoo.com

Cambodia Monastery Bodh Gaya,
Dist.Gaya, 824231 Bihar India

ប្រសិនបើ ព្រះតេជគុណ ពុទ្ធបរិស័ទមានបំណងទៅនមស្ការថ្វាយបង្គំតាមពុទ្ធដ្ឋាននានា ក្នុងប្រទេសឥណ្ឌា នេប៉ាល់ និងតាមប្រទេសផ្សេងៗទៀត ដូចតួមាជាដើម សូមទាក់ទងខាងក្រោមនេះ



**លោក សំ សុផល ប្រធានហេរញ្ញិកពុទ្ធិកបណ្ឌិតសភា**

**ទូរស័ព្ទលេខ** 012 79 28 53, 077 70 00 15

**ឬទីតាំងពុទ្ធិកបណ្ឌិតសភា**

**ក្នុងសាកលវិទ្យាល័យបញ្ញាសាស្ត្រ ខាងត្បូងវិមានឯករាជ្យ ៥00 ម៉ែត្រ អគារលេខ ១៨៤ មហាវិថីព្រះនរោត្តម ។**

**ភ្លេងជាតិ នគររាជ**

១. សូមពួកទេវតា　　រក្សា មហាក្សត្រយើង
ឱ្យបានរុងរឿង　　ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ　　សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះន-របតី　　វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ　　បុរាណថ្កើងថ្កាន។

២. ប្រាសាទសិលា　　កំបាំងកណ្ដាលព្រៃ
គួរឱ្យស្រមៃ　　នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម　　គង់វង្សនៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ　　ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន　　យូរអង្វែងហើយ។

៣. គ្រប់វត្តអារាម　　ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ　　រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក　　ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា　　នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ　　ជាមហានគរ។

## បទសូត្រពេលកំពុងបង្ហូតទង់ព្រះពុទ្ធសាសនា

១. សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទ និងពណ៌ដ៏ភ្លឺផ្លេក។

២. ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើន អនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរ ពន់ពេកក្រៃកន្លង។

៣. ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃសម្ពុទ្ធធំ ចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គ ជាអម្ចាស់។

៤. ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជា ពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែង ឲ្យណាស់គ្រប់ៗគ្នា។

៥. សូមសាសនាពុទ្ធ ចំរើនបំផុត រុងរឿងវិសុទ្ធិ ថ្ងៃថ្លា ហើយមាន
ជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លា ច្រើនសែនលាន។

៦. មានចិត្តស្នេហា គោរពបូជា ចំពោះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ។

៧. យើងខេមរជាតិ ទាំងគ្នាខ្មីឃ្មាត កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។

៨. ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា។

## បទសូត្រទង់ព្រះពុទ្ធសាសនាពេលបង្ហូតឡើងហើយ

១. ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថា ព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មី ទាំងប្រាំមួយពណ៌។
២. ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុង ប្រសើរបវរ
ឆ្វៀលឆ្វាត់កាយជើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
៣. កំណើតនៃព្រះរស្មី កើតដោយបារមី នៃព្រះភគវា
ធ្វើទានឥតមានរុញរា កាលដែលនៅជា ព្រះពោធិសត្វ។
៤. រស្មីពណ៌ខៀវនោះណា កាលឆ្កៀលនេត្រា ទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រ នាមស្រីពិរាស្ត្រ។
៥. រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារ សាច់ដៃធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាង់មាស ទ្រង់វៃបណ្ឌិត។
៦. រស្មីក្រហមនោះណា កាលដែលមាតា ពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត កាត់បេះដូងបិទ ធ្វើថ្នាំមាតា។
៧. រស្មីពណ៌សសុទ្ធសាធ កាលជាព្រះទានវេស្សន្តរក្សត្រា
ឱ្យទានជីវិសសោភា ដល់ព្រាហ្មណ៍ប្រាថ្នា យកពោធិញ្ញាណ។
៨. រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់ យក្សចាប់យកទាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឱ្យយក្សសាមាន្យ ស៊ីប្តូរជីវិត។
៩. រស្មីភ្លឺផ្លេកពណ្ណរាយ កាលជាទន្សាយ ឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិត ជាអត់អាហារ។
១០. រស្មី–ខៀវ–លឿង–ក្រហម ស–ហង្សទានព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារ ចងចាំទុកអើយ។

**មាតិកាអត្ថបទ**


| *លំដាប់រៀន* | *មាតិកា* |
|---|---|
| **បទសរភញ្ញ** | **១** |
| **រតនត្តយបូជា** | **២** |
| **ពុទ្ធរតនប្បណាម** | **២** |
| **ធម្មរតនប្បណាម** | **៦** |
| **សង្ឃរតនប្បណាម** | **៩** |
| **បារមីទាំង៣០** | **១៣** |
| **ធាតុចេតិយនមស្ការគាថា** | **១៧** |
| **នមស្ការស្នាមព្រះពុទ្ធបាទ** | **១៩** |
| **មហាបុរិសលក្ខណៈ ៣២ ប្រការ** | **២០** |
| **បាទវន្ទនា** | **២៣** |
| **សច្ចកិរិយាខាងក្រោយធ្វើបទនមស្ការ** | **២៥** |
| **នមស្ការបូជនីយវត្ថុ គ្រប់ទីកន្លែង** | **២៨** |
| **នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ** | **២៩** |
| **នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ** | **៣១** |
| **ពុទ្ធជយមង្គលគាថា (ពាហុំ)** | **៣៣** |
| **គាថាជិនបញ្ជរ** | **៣៨** |
| **សីមាប្រាំបួនទិស** | **៤៣** |
| **មន្តគាថាមហាមកុដ** | **៤៥** |
| **រំលឹកដល់ទេវតា ៤ ទិស រក្សាឱ្យសុខ** | **៤៥** |
| **អានុភាពព្រះរតនត្រ័យ** | **៤៧** |
| **នមស្ការព្រះពុទ្ធតៃសជ្ជគុរុ** | **៥០** |
| **ពុទ្ធដ្ឋានដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា** | **៥៤** |

| | |
|---|---|
| លុម្ពិនី ស្ថានទីប្រសូត | ៥៦ |
| បូជាស្ថានទីព្រះពុទ្ធទ្រង់ប្រសូត | ៦០ |
| ពុទ្ធគយា | ៦១ |
| បដិច្ចសមុប្បាទ អនុលោម | ៦២ |
| ព្រះពុទ្ធទ្រង់ឧទានក្នុងបឋមយាម | ៦៣ |
| បដិច្ចសមុប្បាទ បដិលោម | ៦៣ |
| ព្រះពុទ្ធទ្រង់ឧទានក្នុងមជ្ឈិមយាម | ៦៤ |
| ព្រះពុទ្ធទ្រង់ឧទានក្នុងបច្ឆិមយាម | ៦៥ |
| សត្តមហាឋាន | ៦៦ |
| ១.ពោធិបល្លង្ក | ៦៧ |
| ទេវគ្រឿងសក្ការៈបូជាត្រង់ទីព្រះពុទ្ធត្រាស់ដឹង | ៦៧ |
| ២.អនិមិសចេតិយ | ៦៨ |
| ៣.រតនចង្កមចេតិយ | ៦៩ |
| ៤.រតនឃរចេតិយ | ៧០ |
| បច្ចយុទ្ទេសោ | ៧១ |
| ៥.អជបាលនិគ្រោធ | ៧៣ |
| មារអារាធនាព្រះពុទ្ធបរិនិព្វាន | ៧៥ |
| ៦.ស្រះមុចលិន្ទ | ៧៦ |
| ៧.រាជាយតនចេតិយ | ៧៨ |
| ព្រហ្មអារាធនាព្រះពុទ្ធអង្គ ត្រង់អជបាលនិគ្រោធ | ៨១ |
| ព្រះពុទ្ធទ្រង់ចាប់ផ្តើមសម្តែងព្រះធម៌ | ៨៦ |
| ព្រៃឥសិបតនមិគទាយវ័ន | ៩០ |
| ធម្មចក្កប្បវត្តនសុត្តារម្ភោ | ៩៥ |
| ធម្មចក្កប្បវត្តនសូត្រ | ៩៦ |
| បូជាស្ថានទីព្រះពុទ្ធសម្តែងធម្មចក្ក | ១០៩ |
| ស្ថានទីបរិនិព្វានរបស់ព្រះពុទ្ធជាអម្ចាស់ | ១១០ |
| មហាសុទស្សនសូត្រ | ១១២ |
| វេឡុវគ្រាម | ១៤០ |
| ចាបាលចេតិយ | ១៤៥ |
| មារអារាធនាព្រះពុទ្ធបរិនិព្វាន | ១៤៩ |

អាយុសង្ខារឱស្សជ្ជនំ ១៥៤

ក្ជាគារសាលានាព្រៃមហាវ័ន ១៥៦

ព្រះពុទ្ធសំឡឹងមើលក្រុងវេសាលី ១៦០

សាលវ័នក្រុងកុសិនារាទីបរិនិព្វាន ១៦៣

ចតុសំវេជនីយដ្ឋាន គឺកន្លែងដ៏អស្ចារ្យ ៤ ១៦៥

សុភទ្ទបរិព្វាជកសួរបញ្ហា ១៦៦

ព្រះពុទ្ធប្រគល់ធម្មវិន័យជាព្រះសាស្ដា ១៦៩

**បច្ឆិមវាចា គឺពាក្យបណ្ដាំចុងក្រោយរបស់ព្រះពុទ្ធ ១៧០**

**ពាក្យបូជាព្រះពុទ្ធបដិមាបរិនិព្វាន ១៧៥**

**ពាក្យបូជាព្រះស្តូបបរិនិព្វាន ១៧៥**

**មកុដពន្ធនចេតិយ ១៧៦**

**បូជាស្ថានទីមកុដពន្ធនចេតិយ ១៧៨**

**មូលគន្ធកុដិវត្តជេតពន ១៧៩**

បូជាស្ថានទីមូលគន្ធកុដិ ១៧៩

ស្ថានទីស្តូបយមកបាដិហារ្យ ១៨០

បូជាស្ថានទីស្តូបយមកបាដិហារ្យ ១៨០

ស្ថានទីសម្ដែងមហាសតិប្បដ្ឋាន ដែនដីកុរុ ១៨២

ស្វាធ្យាយឧទ្ទេសនៃ**មហាសតិបដ្ឋានសូត្រ** ១៨២

ស្តូបសង្កស្ស ស្ថានទីព្រះពុទ្ធចុះពីស្ថានតាវតិង្ស ១៨៥

ពាក្យបូជាស្តូបសង្កស្សនគរ ១៨៦

រតនសូត្រ ១៨៨

ធម្មស្សវនានិសំសកថា ១៩៨

មង្គលចក្កវាឡ ១៩៩

សរណាទីបិកាគាថា ២០៣

ទលិទ្ទសុត្តគាថា ២០៤

អត្ថន័យនៃពាក្យថា ព្រះរតនត្រ័យ ២០៤

ច្រួចទឹក ឧទ្ទិសផលបុណ្យ ២០៦

ការសូមខមាទោសចំពោះសព្វសត្វ ២០៧

សុខាភិយាចនគាថា ២០៨

បត្តិទានគាថា ២០៩

ច្រួចទឹកឧទ្ទិសបុណ្យ ២១២

សព្វបត្តិទានគាថា ២១២

ប្រោះទឹក បត្តិទានគាថា ២១៣
ផ្សាយមេត្តាចំពោះខ្លួនឯង (សម្រាប់បុរស) ២១៥
ផ្សាយមេត្តាចំពោះខ្លួនឯង (សម្រាប់ស្ត្រី) ២១៥
ផ្សាយមេត្តាដល់អ្នកណានីមួយ ២១៦
ផ្សាយមេត្តាមិនកំណត់ ២១៦
ធម៌ផ្សាយមេត្តា ២១៧
សិទ្ធិយាចនគាថា ២១៩
បត្ថយាចនគាថា ២១៩
មន្តសៃយសាស្ត្រ តាមបែបព្រះពុទ្ធសាសនាសុទ្ធសាធ ២២១
បន្ទាប់ពីបទនមស្ការព្រះរតនត្រ័យរួច ក៏គួរថ្វាយបង្គំគ្រូបាអាចារ្យ ២២២
រតនមាលា កម្រងព្រះពុទ្ធ ២៨ ព្រះអង្គ ២២៥
មន្តការពារភយន្តរាយ ២៣០
ចុទ្ទសមគាថា (បជោតា ១៤ បទ) ២៣១
គរហសន្តិគាថា ២៣៣
ទសទិសពុទ្ធគាថា ២៣៥
បណ្ដូលព្រះពុទ្ធគុណ ៩ ២៣៥
នវហរគុណគាថា ២៣៦
លុបឥតិបិសោ-ភគវាតិ (ធ្វើជាផង់ផ្សេងៗ) ២៣៧
លុបព្រះនវហរគុណ ២៣៨
លុបបណ្ដូលព្រះពុទ្ធគុណ ២៣៨
លុប អសំសុ សំសុ សុ ២៣៨
លុបឥស្វាសុ ២៣៩
លុបសុស្វាឥ ២៣៩
មន្តគុណព្រះរតនត្រ័យ ២៣៩
មន្តបណ្ដូលលោកុត្តរធម៌ ២៤០
សូធ្យបូជាព្រះគវម្បតិ (ព្រះគវម្ប៍) ២៤០
សូធ្យបូជាព្រះឧបគុត្ត ២៤០
សូធ្យបូជាព្រះសីវលី ២៤១

| | |
|---|---|
| **សូត្របូជាព្រះមហាកច្ចាយនៈ** | ២៤១ |
| **ន មណីចិន្តា** | ២៤២ |
| **សោឡសមង្គល** | ២៤៣ |
| **ត្រីនិសិន្នេ** | ២៤៤ |
| **ហៅសូត្រត្រឡប់មកវិញ** | ២៤៤ |
| **បូជាទេវតាស្ថិតនៅផ្កាយទាំង ៩ ឬផ្កាយនព្វគ្រោះ** | ២៤៥ |
| **អាការវត្តា (ធម៌អាការវតាពណ៌នាព្រះពុទ្ធគុណ)** | ២៤៦ |
| **កំពូលកណ្ឌព្រះត្រៃបិដក** | ២៥៨ |
| **ធារណបរិត្ត** | ២៧៧ |
| **អសីតិមហាសាវ័ក** | ២៨២ |
| **ជីវទានបាឋៈ (ធម៌ជីវទាន)** | ២៨៤ |
| **មហាមេត្តាបាឋ (ធម៌មហាមេត្រី)** | ២៨៩ |
| **មហាសមយសូត្រ** | ២៩៨ |
| **ឧប្បាតសន្តិ** *បទសូធ្យរម្ងាប់ឧត្បាត ឬរម្ងាប់ហេតុអន្តរាយ* | ៣០៨ |
| **ឥតិបិសោរតនមាលា** | ៣៩៤ |
| **នមក្ការបាលី-ប្រែ** | ៤៣៤ |
| **ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ** | ៤៥៥ |
| **បទថ្វាយផ្កា** | ៤៥៥ |
| **នមោ ៨ បទ** | ៤៥៦ |
| **នមោ ៣ មេ** | ៤៥៦ |
| **នមោ ៣ បទរួបរួមជាមួយបទ** | ៤៥៧ |
| **នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ** | ៤៥៨ |
| **ពាក្យវេរសម្រាប់កឋិនចីវរ** | ៤៦១ |

# បទសរភញ្ញ

សូមថ្វាយបង្គំ-ព្រះសម្ពុទ្ធ ប្រសើរបំផុត-ក្នុងលោកា
ជាគ្រូនៃមនុស្ស-និងទេវតា ទ្រង់ត្រាស់ទេសនា-ប្រដៅសត្វ
ចង្អុលឲ្យដើរ-ផ្លូវកណ្ដាល មាគ៌ាត្រៃកាល-អាចកម្ចាត់
ទុក្ខភ័យចង្រៃ-ឲ្យខ្ចាយបាត់ អាចកាត់សង្សា-រះទុក្ខបាន ។
សាសនាព្រះអង្គ-នៅសព្វថ្ងៃ សត្វមាននិស្ស័យ-ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់-ចេះចាំបាន កាន់តាមលំអាន-បានក្ដីសុខ
ឥតមានសុខណា-ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ-ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ-តទៅមុខ ក្ដីសុខនឹងមាន-ព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំ-ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ-ទាំងគ្រប់សព្វ
រួមជាត្រៃរត្ន-គួរគោរព ជាម្លប់ត្រជាក់-នៃលោកា
ព្រះរូបព្រះធាតុ-នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ-ព្រះសាស្ដា
សូមគុណត្រៃរត្ន-ជួយខេមរា ឲ្យបានសុខា-តរៀងទៅ ។

**បទសរភញ្ញចប់**

# ធម៌នមស្ការ

## រតនត្តយបូជា

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតា-
បិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

*ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះ { ពុទ្ធ / ធម៌ / សង្ឃ } ជាម្ចាស់ ដោយគ្រឿងសក្ការៈ ទាំងឡាយមានទៀន និងធូបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។*

### ពុទ្ធរតនប្បណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

*(សូត្រ ៣ ដង)*

*ប្រែថា កិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*(ក្រាបថ្វាយបង្គំម្ដង)*

យោ សន្និសិន្នោ  វរពោធិមូលេ
មារំ សសេនំ  មហន្តំ វិជេយ្យោ
សម្ពោធិមាគច្ឆិ  អនន្តញាណោ
លោកុត្តមោ តំ  បណមាមិ ពុទ្ធំ ។

ប្រែថា ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គ នោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច  យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា  អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វាន កន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជា ព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ**[1] ។

<u>ប្រែថា</u> **ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ*

**សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ*

**វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥*

**សុគតោ** *ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន*

**លោកវិទូ** *ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក*

**អនុត្តរោ** *ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន*

**បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន*

---

*១ អង្គុត្តរនិកាយ ឆកនិបាត ត្រង់អាហុនេយ្យវគ្គ ៤៦/១២*

**សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្ដាចារ្យនៃទេវតា និងមនុស្សទាំងឡាយ*

**ពុទ្ធោ** *ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង*

**ភគវា** *ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

*(ក្រាបថ្វាយបង្គំម្ដង)*

*រួចហើយត្រូវប្រកាសប្ដេជ្ញាខ្លួនចំពោះព្រះពុទ្ធគុណថា៖*

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

<u>*ប្រែថា*</u> **នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ* **ពុទ្ធោ មេ សរណំ វរំ** *មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្ដីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*(ក្រាបថ្វាយបង្គំម្ដង)*

*រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា៖*

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ខមតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

*(ក្រាបថ្វាយបង្គំម្តង)*

**ធម្មរតនប្បណាម**

អដ្ឋង្គិការិយបថោ ជនានំ

មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

និយ្យានិកោ តំ បនមាមិ ធម្មំ ។

*ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

យេ ច ធម្មា អតីតា ច　　យេ ច ធម្មា អនាគតា

បច្ចុប្បន្នា ច យេ ធម្មា　　អហំ វន្ទាមិ សព្វទា ។

*ប្រែថា* ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែល និព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

*គួរបង្អោនកាយវាចា ហើយតាំងចិត្តរឭកដល់ព្រះធម្មគុណថា៖*

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ[២] ។**

*ប្រែថា* **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ

**ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១

**សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង

**អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គ កើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឹតយូរឡើយ

**ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន

---

២ អង្គុត្តរនិកាយ ឆក្កនិបាត ត្រង់អាហុនេយ្យវគ្គ ៤៦/១៣

**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃការនៃវា

**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ក្រាបថ្វាយបង្គំម្តង)

*ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា៖*

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ

**ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តី ជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្តង)

*រួចហើយត្រូវសូមខមាទោសនឹងព្រះធម្មគុណថា៖*

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

<u>ប្រែថា</u> **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង*

**ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់*

**ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំ ព្រះករុណា ។*

*(ក្រាបថ្វាយបង្គំម្ដង)*

## សង្ឃរតនប្បណាម

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បណមាមិ សង្ឃំ ។

<u>ប្រែថា</u> *ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថា ជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្ដង)*

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។

*<u>ប្រែថា</u> ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបាន សម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយ បង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង។*

*(ក្រាបថ្វាយបង្គំម្តង)*

*រួចហើយគប្បីតាំងចិត្តរឭកដល់ព្រះសង្ឃគុណដោយបន្ពោនកាយវាចាថា៖*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ[៣] ។**

*<u>ប្រែថា</u>* **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌*

---

*៣- បិដក៤៦/៦ ភិក្ខុប្រកបដោយធម៌៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកគួរបូជា។ល។ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរបស់សត្វលោក គឺៈ១-ភិក្ខុប្រកបដោយសទ្ធិន្ទ្រិយ ២-វីរិយិន្ទ្រិយ ៣-សតិន្ទ្រិយ ៤-សមាធិន្ទ្រិយ ៥-បញ្ញិន្ទ្រិយ ៦-បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។*

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា*

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង*

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា*

**យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១*

**អដ្ឋ បុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១*

**ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវក នៃព្រះដ៏មានព្រះភាគ*

**អាហុនេយ្យោ** *លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា*

**ចាហុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា*

**ទក្ខិណេយ្យោ** *លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា*

**អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ*

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។*

*(ក្រាបថ្វាយបង្គំមួង)*

*តទៅគប្បីប្រកាសប្តេជ្ញាខ្លួនចំពោះព្រះសង្ឃគុណថា ៖*

**នត្ថិ មេ សរណំ អញ្ញំ　　សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន　　ហោតុ មេ ជយមង្គលំ ។**

*ប្រែថា* **នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ*

**សង្ឃោ មេ សរណំ វរំ** *មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា*

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តី ជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*រួចហើយត្រូវសូមខមាទោសនឹងព្រះសង្ឃគុណថា ៖*

**ឧត្តមង្គេន វន្ទេហំ　　សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ　សង្ឃោ ខមតុ តំ មមំ ។**

ប្រែថា **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង

**សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់

**សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ ខ្ញុំព្រះករុណា។

(ក្រាបថ្វាយបង្គំម្តង)

## បារមីទាំង៣០

**ឥតិបិ ទានបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបារមី មែនព្រោះហេតុដូច្នេះ ។

**ឥតិបិ ទានឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានឧបបារមី មែនព្រោះហេតុដូច្នេះ។

**ឥតិបិ ទានបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ។

**ឥតិបិ សីលបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបារមី មែនព្រោះហេតុដូច្នេះ។

**ឥតិបិ សីលឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលឧបបារមី មែនព្រោះហេតុដូច្នេះ។

**ឥតិបិ សីលបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មាព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយវិរិយបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវិរិយឧបបារមី មែនព្រោះហេតុដូច្នេះ ។*

១៥

**ឥតិបិ វិរិយបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវិរិយបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទសចារមិសម្បន្នោ ទសឧបចារមិសម្បន្នោ ទសបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមី១០ បរិបូណ៌ហើយ ដោយឧបបារមី១០ បរិបូណ៌ហើយដោយបរមត្ថបារមី១០ មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ សមត្តឹសបារមិសម្បន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមីទាំង៣០ មែនព្រោះហេតុដូច្នេះ ។*

**ធាតុចេតិយនមស្ការគាថា**

១. មហាគោតមោ ជិនវរោ　　កុសិនារម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ　　តេសុ តេសុ បទេសតោ។

*ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ　　សារីរិកធាតុ ព្រះមហាគោតម*
*ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ　　ជិតបុរីរម្យ ក្រុងកុសិនារា ។*
*កិរិយាផ្សាយនូវ ព្រះធាតុនានា　　ផ្សេងៗពីគ្នា ក្នុងទីទាំងឡាយ*
*ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ　　ព្រះធាតុទាំងឡាយ គ្រប់ទីនោះៗ ។*

២. ឧណ្ហីសំ ចតស្សោ ទាឋា　　អក្ខកា ទ្វេ ច ធាតុយោ
អសម្ភិន្នា ឥមា សត្ត　　សេសា ភិន្នា វ ធាតុយោ។

*ព្រះសារីរិកធាតុ ល្អស្អាតទាំងឡាយ　　ដែលមិនបែកសោះ ប្រាំពីរព្រះអង្គ*
*គឺព្រះឧណ្ហី- សធាតុបញ្ចង់(៤)　　មានមួយព្រះអង្គ នៅគង់ល្អស្អាត*
*និងព្រះទាឋា(២) សារីរិកធាតុ　　ទាំង៤ អង្គស្អាត គ្មានឃ្លាតបែកចេញ*
*ព្រះអក្ខកធាតុ(៣) នៅស្អាតពេញលេញ　　គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ*
*ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់　　ប្រាំពីរព្រះអង្គ គង់នៅទាំងអស់*
*ព្រះសារីរិកធាតុ ដ៏សេសពីនោះ　　បែកចេញចំពោះ ចំណែកជំតូច ។*

៣.មហន្តា មុគ្គមត្តា(៤)　　ច　　មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច　　នានាវណ្ណា ច ធាតុយោ

---

*៤- ធ្មឹងថ្គាម ។ ២- ព្រះចង្កូមកែវ ។ ៣- ធ្មឹងដងកាំបិត ។ (៤) កន្លែងខ្លះ មុគ្គមាសាវ. ខ្លះថា ភិន្នមុត្តា ។*

ឯព្រះបរមធាតុ  មានខ្នាតបីយ៉ាង  លោកបានពោលអាង  ទុកជាលំដាប់
ព្រះធាតុខ្នាតធំ  ទំហំប៉ុនគ្រាប់  សណ្តែកបាយកាប់  កាត់មួយកំណាត់
ព្រះធាតុកណ្តាល  ដូចកាលគេកាត់  ប៉ុនមួយកំណាត់  នៃគ្រាប់អង្ករ
ព្រះធាតុខ្នាតតូច  ល្អិតល្អបវរ  លោកបានព្យាករ  ថាប៉ុនគ្រាប់ស្ពៃ ។

## ៤. មហន្តា សុវណ្ណវណ្ណា ច  មុត្តវណ្ណា ច មជ្ឈិមា
## ខុទ្ទកា មកុលវណ្ណា ច  សោឡស ទោណមត្តិកា

ព្រះសារីរិកធាតុ  នៃព្រះភគវា  មានពណ៌ផ្សេងគ្នា  ទាំងបីវិលាស
ព្រះធាតុខ្នាតធំ  មានពណ៌ដូចមាស  ពន្លឺឱភាស  វិសេសពេកក្តាត់ ។
ព្រះធាតុកណ្តាល  វិលាសដូចរ័តន៍  មុក្តាប្រាកដ  ស្មើរចាប់ច្រឡំ
ព្រះធាតុខ្នាតតូច  ដូចផ្កាម្លិះសម  ពណ៌សស្រគាំ  ក្រពុំស្រស់ស្អាត
សរុបព្រះធាតុ  នៃព្រះសាស្តា  លោកបានពោលថា  បើគិតតាមខ្នាត
ដប់ប្រាំមួយនាឡិ  មិនបាត់បង់ខាត  បែងចែកជាខ្នាត  ចំនួនមួយទោណ ។

## ៥. មហន្តា បញ្ច នាឡិយោ  នាឡិយោ បញ្ច មជ្ឈិមា
## ខុទ្ទកា ច នាឡី ចេវ ឯកា  សព្វាបិ ធាតុយោ ។

ព្រះបរមធាតុ  មុនីនាថសាស្តា  ទាំងអស់នោះណា  បែកជាតូចធំ
លោកបានពោលទុក  ថាមានទំហំ  មានតូចមានធំ  មានខ្នាតកណ្តាល ។
ព្រះធាតុខ្នាតធំ  ចំនួនប្រាំនាឡិ  ព្រះធាតុកណ្តាល  ប្រាំនាឡិប្រាកដ
ព្រះធាតុខ្នាតតូច  ប្រាំមួយនាឡិគត់  តាមលោកកំណត់  បីយ៉ាងដូច្នេះ ។

## ៦. អហំ វន្ទាមិ ទូរតោ

ខ្ញុំសូមលើកហត្ថ ផ្គងនមស្ការ  ព្រះធាតុនោះណា អំពីចម្ងាយ
ឧណ្ហីសាក្ខកធាតុទាំងឡាយ  ប្រណម្យដោយកាយ និងវាចាចិត្ត ។
ព្រះទាឋធាតុ និងធាតុដទៃ  នៃព្រះជិនស្រី ស្ថិតនៅឆ្ងាយជិត
ខ្ញុំសូមនមស្ការ ដោយត្បូងខ្ញុំពិត  ឆ្ពោះព្រះវិជិត- មារនោះហោង ។

## នមស្ការស្នាមព្រះពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**

**តិលោកកេតុំ តិភវេកនាថំ**

**យោ លោកសេដ្ឋោ សកលំ កិលេសំ**

**ជេត្វាន ពោធេសិ ជនំ អនន្តំ ។**

*ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្តឲ្យត្រាស់ដឹងហើយ ខ្ញុំសូម ក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីប្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។*

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

*ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្លូវខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូង ចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។*

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ

នទិយា បញ្ច បាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

*ខ្ញុំសូមនមស្ការអំពីចម្ងាយនូវស្ថានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺស្ថាន លើភ្នំសុវណ្ណមាលិកៈ ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។*

## មហាបុរិសលក្ខណៈ ៣២ ប្រការ

១. យោ បុព្វេ កតបុញ្ញត្តា សុប្បតិដ្ឋិតបាទកោ
ចក្កង្កិតតលោ ទីឃ- បណ្ហិអង្គុលិព្រហ្មុជុ។

*ព្រះមហាមុនីព្រះអង្គទ្រង់បំពេញបុណ្យក្នុងកាលមុន ទើប*
*មានផ្ទៃព្រះបាទទាំងគូរាបស្មើល្អ ប្រដាប់ដោយចក្រ កែង*
*ព្រះបាទវែង ម្រាមព្រះហស្តវែង និងម្រាមព្រះបាទវែង*
*ព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម ។*

២. សត្តុស្សទោ មុទុតលុ- ណជាលហត្ថបាទកោ
ឧស្សង្ខុទគ្គលោមោ ចេ- ណិជង្ឃោ សុខុមច្ឆវិ ។

*មានព្រះមំសៈគឺសាច់ ៧ អន្លើដោយបរិបូណ៌ (គឺខ្នងព្រះ*
*ហស្ត ២, ខ្នងព្រះបាទ ២, ព្រះអង្សា ២, ព្រះសូរង ១)*
*ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ មានប្រទាក់ក្រឡា*
*ដូចជាសំណាញ់ មានព្រះបាទដូចជាអណ្តែតឡើងខាងលើ*
*មានព្រះលោមាមានចុង-ងឡើងលើ មានព្រះជង្ឃាគឺស្មង*
*វៀវមូលត្រសូល មានព្រះឆវីល្អិតផូរផង់រលីងស្រិល ។*

**៣.សុវណ្ណវណ្ណោ កោសម្ហិ ឱហិតវត្ថគុយ្ហកោ**

**និគ្រោធបរិមណ្ឌល- ដ្ឋិតជានុបរាមាសោ ។**

*មានស្បែកសម្បុរថ្លៃ (លឿងភ្លឺអន្ទង់) ដូចជាសម្បុរនៃមាស មានព្រះអង្គាវយវៈដែលត្រូវលាក់កំបាំងដោយសំពត់ស្ថិត នៅក្នុងស្រោម មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌល នៃដើមជ្រៃ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាច ស្ទាបអង្អែលព្រះជានុបាន ។*

**៤.សីហកាយ-ចិតន្តរំស- សមវដ្តខន្ធកោ**

**រសគ្គសគ្គី នីលនេត្ត- គោបខុមោណ្ហីសសីសកោ។**

*មានព្រះកាយពាក់កណ្តាលខាងលើ ដូចជាកាយនៃរាជសីហ៍ មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ មានព្រះសូរងមូលសម មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារដ៏លើសលែង សម្រាប់ ទទួលរសអាហារ មានព្រះនេត្រខៀវស្រស់ មានដួងព្រះ នេត្រដូចជាភ្នែកនៃកូនគោ មានព្រះសីរ្ស ហាក់ដូចជាប្រដាប់ ដោយក្បាំងមកុដស្រេចស្រាប់ ។*

**៥.ឯកេកលោមឧណ្ណី ច តាលីសាវិរឡទន្តកោ**

**បហូតជិវ្ហាព្រហ្មស្សរោ ហោតិ សីហហនុបិ ច ។**

*មានព្រះលោមាតែ ១ សរសៃ ៗ គឺក្នុងរណ្តៅរោម ១ មាន រោម ១ មានព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម មានពណ៌សក្បុស មានព្រះទន្ត ៤០ គត់ មានព្រះជិវ្ហាដ៏ធំវែង មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្មមានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ។*

**៦.សមទន្តសុក្កទាឋោ ឥតិ ទ្វត្តឹសលក្ខណោ**

**តំ មុនិន្ទំ មហាបុញ្ញំ វន្ទាមិ បុរិសុត្តមំ ។**

*មានព្រះទន្តជិតស្និទ្ធល្អ មានព្រះទាឋា គឺចង្កូមកែវទាំង ៤ សស្អាត*
*ព្រះសម្ពុទ្ធទ្រង់មានបុរិសលក្ខណៈ ៣២ ប្រការ យ៉ាងនេះ*
*ខ្ញុំសូមនមស្ការនូវព្រះសម្ពុទ្ធ ដែលជាធំជាងអ្នកប្រាជ្ញ*
*ដែលជាអ្នកមានបុណ្យដ៏ធំ ជាបុរសដ៏ឧត្តម ។*

## **បាទវន្ទនា**

*នមស្ការស្នាមព្រះបាទ*
*ដែលប្រដាប់ដោយមង្គល ១០៨*

បាទេសុ យស្ស ជាតានិ ទ្វេ ចក្កានិ សកម្មតោ

នានាការេហិ បុណ្ណានិ វន្ទេ តំ បុរិសុត្តមំ ។

*កងចក្កទាំងឡាយពីរ ដែលបរិបូណ៌ដោយលក្ខណៈផ្សេងៗ ប្រាកដ*
*ហើយដោយកម្មរបស់ខ្លួន ក្នុងស្នាមព្រះបាទរបស់ព្រះមហាបុរស*
*អង្គណា ខ្ញុំព្រះករុណាសូមនមស្ការនូវមហាបុរសអង្គនោះ ។*

សត្តិ ច សិរិវច្ឆោ ច នន្ទិយាវដ្ដមេវ ច

សោវត្ថិកោ វដំសោ ច វឌ្ឍមានញ្ច បីឋកំ ។

*រូបលំពែង រូបផ្ទះកំពូល រូបផ្កាចន្ទ រូបសវត្ថិកៈ រូបផ្កាឈើក្រង*
*លើសីសៈ រូបថាសដាក់គ្រឿងសំណែន រូបតាំងមាស (១-៧) ។*

អង្កុសញ្ចេវ បាសាទោ តោរណំ ឆត្តមេវ ច

ខគ្គោ ច តាលវណ្ដញ្ច មោរហត្ថកវីជនី ។

*រូបកង្វេរ រូបប្រាសាទ រូបសសរបង្គោល រូបឆត្រ រូបព្រះខ័ន*
*រូបផ្លិតស្លឹកត្នោត រូបផ្លិតកន្ទុយក្ងោក (៨-១៤) ។*

ឧណ្ហីសំ មណិ បត្តញ្ច ទាមំ នីលុប្បលំ តថា

រត្តសេតុប្បលញ្ចេវ បទុមំ បុណ្ឌរិកំ តថា ។

*រូបក្បាំង រូបកែវមណី រូបបាត្រ រូបភួងផ្កាឈើ រូបព្រលឹតខៀវ*
*រូបព្រលឹតក្រហម រូបព្រលឹតស រូបផ្កាឈូកក្រហម រូបផ្កាឈូកស។*

**បុណ្ណឃដោ បុណ្ណបាតិ　　　សមុទ្ទោ ចក្កវាឡកំ**

**ហិមវា សិនេរុ ចេវ　　　សូរិយោ ចន្ទិមា តថា ។**

*រូបឆ្នាំងដាក់ទឹកពេញ រូបថាសដាក់ទឹកពេញ រូបមហាសមុទ្រ រូបភ្នំចក្កវាឡ រូបភ្នំហិមពាន្ត រូបភ្នំសិនេរុ រូបព្រះអាទិត្យ រូបព្រះចន្ទ ។ (២៤-៣១)*

**នក្ខត្តា ចតុរោ ទីបា　　　ទ្វិសហស្សបរិត្តកា**

**ចក្កវត្តិ សេតសង្ខោ　　　មច្ឆានំ យុគឡំ តថា ។**

*រូបផ្កាយនក្ខត្តឫក្ស រូបទ្វីបធំទាំង ៤ និងរូបទ្វីបតូច ២,០០០ រូបស្តេចចក្រពត្តិ រូបសង្ខស រូបត្រីគូ (៣២-៣៩) ។*

**ចក្កំ សត្ត មហាគង្គា　　　មហាសេលា មហាសរា**

**សុបណ្ណកោ សុសុមារោ　　　ធជោ បដាកមេវ ច ។**

*រូបកងចក្ក រូបស្ទឹងធំ ៧ ខ្សែ រូបភ្នំទាំង ៧ រូបស្រះធំទាំង ៧ រូបស្តេចគ្រុឌ រូបក្រពើ រូបទង់ជ័យ រូបទង់ជ្រុង (៤០-៦៥) ។*

**បាដង្គី វាលវីជនី　　　កេលាសបព្វតោ តថា**

**សីហរាជា ព្យគ្ឃរាជា　　　វលាហោ ច ឧបោសថោ។**

*រូបវហ៍ រូបផ្លិតកន្ទុយចាមរី រូបភ្នំកៃលាស រូបស្តេចរាជសីហ៍ រូបស្តេចខ្លាធំ រូបស្តេចសេះវលាហក: រូបស្តេចដំរីឧបោសថ (៦៦-៧២) ។*

**វាសុកី នាគរាជា ច　　　ហំសោ ច ឧសភោ តថា**

**ឯរាវណោ មករោ ច　　　ហរិនាវា ចតុម្មុខា ។**

*រូបស្តេចនាគវាសុកី រូបស្តេចហង្ស រូបស្តេចគោឧសភ រូបដំរីឯរាវណ*

*រូបមន្ទីរ រូបសំពៅមាសមុខបួន (៧៣-៧៨)*

សវច្ឆកា តថា គាវី កិន្នរោ កិន្នរីបិ ច

ករវីកោ មយូរោ ច កោញ្ចរាជា តថេវ ច ។

*រូបមេគោដោះ រូបកិន្នរ រូបកិន្នរី រូបសត្វករវីក រូបស្ដេចសត្វក្ងោក*
*រូបស្ដេចសត្វក្រៀល (៧៩-៨៤) ។*

ចក្កវាកទិជោ ចេវ ជីវញ្ជីវកនាមកោ

ឆ កាមាវចរា ទេវា ព្រហ្មលោកា ច សោឡស ។

*រូបស្ដេចសត្វចក្រពាក រូបស្ដេចសត្វព្រហីត រូបទេវលោក ៦ ជាន់*
*រូបព្រហ្មលោក ១៦ ជាន់ (៨៥-១០៨) ។*

ឯតានដ្ឋុត្តរសតំ លក្ខណានិ មហេសិនោ

ចាទេសុ យស្ស ទិស្សន្តេ វន្ទេ តំ បុរិសុត្តមំ ។

*លក្ខណៈ ១០៨ ទាំងនេះ រមែងប្រាកដក្នុងស្នាមព្រះបាទរបស់*
*ព្រះពុទ្ធអង្គណា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធដែលជាបុរសដ៏ឧត្ដមអង្គនោះ ។*

## សច្ចកិរិយាខាងក្រោយធ្វើបទនមស្ការ

នមស្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ

អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។

*ដោយអនុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រព*
*ទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយជាអនេក*
*ក៏ចូលឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។*

## *នមស្ការព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ*

**យោ កប្បកោដីហិបិ អប្បមេយ្យំ**
**កាលំ ករោន្តោ អតិទុក្ករានិ**
**ខេទំ គតោ លោកហិតាយ នាថោ**
**នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្វា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋា ន ។
ធ្វើកម្មជាកម្រ សត្វនិករត្រាប់ពុំបាន
គោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ មនុស្សជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**
**ភវាភវំ គច្ឆតិ ជីវលោកោ**
**នមោ អវិជ្ជាទិក្កិលេសជាលំ**
**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កាមជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា**
**វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ**
**ខេត្តញ្ញនានំ កុសលត្ថិកានំ**
**តមរិយសង្ឃំ សិរសា នមាមិ [៥] ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

**ឥច្ចេវមច្ចន្តនមស្សនេយ្យំ**
**នមស្សមានោ រតនត្តយំ យំ**
**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**
**តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំង ៣ ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកម្មាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។

---
[៥] គាថានេះដកចេញពីគម្ពីរអដ្ឋកថា សមន្តប្បាសាទិកា ត្រង់បណាមគាថា

ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ស្ថាននិព្វានហោង ។

## នមស្ការបូជនីយវត្ថុ គ្រប់ទីកន្លែង

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុម្មហាពោធឹ ពុទ្ធរូបំ សកលំ សទា។**

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរទឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាននានានោះទាំងអស់ ។
ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ ។
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត
សូមទាន់ព្រះអរិ- យមេត្រីថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

២៩

## នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ

វិបស្សិស្ស ច នមត្ថុ   ចក្ខុមន្តស្ស សិរីមតោ
សិខិស្សបិ ច នមត្ថុ   សព្វភូតានុកម្បិនោ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តី អនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី ។*

វេស្សភុស្ស ច នមត្ថុ   ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស   មារសេនប្បមទ្ទិនោ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម វេស្សភូ ព្រះអង្គមានកិលេសលាងស្អាតហើយ ព្រះអង្គមានតបធម៌ សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធ ទ្រង់ព្រះនាមកកុសន្ធៈ ព្រះអង្គញាំញីនូវមារព្រមទាំងសេនា នៃមារ ។*

កោណាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ
កស្សបស្ស ច នមត្ថុ   វិប្បមុត្តស្ស សព្វធិ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម កោណាគមនៈ ព្រះអង្គមានបាបបន្សាត់ចោលហើយ មានព្រហ្មចរិយធម៌នៅរួចហើយ សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះអង្គផុតចាក កិលេសទាំងពួងហើយ ។*

អង្គីរសស្ស នមត្ថុ        សក្យបុត្តស្ស សិរីមតោ

យោ ឥមំ ធម្មំ ទេសេសិ  សព្វទុក្ខាបនូទនំ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម*
*អង្គីរសៈ ព្រះអង្គជាបុត្រនៃសក្យរាជ ដ៏មានសិរី*
*ព្រះសម្ពុទ្ធអង្គឯណា ទ្រង់បានត្រាស់សម្តែងហើយនូវធម៌នេះ*
*ជាធម៌បន្ទោបង់នូវទុក្ខទាំងពួង ។*

យេ ចាបិ និព្វុតា លោកេ    យថាភូតំ វិបស្សិសុំ

តេ ជនា អបិសុណាថ        មហន្តា វីតសារទា។

*ម្យ៉ាងទៀត ព្រះសម្ពុទ្ធទាំងឡាយអង្គឯណា ព្រះអង្គ*
*រំលត់កិលេសហើយក្នុងលោក ទ្រង់ឃើញច្បាស់នូវធម៌តាម*
*សេចក្តីពិត ព្រះសម្ពុទ្ធទាំងឡាយនោះ ព្រះអង្គមិនមាន*
*សេចក្តីញុះញង់សឹកសៀត ទ្រង់ប្រសើរដោយព្រះគុណ*
*មានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)ទៅប្រាសហើយ។*

ហិតំ ទេវមនុស្សានំ      យំ នមស្សន្តិ គោតមំ

វិជ្ជាចរណសម្បន្នំ        មហន្តំ វីតសារទំ។

*ទេវតានិងមនុស្សទាំងឡាយ រមែងនមស្ការ នូវព្រះសម្ពុទ្ធអង្គ*
*ឯណាជាគោតមគោត្រ ជាប្រយោជន៍ដល់ទេវតានិងមនុស្ស*
*ទាំងឡាយ ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈប្រសើរ*
*ដោយព្រះគុណមានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)*
*ទៅប្រាសហើយ ។*

## នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

តណ្ហង្ករោ មហាវីរោ មេធង្ករោ មហាយសោ។

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ*
*ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធ*
*ទាំងនោះ គឺ)ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ព្រះមេធង្ករ ព្រះអង្គមានយសធំ ។*

សរណង្ករោ លោកហិតោ ទីបង្ករោ ជុតិន្ធរោ

កោណ្ឌញ្ញោ ជនបាមោក្ខោ មង្គលោ បុរិសាសភោ។

*ព្រះសរណង្ករ ព្រះអង្គធ្វើឲ្យជាប្រយោជន៍ដល់សត្វលោក*
*ព្រះទីបង្ករព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ព្រះកោណ្ឌញ្ញៈ*
*ព្រះអង្គជាប្រធាននៃពពួកជន ព្រះមង្គលៈព្រះអង្គជាបុរសដ៏ប្រសើរ ។*

សុមនោ សុមនោ ធីរោ រេវតោ រតិវឌ្ឍនោ

សោភិតោ គុណសម្បន្នោ អនោមទស្សី ជនុត្តមោ ។

*ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ ព្រះរេវតៈ*
*ព្រះអង្គញ៉ាំងសេចក្ដីត្រេកអរឲ្យចម្រើន ព្រះសោភិតៈ ព្រះអង្គបរិបូណ៌*
*ដោយព្រះគុណ ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន ។*

បទុមោ លោកបជ្ជោតោ នារទោ វរសារថិ

បទុមុត្តរោ សត្តសារោ សុមេធោ អប្បដិបុគ្គលោ។

*ព្រះបទុមៈ ព្រះអង្គញ៉ាំងលោកឲ្យភ្លឺស្វាង ព្រះនារទៈ ព្រះអង្គដូច*
*ជាសារថីដ៏ប្រសើរ ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ*
*ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ។*

សុជាតោ សព្វលោកគ្គោ　　　បិយទស្សី នរាសភោ

អត្ថទស្សី ការុណិកោ　　　ធម្មទស្សី តមោនុទោ។

*ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង ព្រះបិយទស្សីព្រះអង្គប្រសើរជាងនរជន ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ។*

សិទ្ធត្ថោ អសមោ លោកេ　　　តិស្សោ ច វទតំ វរោ

បុស្សោ ច វរទោ ពុទ្ធោ　　　វិបស្សី ច អនូបមោ។

*ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្តីទាំងឡាយ ព្រះពុទ្ធទ្រង់ព្រះនាមបុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ។*

សិខី សព្វហិតោ សត្ថា　　　វេស្សភូ សុខទាយកោ

កកុសន្ធោ សត្ថវាហោ　　　កោណាគមនោ រណញ្ជហោ

កស្សបោ សិរិសម្បន្នោ　　　គោតមោ សក្យបុង្គវោ ។

*ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឲ្យជាប្រយោជន៍ដល់សត្វទាំងពួង ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស ព្រះកោណាគមនៈ ព្រះអង្គបំបាត់បង់នូវសត្រូវ គឺកិលេស ។ ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។*

# ពុទ្ធជយមង្គលគាថា (ពាហុំ)

ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ

គ្រីមេខលំ ឧទិតឃោរសសេន មារំ

ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

| | |
|---|---|
| *ព្រះមុនិន្ទលោកាចារ្យ* | *ផ្ចាញ់ក្រុងមារចិត្តមោហន្ធ* |
| *និម្មិតដៃមួយពាន់* | *កាន់សាស្ត្រាវុធនានា ។* |
| *ជិះគ្រីមេខលជាតិ* | *កោញ្ចនាទខ្ទ័រពេសុធា* |
| *ព្រមដោយមារសេនា* | *ពន្ទឹកលន់កងស័ព្ទស៊ាន ។* |
| *ដោយធម្មពិធី* | *ទានបារមីជាប្រធាន* |
| *ក្រុងមារចាញ់ទ្រង់ញាណ* | *ប្រណម្យកាយថ្វាយវន្ទា ។* |
| *វីជយមង្គល* | *ចូរមានដល់អ្នករាល់គ្នា* |
| *ដោយតេជៈជយា* | *ព្រះឈ្នះមារគ្រោះនោះហោង ។* |

មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ

ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ

ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

| | |
|---|---|
| *ព្រះមុនិន្ទពិននាយកៈ* | *ផ្ចាញ់អាឡវៈក៏យក្សឃោរឃៅ* |
| *រឹងរូសមិនតាំងនៅ* | *ក្នុងខន្តីគុណសត្យា ។* |
| *របូតអស់រាត្រី* | *ព្រះជិនស្រីទ្រង់យុទ្ធនា* |

ក្រៃលែងក្រុងមារ    ក្នុងបឋមសម្ពោធី ។
ដោយព្រះពិធីញាណ    ទ្រង់ទូន្មានដោយខន្តី
ញុំាងចិត្តអសុរី    ឲ្យបង់ព្យសន៍ចុះវន្ទា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្នះអាឡវកយក្សហោង។

នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

ព្រះមុនិន្ទពិនជិនស្រី    ផ្ចាញ់ដំរីឈ្មោះនាឡា
គិរីវរគជា    ដ៏ហានក្លាចុះព្រេងព្រេច ។
សាហាវធាវឆេះក្រៃ    ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចាក់ក្រុតពេជ្រ    ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រប់    ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី    ញុំាងដំរីឲ្យជ្រះថ្លា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្នះនាឡាគិរី ។

ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវំ តិយោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

ព្រះមុនិន្ទពិនលោកត្រៃ          មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍          មានកម្រងគឺម្រាមដៃ ។
នៃមនុស្សដែលគាត់កាត់          មកដោតចាត់ជាមាល័យ
អង់អាចកំណាចក្រៃ          ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវងាគ្រវី          ដេញព្រះមុនីសាស្ដាចារ្យ
ចម្ងាយផ្លូវកន្តារ          កណ្ដាលព្រៃបីយោជនា ។
វីជយមង្គល          ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា          ព្រះឈ្មោះអង្គុលិមាល ។

កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា

ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ

សន្តេន សោមវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

ព្រះមុនិន្ទមានព្រះភាគ          ផ្ចាញ់ទ្រូស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា          ស្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន          ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្មោះកាលនោះ          ដោយសមាចារពិធី ។
រំងាប់ពាក្យចណ្ឌាល          នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី          គឺសច្ចំពាក្យសត្យា ។
វីជយមង្គល          ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា          ព្រះសាស្ដាឈ្មោះចិញ្ចា ។

សច្ចំ វិហាយមតិសច្ចកវាទកេតុំ

វាទាភិរោបិតមនំ អតិអន្ធភូតំ

បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ    រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា    និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់    ពាក្យសត្យត្រង់តាមគាប់ថៃ
សរសើរខ្លួនឯងក្រៃ    លើកកំពស់ដូចជងទង់ ។
បង្កើតម្បូរងងឹត    ដោយពោលពាក្យឥតទៀងត្រង់
ព្រះទ្រង់បំបាត់បង់    ដោយប្រទីបគឺបញ្ញា ។
វីជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ឈ្នះសច្ចកនិគ្រន្ថ ។

នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ

បុត្តេន ថេរភុជគេន ទមាបយន្តោ

ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

ព្រះមុនិន្ទពិនទ្រង់ញាណ    ញុំាងមោគ្គល្លានមានអំណាច
ឲ្យប្រ្លែងជានាគរាជ    ទៅទូន្មានព្យសន៍កូជង្គ ។
ឈ្មោះនន្ទោបនន្ទ    ចិត្តមោហន្ធរឿងឫទ្ធិរង់
ទិដ្ឋិកាចទ្រនង់    ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឲ្យឧបទេស    ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន    ឱនចុះចាញ់ព្រះចេស្តា ។
វីជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះភគវាឈ្នះនាគហោង ។

ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

| | |
|---|---|
| ព្រះមុនិន្ទពិនគោតម | ផ្ចាញ់មហាព្រហ្មឈ្មោះពកា |
| សម្គាល់ថាអាត្មា | រុងរឿងដោយគុណបរិសុទ្ធ ។ |
| ដែកាន់អាសិរ្ពិស | គឺចិត្តទ្រឹស្តដ៏មុះមុត |
| កាន់ខុសផ្លូវសម្ពុទ្ធ | មិនលើកលាកលះបង់ប្រាណ។ |
| ទ្រង់ឈ្នះដោយពិធី | ឱសថវិសេសសម្រាន្ត |
| ផ្សំត្រូវគាប់សន្តាន | គឺព្រះញាណប្រោសទេសនា ។ |
| រីជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជៈជយា | ឈ្នះព្រហ្មាឥតមានហ្មង ។ |

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទិ
ហិត្វាននេកវិវិធានិ ចុបទ្ទវានិ
មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ។

| | |
|---|---|
| យោ នរោ ជនឯណា | កបបញ្ញាប្រាសក្តិខ្ជិល |
| ឧស្សាហ៍សាងទានសីល | សូធ្យរំលឹកព្រះធម៌ថ្ងៃ ។ |
| គាថាប្រាំបីបទ | នេះកំណត់ឈ្មោះពុទ្ធជ័យ |
| ខំសូធ្យសព្វៗថ្ងៃ | កើតមង្គលជានិរន្តរ៍ ។ |
| សោ នរោ រីជននោះ | បានរំដោះរោគអាសន្ន |

ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្ទង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

## គាថាជិនបញ្ជរ

ជយាសនគតា ពុទ្ធា ជេត្វា មារំ សវាហិនី
ចតុសច្ចាមតរសំ បិវឹសុ យេ នរាសភា។
ព្រះពុទ្ធទាំងឡាយអង្គឯណា ជានរាសភៈទ្រង់ជាអ្នក
ដល់ព្រមនូវជ័យជម្នះហើយទ្រង់ឈ្នះនូវមារព្រមទាំង
សេនារបស់មារ ហើយព្រះអង្គទ្រង់សោយនូវទឹក
អម្រឹតគឺអរិយសច្ចៈបួន ។

តណ្ហង្ករាទយោ ពុទ្ធា អដ្ឋវីសតិ នាយកា
សព្វេ បតិដ្ឋិតា មយ្ហំ មត្ថកេ តេ មុនិស្សរា។
ព្រះពុទ្ធទាំងឡាយអង្គនោះ ជានាយកជាកំពូលនៃអ្នក
ប្រាជ្ញមានម្ភៃប្រាំបីព្រះអង្គមានព្រះពុទ្ធព្រះនាមតណ្ហង្ករ
ជាដើម សូមព្រះពុទ្ធទាំងឡាយទាំងពួងអង្គនោះ មក
ប្រតិស្ឋានលើត្បូងគឺក្បាលរបស់ខ្ញុំព្រះអង្គ ។

សិរេ បតិដ្ឋិតោ ពុទ្ធោ ធម្មោ ច មម លោចនេ
សង្ឃោ បតិដ្ឋិតោ មយ្ហំ ឧរេ សព្វគុណាករោ។
សូមព្រះពុទ្ធមកប្រតិស្ឋានលើសិរសា សូមព្រះធម៌
មកប្រតិស្ឋានត្រង់កែវភ្នែកទាំងពីរ សូមព្រះសង្ឃមក
ប្រតិស្ឋានលើទ្រូងរបស់ខ្ញុំ ។

ហទយេ អនុរុទ្ធោ ច សារិបុត្តោ ច ទក្ខិណេ
កោណ្ឌញ្ញោ បិដ្ឋិភាគស្មឹ មោគ្គល្លានោសិ វាមកេ។

*សូមព្រះអនុរុទ្ធមកប្រតិស្ឋានត្រង់ហឫទ័យរបស់ខ្ញុំ ព្រះសារីបុត្រសូមប្រតិស្ឋានលើស្មាស្តាំ ព្រះកោណ្ឌញ្ញៈសូមប្រតិស្ឋានខាងខ្នង ព្រះមោគ្គល្លានសូមប្រតិស្ឋានលើស្មាខាងឆ្វេងរបស់ខ្ញុំ ។*

ទក្ខិណេ សវនេ មយ្ហំ អាសុំ អានន្ទរាហុលា
កស្សបោ ច មហានាមោ ឧភោសុំ វាមសោតកេ។

*ព្រះអានន្ទនិងព្រះរាហុលសូមមកប្រតិស្ឋានត្រង់ត្រចៀកស្តាំ ព្រះកស្សបៈ និងព្រះមហានាម សូមមកប្រតិស្ឋានត្រង់ត្រចៀកឆ្វេង ។*

កេសន្តេ បិដ្ឋិភាគស្មឹ សុរិយោវ បភង្ករោ
និសិន្នោ សិរិសម្បន្នោ សោភិតោ មុនិបុង្គវោ។

*ព្រះសោភិតៈអ្នករុងរឿងដូចព្រះអាទិត្យ ដល់ព្រមដោយសិរី ជាមុនីដ៏ប្រសើរ សូមមកប្រតិស្ឋានត្រង់ចុងសក់ ។*

កុមារកស្សបោ ថេរោ មហេសី ចិត្រវាទកោ
សោ មយ្ហំ វទនេ និច្ចំ បតិដ្ឋាសិ គុណាករោ។

*ព្រះកុមារកស្សបត្ថេរជាអ្នកស្វែងរកនូវគុណដ៏ធំ ជាអ្នកមានវាចាពីរោះ ជាអ្នកធ្វើនូវសេចក្តីល្អ សូមមកប្រតិស្ឋានត្រង់មាត់ខ្ញុំជានិច្ច ។*

បុណ្ណោ អង្គុលិមាលោ ច ឧបាលិ នន្ទសីវលី

ថេរា បញ្ច ឥមេ ជាតា នលាដេ តិលកា មម ។

*ព្រះថេរៈទាំងប្រាំព្រះអង្គគឺ ព្រះបុណ្ណៈ ព្រះអង្គុលិមាល ព្រះឧបាលិ ព្រះនន្ទ និងព្រះសីវលី សូមមកប្រតិស្ឋានត្រង់លលាដ៍របស់ខ្ញុំ ។*

សេសាសីតិ មហាថេរា វិជិតា ជិនសាវកា

ជលន្តា សីលតេជេន អង្គមង្គេសុ សណ្ឋិតា ។

*ព្រះថេរៈទាំងឡាយប៉ែតសិបព្រះអង្គដ៏សេស ជាអ្នកឈ្នះកិលេស ជាសាវករបស់ព្រះជិនស្រី រុងរឿងដោយតេជះនៃសីល សូមមកប្រតិស្ឋានត្រង់អវយវៈតូចនិងអវយវៈធំរបស់ខ្ញុំ ។*

រតនំ បុរតោ អាសិ ទក្ខិណេ មេត្តសុត្តកំ

ធជគ្គំ បច្ឆតោ អាសិ វាមេ អង្គុលិមាលកំ ។

*សូមអារាធនារតនបរិត្តមករក្សាពីខាងមុខ មេត្តបរិត្តមករក្សាពីខាងស្តាំ ធជគ្គបរិត្តមករក្សាពីខាងក្រោយ អង្គុលិមាលបរិត្តមករក្សាពីខាងឆ្វេង ។*

ខន្ធមោរបរិត្តញ្ច អាដានាដិយសុត្តកំ

អាកាសេ ឆទនំ អាសិ សេសា បាការសណ្ឋិតា ។

*សូមអាពធនាខន្ធបរិត្ត មោរបរិត្ត និង អាដានាដិយបរិត្ត ជាគ្រឿងក្រោះបាំងកណ្ដាលអាកាស ព្រះបរិត្តដទៃជារនាំង បាំងដោយជុំវិញ ។*

ជិនានំ ពលសំយុត្តេ ធម្មចាការលង្កតេ

វសតោ មេ សកិច្ចេន សទា សម្ពុទ្ធបញ្ជរេ ។

វាតបិត្តាទិសញ្ជាតា ពាហិរជ្ឈត្តុបទ្ទវា

អសេសា វិនយំ យន្តុ អនន្តជិនតេជសា។

*កាលខ្ញុំធ្វើនូវកិច្ចរបស់ខ្លួនជាក្រោះកែវរបស់ព្រះសម្ពុទ្ធ ទ្រង់ជាពុទ្ធានុភាព ដែលឡោមព័ទ្ធដោយរនាំងនៃព្រះធម៌ជានិច្ចហើយ សូមអន្តរាយទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅ ដែលកើតអំពីខ្យល់និងប្រមាត់ជាដើម សូមដល់នូវសេចក្ដីវិនាសបាត់ទៅ ដោយតេជះនៃព្រះជិនស្រីមិនមានទីបំផុត ។*

ជិនបញ្ជរមជ្ឈដ្ឋំ វិហរន្តំ មហីតលេ

សទា ចាលេន្តុ មំ សព្វេ តេ មហាបុរិសាសភា។

*សូមព្រះមហាបុរសព្រះអង្គជាអ្នកអង់អាចគ្រប់ព្រះអង្គ សូមអភិបាលរក្សានូវខ្ញុំដែលជាអ្នកស្ថិតនៅក្នុងជិនបញ្ជរ ដំណើរជីវិតនៅលើផែនដីគ្រប់កាលទៅហោង ។*

ឥច្ចេវមច្ចន្តកតោ សុរក្ខោ

ជិនានុភាវេន ជិតូបទ្ទវោ

ធម្មានុភាវេន ជិតារិសង្ឃោ

សង្ឃានុភាវេន ជិតន្តរាយោ

សទ្ធម្មានុភាវបាលិតោ ចរាមិ ជិនបញ្ជរេ ។

*ខ្ញុំបានទទួលនូវការរក្សាយ៉ាងល្អ ដោយប្រការយ៉ាងនេះ*

*សូមឲ្យខ្ញុំឈ្នះនូវឧបទ្រពដោយអានុភាពនៃព្រះជិនស្រី*

*ឈ្នះសឹកសត្រូវដោយអានុភាពនៃព្រះធម៌ ឈ្នះអន្តរាយ*

*ទាំងឡាយដោយអានុភាពនៃព្រះសង្ឃ, អានុភាពនៃព្រះ*

*សទ្ធម្ម សូមគ្រប់គ្រងរក្សាខ្ញុំក្នុងជិនបញ្ជរនេះ ។*

# សីមាប្រាំបួនទិស

ពុទ្ធោ ច មជ្ឈិមេ សេដ្ឋោ    សារិបុត្តោ ច ទក្ខិណោ
បច្ឆិមេបិ ច អានន្ទោ    ឧត្តរេ មោគ្គល្លានោ ច ។
កោណ្ឌញ្ញោ បុព្វភាគេ ច    ពាយព្វេ ច គវម្បតិ
ឧបាលិ ហរតីឋានេ    អាគនេយ្យេ ច កស្សបោ ។
រាហុលោ ចេវ ឦសានេ    សព្វេ តេ ពុទ្ធមង្គលា
យោ ញត្វា បូជិតោ លោកេ    និទ្ទុក្ខោ និរុបទ្ទវោ
មហាតេជោ សទា ហោតុ    សព្វសោត្ថី ភវន្តុ មេ ។

## *ប្រែជាកាព្យ*

*អហំតាំងស្មារតី    ឱនសិរសីថ្វាយបង្គំ*
*ព្រះពុទ្ធជាធំ    ទ្រង់និយមជាកណ្ដាល ។*
*រីអង្គអរហន្ដា    គង់ទិសាសព្វៗកាល*
*ព្រះទ័យត្រេកត្រអាល    ប្រោសប្រទានធម៌ទេសនា ។*
*ព្រះសារីបុត្រគង់ខាងស្ដាំ    ទក្សិណចាំព្រះសាស្ដា*
*ព្រះអានន្ទគង់បច្ឆិមា    ក្រោយកាយាព្រះអង្គស្មោះ ។*
*ព្រះមោគ្គល្លានណា    គង់ឧត្ដរាឆ្វេងចំពោះ*
*ព្រះកោណ្ឌញ្ញត្ថេរនោះ    គង់ទិសបូព៌ចំព្រះភ័ក្ត្រ ។*

ព្រះគវម្បតិត្ថេរ　　គង់នៅឯពាយ័ព្យជាក់
ព្រះឧបាលិត្ថេរៈ　　គង់និរតីនៃព្រះអង្គ ។
ព្រះកស្សបត្ថេរ　　គង់នៅឯអាគ្នេយ៍ត្រង់
រាហុលបុត្រព្រះអង្គ　　គង់នៅត្រង់ទិសឦសាន ។
បើអ្នកណាបានយល់　　ពុទ្ធមន្តលរក្សាបាន
ទន្ទេញទុកក្នុងប្រាណ　　ប្រឹងសិក្សារៀនឲ្យចាំ ។
កាលអង្គគង់ធម្មា　　ចាត់ចែងជាតាមចំណាំ
ចំណែកចែកឆ្វេងស្តាំ　　ចាំគ្រប់ទិសទាំង ៨ ។
បើអ្នកណាខិតខំ　　ថ្វាយបង្គំរាល់រាត្រី
សត្រូវទាំងប្រាំបី　　ទិសមកបៀតបៀនពុំបាន ។
ទុក្ខរោគនិងព្យាបាទ　　ទាំងឧត្បាតចៀសវៀងខាន
អ្វី ៗ បៀតពុំបាន　　រួចដល់ស្ថាននិព្វានហោង ។

## មន្តគាថាមហាមង្គល

*មន្តគាថានេះគ្រូបាអាចារ្យទាំងឡាយដែលទ្រទ្រង់ចាំមកថា មានអានុភាពស័ក្តិសិទ្ធិណាស់ អាចការពារអន្តរាយគ្រប់បែបយ៉ាងបាន ។ តែត្រូវសូធ្យចំនួន ១៨ ចប់ ។*

**ឥតិបិសោវិសេសេឥ ឥសេសេពុទ្ធនាមេឥ**

**ឥមេនាពុទ្ធតំសោឥ ឥសោតំពុទ្ធបិតិឥ ។**

**រំលឹកដល់ទេវតា ៤ ទិស រក្សាឱ្យសុខ**

បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា

តេបិ អម្ហេ អនុរក្ខន្តុ អរោគេន សុខេន ច។

*ភូតគឺគន្ធព្វទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងកើត គន្ធព្វទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា

តេបិ អម្ហេ អនុរក្ខន្តុ អរោគេន សុខេន ច។

*ទេវតាទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងត្បូង ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

បច្ឆិមស្មឹ ទិសាភាគេ សន្តិ នាគា មហិទ្ធិកា

តេបិ អម្ហេ អនុរក្ខន្តុ អរោគេន សុខេន ច។

*នាគទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងលិច នាគទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយ ដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

ឧត្តរស្មឹ ទិសាភាគេ　　សន្តិ យក្ខា មហិទ្ធិកា

តេបិ អម្ហេ អនុរក្ខន្តុ　　អារោគេន សុខេន ច ។

*យក្ខទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសាភាគខាងជើង យក្ខទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយ ដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

បុរត្ថិមេន ធតរដ្ឋោ　　ទក្ខិណេន វិរូឡ្ហកោ

បច្ឆិមេន វិរូបក្ខោ　　កុវេរោ ឧត្តរំ ទិសំ ។

*ស្តេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមទិស ស្តេចវិរុឡ្ហកៈ (នៅរក្សា)ខាងទក្ខិណទិស ស្តេចវិរូបក្ខៈ (នៅរក្សា)ខាងបច្ឆិមទិស ស្តេចកុវេរៈ (នៅរក្សា)ខាងឧត្តរទិស ។*

ចត្តារោ តេ មហារាជា　　លោកចាលា យសស្សិនោ

តេបិ អម្ហេ អនុរក្ខន្តុ　　អារោគេន សុខេន ច ។

*មហារាជទាំងឡាយ៤នោះសុទ្ធតែមានយស ជាអ្នករក្សានូវលោក មហារាជទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយ ដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង។*

អាកាសដ្ឋា ច ភុមដ្ឋា　　ទេវា នាគា មហិទ្ធិកា

តេបិ អម្ហេ អនុរក្ខន្តុ　　អារោគេន សុខេន ច ។

*ទេវតានិងនាគទាំងឡាយ មានឫទ្ធិច្រើន ដែលស្ថិតនៅក្នុងអាកាសក្តី ស្ថិតនៅលើផែនដីក្តី ទេវតានិងនាគទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

ឥទ្ធិមន្តោ ច យេ ទេវា    វសន្តា ឥធ សាសនេ
តេបិ អម្ហេ នុរក្ខន្តុ    អរោគេន សុខេន ច។

*ទេវតាទាំងឡាយឯណា មានឫទ្ធិច្រើន ដែលស្ថិតនៅក្នុងសាសនានេះ ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយ ដោយមិនឲ្យមានរោគផង ឲ្យមានសេចក្ដីសុខផង។*

## អានុភាពព្រះរតនត្រ័យ

១. មារសេនប្បមទ្ទនា    ឈានស្ស សុខឈាយនោ
តេជោពលេន មហតា    សទា មង្គលមត្ថុ នោ។

*ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះជិនស្រី ព្រះអង្គទ្រង់មានសេចក្ដីសុខក្នុងឈាន ព្រោះបានកម្ចាត់បង់នូវមារាធិរាជព្រមទាំងសេនា សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាល ទាំងពួង ។*

២. នានាគុណវិចិត្តស្ស    រូបកាយស្ស សត្ថុនោ
សព្វទេវមនុស្សានំ    មារពន្ធវិមោចិនោ
មេត្តាពលេន មហតា    សទា មង្គលមត្ថុ នោ។

*ដោយតេជានុភាពនៃព្រះមេត្តាដ៏ធំក្រៃលែងនៃព្រះរូបកាយដ៏វិចិត្រផ្សេងៗរបស់ព្រះសាស្ដា ព្រះអង្គទ្រង់ញ៉ាំងទេវតានិងមនុស្សទាំងពួង ឲ្យរួចផុតចាកគ្រឿងចំណងរបស់មារ សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

៣. សព្វញ្ញុតាទិកាយស្ស    ធម្មកាយស្ស សត្ថុនោ

ចក្ខាទ្យគោចរស្សាបិ　　គោចរស្សេវ ភ្វិរយា
តេជោពលេន មហាតា　　សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះធម្មកាយ ដែលមានព្រះសព្វញ្ញុតញ្ញាណជាដើមរបស់ព្រះសាស្តា សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

៤. រូបកាយសទិសស្ស　　និម្មិតស្ស មហេសិនោ
ធម្មស្ស វត្ថុនោ សគ្គេ　　ទេវានំ សុគតា បតិ
តេជោពលេន មហាតា　　សទា មង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះពុទ្ធនិម្មិត ដែលព្រះពុទ្ធជាម្ចាស់ទ្រង់និម្មិតហើយ ដូចជាព្រះរូបកាយរបស់ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ សម្តែងធម៌ដល់ទេវតាទាំងឡាយក្នុងស្ថានតាវត្តិង្ស សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

៥. សិក្ខិត្វា មានុសេ ទេវេ　　មោចយិត្វា សទេវកេ
សង្ខារេ បជហន្តស្ស　　និព្វុតស្ស មហេសិនោ
មហាន្តេនានុភាវេន　　សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជាអ្នកស្វែងរកនូវគុណធំ ព្រះអង្គទ្រង់បង្រៀននូវទេវតានិងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ញុំាងទេវតានិងមនុស្សទាំងឡាយ ឲ្យរួចផុតចាកអន្ទាក់របស់មារ លះសង្ខារទាំងឡាយបរិនិព្វានហើយ សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

៦. ចតុរាសីតិសហស្ស ធម្មក្ខន្ធស្ស តេជសា

នវង្គសាសនស្សាបិ នវលោកុត្តរស្ស ច

សព្វទាបបវាហេន សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពនៃព្រះធម៌ ៨៤,០០០ ព្រះធម្មក្ខន្ធ នវង្គសត្ថុសាសន៍ និងនវលោកុត្តរធម៌ ដែលនាំបាបទាំងពួងចេញហើយ សូមមង្គលទាំងពួង ចូរកើតមានដល់យើងទាំងឡាយគ្រប់កាល ទាំងពួង ។*

៧. មហាតោរិយសង្ឃស្ស បុញ្ញក្ខេត្តស្ស តាទិនោ

បហីនសព្វទាបស្ស សីលាទិក្ខន្ធធារិនោ

មហាតេជានុភាវេន សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះអរិយសង្ឃ ជាស្រែបុណ្យ ដែលមិនកម្រើកញាប់ញ័រ ជាអ្នកលះបាបទាំងពួងហើយ ទ្រទ្រង់នូវគុណមានសីលជាដើម សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

៨. ទាតាលេ ភូតលាកាសេ ទេវយក្ខបិសាចកា

វិជ្ជាធរា ច គន្ធព្វា នាគកុម្ភណ្ឌរក្ខសា

សព្វេសមានុភាវេន សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពនៃសត្វទាំងពួង គឺទេវតា យក្ខ បិសាច វិជ្ជាធរ គន្ធព្វ នាគ កុម្ភណ្ឌ និងរក្ខសទេវតាទាំងឡាយ ដែលស្ថិតនៅក្រោមផែនដី លើផែនដី និងក្នុងអាកាស សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

# នមស្ការព្រះពុទ្ធ
## ដោយថ្វាយព្រះនាមថា ភៃសជ្យគុរុ (គ្រូនៃឱសថ)

**ធរណី (ភាសាសំស្ក្រឹត)**

**នមោ ភគវតេ ភៃសជ្យគុរុ**
**វៃឌូរ្យប្រភរាជាយ តថាគតាយ**
**អរហតេ សម្យកសម្ពុទ្ធាយ តទ្យថា**
**ឱម ភៃសជ្យេ ភៃសជ្យេ មហាភៃសជ្យេ**
**ភៃសជ្យេរាជាយ សមុទគតេ ស្វាហា ។**

*សូមឲ្យសព្វសត្វបានសម្រេចនូវជោគជ័យ! ខ្ញុំសូមនមស្ការនូវព្រះដ៏មានព្រះភាគ ដែលជាភៃសជ្យគុរុ ដូចជាស្ដេចនៃពន្លឺកែវពិទូរ្យ ជាព្រះតថាគតដែលទ្រង់មានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺព្រះនិព្វាន ជាព្រះអរហន្ត ដែលទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដោយប្រពៃចំពោះព្រះអង្គឯង គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គ*
*ឱម ព្រះអង្គជាគ្រូពេទ្យ ជាគ្រូពេទ្យ ជាកំពូលគ្រូពេទ្យ ជាស្ដេចនៃគ្រូពេទ្យ ។*

ធរណីមួយបែបទៀត

**नमो भगवते भैषज्यगुरु**

**वैडूर्यप्रभराजाय तथागताय**

**अर्हते सम्यक्संबुद्धाय तद्यथा**

**ॐ भैषज्ये भैषज्ये भैषज्य**

**समुद्गते स्वाहा.**

**នមោ ភគវតេ ភៃសជ្យគុរុ**
**វៃទូរ្យប្រភរាជាយ តថាគតាយ**
**អរហតេ សម្យក្សម្ពុទ្ធាយ តទ្យថា**
**ឱម ភៃសជ្យេ ភៃសជ្យេ ភៃសជ្យេ**
**សមុទគតេ ស្វាហា ។**

## អត្ថន័យនៃគាថាធរណី

**នមោ** កិរិយានមស្ការនៃខ្ញុំចូរមាន

**ភគវតេ** ព្រះដ៏មានព្រះភាគ

**ភៃសជ្យគុរុ** ព្រះនាមព្រះពុទ្ធ ដែលបានថ្វាយនាមព្រះពុទ្ធអង្គ សមណគោតម បរមគ្រូ ដែលទ្រង់បានព្យាបាលសព្វសត្វ ឲ្យរួចផុតចាកជំងឺទាំងឡាយ មានរាគៈ ទោសៈ និងមោហៈ ជាជំងឺធ្ងន់ធ្ងរ សាហាវក្នុងសង្សារវដ្តនេះ រហូតដល់ព្រះអដ្ឋកថាថ្វាយព្រះនាម ព្រះអង្គថា **គ្រូពេទ្យ** ទៀតផង ។ ដូចអដ្ឋកថា បរមត្ថជោតិកាថា សានុសយកិលេសព្យាធិហរណសមត្ថតាយ វា កុសលោ វេជ្ជោ វិយ ពុទ្ធោ, សម្មា បយុត្តភេសជ្ជមិវ ធម្មោ, ភេសជ្ជបយោគេន សមុបសន្តព្យាធិ វិយ

ជនសមុទាយោ សមុបសន្តកិលេសព្យាធានុសយោ សង្ឃោ ។ ព្រះពុទ្ធដូចជាគ្រូពេទ្យ ដែលទ្រង់ឈ្លាសអាចនាំចេញនូវជំងឺគឺអនុសយកិលេស, ព្រះធម៌ ដូចភេសជ្ជៈ គឺថ្នាំដែលប្រកបដោយត្រឹមត្រូវ, ព្រះសង្ឃដូចជាជនអ្នកមានជំងឺ បានជាសះស្បើយហើយ ដោយការប្រកបនូវថ្នាំគឺព្រះធម៌ ឬដូចជាអ្នកដែលមាន កិលេសស្ងប់រម្ងាប់ហើយ ។

**វេឡុរិយប្រភរាជាយ** ដូចជាស្តេចនៃពន្លឺកែវពិទូរ្យ មានន័យថា កែវពិទូរ្យជារតនៈដែលមានតម្លៃមិនអាចកាត់ថ្លៃបាន មានពណ៌ដ៏ខៀវស្រស់ ។ សេចក្តីនេះកែវពិទូរ្យ បានដល់ ព្រះធម្មរតនៈ ។ ពាក្យថា **ប្រភា** មានន័យថា ពណ៌ខៀវ ជាពណ៌អធិបតីលើលោក គឺព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងមានមុខឆ្ពោះទៅរកលោកុត្តរៈ ។

**តថាគតាយ** មានន័យថា ព្រះតថាគត ដែលព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺព្រះនិព្វាន ។

**អរហតេ** មានន័យថា ព្រះអរហន្ត ព្រោះព្រះអង្គជាអ្នក បរិសុទ្ធដ៏ក្រៃលែងព្រោះមិនមានកិលេស ជាគ្រឿងសៅហ្មង ។

**សម្យកសម្ពុទ្ធាយ** មានន័យថា ព្រះអង្គទ្រង់ត្រាស់ដឹងនូវ សម្មាសម្ពោធិញ្ញាណដោយព្រះអង្គឯង មិនបានសិក្សាក្នុងសំណាក់ គ្រូអាចារ្យណានីមួយឡើយ ។

**តទ្យថា** មានន័យថា មានព្រះគុណដូច្នេះឯង ។

**ឱម** ជាពាក្យពោលសង្ខេបដល់គុណព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

**ភៃសជ្យេ** មានន័យថា គ្រូពេទ្យ ដូចន័យខាងដើម ។

**មហាភៃសជ្យេ** មានន័យថា គ្រូពេទ្យដ៏ធំ ដូចន័យខាងដើម ។

**ភៃសជ្យេរាជាយ**មានន័យថា ជាស្តេចនៃគ្រូពេទ្យ ដូចន័យ ខាងដើម ។

**សមុទគតេ ស្វាហា** *សូមឲ្យសព្វសត្វបានសម្រេចនូវជោគជ័យ ។ ជាពាក្យអាងទៅលើគុណានុភាពនៃការសរសើរគុណព្រះ ពុទ្ធ សូមឲ្យបាននូវជោគជ័យ និងជាសះស្បើយចាកជំងឺទាំងឡាយ ដោយសច្ចកិរិយានេះ ។*

## ពុទ្ធដ្ឋានដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា

*ព្រះពុទ្ធជាបរមគ្រូដ៏កំពូលឯក ដែលទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បានប្រកាសសម្តែងនូវព្រះធម៌ ព្រះវិន័យ ចំនួន ៤៥ វស្សា ។ ព្រះធម៌ព្រះវិន័យ បានស្ថិតនៅក្នុងព្រះត្រៃបិដក មានចំនួន ៨៤,០០០ ព្រះធម្មក្ខន្ធ ដោយបានការថែរក្សារបស់មហាសាវកទាំងឡាយ មានព្រះមហាកស្សបៈជាដើម ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះធរមាននៅ ពុទ្ធបរិស័ទទាំងឡាយ មានភិក្ខុជាដើម តែងចូលទៅនមស្ការចំពោះព្រះអង្គ បន្ទាប់ពីចេញវស្សាហើយ ។ ចំណុចត្រង់នេះ ដែលធ្វើឲ្យព្រះអានន្ទ ក្រាបទូលសួរព្រះអង្គ នៅពេលព្រះអង្គ ទ្រង់ជិតបរិនិព្វានថា[១]*

*បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សាក្នុងទិសទាំងឡាយ រួចហើយតែងមកដើម្បីគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គ តែងបានជួបនឹងពួក ភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណើះ តតនឹងព្រះមានព្រះភាគទៅ យើងខ្ញុំទាំងឡាយ នឹងលែងបានជួប លែងបានចូលទៅអង្គុយជិតពួកភិក្ខុ អ្នកចម្រើនដោយចិត្តហើយ ។*

*ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា*

*ម្នាលអានន្ទ សំវេជនីយដ្ឋាន (ដែលជាទីគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្រ អ្នកមានសទ្ធានេះ មាន ៤ កន្លែង គឺ*

**១-ឥធ តថាគតោ ជាតោ** *ដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះ*

**២-ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ** *ដោយរលឹកឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះដូច្នេះ*

**៣-ឥធ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ** *ដោយរលឹកឃើញថា ព្រះតថាគតបានសម្តែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ*

---

[១] *ទីឃ.មហា.១៦/២៩៤ ។*

**៤-ឥធ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោ** *ដោយរលឹកឃើញថា ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនេះ ដូច្នេះ ។*

អាគមិស្សន្តិ ខោ អានន្ទ សទ្ធា ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ឥធ តថាគតោ ជាតោតិបិ ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិបិ ឥធ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតន្តិបិ ឥធ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិបិ។ យេ ហិ កេចិ អានន្ទ ចេតិយចារិកំ អាហិណ្ឌន្តា បសន្នចិត្តា កាលង្ករិស្សន្តិ សព្វេ តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សន្តិ។

*ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា* ***នឹងមក*** *ដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតសម្តែងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះក្តី ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ។*

## លុម្ពិនី ស្ថានទីប្រសូត

*ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ មុន ព.ស.៨០ ឆ្នាំ ព្រះនាងមហាមាយា ជាអគ្គមហេសីនៃព្រះបាទសុទ្ធោទនៈ ជាស្តេចសក្យវង្ស គ្រប់គ្រងនគរកបិលពស្តុ ទ្រង់យាង ទៅទេវទហៈ ដែលជានគរព្រះបិតា ខាងកោលិយវង្ស ដើម្បីប្រសូតព្រះរាជឱរស ។*

*ក្នុងកណ្តាលផ្លូវ នាព្រំប្រទល់នៃនគរទាំងពីរ ព្រះនាងក៏ប្រសូតព្រះបរមពោធិសត្វ ក្នុងឧទ្យានលុម្ពិនី ។ កាលព្រះបរមពោធិសត្វ ទ្រង់ប្រសូតចាកព្រះគភ៌នៃព្រះមាតា បានយាង ចំនួន ៧ ជំហាន ហើយប្រកាសអាសភិវាចា[១]ថា :*

អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ។

*អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គល ប្រសើរបំផុតរបស់លោក នេះជាកំណើតបំផុតរបស់អញ ឥឡូវនេះ ភពថ្មីតពីនេះទៅទៀត មិនមានឡើយ ។*

---

[១] *ទីឃ.មហា.១៦/៣១ ។*

សសរស្តម្ភ និងអគារទីព្រះអង្គប្រសូត



ស្ថានទីព្រះពុទ្ធទ្រង់ប្រសូត



សិលាចារឹកព្រះបាទអសោកមហារាជ



សិលាចារឹកបែបបាលីខ្មែរ

**ទេវាន បិយេន បិយទសិន លាជិន**

**វីសតិវសាភិសិតេន អតន អាគាច**

**មហីយិតេ ហិទ ពុធេ ជាតេ សក្យមុនីតិ**

**សីលាវិគឌភី ចា កាលាបិត សិលាថភេ**

**ច ឧសបាបិតេ ហិទ ភគវំ ជាតេតិ**

**លុម្មិនិគាមេ ឧពលិកេ កដេ អដ្ឋ**

**ភាគិយេ ច ។**

## អត្ថន័យនៃសិលាចារឹកព្រះបាទអសោក

ព្រះបាទទេវានម្បិយ បិយទស្សី កាលទ្រង់បានអភិសេកហើយ ២០ ឆ្នាំ បានយាងមកនមស្ការត្រង់ទីនេះ ដោយព្រះអង្គឯង ដោយថា ព្រះពុទ្ធសក្យមុនី បានប្រសូត ក្នុងទីនេះ ទ្រង់ឲ្យសាងរបងថ្ម និងប្រតិស្ឋានសសរស្តម្ភទុកជាទីសំគាល់ ។ ដោយព្រះដ៏មានព្រះភាគ ទ្រង់ប្រសូតទីនេះ ទើបទ្រង់ប្រោសឲ្យអ្នកស្រុកលុម្ពិនី មិនត្រូវបង់ព័ន្ធសួយអាករទូទៅ ឲ្យយកត្រឹម ១ ភាគ ៨ ប៉ុណ្ណោះ ។

នៅមានរូបបដិមាព្រះនាងមហាមាយាទេវី ដែលបានរកឃើញនៅក្នុងមាយាទេវីវិហារ ដែលកសាងនៅក្នុងសម័យគុបតៈ ជាសក្ខីមួយដ៏សំខាន់ បញ្ជាក់ដល់ស្ថានទីប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ ។



Lumbini (Devnagari: लुम्बिनी) is a Buddhist pilgrimage site in the Rupandehi district of Nepal.

បច្ចុប្បន្នស្ថានទីព្រះពុទ្ធទ្រង់ប្រសូត ស្ថិតនៅជាយដែនប្រទេសនេប៉ាល់ ស្ថិតនៅក្នុ ស្រុក រូបន្ទេហី ប្រទេសនេប៉ាល់ ។

៥៩

# ផែនទីប្រទេសនេប៉ាល់



*បូជាស្ថានទីព្រះពុទ្ធទ្រង់ប្រសូត*

**វន្ទាមិ ភន្តេ ភគវា ឥមំ សំវេជនីយំ ឋានំ, យត្ថាគតោម្ហិ, សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ, ឥធ លុម្ពិនីវនេ តថាគតេន មជ្ឈិមេសុ ជនបទេសុ អរិយកេសុ មនុស្សេហិ ឧប្បន្នំ ។ ភាសិតា ច អាសភិវាចា អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។**

**សាធុ នោ ភន្តេ, ឥមេហិ សក្ការេហិ អភិបូជយាមិ, ស្វាក្ខាតញ្ច នមាមិ, មយ្ហំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណាបានចារិកមកដល់ហើយ និងសូមនមស្ការថ្វាយបង្គំនូវសំវេជនីយដ្ឋាននេះ ដែលកុលបុត្រអ្នកមានសទ្ធាគួរទស្សនា ដែលជាស្ថានទីព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយ ក្នុងពួកមនុស្សអរិយកៈ ក្នុងមជ្ឈិមប្រទេស ក្នុងឧទ្យានលុម្ពិនីនេះ ហើយបានត្រាស់អាសភិវាចាដ៏អង់អាចថា អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតចុងបំផុតរបស់អញ ឥឡូវនេះ ភពថ្មីតពីនេះទៅទៀត មិនមានឡើយ ។*

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមបូជានូវសំវេជនីយដ្ឋានទី ១ នេះ ដោយគ្រឿងសក្ការៈទាំងឡាយនេះ និងសូមនមស្ការចំពោះព្រះធម៌ ដែលព្រះអង្គទ្រង់សម្ដែងដ៏ល្អហើយ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះករុណា អស់កាលជាយូរអង្វែងទៅហោង ។*

## ពុទ្ធគយា

*ពុទ្ធគយា ជាស្ថានទីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ដែលស្ថិតនៅក្នុងស្រុក គយា វដ្ឋពិហារ ប្រទេសឥណ្ឌា ។ សម័យពុទ្ធកាល ហៅថា ឧរុវេលាសេនានិគម ។*

*ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ មុន ព.ស.៤៥ ឆ្នាំ ។ បន្ទាប់ពីមហាបុរស ទ្រង់ធ្វើទុក្ករកម្ម ដែលអ្នកដទៃមិនអាចធ្វើបាន ដើម្បីស្វែងរកមោក្ខធម៌ ក្នុងបដិបទា ជាអត្តកិលមថានុយោគហើយ ។ ព្រះអង្គបែរមកបដិបត្តិជាផ្លូវមជ្ឈិមាបដិបទា ដែលអមរវាងខាងផ្លូវទាំងពីរ ។ ក្នុងបឋមយាម ទ្រង់បានចាក់ធ្លុះនូវបុព្វេនិវាសនុស្សតិញ្ញាណ ដែលជាបញ្ញាអាចរលឹកជាតិបាន គ្មានទីបំផុត, ក្នុងមជ្ឈិមយាម ទ្រង់បាននូវទិព្វចក្ខុញ្ញាណ ដែលជាបញ្ញាដឹងពីកំណើតរបស់សត្វ, ក្នុងបច្ឆិមយាម ទ្រង់មានបញ្ញាឈានចុះក្នុងបដិច្ចសមុប្បាទ គឺបច្ចយាការៈ ដែលព្រះពុទ្ធគ្រប់ព្រះអង្គបដិបត្តិមក ។ គ្រាកាលព្រះមហាបុរសពិចារណាបច្ចយាការៈ ដែលប្រកបដោយបទទាំង ១២ ដោយអនុលោម និងបដិលោម ដោយអំណាចវដ្តៈ និងវិវដ្តៈ ។ ផែនដីកម្រើករំពើកញាប់ញ័រ រហូតដល់មួយម៉ឺនលោកធាតុ រហូតដល់ទឹកជាទីទ្រផែន ។ លំដាប់នោះ មហាបុរសទ្រង់ញុំាងចតុត្ថជ្ឈាន មានអានាបានៈជាអារម្មណ៍ឲ្យកើតហើយ ទ្រង់ធ្វើចតុត្ថជ្ឈានឲ្យជាបាទ ចម្រើនវិបស្សនាញុំាងកិលេសទាំងពួង ឲ្យអស់ទៅក្នុងមគ្គទី ៤ គឺអរហត្តមគ្គ ដែលព្រះអង្គទ្រង់ទម្លុះតាមលំដាប់នៃមគ្គ តាំងតែសោតាបត្តិមគ្គជាដើមមក ក្នុងជំណាលគ្នានឹងអរុណរះឡើង ទ្រង់ក៏អស់អាសវៈមិនមានសេសសល់ ហើយបន្លឺឧទានវាចា[១]ថា ៖*

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ

គហាការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ។

គហាការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

[១] *ខុទ្ទក.ធម្ម.៥២/៥៤ ។*

សព្វា តេ ផាសុកា ភគ្គា គហក្ខូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

*នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។*

## បដិច្ចសមុប្បាទ អនុលោម

*សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគ បានត្រាស់ដឹងជាដំបូងទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់ដោយព្រះភ្លែនតែមួយអស់ ៧ ថ្ងៃក្រោមម្លប់ពោធិព្រឹក្សទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។ វេលានោះព្រះដ៏មានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ជាអនុលោមប្បដិលោម គឺពិចារណាបណ្តោយចុះនឹងច្រាសឡើង អស់បឋមយាមនៃរាត្រីដោយន័យថា* អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

*សង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាហេតុ វិញ្ញាណកើតមាន ព្រោះ មានសង្ខារជាហេតុ នាមរូបកើតមាន ព្រោះមានវិញ្ញាណជាហេតុ សឡាយតនៈកើត មាន ព្រោះមាននាមរូបជាហេតុ ផស្សៈកើតមាន ព្រោះមាន សឡាយតនៈជាហេតុ វេទនាកើតមាន ព្រោះ*

មានផស្សៈជាហេតុ តណ្ហាកើតមាន ព្រោះមានវេទនាជាហេតុ ឧបាទានកើតមាន ព្រោះមានតណ្ហាជាហេតុ ភពកើតមានព្រោះ មានឧបាទានជាហេតុ ជាតិកើតមាន ព្រោះមានភពជាហេតុ សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយកើតមាន ព្រោះមានជាតិជាហេតុ សេចក្តីកើតឡើង នៃកងទុក្ខទាំងអស់នេះរមែងមានយ៉ាងនេះឯង ។

**ព្រះពុទ្ធទ្រង់ឧទានក្នុងបឋមយាម**

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

ធម៌[១]ទាំងឡាយរមែងប្រាកដដល់ខីណាសវព្រាហ្មណ៍
អ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស
ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់
ខីណាសវព្រាហ្មណ៍នោះក៏សឹងតែរម្ងាប់អស់ទៅក្នុងកាល
នោះថាខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ព្រមទាំងហេតុ។

## បដិច្ចសមុប្បាទ បដិលោម

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណ-និរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហា-និរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោ

១. អដ្ឋកថា ថា បានដល់ពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ ។

ធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

*សេចក្តីរលត់សង្ខារកើតមាន ព្រោះវិនាស នឹងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្តីរលត់ ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិកើត មាន ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះតែងមានយ៉ាងនេះ ។*

**ព្រះពុទ្ធទ្រង់ឧទានក្នុងមជ្ឈិមយាម**

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បច្ចយានំ អវេទិ ។

*ធម៌ទាំងឡាយប្រាកដដល់ខីណាសវព្រាហ្មណ៍*
*អ្នកមានព្យាយាមញ៉ាំងកិលេស ឲ្យក្តៅអ្នកដុតបង់នូវកិលេស*
*ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង*
*របស់ខីណាសវព្រាហ្មណ៍នោះ តែងរម្ងាប់អស់ទៅ*
*ក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះបានដឹងច្បាស់*
*នូវព្រះនិព្វានជាទីអស់ទៅនៃបច្ច័យ ។*

## ព្រះពុទ្ធទ្រង់ឧទានក្នុងបច្ឆិមយាម

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខំ ។

*ធម៌ទាំងឡាយប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះរមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារហើយឋិតនៅ ក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើងធ្វើអាកាសឲ្យរុងរឿង ដោយរស្មីរបស់ខ្លួនកម្ចាត់បង់នូវងងឹត ស្ថិតនៅ ដូច្នោះឯង។*

# សត្តមហាឋាន
## ( មហាឋានទាំង ៧ កន្លែង )



### ១.ពោធិបល្ល័ង្ក

ព្រះពុទ្ធជាអម្ចាស់ទ្រង់គង់បន្ទឹព្រះឧទានយ៉ាងនេះហើយ ទ្រង់ត្រិះរិះថា យើងត្រាច់ទៅក្នុងសង្សារវដ្ត អស់ ៤ អសង្ខេយ្យ ១ សែនកប្ប ព្រោះហេតុតែបល្ល័ង្កនេះឯង ។ បល្ល័ង្កនេះ ជាវិជយបល្ល័ង្ករបស់យើង យើងគង់លើបល្ល័ង្កនេះ សេចក្តីត្រិះរិះមិនទាន់បរិបូណ៌ដរាបណា យើងនឹងមិនក្រោកចាកបល្ល័ង្កនេះ ដរាបនោះ ហើយព្រះអង្គចូលនិរោធសមាបត្តិច្រើនសែនកោដិ សោយវិមុត្តិសុខលើបល្ល័ង្កនេះ អស់ចំនួន ៧ ថ្ងៃ ។ ស្ថានទីមាននោះ ឈ្មោះថា ពោធិបល្ល័ង្ក ។

## ថ្វាយគ្រឿងសក្ការៈបូជាត្រង់ទីព្រះពុទ្ធត្រាស់ដឹង

**វន្ទាមិ ភន្តេ ភគវា ឥមំ ពោធិរុក្ខចេតិយំ, សំវេជនីយំ ឋានំ, យត្ថាគតោម្ហិ, សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ, ឥធ គយាសីសេ, តថាគតេន សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធំ ។**

**សាធុ នោ ភន្តេ, ឥមេហិ សក្ការេហិ អភិបូជយាមិ, ស្វាក្ខាតញ្ច នមាមិ, មយ្ហំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណាបានចារិកមកដល់ហើយ និងសូមនមស្ការថ្វាយបង្គំនូវស្រីមហាពោធិព្រឹក្ស និងព្រះចេតិយ ដែលជាសំវេជនីយដ្ឋាន ដែលកុលបុត្រអ្នកមានសទ្ធាគួរទស្សនា ជាស្ថានទីដែលព្រះតថាគត ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស ក្នុងគយាសីសប្រទេសនេះ ។*

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមបូជានូវសំវេជនីយដ្ឋានទី ២ នេះ ដោយគ្រឿងសក្ការៈទាំងឡាយនេះ និងសូមនមស្ការចំពោះព្រះធម៌ ដែលព្រះអង្គទ្រង់សម្តែងដ៏ល្អហើយ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណា អស់កាលជាយូរអង្វែងទៅហោង ។*



**២.អនិមិសចេតិយ**

ព្រះពុទ្ធជាម្ចាស់ចេញពីសមាបត្តិក្នុងថ្ងៃទី ៨ ដែលជាសប្តាហ៍ទី ២ បន្ទាប់ពីត្រាស់ដឹង ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ពួកទេវតាខ្លះថា ព្រះសិទ្ធត្ថគង់លើបល្ល័ង្ក រហូតដល់ទៅ ៧ ថ្ងៃ មិនក្រោកចាកបល្ល័ង្កនោះ ព្រះអង្គប្រហែលជាមានកិច្ច ដែលត្រូវធ្វើទៀតទេដឹង ព្រោះនៅមិនទាន់លះសេចក្តីអាល័យក្នុងបល្ល័ង្កនេះ ដើម្បីទ្រង់រម្ងាប់សេចក្តីត្រិះរិះរបស់ពួកទេវតាទាំងនោះ ទ្រង់ហោះឡើងទៅកាន់អាកាស **សម្តែងយមកបាដិហារ្យ** ។ គ្រាកាលព្រះអង្គ ទ្រង់សម្តែងបាដិហារ្យហើយ ព្រះអង្គទ្រង់យាងចុះទិសខាងជើង ឆៀងខាងកើត សម្លឹងមើលមកពោធិបល្ល័ង្ក ដោយមិនប៉ប្រិចព្រះនេត្រ អស់ចំនួន ៧ ថ្ងៃ ដោយទ្រង់ត្រិះរិះថា យើងបានចាក់ធ្លុះសព្វញ្ញុតញ្ញាណ ត្រង់បល្ល័ង្កនេះហ្ន៎! ។ ស្ថានទីនេះ មានឈ្មោះថា **អនិមិសចេតិយ** ។



**៣.រតនចង្កមចេតិយ**

*ក្នុងសប្តាហ៍ទី ៣ រាប់អំពីត្រាស់ដឹង ព្រះសាស្តាទ្រង់និម្មិតទីចង្ក្រមក្នុងរវាងពោធិបល្ល័ង្ក និងស្ថានទីគង់ ។ ព្រះអង្គទ្រង់ចង្ក្រមលើរតនចង្ក្រមអំពីទិសខាងកើត ទៅទិសខាងលិច រហូតដល់ ៧ ថ្ងៃ ។ ស្ថានទីនេះ មានឈ្មោះថា **រតនចង្កមចេតិយ** ។*



## ៤.រតនឃរចេតិយ

ក្នុងសប្តាហ៍ទី ៤ ទេវតាទាំងឡាយ និម្មិតផ្ទះកែវនៅទិសពាយព្យអំពីដើមមហាពោធិ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់សមាធិក្នុងផ្ទះកែវនោះ ពិចារណាអភិធម្មបិដក និងសមន្តបដ្ឋានជាអនន្តន័យ មានន័យមិនមានទីបំផុតក្នុងអភិធម្មនោះ ដោយពិស្តារ រហូតដល់ ៧ ថ្ងៃ ។ ស្ថានទីនេះ មានឈ្មោះថា **រតនឃរចេតិយ** ។

*កាលពុទ្ធបរិស័ទដែលបានមកដល់ស្ថានទីនេះហើយ គួរស្វាធ្យាយនូវគម្ពីរអភិធម្ម ដោយសង្ខេប ជាពិសេស គម្ពីរមហាបដ្ឋាន ។ ខ្ញុំ សូមលើកជារបៀបសូធ្យដោយសង្ខេប មានដូចតទៅ* :

## បច្ចយុទ្ទេសោ

ហេតុប្បច្ចយោ, អារម្មណប្បច្ចយោ, អធិបតិប្បច្ចយោ, អនន្តរប្បច្ចយោ, សមនន្តរប្បច្ចយោ, សហជាតប្បច្ចយោ, អញ្ញមញ្ញប្បច្ចយោ, និស្សយប្បច្ចយោ, ឧបនិស្សយប្បច្ចយោ, បុរេជាតប្បច្ចយោ, បច្ឆាជាតប្បច្ចយោ, អាសេវនប្បច្ចយោ, កម្មប្បច្ចយោ, វិបាកប្បច្ចយោ, អាហារប្បច្ចយោ, ឥន្ទ្រិយប្បច្ចយោ, ឈានប្បច្ចយោ, មគ្គប្បច្ចយោ, សម្បយុត្តប្បច្ចយោ, វិប្បយុត្តប្បច្ចយោ, អត្ថិប្បច្ចយោ, នត្ថិប្បច្ចយោ, វិគតប្បច្ចយោ, អវិគតប្បច្ចយោ

( ក ) តិកញ្ច បដ្ឋានវរំ ទុកុត្តមំ,
ទុកំ តិកញ្ចេវ តិកំ ទុកញ្ច;
តិកំ តិកញ្ចេវ ទុកំ ទុកញ្ច,
ឆ អនុលោមម្ហិ នយា សុគម្ភីរា ។

( ១ ) តិកញ្ច បដ្ឋានវរំ ទុកុត្តមំ,
ទុកំ តិកញ្ចេវ តិកំ ទុកញ្ច;
តិកំ តិកញ្ចេវ ទុកំ ទុកញ្ច,
ឆ បច្ចនីយម្ហិ នយា សុគម្ភីរា ។

(ក) តិកញ្ច បដ្ឋានវរំ ទុកុត្តមំ,
ទុកំ តិកញ្ចេវ តិកំ ទុកញ្ច;
តិកំ តិកញ្ចេវ ទុកំ ទុកញ្ច,
ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា ។

(ឃ) តិកញ្ច បដ្ឋានវរំ ទុកុត្តមំ,
ទុកំ តិកញ្ចេវ តិកំ ទុកញ្ច;
តិកំ តិកញ្ចេវ ទុកំ ទុកញ្ច,
ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ភីរា ។

ចតុវីសតិប្បច្ចយវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា ។



## ៥.អជបាលនិគ្រោធ

លុះថ្ងៃ៧កន្លងទៅហើយ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ចេញចាកសមាធិនោះ ហើយទ្រង់ចេញពីម្លប់ពោធិព្រឹក្ស យាងចូលទៅកាន់ដើមអជបាលនិគ្រោធ លុះចូលទៅដល់ហើយ ទ្រង់គង់ពែនភ្នែនតែមួយបន្តុយអស់៧ថ្ងៃ ក្រោមម្លប់អជបាលនិគ្រោធព្រឹក្ស[១] សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។ គ្រានោះមានព្រាហ្មណ៍ម្នាក់ ឈ្មោះ ហុំហុំក

១. ដើមជ្រៃដែលជាទីជ្រកអាស្រ័យនៃពួកជនអ្នកឃ្វាលពពែ ។

ជាតិកៈ (មានជាតិជាអ្នកធ្វើនូវសំឡេងគម្រាមថាហុំហុំ) ចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយមួយអន្លើដោយព្រះដ៏មានព្រះភាគ លុះធ្វើពាក្យ គួរជាទីរីករាយ គួរជាទីរឭកឲ្យសម្រេចហើយ ក៏ឋិតនៅក្នុងកន្លែងដ៏សមគួរ។ លុះ ព្រាហ្មណ៍នោះឋិតនៅក្នុងកន្លែងដ៏សមគួរហើយទើបនិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគ ថា បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលដែលបានឈ្មោះថា ព្រាហ្មណ៍ ដោយហេតុប៉ុន្មានយ៉ាង ម្យ៉ាងទៀតធម៌អ្វីខ្លះ សម្រាប់ធ្វើបុគ្គលឲ្យជាព្រាហ្មណ៍។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា ៖

យោ ព្រាហ្មណោ ពាហិតបាបធម្មោ
និហុំហុង្កោ និក្កសាវោ យតត្តោ
វេទន្តគូ វុសិតព្រហ្មចរិយោ
ធម្មេន សោ ព្រហ្មវាទំ វទេយ្យ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ ។

ព្រាហ្មណ៍ណាមានបាបធម៌បណ្តែតចោលហើយមានសំឡេងគម្រាមថា ហុំហុំ លះចោលហើយ
មានទឹកអម្ចត់គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ (គឺមគ្គញ្ញាណទាំង៤) មានមគ្គព្រហ្មចរិយៈនៅរួចហើយ ម្យ៉ាងទៀត ព្រាហ្មណ៍ណាមិនមានគំនរគឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួចក្នុងលោកសន្និវាស ព្រាហ្មណ៍នោះគួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន។

## មារអារាធនាព្រះពុទ្ធបរិនិព្វាន

*កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងអជបាលនិគ្រោធនេះ ។ កាលណោះ មារមានចិត្តបាប បានចូលទៅទូលព្រះដ៏មានព្រះភាគ[១]ថា*

បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ

*បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។*

*ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា*

*ម្នាលមារមានចិត្តបាប ពួកភិក្ខុ (ភិក្ខុនី ឧបាសក ឧបាសិកា) ជាសាវ័ករបស់តថាគត ដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ។*

[១] *ទីឃ.មហា.១៦/២៣៧ ។*



## ៦.ស្រះមុចលិន្ទ

លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ក្រោកចាក សមាធិនោះ ហើយទ្រង់ចេញអំពីម្លប់អជបាលនិគ្រោធព្រឹក្សយានចូលទៅកាន់ដើមរាំង លុះចូលទៅដល់ហើយ ទ្រង់គង់ដោយព្រះភ្លែនតែមួយអង្គុយអស់៧ថ្ងៃក្រោមម្លប់រាំង សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។

សម័យនោះឯង មហាមេឃពុំជួកាល ក៏បណ្តាលឡើងជាភ្លៀង។ មានភ្លៀងរលឹមអស់ ៧ថ្ងៃ បណ្តាលឲ្យអាប់ពន្លឺព្រះអាទិត្យដោយអំណាចខ្យល់ត្រជាក់។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួនហើយពេនព័ទ្ធព្រះកាយព្រះដ៏មានព្រះភាគ ៧ ជុំដោយភ្លែន (របស់ខ្លួន) ហើយលើកពពារដ៏ធំបាំងពីខាងលើព្រះសិរ្សព្រះដ៏មានព្រះភាគ ហើយឋិតនៅដោយគិតថា រងាកុំបីបៀតបៀនព្រះដ៏មានព្រះភាគ ក្តៅក៏កុំបីបៀតបៀន ព្រះដ៏មានព្រះភាគ សម្ផស្សរបោមមូសខ្យល់កម្តៅថ្ងៃពស់តូចពស់ធំក៏កុំបីបៀតបៀន ព្រះដ៏មានព្រះភាគឡើយ ។ លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ មុច្ចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃ

ស្រឡះហើយក៏រំសាយភេ្ននចេញចាកព្រះកាយព្រះដ៏មានព្រះភាគ ហើយប្រែភេទរបស់ខ្លួននិម្មិតជាភេទមាណព ឈរប្រណម្យអញ្ជលី នមស្ការព្រះដ៏មាន ព្រះភាគ ពីខាងទីចំពោះព្រះភក្ត្រព្រះអង្គ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តី នេះហើយ ក៏ទ្រង់ឧទានគាថាក្នុងវេលានោះថា ៖

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សំយមោ។

សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស យោ វិនយោ ឯតំ វេ បរមំ សុខំ។

សេចក្តីស្ងាត់ចាកកិលេស របស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើតសេចក្តីសុខ សេចក្តីមិនព្យាបាទនិងសេចក្តីសង្រួម មិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក សេចក្តីណាយចាករាគៈនិងការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក កិរិយាកម្ចាត់បង់នូវអស្មិមានះ កិរិយាកម្ចាត់បង់នូវអស្មិមានះនោះ ជាសុខយ៉ាងក្រៃលែង។



## ៧.រាជាយតនចេតិយ

លំដាប់នោះព្រះដ៏មានជោគទ្រង់ក្រោកចេញចាកសមាធិនោះហើយ យាងចេញពីម្លប់ដើមរាំង ហើយយាងចូលទៅកាន់ដើមរាជាយតនៈ[១] លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្នែនតែមួយអន្លុយអស់ ៧ ថ្ងៃ ក្រោម ម្លប់ដើមរាជាយតនៈ ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូននឹងគ្នាបង្កើត) ឈ្មោះតបុស្សៈ១ ភល្លិកៈ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញអំពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ។ គ្រានោះ មានទេវតាជាញាតិសាលោហិត[២]របស់តបុស្សៈ និងភល្លិកៈពាណិជ បាននិយាយពាក្យនេះ នឹងត

---

១.ដើមកែស ។ ២. ញាតិសាលោហិតនោះ គឺជនដែលធ្លាប់ជាញាតិរបស់ពាណិជទាំងនោះមកកើតជាទេវតា ។

បុស្ស:និងភល្លិក:ពាណិជថា ម្នាលគ្នាយើង ព្រះដ៏មានព្រះភាគនេះទើបនឹងបាន ត្រាស់ជាដំបូង ឥឡូវព្រះអង្គគង់នៅក្រោមម្លប់រាជាយតន:(ឯណោះ) អ្នកទាំងឡាយ គួរចូលទៅបូជាព្រះដ៏មានព្រះភាគអង្គនោះដោយសដូវផង់និងសដូវដុំចុះ ការបូជានោះ នឹងបានជាប្រយោជន៍និងសេចក្ដីសុខដល់អ្នកទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ តបុស្ស:និងភល្លិក:ពាណិជក៏នាំយកនូវសដូវផង់និងសដូវដុំ ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងកន្លែងដ៏សមគួរ។ លុះតបុស្ស:និងភល្លិក:ពាណិជឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំរបស់យើងខ្ញុំព្រោះថា ការទទួលនឹងបានជាប្រយោជន៍ និងសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ធម្មតា ព្រះតថាគតទាំងឡាយមិនដែលទទួល (អាមិស:) ផ្ទាល់នឹងដៃឡើយ បើដូច្នេះតើ តថាគត គួរទទួលនូវសដូវផង់នឹងសដូវដុំដោយវត្ថុអ្វីហ្ន៎។ គ្រានោះ មហារាជ[១]ទាំង ៤ ទ្រង់ជ្រាប ព្រះតម្រិះរបស់ព្រះដ៏មានព្រះភាគ (ដោយចិត្តរបស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ ៤ អំពីទិសទាំង ៤ បង្អោនចូលមកថ្វាយព្រះដ៏មាន-ព្រះភាគដោយពាក្យថា បពិត្រព្រះអង្គ ដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់និងសដូវដុំដោយបាត្រនេះចុះ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនូវសដូវផង់និងសដូវដុំ ដោយបាត្រថ្មកែវទាំងឡាយដ៏មានតម្លៃច្រើន លុះទទួលស្រេចហើយ ក៏ទ្រង់សោយ(ក្នុងពេលនោះ)។ គ្រានោះឯង តបុស្ស: និងភល្លិក:ពាណិជ បាននិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគ ដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះដ៏មានព្រះភាគ និងព្រះធម៌ជាទីរឭក សូម ព្រះអង្គទ្រង់ជ្រាប នូវយើងខ្ញុំទាំងឡាយថា ជាឧបាសកបានដល់នូវទីរឭក ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះ ជាដើមតរៀងទៅ។ ក៏ឯពាណិជទាំងពីរនាក់នោះបាននាមបញ្ញត្តិថា ទ្វេវាចិកឧបាសកជាដំបូងក្នុងលោក។

---

១. លោកបាលទេវបុត្តទាំង៤ ដែលជាស្ដេចធំក្នុងស្ថានសួគ៌ឈ្មោះចតុម្មហារាជក:។ ២. ឧបាសកបានបញ្ចេញវាចាប្ដេជ្ញាខ្លួនយកព្រះពុទ្ធនិងព្រះធម៌ទាំងពីរជា ទីពឹងទីរឭកព្រោះ ក្នុងពេលនោះមិនទាន់មានព្រះសង្ឃនៅឡើយ។

នៅក្នុងអដ្ឋកថាវិនយបិដក មហាវគ្គ រាជាយតនកថា ពោលថា

ព្រះដ៏មានព្រះភាគបានប្រទានទូវព្រះកេសធាតុដល់ពាណិជ្ជទាំងពីរ ដូចជាបានអភិសេកដោយអមតធម៌ មានចិត្តត្រេកអររីករាយ តម្កល់ព្រះធាតុក្នុងប្រអប់មាស ហើយថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ត្រឡប់ទៅកាន់នគររបស់ខ្លួន ។



មានសេចក្តីបញ្ជាក់ថា តបុស្ស: និងភល្លិក:បានអារាធនាព្រះកេសធាតុ ទៅប្រតិស្ថានក្នុងព្រះចេតិយស្វេដាហ្គង់ ប្រទេសភូមា សព្វថ្ងៃនេះ ។



# ព្រហ្មអារាធនាព្រះពុទ្ធអង្គ ត្រង់អជបាលនិគ្រោធ

*កាលព្រះពុទ្ធជាអម្ចាស់ ទ្រង់គង់ក្នុងសត្តមហាឋានទាំង ៧ កន្លែងនេះហើយ ព្រះអង្គទ្រង់យាងទៅកាន់អជបាលនិគរោធម្តងទៀត[១] ។*

*លំដាប់នោះ ព្រះដ៏មានព្រះភាគគង់សម្ងំនៅក្នុងទីស្ងាត់តែមួយព្រះអង្គ ទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ គឺសត្វឃើញបានដោយកម្រ ជាធម៌គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌លុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះសុទ្ធតែនៅកំពុង រីករាយ ក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើប ស្រាលក្នុង សេចក្តីអាល័យ (ចំពោះកាមទាំងឡាយនៅឡើយ) ក៏បដិច្ចសមុប្បាទធម៌ គឺធម៌ជា បច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុនាំឲ្យពពួកសត្វនៅរីករាយក្នុងសេចក្តីអាល័យ នៅត្រេកត្រអាលក្នុងសេចក្តីអាល័យ នៅស្រើបស្រាលក្នុងសេចក្តីអាល័យ ឃើញបានដោយកម្រ ម្យ៉ាងទៀត ធម៌ណាសម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបោលនូវឧបធិគឺខន្ធនិងកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយ ចាករាគៈ ជាទីរលត់នៃទុក្ខគឺនិព្វាន ធម៌ទាំងអម្បាលនេះជាហេតុដែលពពួកសត្វឃើញ បានដោយកម្រក្រៃពេក បើទុកជាតថាគតសម្តែងធម៌ទៅក៏គង់សត្វទាំងឡាយជទៃមិនអាច នឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ។ ហេតុនោះ សេចក្តីលំបាក សេចក្តីនឿយ ព្រួយមុខជានឹងមានដល់តថាគតមិនខាន។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យ សមគួរនេះ ព្រះដ៏មានព្រះភាគមិនដែលបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដ ដល់ព្រះអង្គថា ៖*

កិច្ឆេន មេ អធិគតំ ហលំ ទានិ បកាសិតុំ
រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ។

---

[១] *វិនយ.មហា.៦/១៣ ។*

បដិសោតគាមឹ និបុណំ　　គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ　　តមោខន្ធេន អាវុដា។

*ឥឡូវនេះតថាគត គួរសម្តែងនូវធម៌ ដែលតថាគតបានត្រាស់ដឹងហើយ ដោយកម្រ (នោះទៅចុះ)។ ប៉ុន្តែសត្វទាំងឡាយដែលរាគៈទោសៈគ្របសង្កត់ ក៏មិនអាចនឹង ត្រាស់ដឹងនូវធម៌នេះ បានដោយងាយទេ។ សត្វទាំងឡាយ ដែលកំពុងត្រេកអរ ដោយរាគៈដែលគំនរងងឹត (គឺអវិជ្ជា) កំពុងបិទបាំង (យ៉ាងនេះ) មុខជានឹងមិនឃើញ នូវធម៌ដែលនាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតឆ្មារ ជ្រាលជ្រៅ សត្វឃើញបាន ដោយកម្រ (នោះទេ)។*

*លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យរបស់ ព្រះដ៏មានព្រះភាគដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងត្រិះរិះដូច្នេះថា អើហ្ន៎ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ មានព្រះហឫទ័យឱនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅ ដើម្បីសម្តែងធម៌ (យ៉ាងនេះ) ឱ សត្វលោកវិនាសតើហ្ន៎ ឱ សត្វលោកវិនាសតើហ្ន៎។ គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគ (ដោយឆាប់ភ្លាម) ប្រៀបដូចបុរសអ្នកមានកម្លាំងលាចេញនូវដើមដៃ ដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃដែលខ្លួនលាចេញ។ លំដាប់នោះ សហម្បតិព្រហ្មធ្វើសំពត់ឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះត្រង់ព្រះដ៏មានព្រះភាគ ទើបពោលពាក្យនេះនឹង ព្រះដ៏មានព្រះភាគថា*

ទេសេតុ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ។ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ។

*បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងធម៌ សូមព្រះសុគតសម្តែងធម៌ (ដ្បិត) សត្វទាំងឡាយដែលមានធូលី គឺរាគាទិកិលេសដ៏ស្រាល ស្តើងក្នុងភ្នែកគឺបញ្ញា តែខានស្តាប់ធម៌ ក៏មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយ អ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ។*

ពេលនោះ សហម្បតីព្រហ្ម ក៏ពោលជាគាថាថា

ចាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេតំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ ។

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិលតែងគិត ជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយ ក្នុងដែនមគធៈ។ សូមព្រះអង្គ បើកនូវទ្វារនៃព្រះនិព្វាននោះ សត្វទាំងឡាយប្រុងចាំស្តាប់ធម៌ ដែល ព្រះអង្គជាអ្នកប្រាសចាកមន្ទិលទ្រង់ ត្រាស់ដឹងតាម (លំអានព្រះពុទ្ធ អំពីបូរាណ)។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតំ ។

ប្រៀបដូចជាបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយ ថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជន ដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមាន សេចក្តី សោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទដ៏ហើយ ដោយ ធម៌ ពិចារណាមើលនូវប្រជុំជនអ្នកប្រឡំ ដោយសេចក្តីសោក ដែល ជាតិជរាកំពុង គ្របសង្កត់ មានឧបមាដូច្នោះដែរ ។

ឧដ្ឋេហិ វីរ វិជិតសង្គាម
សត្ថវាហ អណណ វិចរ លោកេ
ទេសស្សុ ភគវា ធម្មំ
អញ្ញាតារោ ភវិស្សន្តិ។

*បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាមហើយជានាយកនៃពួកសត្វ អ្នកមិនជាប់ជំពាក់បំណុលគឺកាមសូមព្រះអង្គ ក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក។ សូមព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ សត្វទាំងឡាយអ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ។*

*គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់ នូវសេចក្តីអារាធនារបស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់ រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ។ ព្រះដ៏មានព្រះភាគ កាលទ្រង់រមើលមើលនូវ សត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយមានធូលី គឺរាគាទិក្កិលេស តិចក្នុងភ្នែក (ខ្លះ) មានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយរឹង (ខ្លះ) មានឥន្ទ្រិយទន់ (ខ្លះ) មានអាការៈល្អ (ខ្លះ) មានអាការៈអាក្រក់ (ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) ជាអ្នកឃើញបរលោក និងទោសដោយសភាពគួរឲ្យខ្លាចខ្លះ។ (សេចក្តីប្រៀបថា) មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិខ្លះគឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលិតក្តី ផ្កាឈូក*

ក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ផុះខ្ពស់ ឡើងផុតទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះដ៏មានព្រះភាគ កាលទ្រង់រមិល មើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយមានធូលី គឺ រាគាទិក្កិលេសតិច ក្នុងភ្នែក (ខ្លះ) មានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មាន ឥន្ទ្រិយរឹង (ខ្លះ) មានឥន្ទ្រិយ ទន់ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការមិនល្អ (ខ្លះ) ជាសត្វ ដែលព្រះអង្គគួរឲ្យត្រាស់ដឹង បានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) សត្វជំពូកខ្លះឃើញបរលោក និង ទោសដោយសភាពគួរខ្លាចមានឧបមាយ៉ាងដូច្នោះឯង លុះទ្រង់ឃើញហើយ ទើបទ្រង់សម្តែង ជាបទគាថានឹងសហម្បតិព្រហ្មថា ៖

អបារុតា តេសំ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ។

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណា មាន សោតប្បសាទ សត្វ ទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាចុះ។ ម្នាលមហាព្រហ្ម តថាគតមានសេចក្តីសម្គាល់ ក្នុងការលំបាក បានជាមិនសម្តែងធម៌ដ៏ឧត្តម ដែលស្ទាត់ក្នុងសំណាក់ មនុស្សទាំង ឡាយ។

# ព្រះពុទ្ធទ្រង់ចាប់ផ្តើមសម្តែងព្រះធម៌

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។ លំដាប់នោះ ព្រះដ៏មាន ព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះទៀតថា អាឡារតាបសកាលាមគោត្រនេះ ជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែក យូរមកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ដល់អាឡារតាបសកាលាមគោត្រជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។ គ្រានោះ មានទេវតា(អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូល ព្រះដ៏មានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន អាឡារតាបស កាលាមគោត្រ ធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមគោត្រ ធ្វើកាលកិរិយា ស្លាប់ទៅ ៧ ថ្ងៃហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា អាឡារតាបសកាលាមគោត្រ (នោះ) មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបស នោះបានស្តាប់ធម៌នេះ គប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតសម្តែងធម៌ដល់អ្នកណា ជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបាន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា ឧទ្ទកតាបសរាមបុត្រនេះឯង ជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាស វាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិច ក្នុងភ្នែកយូរណាស់មកហើយ បើដូច្នោះ គួរតថាគត សម្តែងធម៌ដល់ ឧទ្ទកតាបសរាមបុត្រនេះ ជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបាន។ គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូល ព្រះដ៏មានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទកតាបសរាមបុត្រ ធ្វើកាលកិរិយា ស្លាប់អំពីពេលព្រលប់ទៅហើយ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ ជ្រាបថា ឧទ្ទកតាបសរាមបុត្រ ធ្វើកាលកិរិយា ស្លាប់អំពីពេលព្រលប់ទៅហើយដែរ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះ

តម្រិះដូច្នេះថា ឧទ្ទកតាបសរាមបុត្រមានសេចក្ដីសាបសូន្យធំ ប្រសិនបើតាបសនោះបាន ស្ដាប់ធម៌នេះគប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះ ដូច្នេះថា តថាគតគួរសម្ដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណា នឹងត្រាស់ដឹងធម៌នេះឆាប់ រហ័សបាន។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះតម្រិះ ដូច្នេះក្នុង លំដាប់នោះថា បញ្ចវគ្គិយ[១]ភិក្ខុ ទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះថាបានបម្រើតថាគតកាលដែលកំពុងបញ្ជូន ចិត្តទៅក្នុងព្យាយាម[២]បើដូច្នោះ គួរតថាគត សម្ដែងដល់ បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយ នៅឯណា ។ លុះព្រះដ៏មានព្រះភាគទ្រង់ឃើញ បញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងឥសិបតន មិគទាយវន ទៀបក្រុងពារាណសី ដោយ ទិព្វចក្ខុដ៏បរិសុទ្ធស្អាតកន្លងលើសចក្ខុរបស់មនុស្ស។ គ្រានោះ ព្រះដ៏មានព្រះភាគ គង់នៅ ក្នុងឧរុវេលាប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យ ទើបទ្រង់យាងទៅកាន់ចារិក សំដៅ ទៅរកក្រុងពារាណសី។

ក្នុងចន្លោះផ្លូវដែលព្រះពុទ្ធទ្រង់យាងទៅពារាណសី បានជួបនឹងឧបកាជីវកមួយនាក់ ដោយសាកសួរព្រះអង្គថា

ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នក ជ្រះថ្លាណាស់ ឆវិវណ្ណរបស់អ្នក ក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា? អ្នកណាជាគ្រូរបស់អ្នក? អ្នកពេញចិត្តនឹងធម៌របស់គ្រូណា?

ព្រះពុទ្ធទ្រង់ត្រាស់ឆ្លើយតបជាពាក្យឧទានថា

---

១. ភិក្ខុមានគ្នា៥រូប។ ២. កំពុងខំប្រឹងបំពេញព្យាយាមឲ្យបានត្រាស់ជាព្រះពុទ្ធ។

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហាក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ។

*តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា ។*

ន មេ អាចរិយោ អត្ថិ　　　សទិសោ មេ ន វិជ្ជតិ
សទេវកស្មិំ លោកស្មិំ　　　នត្ថិ មេ បដិបុគ្គលោ។

អហញ្ហិ អរហា លោកេ　　　អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ　　　សីតិភូតោស្មិ និព្វុតោ។

*តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយក្នុងលោកនេះព្រមទាំងទេវលោកមិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ។ ព្រោះថា តថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុតជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់មានភ្លើងកិលេសរលត់ហើយ។*

ធម្មចក្កំ បវត្តេតុំ　　　គច្ឆាមិ កាសិនំ បុរំ
អន្ធីភូតស្មិំ លោកស្មិំ　　　អាហញ្ឆំ អមតទុន្ទុភិន្តិ។

*ឥឡូវតថាគតទៅ កាន់ក្រុងនៃពួកជនអ្នកកាសី ដើម្បីនឹងសម្តែង*

ធម្មចក្ក (ដោយបំណងថា) តថាគត នឹងទូងនូវស្គរ គឺអមតនិព្វាន
ចំពោះ សត្វលោក ដែលងងឹត គឺអវិជ្ជាកំពុងគ្របសង្កត់។

កាលព្រះពុទ្ធជាម្ចាស់ ត្រាស់យ៉ាងនេះ ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្ដេជ្ញាខ្លួនអ្នកថាយ៉ាងណា អ្នក (គួរដើម្បីបាននូវឈ្មោះ) ថា អនន្តជិនៈ (យ៉ាងនោះឯង)។

ព្រះពុទ្ធជាអម្ចាស់ ទ្រង់បន្ដបន្លឺព្រះឧទានថា

មាទិសា វេ ជិនា ហោន្តិ យេ បត្តា អាសវក្ខយំ
ជិតា មេ បាបកា ធម្មា តស្មាហមុបក ជិនោ។

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ ជនទាំងឡាយ នោះឈ្មោះថា ជិនៈ (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ។ តថាគតបាន ឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគត បាននូវ ឈ្មោះថា ជិនៈ (ជាអ្នកឈ្នះបាបធម៌)។

កាលព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកាជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹង ពិតមែនហើយ(ថាហើយ) ក៏ងក់ក្បាលហើយចៀសចេញទៅ។




មហាគន្ធីស្តូប ទីកន្លែងដែលបញ្ចវគ្គិយភិក្ខុឃើញព្រះពុទ្ធយាងមក




## ព្រៃឥសិបតនមិគទាយវ័ន

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ហើយក៏ យាង ចូលទៅក្រុងពារាណសី រួចហើយយាងទៅឯឥសិបតនមិទាយវ័ន សំដៅទៅរក កន្លែង ដែលបញ្ចវគ្គិយភិក្ខុនៅ។ បញ្ចវគ្គិយភិក្ខុ បានឃើញព្រះដ៏មានព្រះភាគយាងមក អំពីចម្ងាយ លុះឃើញហើយ ក៏ធ្វើប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះ ជាអ្នកប្រតិបត្តិ ដើម្បីល្មោភ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីភាវៈល្មោភ ឥឡូវនេះលោកនិមន្តមកយើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលយកបាត្រចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ។ ព្រះដ៏មានព្រះភាគ យាងចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណា ៗ បញ្ចវគ្គិយភិក្ខុ ទាំងនោះ ក៏មិនអាចដើម្បីឋិតនៅ ក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការនោះៗ បានឡើយ ក៏ស្រាប់តែក្រោកទទួលព្រះដ៏មានព្រះភាគ ខ្លះទទួល យកបាត្រចីវររបស់ព្រះអង្គ ខ្លះក្រាល

អាសនៈថ្វាយ ខ្វះតម្កល់ទឹកលាងព្រះបាទ យកតាំង សម្រាប់រងព្រះបាទនិងឈ្នាន់រង ព្រះបាទមកថ្វាយ។ ព្រះដ៏មានព្រះភាគ គង់លើអាសនៈ ដែលបញ្ចវគ្គិយភិក្ខុទាំងឡាយ រៀបចំទុកហើយ។ លុះព្រះដ៏មានព្រះភាគ គង់ហើយ ក៏ទ្រង់លាងព្រះបាទទាំងពីរ។ ទើប បញ្ចវគ្គិយភិក្ខុ ហៅព្រះដ៏មានព្រះភាគ ដោយចំព្រះនាមផង ដោយពាក្យថា អាវុសោផង។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យហៅយ៉ាងនេះហើយ ព្រះភគវន្តមុនី ទ្រង់មាន ព្រះពុទ្ធដីកាយ៉ាងនេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នា កុំហៅតថាគតដោយចំ ឈ្មោះនិងពាក្យថា អាវុសោ ឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ ចូរប្រុងសោតប្បសាទចុះ ឥឡូវតថាគតនឹងប្រៀបប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះហើយបួស ក្នុងភាពនៃបុគ្គលគ្មានការងារ ជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌[១]នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ កាលព្រះដ៏មាន ព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលអ្នកដទៃ ធ្វើតាម បានដោយកម្រផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ហើយឃ្លាតចាកព្យាយាម ហើយវិលត្រឡប់មកដើម្បីល្មោភច្រើន ហើយក៏នឹងបានត្រាស់ដឹង ឧត្តរិមនុស្សធម៌ ដ៏វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេស ដូចម្តេចបាន។ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ ទើបព្រះដ៏មាន ព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះ នឹង

---

១. អនុត្តរធម៌ គឺព្រះអរហត្តផល។

បញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនប្រតិបត្តិដើម្បី ល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់ ដើម្បីល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅ នូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹង ហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះហើយ បួសក្នុងភាពនៃបុគ្គលមិនមានការងារ ជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីជាប្រយោជន៍ដល់ អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិគួរដល់ពាក្យប្រដៅ របស់តថាគត ហើយ ពុំយូរឡើយ មុខជានឹង បាន ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុត នៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយ ឥរិយាបថទាំង ៤ ។ បញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគ ជា គម្រប់ពីរដងផង ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយ ជាគម្រប់ពីរដងផង ។បេ។ បញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យនេះ នឹងព្រះ ដ៏មានព្រះភាគ ជាគម្រប់បីដងទៀតថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បាន ត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តមអាចកំម្ចាត់បង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលជន ដទៃ ធ្វើតាមបានដោយកម្រនោះផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បី ល្មោភច្រើន ហើយឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីល្មោភច្រើន នឹងបានត្រាស់ដឹងឧត្តរិមនុស្សធម៌ដ៏វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេស ដូចម្តេចបាន។ កាលបើ បញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរ ពិចារណាមើលនូវពាក្យរបស់តថាគតឥឡូវនេះ ដូចគ្នា នឹងកាលមុនអំពីកាលឥឡូវ នេះដែរ ឬទេ។ បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យហ្នឹង ព្រះអង្គ មិនដែល ពោលទេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជា អរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ ចូរប្រុង

សោតប្បសាទចុះ។ តថាគតនឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះបួសក្នុង ភាពនៃបុគ្គលមិនមានការងារ ជាប្រយោជន៍ ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិ គួរតាមពាក្យប្រដៅ របស់តថាគត ពុំយូរឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯងក្នុង បច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្ត ដោយឥរិយាបថទាំង ៤ ។ ព្រះដ៏មានព្រះភាគបានញុំាងបញ្ចវគ្គិយភិក្ខុទាំងឡាយ ឲ្យយល់ ច្បាស់ (ក្នុងពេលនោះ) ។លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយភិក្ខុទាំងឡាយ តាំងចិត្តស្តាប់ព្រះដ៏មានព្រះភាគ ផ្ទៀងនូវសោតប្បសាទ ហើយផ្ចង់ចិត្ត ដើម្បីដឹងច្បាស់។

បន្ទាប់មកព្រះពុទ្ធជាអម្ចាស់ ទ្រង់សម្តែងនូវធម្មចក្កប្បវត្តនសូត្រ ។



កាលពុទ្ធបរិស័ទដែលបានមកដល់ទីដែលព្រះពុទ្ធជាអម្ចាស់ ទ្រង់សម្ដែងធម្មចក្កនេះ ហើយ គួរនាំគ្នាស្វាធ្យាយធម្មចក្កប្បវត្តនសូត្រ ដើម្បីជាពុទ្ធបូជាចំពោះព្រះពុទ្ធជាអម្ចាស់ ។



# ធម្មចក្កប្បវត្តនសុត្តារម្ភោ

អនុត្តរំ អភិសម្ពោធឹ សម្ពុជ្ឈិត្វា តថាគតោ
បឋមំ យំ អទេសេសិ ធម្មចក្កំ អនុត្តរំ
សម្មទេវ បវត្តេន្តោ លោកេ អប្បដិវត្តិយំ

*ព្រះតថាគតជាម្ចាស់ ទ្រង់បានត្រាស់ដឹងនូវព្រះអនុត្តរាភិសម្ពោធិញ្ញាណហើយ កាលព្រះអង្គនឹងញ៉ាំងធម៌ ដែលឥតមានអ្នកណានឹងឲ្យប្រព្រឹត្តទៅក្នុងលោក ព្រះអង្គអាចឲ្យប្រព្រឹត្តទៅបាន ដោយប្រពៃពិត ទ្រង់បានសម្ដែងហើយនូវធម៌ណា ដែលហៅថា ធម្មចក្កដ៏ប្រសើរ ជាមុនដំបូងបំផុត*

យត្ថាក្ខាតា ឧភោ អន្តា បដិបត្តិ ច មជ្ឈិមា
ចតូស្វារិយសច្ចេសុ វិសុទ្ធំ ញាណទស្សនំ

*អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ ២ ប្រការ និង ផ្លូវប្រតិបត្តិជាកណ្ដាល និងប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់ ក្នុងអរិយសច្ចទាំងឡាយ ៤ ជាប្រាជ្ញាដ៏បរិសុទ្ធ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្ដែងហើយ ក្នុងព្រះធម៌ដែលហៅថា ធម្មចក្កឯណា*

ទេសិតំ ធម្មរាជេន សម្មាសម្ពោធិកិត្តនំ
នាមេន វិស្សុតំ សុត្តំ ធម្មចក្កប្បវត្តនំ
វេយ្យាករណបាឋេន សង្គីតំ តំ ភណាម សេ។

*យើងទាំងឡាយសូមស្វាធ្យាយនូវព្រះធម្មចក្កនោះដែលព្រះសម្មាសម្ពុទ្ធ ជាធម្មរាជ ទ្រង់សម្ដែងហើយ ប្រាកដដោយឈ្មោះថាធម្មចក្កប្បវត្តនសូត្រ ជាព្រះសូត្រប្រកាសនូវសម្មាសម្ពោធិញ្ញាណ ដែលព្រះសង្គីតិកាចារ្យ បាន ប្រជុំគ្នាសង្គាយនារៀបរៀងដោយរបៀបជាវេយ្យាករណបាឋ គឺជាបាលីបទ រាយឥតមានគាថាលាយផងឡើយ ។*

# ធម្មចក្កប្បវត្តនសូត្រ

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះធម្មចក្កប្បវត្តនសូត្រ) គឺខ្ញុំ (ឈ្មោះ អានន្ទ) បានស្តាប់មក ហើយ យ៉ាងនេះថា*

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ *សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។*

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ *ព្រះដ៏មានព្រះ ភាគទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុ[៦]ទាំងឡាយ ក្នុងទីនោះឯង (ឲ្យតាំង ចិត្តស្តាប់នូវភាសិតនេះថា)*

ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា *ម្នាលភិក្ខុទាំងឡាយ អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ ។*

កតមេ ទ្វេ *អន្តធម៌ទាំងឡាយពីរយ៉ាងនោះដូចម្តេច ?*

យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ *ធម៌ណា ដែលប្រកបខ្លួនឲ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ*

ហីនោ *ជាធម៌ថោកទាប*

គម្មោ *ជាធម៌របស់អ្នកស្រុក*

បោថុជ្ជនិកោ *ជាធម៌របស់បុថុជ្ជន*

អនរិយោ *មិនមែនជារបស់អរិយបុគ្គលទេ*

អនត្ថសញ្ហិតោ *មិនប្រកបដោយប្រយោជន៍ឡើយ ។*

យោ ចាយំ អត្តកិលមថានុយោគោ *ធម៌ណាដែលប្រកបសេចក្តីលំបាកដល់ខ្លួន*

---

[៦] *ភិក្ខុមានចំនួន៥រូប គឺឈ្មោះ កោណ្ឌញ្ញៈ១ វប្បៈ១ ភទ្ទិយៈ១ មហានាម១ អស្សជិ១ ។*

ទុក្ខោ ជាហេតុនាំឲ្យលំបាកកាយទទេៗ

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ

ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាលមិនលាយប្រឡំ ដោយអន្តធម៌ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ (ភ្នែកគឺប្រាជ្ញា) ធ្វើឲ្យកើតសេចក្តី ដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។

កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីប្រតិបត្តិ ជាកណ្តាលដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើត បញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខនោះ តើដូចម្តេច ?

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវ មានអង្គ ៨ ដ៏ប្រសើរ នេះឯង (ហៅថាសេចក្តីប្រតិបត្តិជាកណ្តាល)

សេយ្យថីទំ អដ្ឋង្គិកមគ្គនោះ ដូចម្តេច?

សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ

សម្មាសង្កប្បោ *សេចក្តីត្រិះរិះត្រូវ*

សម្មាវាចា *សម្តីត្រូវ*

សម្មាកម្មន្តោ *ការងារត្រូវ*

សម្មាអាជីវោ *កិរិយាចិញ្ចឹមជីវិតត្រូវ*

សម្មាវាយាមោ *ព្យាយាមត្រូវ*

សម្មាសតិ *សេចក្តីរឭកត្រូវ*

សម្មាសមាធិ *កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ*

អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនេះ ឯង ដែលហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។

*ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយាកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ ជរា គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ព្យាធិ គឺជំងឺតម្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ*

មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និង សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកប ដោយសត្វនិង សង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាសចាក សត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កាលបើចង់បាន នូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធទាំងឡាយ ៥ ដែលតថាគតសម្តែងហើយដោយបំព្រួញ ក៏ជា ហេតុនាំមកនូវទុក្ខ កងទុក្ខ មានជាតិជាដើមនេះ ឈ្មោះថាទុក្ខអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា ចោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវភពថ្មី ប្រកបដោយតម្រេកដោយ អំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះជាប្រក្រតី តណ្ហានោះ ដូម្តេចខ្លះ? (តណ្ហានោះ) គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គមិនឲ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយា រលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនអាល័យ ក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហា ដោយអរិយមគ្គមិនឲ្យមាន សេសសល់ជាដើមនោះឯង ឈ្មោះថា ទុក្ខនិរោធអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ

*ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គ ដ៏ប្រសើរនេះឯង ដូចម្តេចខ្លះ ? គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមរេព្វកត្រូវ កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ អដ្ឋង្គិកមគ្គ ដ៏ប្រសើរនេះឯង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។*

*(កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការដូច្នេះហើយ ទើបត្រាស់ទេសនានូវញាណទាំង ៣ ប្រការ គឺសច្ចញ្ញាណ កិច្ចញ្ញាណ កតញ្ញាណ ឲ្យទូទៅក្នុងអរិយសច្ច ៤ តទៅទៀតថា)*

ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ

*ម្នាលភិក្ខុទាំងឡាយ ចក្ខុ[៧]កើតឡើងហើយ ញាណ[៨]កើតឡើងហើយ បញ្ញា[៩]កើតឡើងហើយ វិជ្ជា[១០]កើតឡើងហើយ ពន្លឺភ្លឺស្វាង[១១]កើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម[១២]តថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខអរិយសច្ច ដូច្នេះឡើយ ។*

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ

---

*[៧] បញ្ញាដែលឃើញច្បាស់ ។*

*[៨] បញ្ញាដែលដឹងច្បាស់ ។*

*[៩] បញ្ញាដែលដឹងមិនខុសមិនភ្លាត់ ។*

អថ ខោ ភគវា គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា វិហារា និក្ខម្ម វិហារបច្ឆាយាយំ បញ្ញត្តេ អាសនេ និសីទិ។ *លុះព្រះមានព្រះភាគ សះស្បើយចាកព្រះអាពាធហើយ ទើបនឹងស្បើយចាកអាពាធ មិនយូរប៉ុន្មាន ទ្រង់ស្តេចចេញអំពីវិហារ ទៅគង់លើអាសនៈដែលគេបានក្រាលទុកត្រង់ម្លប់វិហារ* ។ អថ ខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ *គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ* ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ។ *លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ*

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា ទិដ្ឋោ មេ ភន្តេ ភគវតោ ផាសុ ទិដ្ឋំ មេ ភន្តេ ភគវតោ ខមនីយំ អបិ ច មេ ភន្តេ មធុរកជាតោ វិយ កាយោ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញព្រះមានព្រះភាគ ទ្រង់បានសេចក្តីសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគអត់ធន់បាន បពិត្រព្រះអង្គដ៏ចម្រើន ក៏កាយរបស់ខ្ញុំព្រះអង្គហាក់ ដូចជាស្រយុតស្រយង់ពេកណាស់ ។ ទិសាបិ មេ ន បក្ខាយន្តិ ធម្មាបិ មំ ន បដិភន្តិ ភគវតោ គេលញ្ញេន អបិ ច មេ ភន្តេ អហោសិ កាចិទេវ អស្សាសមត្តា ន តាវ ភគវា បរិនិព្វាយិស្សតិ ន យាវ ភគវា ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរតីតិ ។ សូម្បីទិសទាំងឡាយ ក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ សូម្បីធម៌ទាំងឡាយក៏មិនច្បាស់លាស់ដល់ខ្ញុំព្រះអង្គ ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់ព្រះអាពាធ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែខ្ញុំព្រះអង្គមានសេចក្តីសង្ឃឹមខ្លះថា ព្រះមានព្រះភាគមិនទាន់ សំដែងធម៌ នីមួយដ៏ប្លែកប្រារព្ធនឹងភិក្ខុសង្ឃដរាបណាទេ ព្រះមានព្រះភាគនឹងមិនទាន់បរិនិព្វាន ដរាបនោះ ។ កិំ បនានន្ទ ភិក្ខុសង្ឃោ មយិ បច្ចាសីសតិ ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ ករិត្វា។ នត្ថានន្ទ តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ។ យស្ស នូន អានន្ទ ឯវមស្ស អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា សោ នូន អានន្ទ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរេយ្យ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ភិក្ខុសង្ឃ នៅនឹកប៉ុនប៉ងអ្វីក្នុងតថាគតទៀត ម្នាលអានន្ទ ធម៌ដែលតថាគតសំដែងហើយ ធ្វើមិនឲ្យមានខាងក្នុង ខាងក្រៅ ម្នាលអានន្ទ កណ្តាប់ដៃនៃអាចារ្យ មិនមានក្នុងធម៌ទាំងឡាយរបស់តថាគតទេ ម្នាលអានន្ទ អ្នកណាមានគំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះក្តី ថាភិក្ខុសង្ឃជាអ្នកអាងនូវអាត្មាអញដូច្នេះក្តី ម្នាលអានន្ទ អ្នកនោះសមជាពោលពាក្យណា មួយប្រារព្ធនឹងភិក្ខុសង្ឃមិនខាន ។ តថាគតស្ស ខោ អានន្ទ ន ឯវំ ហោតិ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា។ សកិំ

អានន្ទ តថាគតោ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរិស្សតិ។ ម្នាលអានន្ទ តថាគតមិនមាន គំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ ឬថាភិក្ខុសង្ឃជាអ្នកអាងនូវអាត្មាអញដូច្នេះសោះឡើយ ។ ម្នាលអានន្ទ ព្រះតថាគត នឹងពោលពាក្យណាមួយ ប្រារព្ធនឹងភិក្ខុសង្ឃ ធ្វើអ្វីទៀត ។ អហំ ខោ បនានន្ទ ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ ។ អាសីតិកោ មេ វយោ វត្តតិ។ ម្នាលអានន្ទ ឥឡូវនេះតថាគតគ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងអាយុកាលដល់បច្ឆិមវ័យហើយ វ័យតថាគតបាន ៨០ ឆ្នាំ ហើយ ។សេយ្យថាបិ អានន្ទ ជជ្ជរសកដំ វេឋមិស្សកេន យាបេតិ ឯវមេវ ខោ អានន្ទ វេឋមិស្សកេន មញ្ញេ តថាគតស្ស កាយោ យាបេតិ ។ ម្នាលអានន្ទ រទេះចាស់ដែលបរទៅបាន ព្រោះការអបដោយឫស្សី យ៉ាងណាមិញ ម្នាលអានន្ទ កាយរបស់តថាគតនឹងប្រព្រឹត្តទៅបាន ដូចជារទេះអបដោយឫស្សីយ៉ាងនោះឯង ។ យស្មិំ អានន្ទ សមយេ តថាគតោ សព្វនិមិត្តានំ អមនសិការា ឯកច្ចានំ វេទនានំ និរោធា អនិមិត្តំ ចេតោសមាធិំ ឧបសម្បជ្ជ វិហរតិ ផាសុតរោ អានន្ទ តស្មិំ សមយេ តថាគតស្ស កាយោ ហោតិ ។ ម្នាលអានន្ទ សម័យណា ដែលព្រះតថាគតចូលចេតោសមាធិ ( សេចក្តីតាំងចិត្តមាំ ) ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ព្រោះរំលត់វេទនាពួកខ្លះ ម្នាលអានន្ទ សម័យនោះ កាយនៃតថាគតក៏បានសេចក្តីសប្បាយ គ្រាន់បើ ។ តស្មាតិហានន្ទ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា។ ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក កុំយករបស់ដទៃជាទីរលឹក ចូរយកធម៌ជាទីពឹង យកធម៌ជាទីរលឹក កុំយករបស់ដទៃជាទីរលឹកឡើយ ។ កាថញ្ចានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ម្នាលអានន្ទ ភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌

ជាទីពឹង យកធម៌ជាទីរលឹក មិនយករបស់ដទៃជាទីរលឹកនោះ តើដូចម្តេច ។ ឥធានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា ទោមនស្សំ។ វេទនាសុ ។បេ។ ចិត្តេ ។បេ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជា នោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយ ក្នុងកាយ មានព្យាយាមដុតកំដៅកិលេស មានសម្បជញ្ញៈ មានសតិកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក គឺ ឧបាទានក្ខន្ធចេញ ។ ក្នុង វេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាម ដុតកំដៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ចេញ ។ ឯវំ ខោ អានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ ម្នាលអានន្ទ យ៉ាងនេះឯង ភិក្ខុឈ្មោះថា យកខ្លួនជាទីពឹង យកខ្លួនជាទីរលឹកមិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិន យករបស់ដទៃ ជាទីរលឹក ។ យេ ហិ កេចិ អានន្ទ ឯតរហិ វា មម វា អច្ចយេន អត្តទីបា វិហរិស្សន្តិ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា តមតគ្គេ មេ តេ អានន្ទ ភិក្ខូ ភវិស្សន្តិ យេ កេចិ សិក្ខាកាមាតិ ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះក្តី អំណើឥតពីតថាគតទៅក្តី ភិក្ខុណាមួយ យកខ្លួនជាទីពឹង យកខ្លួន ជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិនយក របស់ដទៃជាទីរលឹកឡើយ ម្នាលអានន្ទ មួយទៀត ភិក្ខុណាមួយ ជាអ្នកប្រាថ្នានូវសិក្ខា ភិក្ខុទាំងនោះនឹងតាំងនៅក្នុងគុណដ៏ប្រសើរបំផុតរបស់តថាគតដែរ ។

# ចាបាលចេតិយ

អថ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅទ្រង់បិណ្ឌបាត្រ ក្នុងក្រុងវេសាលី ។ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ លុះទ្រង់ត្រាច់ទៅបិណ្ឌបាត្រ ក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាត្រក្នុងវេលាខាងក្រោយភត្តហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា គណ្ហាហិ អានន្ទ និសីទនំ យេន ចាបាលំ ចេតិយំ តេនុបសង្កមិស្សាម ទិវា វិហារាយាតិ ។ ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈ ទៅ យើងនឹងចូលទៅសម្រាកក្នុងវេលាថ្ងៃឯបាវាលចេតិយ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាម ៗ ខាងក្រោយព្រះមានព្រះភាគ ។ អថ ខោ ភគវា យេន ចាបាលំ ចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ គ្រានោះ ព្រះមានព្រះភាគ ស្តេចចូលទៅកាន់បាវាលចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ អាយស្មាបិ ខោ អានន្ទោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ។ ចំណែកខាង ព្រះអានន្ទមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះ ភាគ ទ្រង់មានព្រះបន្ទូលដូច្នេះថា រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ ។ ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ឧទេន

*ចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ* យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ *ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ ធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន* តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ *ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុ កប្បក៏បាន ។* ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ *ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិកយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនា ព្រះមានព្រះភាគថា* តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មារេន បរិយុដ្ឋិតចិត្តោ ។ *បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បី*

ប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកទេវតានិង មនុស្សដូច្នេះ សោះ ព្រោះមារចូលមកជ្រែកគំនិត ។ ទុតិយម្បិ ខោ ភគវា ។បេ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលជាគម្រប់ ២ ដងផង ។ បេ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទមានអាយុជា គម្រប់ ៣ ដងផងថា រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ ។ ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ។ ម្នាលអានន្ទ ឯឥទ្ធិបាទ ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយ ៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយ ៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បី

ឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិក យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏នៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនា ព្រះមានព្រះភាគថា តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មារេន បរិយុដ្ឋិតចិត្តោ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគត ឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយដូច្នេះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។ អថ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរដឹងនូវកាលដែលគួរនឹងទៅ ក្នុងកាល ឥឡូវនេះចុះ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា អវិទូរេ អញ្ញតរស្មិំ រុក្ខមូលេ និសីទិ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយអង្គុយទៀបគល់ឈើមួយ ក្នុងទីមិនឆ្ងាយ ។

## មារអារាធនាព្រះពុទ្ធបរិនិព្វាន

អថ ខោ មារោ បាបិមា អចិរបក្កន្តេ អាយស្មន្តេ អានន្ទេ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ។ កាលបើព្រះអានន្ទមានអាយុ ចេញទៅហើយមិនយូរប៉ុន្មានគ្រានោះ ក្រុងមារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ ឯកមន្តំ ឋិតោ ខោ មារោ បាបិមា ភគវន្តំ ឯតទវោច លុះក្រុងមារមានចិត្តបាបឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោ ទានិ ភន្តេ ភគវតោ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានី ករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។ ឯតរហិ ខោ បន ភន្តេ ភិក្ខូ ភគវតោ សាវកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ

សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ។ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវ័ករបស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅបពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនីជាសាវិការបស់តថាគត ដែលឈ្លាស វាងវៃក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួនហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះដូច្នេះ ។

ឯតរហិ ខោ បន ភន្តេ ភិក្ខុនិយោ ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ

អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញាបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ។

*បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងកាលឥឡូវនេះ ពួកភិក្ខុនីជាសាវិការបស់ព្រះមានព្រះភាគ បានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ បានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិន ដោយល្អតាមពាក្យសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើនឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ។*

ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧបាសកា ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញាបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ។

*បពិត្រព្រះអង្គដ៏ចម្រើនមួយទៀត ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាល មារមានចិត្តបាប ពួកឧបាសកជាសាវ័ករបស់តថាគត ដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈ នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ*

*ហើយសំដែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ  តថាគតក៏នឹងមិនទាន់បរិនិព្វានដរាប នោះ ដូច្នេះ ។*

ឯតរហិ ខោ បន ភន្តេ ឧបាសកា ភគវតោ សាវកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ។

*បពិត្រព្រះអង្គដ៏ចម្រើនក៏ឥឡូវនេះពួកឧបាសកជាសាវ័ករបស់ព្រះមានព្រះភាគ ឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិសមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធមម៌ហើយ ទាំងបានរៀនទូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនទូវបរប្បវាទ ដែលកើតឡើង ហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះសូមព្រះមានព្រះភាគ បរិនិព្វានទៅសូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹង បរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។*

ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេនសុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ។

*បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកឧបាសិកា ជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃក្លៀវក្លា*

*ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌នៅមិនទាន់មានទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតក៏នឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ។*

ឯតរហិ ខោ បន ភន្តេ ឧបាសិកា ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ។

*បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ពួកឧបាសិកា ជាសាវិកា របស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរប្រព្រឹត្តតាមធម៌ហើយទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិន នូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។*

ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥធំ ព្រហ្មចរិយំ ន ឥទ្ធំ ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ។ ឯតរហិ ខោ បន ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធំ ចេវ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោតិ។

*បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចរិយៈរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា នឹងមិនទាន់ពេញបរិបូណ៌ ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ចេះសំដែងបានដោយប្រពៃ ដរាបណាតថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចរិយរបស់ព្រះមានព្រះភាគនេះ ខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្សចេះសំដែងបានដោយល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះសូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។*

ឯវំ វុត្តេ ភគវា មារំ បាបិមន្តំ ឯតទវោច អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ។ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ។

*កាលបើក្រុងមារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ភាសិតនេះទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។*

## អាយុសង្ខារឱស្សជ្ជនំ

អថ ខោ ភគវា ចាបាលេ ចេតិយេ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជិ។ ឱស្សដ្ឋេ ច ភគវតា អាយុសង្ខារេ មហាភូមិចាលោ អហោសិ ភឹសនកោ សលោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

*លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារឰដ៏បាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កក្រើកផែនដីយ៉ាងធំគួរឲ្យភ្ញាក់ភ្ញើក ព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា*

តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជិ មុនិ
អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ។

*ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវ*
*ព្រះនិព្វានដែលមានគុណប្រៀបមិនបានផង នូវភពផង ទ្រង់*
*លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរ*
*នូវអារម្មណ៍ខាងក្នុង (ដោយអំណាចសមថៈ) ផង ទ្រង់បាន*
*ទំលាយនូវបណ្តាញ គឺកិលេសដែលកើតមាននៅ ក្នុងខ្លួន*
*ដូចជាក្រោះ ។*

## កូដាគារសាលានាព្រៃមហាវ័ន

អថ ខោ ភគវា អាយស្មតា អានន្ទេន សទ្ធិំ យេន មហាវនំ កូដាគារសាលា តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ

*លំដាប់នោះ ព្រះមានព្រះភាគ ក៏ស្តេចចូលទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន មួយអន្លើដោយព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា*

គច្ឆ ត្វំ អានន្ទ យាវតិកា ភិក្ខូ វេសាលិំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេហីតិ។

*ម្នាលអានន្ទ អ្នកចូរទៅឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅ ក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ។*

ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យាវតិកា ភិក្ខូ វេសាលិំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ។ ឯកមន្តំ ឋិតោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សន្និបតិតោ ភន្តេ ភិក្ខុសង្ឃោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ។

*ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅ ក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ជ្រាបនូវកាលគួរក្នុងកាលឥឡូវនេះ ។*

អថ ខោ ភគវា យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា

តស្មាតិហ ភិក្ខវេ យេ តេ មយា ធម្មា អភិញ្ញា ទេសិតា តេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ។

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ។

កតមេ ច តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា យេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ។

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀតសាសនព្រហ្មចរិយៈនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បី សេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយ ប្រ

*ការណា ធម៌ទាំងឡាយណាដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បី រៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះធម៌ទាំងឡាយនោះតើដូចម្តេច ។*

សេយ្យថិទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ។

*គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។*

ឥមេ ខោ តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា យេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ។

*ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។*

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ។ នចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ។ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្ដីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្ដា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។
យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។

*ពួកជនណា ៗ ទោះបីក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី*
*អ្នកមានក្ដី អ្នកក្រក្ដី ជនទាំងអស់នោះ តែងមានសេចក្ដីស្លាប់*
*នៅពីខាងមុខ ។ ភាជន៍ដី ដែលស្មូនឆ្នាំង ធ្វើហើយ ទោះបីតូចក្ដី*
*ធំក្ដី ឆ្អិនក្ដី ឆៅក្ដីភាជន៍ទាំងអស់នោះមានកិរិយាបែកធ្លាយ*
*ជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។*

អថាបរំ ឯតទវោច សត្ថា

*ព្រះសាស្ដា ទ្រង់មានព្រះបន្ទូល ដូច្នេះ តទៅទៀតថា*

បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ ។

*វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគត*
*មានប្រមាណតិច តថាគតនឹង លះបង់អ្នកទាំងឡាយ*

ហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

អប្បមត្តា សតីមន្តោ    សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា    សចិត្តមនុរក្ខថ។
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ
ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ
ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយ ៗ ចុះ ។
យោ ឥមស្មិំ ធម្មវិនយេ    អប្បមត្តោ វិហស្សតិ
បហាយ ជាតិសំសារំ    ទុក្ខស្សន្តំ ករិស្សតីតិ ។
ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ
(ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារហើយធ្វើនូវ
ព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។

## ព្រះពុទ្ធសម្លឹងមើលក្រុងវេសាលី

អថ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលិំ បិណ្ឌាយ បាវិសិ។ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ នាគាបលោកិតំ វេសាលិំ អបលោកេត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ

គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរ ចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី។ លុះស្តេចទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ទ្រង់ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ទ្រង់ងាកក្រឡេកមើលនូវក្រុងវេសាលីដូចជាដំរីដែលក្រឡេកបែរមើល ( នូវទីខាងក្រោយ ) ហើយត្រាស់នឹងព្រះអានន្ទមានអាយុថា

ឥទំ បច្ឆិមកំ អានន្ទ តថាគតស្ស វេសាលិយា ទស្សនំ ភវិស្សតិ។ អាយាមានន្ទ យេន ភណ្ឌគាមោ តេនុបសង្កមិស្សាមាតិ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ។

*ម្នាលអានន្ទ តថាគត ឃើញក្រុងវេសាលីម្តងនេះជាបច្ឆិមទស្សនៈ ( ការឃើញទីបំផុត ) ម្នាលអានន្ទ មក យើងនឹងទៅកាន់ ភណ្ឌគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។*

អថ ខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ភណ្ឌគាមោ តទវសរិ។ តត្រ សុទំ ភគវា ភណ្ឌគាមេ វិហរតិ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ

*លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ភណ្ឌគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងភណ្ឌគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ បានត្រាស់នឹងភិក្ខុទាំងឡាយថា*

ចតុន្នំ ភិក្ខវេ ធម្មានំ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច។

*ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាធ្លុះនូវធម៌ទាំង ៤ យ៉ាង ។*

កតមេសំ ចតុន្នំ អរិយស្ស ភិក្ខវេ សីលស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមំ ចេវ តុម្ហាកញ្ច។

*ធម៌ទាំង ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹងមិនបានចាក់ធ្លុះនូវអរិយសីល ។*

អរិយស្ស ភិក្ខវេ សមាធិស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមំ ចេវ តុម្ហាកញ្ច។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសមាធិ ។

អរិយាយ ភិក្ខវេ បញ្ញាយ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមំ ចេវ តុម្ហាកញ្ច។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយបញ្ញា ។

អរិយាយ ភិក្ខវេ វិមុត្តិយា អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមំ ចេវ តុម្ហាកញ្ច។

ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយវិមុត្តិ ។

តយិទំ ភិក្ខវេ អរិយំ សីលំ អនុពុទ្ធំ បដិវិទ្ធំ អរិយោ សមាធិ អនុពុទ្ធោ បដិវិទ្ធោ អរិយា បញ្ញា អនុពុទ្ធា បដិវិទ្ធា អរិយា វិមុត្តិ អនុពុទ្ធា បដិវិទ្ធា ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិ ទានិ បុនព្ភវោតិ។

ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយសមាធិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយបញ្ញាបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយវិមុត្តិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺ សេចក្តីប្រាថ្នាក្នុងភព ក៏សូន្យទៅ ខ្សែគឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏អស់ទៅ ភពថ្មីទៀត ក៏មិនមានក្នុងកាលឥឡូវនេះឡើយ ។

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់ត្រាស់ដូច្នេះតទៅទៀតថា ។

សីលំ សមាធិ បញ្ញា ច　　វិមុត្តិ ច អនុត្តរា
អនុពុទ្ធា ឥមេ ធម្មា　　គោតមេន យសស្សិនា។

ឥតិ ពុទ្ធោ អភិញ្ញាយ    ធម្មមក្ខាសិ ភិក្ខុនំ
ទុក្ខស្សន្តករោ សត្ថា    ចក្ខុមា បរិនិព្វុតោតិ ។

*ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ដ៏ប្រសើរ ព្រះគោតមព្រះអង្គមានយស បានត្រាស់ដឹងហើយ ព្រះពុទ្ធ ទ្រង់ត្រាស់ដឹង យ៉ាងនេះហើយ ទើបសំដែងធម៌ប្រាប់ចំពោះ ភិក្ខុទាំងឡាយ ព្រះសាស្តាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វានជាទីបំផុត នៃកងទុក្ខ ទ្រង់បរិនិព្វានហើយ ។*

## សាលវ័នក្រុងកុសិនារាទីបរិនិព្វាន

*គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទ មានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ត្រើយខាងនាយ នៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័ន របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័ន របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងសិនារា ព្រមដោយភក្ខុសង្ឃ ជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែ ឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយរៀបចំគ្រែ ឲ្យមានក្បាលដំណេក បែរទៅទិសខាងជើង ក្នុងចន្លោះ ដើមសាលព្រឹក្រទាំងគូថ្វាយ។ គ្រានោះ ព្រះមានព្រះភាគ មានព្រះសតិសម្បជញ្ញៈទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទធ្វេងតម្រួតលើព្រះបាទស្តាំ ។*

*សម័យនោះឯង សាលព្រឹក្រទាំងគូ ក៏មានផ្ការីកស្គុះស្គាយទាំងអស់ ( តាំងពីគល់ដល់ចុង ) ដោយអកាលបុប្ផា ( ផ្កាពុំដួកាល ) សាលព្រឹក្សទាំងគូនោះ ក៏រោយរាយ បាចសាច ( នូវផ្កា ) លើសរីរៈព្រះតថាគតដើម្បីបូជាព្រះតថាគត សូម្បីមន្ទារវបុស្ស (ផ្កាមន្ទារវៈ )*

*ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស ផ្កាទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងលំអិតខ្លឹមចន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះមក អំពីអាកាស លំអិតទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទាំងចម្រៀងជាទិព្វ ក៏លាន់ឮ ឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ សាលព្រឹក្សទាំងគូ មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងអំពីគល់ដរាបដល់ចុង ) ដោយអកាលបុប្ផ រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងផ្កាមន្ទារវៈជាទិព្វ ធ្លាក់ចុះអំពីអាកាស ផ្កាទាំងនោះ រោយរាយ បាចសាចលើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងលំអិតខ្លឹមចន្ទន៍ជាទិព្វ ធ្លាក់ចុះអំពីអាកាស លំអិតទាំងនោះ រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត*

ន ខោ អានន្ទ ឯត្តាវតា តថាគតោ សក្កតោ វា ហោតិ គរុកតោ វា មានិតោ វា បូជិតោ វា អបចិតោ វា។

*ម្នាលអានន្ទ ព្រះតថាគតមិនបាន ឈ្មោះថាបរិស័ទធ្វើសក្ការៈក្តី គោរពក្តី រាប់អានក្តី បូជាក្តី នឹងកោតក្រែងក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ ។*

យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្ប-ដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុំ ករោតិ មានេតិ បូជេតិ អបចិយតិ បរមាយ បូជាយ។

*ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម។*

តស្មាតិហានន្ទ ធម្មានុធម្មប្បដិបន្នា វិហរិស្សាម សាមីចិប្បដិបន្នា អនុធម្មចារិនោតិ។ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វំ។

ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

## ចតុសំវេជនីយដ្ឋាន គឺកន្លែងដ៏អស្ចារ្យ ៤

ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើនកាលពីដើម ពួកភិក្ខុនៅចាំវស្សាក្នុង ទិសទាំងឡាយរួចហើយ តែងមកដើម្បីគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គ តែងបានជួបនឹងពួកភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណើះតតទឹងព្រះមានព្រះភាគទៅ យើងខ្ញុំព្រះអង្គ នឹងលែងបានជួបលែងបានចូលទៅអង្គុយជិតពួកភិក្ខុ អ្នកចម្រើនដោយចិត្តហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា

ម្នាលអានន្ទ សំវេជនីយដ្ឋាន ( ទីដែលគួរអស្ចារ្យ ) ដែលគួរឃើញ របស់កុលបុត្តអ្នកមានសទ្ធានេះ ៤ កន្លែង ។ សំវេជនីយដ្ឋាន ៤ កន្លែងតើដូចម្តេច ។

ឥធ តថាគតោ ជាតោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ។

ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគត ប្រសូតក្នុងទីដូច្នេះ ១ ។

ឥធ តថាគតោ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ។

ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញ របស់កុលបុត្តអ្នកមានសទ្ធា ដោយរឭកឃើញថាព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីដូច្នេះ ១ ។

ឥធ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតន្តិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ។

ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគត បានសំដែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ ១ ។

៩៨ តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិ អានន្ទ សទ្ធស្ស កុលបុត្តស្ស ទស្សនីយំ សំវេជនីយំ ឋានំ។

*ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញ របស់កុលបុត្តអ្នកមានសទ្ធា ដោយវព្វកឃើញថាព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះដូច្នេះ ១ ។*

*ម្នាលអានន្ទ នេះឯង សំវេជនីយដ្ឋាន ដែលគួរឃើញ ៤ កន្លែង របស់កុលបុត្តអ្នកមានសទ្ធា ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា នឹងមកដោយរព្វកឃើញថា ព្រះតថាគត ប្រសូតក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគត ត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះដូច្នេះក្តី ព្រះតថាគតសំដែងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះក្តី ។*

យេ ហិ កេចិ អានន្ទ ចេតិយចារិកំ អាហិណ្ឌន្តា បសន្នចិត្តា កាលង្កិរិស្សន្តិ សព្វេ តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សន្តិ។

*ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅពួកជនទាំងអស់នោះ លុះមានរាងកាយ បែកធ្លាយទៅខាងមុខបន្ទាប់ អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្សសុគតិ និងឋានសួគ៌ ។*

## **សុភទ្ទបរិព្វាជកសួរបញ្ហា**

*សម័យនោះឯង មានបរិព្វាជកឈ្មោះសុភទ្ទ នៅក្នុងក្រុងកុសិនារា ។ សុភទ្ទបរិព្វាជក បានឮដំណឹងថា ព្រះសមណគោតម នឹងបរិនិព្វានក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ។ គ្រានោះ សុភទ្ទបរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យនេះ អាត្មាអញបានឮមកអំពីពួកបរិព្វាជក ជាមនុស្សចាស់ទុំ ជាអាចារ្យតៗគ្នាមក តែងនិយាយថាព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយជងមួយកាល ក៏ក្នុងបច្ឆិម-យាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់អាត្មាអញ ទាំងអាត្មាអញមានសេចក្តីជ្រះថ្លាក្នុងព្រះសមណគោតមដែរ អាត្មាអញគួរលះបង់នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតមអាចនឹងសំដែងធម៌ ដល់អាត្មាអញយ៉ាងនោះបាន ។ គ្រានោះសុភទ្ទបរិព្វាជក ក៏ចូលទៅរកព្រះអានន្ទ*

មានអាយុ ក្នុងសាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះ ខ្ញុំបានឮមកអំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យតៗគ្នាថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយដងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លាក្នុងព្រះសមណគោតមដែរ ខ្ញុំគួរលះបង់នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតម អាចនឹងសំដែងធម៌ដល់ខ្ញុំយ៉ាងនោះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូម ឲ្យបានគាល់ព្រះសមណគោតមផង ។ លុះសុភទ្ទបរិព្វាជក និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានពោលទៅនឹងសុភទ្ទបរិព្វាជកដូច្នេះថា ម្នាលអាវុសោសុភទ្ទ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់ ។ សុភទ្ទបរិព្វាជក បាននិយាយជាគម្រប់ពីរដងផង ។ បេ ។ សុភទ្ទបរិព្វាជក បាននិយាយនឹងព្រះអានន្ទមានអាយុ ជាគម្រប់បីដងផងដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះខ្ញុំបានឮមក អំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យតៗគ្នាមក តែងនិយាយថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយដងមួយកាល ក៏ក្នុងបច្ឆិម-យាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លាក្នុងព្រះសមណគោតមដែរ ខ្ញុំគួរលះបង់សេចក្តីសង្ស័យនេះបាន យ៉ាងណាព្រះសមណគោតម អាចនឹងសំដែងធម៌ ដល់ខ្ញុំយ៉ាងនោះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូមឲ្យបានគាល់ចំពោះព្រះសមណគោតមផង ។ ព្រះអានន្ទមានអាយុ បានពោលទៅនឹងសុភទ្ទបរិព្វាជក ជាគម្រប់បីដងទៀត ដូច្នេះថា ម្នាលអាវុសោសុភទ្ទ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់ ។ ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់កថាសល្លាបៈនេះរបស់ព្រះអានន្ទមានអាយុ ជាមួយនឹងសុភទ្ទបរិព្វាជក ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ កុំឡើយ អ្នកកុំឃាត់សុភទ្ទ ម្នាលអានន្ទសុភទ្ទចូរបានឃើញតថាគតចុះ សុភទ្ទ

នឹងសួរនូវសេចក្តីណាមួយនឹងតថាគត គាត់ចង់ដឹងនូវសេចក្តីនោះមែន ទើបគាត់មកសួរតថាគត មិនមែនគាត់សួរចង់បៀតបៀនទេ បើសុភទ្ទនេះសួរហើយ តថាគតសំដែងធម៌ណា គាត់នឹងបានដឹងធម៌នោះឆាប់ក្លាម ។ ទើបព្រះអានន្ទមានអាយុ ពោលទៅនឹងសុភទ្ទបរិព្វាជក ដូច្នេះថា ម្នាលអាវុសោសុភទ្ទ ព្រះមានព្រះភាគ ទ្រង់បើកឱកាសដល់អ្នកហើយ អ្នកចូរទៅចុះ ។ គ្រានោះ សុភទ្ទបរិព្វាជក ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុភទ្ទបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ណា ជាពួកគណៈ ជាគណាចារ្យល្បីល្បាញ មានយស អ្នកធ្វើលទ្ធិដូចកំពង់ ដែលជនច្រើនគ្នាគេសន្មតថា ល្អ ដូចយ៉ាងគ្រូឈ្មោះ បូរណកស្សប មក្ខលិគោសាល អជិតកេសកម្ពល បកុធកច្ចាយនៈ សញ្ជយវេលដ្ឋបុត្ត និគណ្ឋនាដបុត្ត ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹង ដូចជាពាក្យប្តេជ្ញារបស់ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ ណ្ហើយចុះ ពាក្យដែលអ្នកនិយាយថា ពួកជនទាំងនោះសុទ្ធតែត្រាស់ដឹងដូចជាពាក្យប្តេជ្ញារបស់ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលសុភទ្ទ តថាគតនឹងសំដែងធម៌ដល់អ្នក អ្នកចូរស្តាប់ធម៌នោះ ចូរតាំងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងផង ។ សុភទ្ទបរិព្វាជកទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

យស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ន ឧបលព្ភតិ សមណោបិ តត្ថ ន ឧបលព្ភតិ។ ទុតិយោបិ តត្ថ សមណោ ន ឧបលព្ភតិ។ តតិយោបិ តត្ថ សមណោ ន ឧបលព្ភតិ។ ចតុត្ថោបិ តត្ថ សមណោ ន ឧបលព្ភតិ។ យស្មិញ្ច ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ សមណោបិ តត្ថ ឧបលព្ភតិ

ទុតិយោបិ តត្ថ សមណោ ឧបលព្ភតិ តតិយោបិ តត្ថ សមណោ ឧបលព្ភតិ ចតុត្ថោបិ តត្ថ សមណោ ឧបលព្ភតិ។

*ម្នាលសុភទ្ទ អរិយមគ្គ មានអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈ ទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈ ទី ៣ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក្តី ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ លុះតែអរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈ (ទី ១) ក្តី ទើបមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី មានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក្តី មានក្នុងធម្មវិន័យនោះ សមណៈទី ៤ក្តី ក៏មានក្នុងធម្មវិន័យនោះដែរ ។*

ឥមស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ ឥធេវ សុភទ្ទ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហិ ។ ឥមេ ច សុភទ្ទ ភិក្ខូ សម្មា វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស។

*ម្នាលសុភទ្ទអរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈ (ទី១) ក៏មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ (វាទៈនៃគ្រូដទៃ) អំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ ។*

## ព្រះពុទ្ធប្រគល់ធម្មវិន័យជាព្រះសាស្តា

*គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា*

សិយា ខោ បនានន្ទ តុម្ហាកំ ឯវមស្ស អតីតសត្ថុកំ បាវចនំ នត្ថិ នោ សត្ថាតិ។ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ។

ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើងឈ្មោះថាមិនមានឡើយ ។ ម្នាលអានន្ទ សេចក្តីនេះ អ្នកកុំចូលចិត្តយ៉ាងនេះឡើយ ។

យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។

ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសំដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះឥតអំពីតថាគតទៅ ធម៌និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ ។

## បច្ឆិមវាចា គឺពាក្យបណ្តាំចុងក្រោយរបស់ព្រះពុទ្ធ

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

ហន្ទ ទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ។

ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលកាន់បឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ហើយចូលកាន់ទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ហើយចូលកាន់តតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ហើយចូលកាន់ចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ហើយចូលកាន់អាកាសានញ្ចាយតនសមាបត្តិ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ចូលអាកិញ្ចញ្ញាយតនសមាបត្តិ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ

ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិត-និរោធ (សេចក្តីរលត់នៃសញ្ញានិងវេទន) ។ គ្រានោះ ព្រះអានន្ទមានអាយុ ពោលទៅនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រអនុរុទ្ធដ៏ចម្រើន ព្រះមានព្រះភាគ មិនទាន់បរិនិព្វានទេ ព្រះអង្គទ្រង់ចូលកាន់សញ្ញាវេទយិតនិរោធ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិហើយ ថយមកចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិវិញ ចេញអំពីនេវសញ្ញានា-សញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់វិញ្ញាណញ្ចាយត-នសមាបត្តិវិញ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់អាកាសានញ្ចាយតនសមាបត្តិវិញ ចេញអំពីអាកាសនញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់ចតុត្ថជ្ឈានវិញ ចេញអំពីចតុត្ថជ្ឈានហើយ ថយមកចូលកាន់តតិយជ្ឈានវិញ ចេញអំពីតតិយជ្ឈានហើយ ថយមកចូលកាន់ទុតិយជ្ឈានវិញ ចេញអំពីទុតិយជ្ឈានហើយ ថយមកចូលកាន់បឋមជ្ឈានវិញ ចេញអំពីបឋមជ្ឈានហើយ ក៏ចូលកាន់ទុតិយជ្ឈានទៀត ចេញអំពីទុតិយជ្ឈានហើយ ក៏ចូលកាន់តតិយជ្ឈានទៀត ចេញអំពីតតិយជ្ឈានហើយ ក៏ចូលកាន់ចតុត្ថជ្ឈានទៀត ។ លុះព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វានក្នុងចន្លោះនោះ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ការកក្រើកនៃផែនដីធំ គួរស្បែមគួរព្រឺរោម ក៏កើតមាន ទាំងផ្គរ ក៏លាន់ឮគគ្រឹកគគ្រេងព្រមនឹងការបរិនិព្វាន ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ សហម្បតិព្រហ្ម ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

សព្វេវ និក្ខិបិស្សន្តិ　　ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា　　លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ　　សម្ពុទ្ធោ បរិនិព្វុតោ ។

*ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាកដដូច្នេះ*
*ព្រះតថាគតជាសម្ពុទ្ធបរិបូណ៌ ហើយដោយកម្លាំង*
*ទ្រង់បរិនិព្វានហើយ ក្នុងលោកណា ពួកសត្វទាំងអស់*
*មុខជានឹងដាក់ចុះនូវរាងកាយ ក្នុងលោក (នោះ)*
*មិនខានឡើយ ។*

*កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះឥន្ទ្រជាធំជាងទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា*

អនិច្ចា វត សង្ខារា　　ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ　　តេសំ វូបសមោ សុខោ

*សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើង*
*នឹងវិនាសទៅវិញជាធម្មតា លុះកើតឡើងហើយក៏រលត់*
*ទៅវិញ កិរិយារម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវ*
*សេចក្តីសុខ។*

*កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអនុរុទ្ធមានអាយុ ក៏ពោលនូវគាថា ទាំងនេះ ព្រមនឹងការបរិនិព្វានថា*

នាហុ អស្សាសបស្សាសោ　　ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ　　យំ កាលមការី មុនិ។

ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធ
នូវអនុបាទិសេសនិព្វានហើយ ទ្រង់ធ្វើមរណកាល
អស្សាសបស្សាសៈ នៃព្រះមុនីនាថ ជាតាទិបុគ្គល
ដែលមានព្រះទ័យខ្ជាប់ខ្ជួននោះ មិនមានហើយ ។

អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហុ ។

ព្រះមុនីនាថ ទ្រង់អត់សង្កត់វេទនាបានដោយចិត្តមិនរួញរា
សេចក្តីរលត់នៃចិត្តក៏កើតមាន បីដូចជាការរលត់នៃប្រទីប ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអានន្ទមានអាយុ ក៏ពោលនូវគាថា នេះ ព្រមនឹងការបរិនិព្វានថា

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ ។

កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុ ប្រសើរទាំងពួង
ទ្រង់បរិនិព្វានហើយ សេចក្តីញាប់ញ័រក្តី សេចក្តីព្រឺរោមក្តី
ក៏កើតមានប្រាកដ ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ភិក្ខុទាំងឡាយណា ដែលមិនទាន់ប្រាសចាករាគៈ មាននៅក្នុងទីនុ៎ះ ភិក្ខុទាំងនោះ ពួកខ្លះក៏ផ្គងឡើងនូវកំភួនដៃហើយកន្ទក់កន្ទេញផ្តួលខ្លួនបម្រះនឿលទៅមក ហាក់ដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ប្រញាប់បាត់

ទៅពេកណាស់ ។ ឯពួកភិក្ខុណា ដែលប្រាសចាករាគៈហើយ ភិក្ខុទាំងនោះ មានសតិនិងសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនោះ បុគ្គលគប្បីបានទូវសេចក្តីទៀងទាត់ ក្នុងខន្ធប្បវត្តិនេះអំពីណា ។

លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ប្រាប់ពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ សេចក្តីនេះ ព្រះមានព្រះភាគ ទ្រង់បានសំដែងមកពីមុនហើយថា សេចក្តីព្រាត់ប្រាស វិនាស ប្រែប្រួលចាសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបានទូវសេចក្តីមិនព្រាត់ប្រាសនោះ ក្នុងខន្ធប្បវត្តិនេះអំពីណា ធម្មជាតណា ដែលកើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្តីទ្រុឌទ្រោមជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ ( ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ម្នាលអាវុសោទាំងឡាយ ទេវតាទាំងឡាយ នឹងពោលទោសមិនខាន ។ ព្រះអានន្ទសួរថា បពិត្រអនុរុទ្ធដ៏ចម្រើន ចុះពួកទេវតាធ្វើទុកក្នុងចិត្តដូចម្តេច ។ ព្រះអនុរុទ្ធមានថេរវាចាថា ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសំគាល់ គឺនិម្មិតផែនដីក្នុងអាកាស រំសាយសក់កន្ទក់កន្ទេញ ផ្គងឡើងនូវកំភួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះននៀលទៅមកបីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគតទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់ប្រញាប់បាត់បង់ពេកណាស់ ។

## ពាក្យបូជាព្រះពុទ្ធបដិមាបរិនិព្វាន

**វន្ទាមិ ភន្តេ ឥមំ ពុទ្ធបដិមំ, ឥមស្មឹ កុសិនារាយំ សាលវនោទ្យានេ ពុទ្ធស្ស ភគវតោ បរិនិព្វានដ្ឋានេ អយំ វន្ទនា អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។**

*បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះបដិមានេះ ក្នុងសាលវនោទ្យាន ត្រង់ក្រុងកុសិនារា ដែលជាស្ថានទីបរិនិព្វានរបស់ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ សូមការថ្វាយបង្គំនេះ ចូរប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខ អស់កាលជាអង្វែងទៅហោង ។*

## ពាក្យបូជាព្រះស្តូបបរិនិព្វាន

**វន្ទាមិ ភន្តេ ឥមំ បរិនិព្វានថូបំ, ឥមស្មឹ កុសិនារាយំ សាលវនោទ្យានេ ពុទ្ធស្ស ភគវតោ បរិនិព្វានដ្ឋានេ អយំ វន្ទនា អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។**

*បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវស្តូបជាទីបរិនិព្វាននេះ ក្នុងសាលវនោទ្យាន ត្រង់ក្រុងកុសិនារា ដែលជាស្ថានទីបរិនិព្វានរបស់ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ សូមការថ្វាយបង្គំនេះ ចូរប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខ អស់កាលជាអង្វែងទៅហោង ។*

# មកុដពន្ធនចេតិយ




សម័យនោះឯង ពួកមល្លក្សត្រ ៤ អង្គ ដែលជាប្រធានទ្រង់ជម្រះសីសៈ ហើយ ទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈ្មួលនូវជើងថ្ករនៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងឈ្មួលឲ្យឆេះបាន ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បានពោលទៅនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាពួកមល្លក្សត្រិយ៍ ជាប្រធានទាំង ៤ អង្គនេះ ជម្រះសីសៈហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈ្មួលជើងថ្ករ នៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងឈ្មួលឲ្យឆេះបាន ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋៈទាំងឡាយ បំណងរបស់ពួកទេវតាផ្សេងគ្នា ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតាដូចម្ដេច ។ បពិត្រ វាសិដ្ឋៈទាំងឡាយ បំណងរបស់ពួកទេវតាថា ព្រះមហាកស្សបមានអាយុនេះ កំពុងនិមន្តតាមផ្លូវឆ្ងាយ ចេញអំពីក្រុងបាវា មកកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើនប្រមាណ ៥០០ រូប ។ ព្រះមហាកស្សបមានអាយុ មិនទាន់បានថ្វាយបង្គំនូវព្រះបាទានៃព្រះមានព្រះភាគ ដោយដៃរបស់ខ្លួនដរាបណា ជើងថ្ករព្រះមានព្រះភាគ ក៏មិនទាន់ឆេះដរាបនោះ ។ ពួកមល្លក្សត្រិយ៍តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតា យ៉ាងណា ការថ្វាយព្រះភ្លើងនូវព្រះសរីរៈនៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។ គ្រានោះព្រះមហាកស្សបមានអាយុ ចូលទៅកាន់ជើងថ្ករនៃព្រះមានព្រះភាគ ក្នុង**មកុដពន្ធនចេតិយ**របស់ពួកមល្លក្សត្រ ទៀបក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ក៏ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ធ្វើប្រទក្សិណជើងថ្ករ ៣ ជុំហើយ បើកអំពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទានៃព្រះមាន ព្រះភាគ ដោយសិរ្បៈ ។ ឯពួកភិក្ខុទាំង ៥០០ រូបនោះ ក៏ធ្វើចីវរឆៀងស្មាម្ខាងហើយ ប្រណម្យអញ្ជលីធ្វើប្រទក្សិណ ៣ ជុំហើយ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយដោយសិរ្បៈ ។ កាលដែលព្រះមហាកស្សបមានអាយុ និងពួកភិក្ខុទាំង ៥០០ រូបនោះ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគរួចហើយ ជើងថ្ករព្រះមានព្រះភាគ ក៏ឆេះឯង ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយ អាការៈណាទោះព្រះឆវិក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការៈនោះ ក៏ឆេះអស់ មិនមានផេះ និងកំញ៉មឲ្យងឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ។ សប្បិឬប្រេង ដែលភ្លើងឆេះ ក៏មិនមានផេះកំញ៉មយ៉ាងណាមិញ ព្រះសរីរៈ

របស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយ អាការៈណាទោះព្រះឆវីក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការៈនោះ ក៏ឆេះអស់មិនមានផេះនិងកំញ៉ុមឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ក៏យ៉ាងនោះដែរ ។ បណ្តាសំពត់ទាំង ៥០០ គូនោះ សំពត់ពីរ គឺសំពត់ជាន់ក្នុងបំផុត១ សំពត់ជាន់ក្រៅបំផុត ១ ក៏ឆេះអស់ ។ លុះសរីរៈព្រះមានព្រះភាគ ដែលត្រូវភ្លើងឆេះហើយធារទឹកក៏បង្អុរអំពីអាកាស រំលត់ជើងថ្ករនៃព្រះមានព្រះភាគ ។ទាំងមានទឹកខ្ពុរចេញ អំពីដើមសាលព្រឹក្ស រំលត់ជើងថ្ករ នៃព្រះមានព្រះភាគ ។ ទើបពួកមល្លក្សត្រ អ្នកក្រុងកុសិនារា រំលត់ជើងថ្ករនៃព្រះមានព្រះភាគដោយទឹកក្រអូបទាំងពួង ។ គ្រានោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ក៏ធ្វើនូវការបញ្ជរលំពែង រួចព័ទ្ធដោយកំពែងធ្នូ ហើយធ្វើសក្ការៈ គោរព រាប់អានបូជាព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ដោយរបាំចម្រៀង ភ្លេងប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ អស់ ៧ថ្ងៃក្នុងសណ្ឋាគារដ្ឋាន ។

## បូជាស្ថានទីមកុដពន្ធនចេតិយ

**វន្ទាមិ ឥមំ ចេតិយំ មកុដពន្ធនសញ្ញិតំ ទស្សនីយំ សំវេជនីយំ ពុទ្ធស្ស ឥគវតោ សរីរស្ស ឈាបនដ្ឋានំ អយំ វន្ទា អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។**

ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះចេតិយ ដែលមានឈ្មោះថា មកុដពន្ធនចេតិយ ជាស្ថានទីបូជាភ្លើងព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ ដែលជាស្ថានទីគួរឃើញ ដែលនាំកើតនូវសំវេគ ។ សូមការថ្វាយបង្គំនេះ ចូរប្រព្រឹត្តទៅជាប្រយោជន៍ ដើម្បីសេចក្តីសុខ សេចក្តីចម្រើន ដល់ខ្ញុំព្រះករុណា អស់កាលជាអង្វែងទៅហោង ។

# មូលគន្ធកុដិវត្តជេតពន




**បូជាស្ថានទីមូលគន្ធកុដិ**

**វន្ទាមិ ភន្តេ ភគវា ឥមំ សាវត្ថិយំ ជេតវនំ អនាថបិណ្ឌិកស្ស អារាមំ យត្ថា-គតោម្ហិ ឥធ ខោ បន ភគវា ឯកូនវីសំ វស្សានិ វិហាសិ, មង្គលសុត្តំ ទេសេសិ មិតោ អហំ អង្គុលិមាល តុញ្ហតិដ្ឋាតិ អង្គុលិមាលចោរំ អភិជិនិ បដិលភ សតី ភគនីតិ បដាចារញ្ហ សតិវិរហិតំ វិនេសិ ។**

**សាធុ នោ ភន្តេ ឥមេហិ សក្ការេហិ អភិបូជយាមិ ស្វាក្ខាតញ្ច នមាមិ មយ្ហំ ទីឃរត្តំ ហិតាយ សុខាយ ។**

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា មកដល់វត្តជេតពន មហាវិហារ ហើយ ដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ, ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីនេះ រហូតដល់ ១៩ វស្សា ទ្រង់សម្តែងមង្គលសូត្រ កែបញ្ហារបស់ទេវតានិងមនុស្ស និងទ្រង់សម្តែងព្រះធម៌ ដែលជាឧបាយនាំសត្វចេញចាកទុក្ខទាំងពួង ទ្រង់ឈ្នះចោរអង្គុលិមាល និងញ៉ាំងនាង បដាចារដែលមានសតិវិបល្លាសឲ្យសះស្បើយ ក្នុងស្ថាននេះឯង ។*

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមបូជាដ៏ក្រៃលែង ដោយគ្រឿង សក្ការៈទាំងនេះ និងសូមបង្អោនលើកដល់ព្រះធម៌ ដែលទ្រង់សម្តែងដ៏ល្អហើយ ។ សូមការ*

*បូជាសក្ការៈក្នុងគ្រានេះ ចូរប្រព្រឹត្តទៅជាប្រយោជន៍ ដើម្បីសេចក្ដីសុខ សេចក្ដីចម្រើន និង មគ្គផលនិព្វានដល់ខ្ញុំព្រះករុណា អស់កាលជា អង្វែងទៅហោង ។*

## ស្ថានទីស្តូបយមកបាដិហារ្យ



**បូជាស្ថានទីស្តូបយមកបាដិហារ្យ**

**វន្ទាមិ ភន្តេ ភគវា ឥមំ យមកបាដិហារិយករណដ្ឋានំ,យត្ថាគតោម្ហិ, ឥធ ខោ បន ភគវា អនេកវិធំ យមកបាដិហារិយំ អកាសិ តិត្ថិយេ ទមិតុំ ។ តតោ សោ ភគវា ទេវលោកំ គន្ត្វា តាវតឹសភវនេ បណ្ឌុកម្ពលសិលាសនេ តេមាសំ វស្សូបគតោ អភិធម្មបិដកំ ទេសេន្តោ ពុទ្ធមាតរំ សបរិវារំ សោតាបត្តិផលេ បតិដ្ឋាបេសិ ។**

**សាធុ នោ ភន្តេ, ឥមេហិ សក្ការេហិ អភិបូជយាមិ, ស្វាក្ខាតញ្ច នមាមិ, មយ្ហំ ទីឃរត្តំ ហិតាយ សុខាយ ។**

បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា មកដល់ហើយ ស្ថានទីដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងយមកបាដិហារ្យ ដើម្បីទូន្មានពួកអន្យតិរ្ថិយ ដែលជាមិច្ឆាទិដ្ឋិ រួចហើយទ្រង់និមន្តទៅកាន់ទេវលោក ទ្រង់ចាំវស្សាក្នុងបណ្ឌុកម្ពលសិលាសនៈ ក្នុងស្ថានតាវត្តិង្ស និងសម្តែងអភិធម្មបិដក ប្រោសព្រះពុទ្ធមាតា ព្រមទាំងទេពជាបរិវារ ឲ្យបានសម្រេចនូវសោតាបត្តិផល ។

បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមបូជាដ៏ក្រៃលែង ដោយគ្រឿងសក្ការៈទាំងនេះ និងសូមបង្អោនរលឹកដល់ព្រះធម៌ ដែលទ្រង់សម្តែងដ៏ល្អហើយ ។ សូមការបូជាសក្ការៈក្នុងគ្រានេះ ចូរប្រព្រឹត្តទៅជាប្រយោជន៍ ដើម្បីសេចក្តីសុខ សេចក្តីចម្រើន និងមគ្គផលនិព្វានដល់ខ្ញុំព្រះករុណា អស់កាលជា អង្វែងទៅហោង ។

# ស្ថានទីសម្តែងមហាសតិប្បដ្ឋាន ដែនដីកុរុ




**ស្វាធ្យាយឧទ្ទេសនៃមហាសតិបដ្ឋានសូត្រ**

ឯវម្មេ សុតំ *ខ្ញុំបានស្តាប់មកយ៉ាងនេះ។* ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ *សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងកម្មាសធម្មនិគមរបស់អ្នកកុរុក្នុងដែនកុរុ។* តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ "ភិក្ខវោ"តិ ។ "ភទន្តេ"តិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ *កាលព្រះមានព្រះភាគទ្រង់គង់នៅក្នុងកម្មាសធម្មនិគមនោះឯង បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។* ភគវា ឯតទវោច *ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា* "ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា, សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ, យទិទំ ចត្តារោ សតិប្បដ្ឋានា។

ម្នាលភិក្ខុទាំងឡាយផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។

"កតមេ ចត្តារោ ? ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួនមានសតិ (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ១ ។

វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា, វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញ នូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេសជាអ្នកដឹងខ្លួនមានសតិ (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ១ ។

ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេសជាអ្នកដឹងខ្លួនមានសតិ (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ១ ។

ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ។

ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានសតិ (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ១។

ឧទ្ទេសោ និដ្ឋិតោ ចប់ឧទ្ទេសវារកថា។

# ស្តូបសង្កស្ស ស្ថានទីព្រះពុទ្ធចុះពីស្ថានតាវត្តិង្ស



បន្ទាប់ពីព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ចាំវស្សាក្នុងស្ថានតាវត្តិង្សហើយ ព្រះអង្គយាង ចុះពីស្ថានតាវត្តិង្ស មកកាន់មនុស្សលោកវិញ ។ ពេលនោះ សក្កទេវរាជ បាននិម្មិតនូវជណ្តើរ ៣ គឺជណ្តើរមាសនៅខាងស្តាំ ជណ្តើរប្រាក់នៅខាងឆ្វេង និងជណ្តើរកែវមណីនៅចំកណ្តាល ចំពោះក្បាលកាំជណ្តើរជាប់ពីភ្នំសិនេរុ រហូតមកដល់ជិតទ្វារសង្កស្សនគរនេះ ។ ព្រះពុទ្ធជាអម្ចាស់ទ្រង់យាងចុះចំកណ្តាលគឺជណ្តើរកែវមណី នៅឯខាងស្តាំសុទ្ធតែពួកទេវតាទាំងឡាយ ហែហមព្រះអង្គចុះមក ឯខាងឆ្វេងវិញ សុទ្ធតែពួកមហាព្រហ្ម ។ ពេលនោះ មានព្រឹត្តិការដ៏អស្ចារ្យមួយ គឺព្រះពុទ្ធទ្រង់សម្តែងបាដិហារ្យ ដែលមានឈ្មោះថា **ទេវោរោហណបាដិហារ្យ** គឺបាដិហារ្យដែលបើកឲ្យសត្វលោកឃើញគ្នាទៅវិញទៅមក តាំងពីមនុស្សលោករហូតដល់ទៅមហាព្រហ្មលោក ខាងក្រោមរហូតដល់ទៅ មហាអវិចីនរក និងរហូត ដល់ទៅមួយម៉ឺនចក្កវាឡ ។ រឿងនេះដែលពុទ្ធសាសនិកតែងប្រារព្ធពិធីបុណ្យក្នុងថ្ងៃ ១៥ កើត ខែ អស្សុជថា **អស្សុជបូជា** ។

## ពាក្យបូជាស្តូបសង្កស្សនគរ

**វន្ទាមិ ភន្តេ ភគវា ទេវោរោហណចេតិយដ្ឋានំ, យត្ថាគតោម្ហិ, ឥធ ខោ បន ភគវា ទេវលោកតោ ឱរោហតិ, តទា ភគវា លោកវិវរណបាដិហារិយំ អកាសិ យថា ទេវមនុស្សា អញ្ញមញ្ញំ បស្សិំសុ ។ អាកាសេ មហាព្រហ្មា ចេវ សក្កោ ទេវរាជា ច សបរិវារោ ភគវន្តំ ឧយ្យោជេសុំ , បឋវីតលេ ចតស្សោ បរិសា ភគវតោ បច្ចុគ្គមនំ អកំសុ ។**

**សាធុ នោ ភន្តេ, ឥមេហិ សក្ការេហិ អភិបូជយាមិ, ស្វាក្ខាតញ្ច នមាមិ, មយ្ហំ ទីឃរត្តំ ហិតាយ សុខាយ ។**

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា មកដល់ហើយ ស្ថានទីដែលព្រះដ៏មានព្រះភាគទ្រង់ចុះពីទេវលោក ត្រង់ទីនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងបាដិហារ្យដល់លោកទាំង ៣ ឲ្យទេវតានិងមនុស្សទាំងឡាយ ឃើញគ្នាទៅវិញទៅមក ក្នុងនភាកាស ស្តេចមហាព្រហ្ម សក្កទេវរាជ ព្រមដោយទេពបរិវារ មកហែហមដំណើរព្រះដ៏មានព្រះភាគ ចំណែកខាងក្រោម បរិស័ទទាំង ៤ រង់ចាំទទួលព្រះអង្គ ក្នុងស្ថានទីនេះ ។*

*បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមបូជាដ៏ក្រៃលែង ដោយគ្រឿងសក្ការៈទាំងនេះ និងសូមបង្អោនរលឹកដល់ព្រះធម៌ ដែលទ្រង់សម្តែងដ៏ល្អហើយ ។ សូមការបូជាសក្ការៈក្នុងគ្រានេះ ចូរប្រព្រឹត្តទៅជាប្រយោជន៍ ដើម្បីសេចក្តីសុខ សេចក្តីចម្រើន និងមគ្គផលនិព្វានដល់ខ្ញុំព្រះករុណា អស់កាលជា អង្វែងទៅហោង ។*

គណៈធម្មយាត្រាមកដល់ទីក្រុងវេសាលី គួរនាំគ្នាស្វាធ្យាយរតនបរិត្ត ដែលព្រះពុទ្ធជាម្ចាស់ ត្រាស់សម្តែងក្នុងវេសាលីនេះឯង មានប្រវត្តិពោលមកថា

ក្នុងសម័យមួយ ទីក្រុងវេសាលី រាំងភ្លៀង អត់អាហារ មានមនុស្សស្លាប់ជាបន្តបន្ទាប់ ។ ពេលនោះ មនុស្សទាំងឡាយ យកសាកសពទៅបោះចោលខាងក្រៅក្រុង ។ ពេលនោះ ពួកអមនុស្សធុំក្លិនសាកសពទាំងឡាយ ក៏នាំគ្នាមកចូលខាងក្នុងក្រុង ហើយធ្វើអន្តរាយ ឲ្យមនុស្សកាន់តែស្លាប់ច្រើនឡើងៗ ហើយបណ្តាលអហិវាតករោគឲ្យកើតឡើងបៀតបៀនមនុស្សទៀតផង ។ ខណៈពេលនោះ ទីក្រុង វេសាលីមានអន្តរាយ ៣ យ៉ាង គឺ ទុព្ភិក្ខភ័យ គឺអត់បាយ ១ អមនុស្សភ័យ គឺអមនុស្សបៀតបៀន ១ រោគភ័យ ជំងឺបៀតបៀន ១ ។

ក្នុងខណៈនោះ មនុស្សទាំងឡាយត្រិះរិះថា ទីក្រុងនេះ មិនធ្លាប់មានភ័យបែបនេះ អស់ ៧ រាជ្យហើយ ។ ទើបនាំគ្នាទៅក្រាបទូលព្រះរាជាថា ភ័យនេះអាចកើតមកពីព្រះអង្គ គ្រប់គ្រងដែនមិនប្រកបដោយធម៌ ។ ពេលនោះ ព្រះរាជាឲ្យប្រជាពលរដ្ឋពិចារណារកទោសព្រះអង្គ តែរកទោសព្រះរាជាមិនឃើញមាន ។ ទើបពិភាក្សាគ្នា ដើម្បីនិមន្តសាស្តាអង្គណាទីមួយ មករំលត់ទុក្ខ ។ អ្នកខ្លះឲ្យយោបល់ថា និមន្តអន្យតិរ្ថិយ ។ អ្នកខ្លះទៀតថា និមន្តព្រះពុទ្ធជាម្ចាស់ ។ ក្នុងទីបំផុត ក៏ព្រមព្រៀងគ្នា និមន្តព្រះពុទ្ធជាម្ចាស់ មកប្រោស ។ ពេលនោះ ពួកលិច្ឆវីក្សត្រ ពីរនាក់ក៏មកអារាធនាព្រះពុទ្ធ ទូលនិមន្តព្រះអង្គ មករំងាប់ភ័យនោះ ។

កាលព្រះពុទ្ធទ្រង់យាងមកដល់ទីក្រុងវេសាលី សក្កទេវរាជ ព្រមទាំងបរិវារជាច្រើន ក៏មកគាល់ព្រះពុទ្ធជាម្ចាស់ ក្នុងស្ថានទីនោះ ធ្វើឲ្យពួក អមនុស្សមួយចំនួននាំគ្នាគេចចេញបាត់ទៅ ។ ពេលនោះ ព្រះពុទ្ធជាម្ចាស់ បង្រៀនព្រះបរិត្តនេះដល់ព្រះអានន្ទ និងឲ្យព្រះអានន្ទ សូធ្យព្រះបរិត្តនេះ ជុំវិញកំពែងទីក្រុង រហូតអស់បីយាមនៃរាត្រី ។ ពួកអមនុស្សដែលនៅសេសសល់ក៏នាំគ្នាគេចចេញទៅអស់រលីង ព្រោះខ្លាចអានុភាពនៃព្រះបរិត្តនេះ ។ គ្រាអមនុស្សចេញបាត់អស់ហើយ មនុស្សទាំងឡាយ ក៏បានជាសះស្បើយ ពីជំងឺ ។ ពេលនោះ

មនុស្សទាំងឡាយ ក៏មកប្រជុំគ្នាត្រង់កណ្តាលទីក្រុង ហើយបាននិមន្តព្រះពុទ្ធជាម្ចាស់ មកទីនោះ ។ ពេលនោះ ព្រះពុទ្ធជាម្ចាស់ បានត្រាស់សម្តែងរតនបរិត្តនេះដល់ពុទ្ធបរិស័ទ ដែលមកប្រជុំគ្នាក្នុងទីនោះ។

ម្យ៉ាងទៀត គាថាបីខាងចុង ជាគាថាដែលសក្កទេវរាជពោលឡើង ដោយត្រិះរិះថា ព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើឲ្យមនុស្សទាំងឡាយ បាននូវសេចក្តីសុខ ដោយអាងសច្ចវាចាពោលដល់គុណព្រះរតនត្រ័យ យើងគួរធ្វើឲ្យមនុស្សទាំងឡាយ បានប្រសព្វនូវសុខ ដោយអាងគុណព្រះរតនត្រ័យដូចគ្នា ដូច្នេះ ព្រះឥន្ទក៏ពោលបីគាថានោះ ។

## **រតនសុត្រ**

យានីធ ភូតានិ សមាគតានិ

ភុម្មានិ វា យានិ វ អន្តលិក្ខេ

សព្វេវ ភូតា សុមនា ភវន្តុ

អថោបិ សក្កច្ច សុណន្តុ ភាសិតំ។

ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី
ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី
ដែលមកប្រជុំគ្នាក្នុងទីនេះ សូមពួកភូតទាំងអស់នោះ
មានចិត្តល្អ ម្យ៉ាងទៀត ចូរស្តាប់នូវភាសិត
ដោយគោរព ។

តស្មា ហិ ភូតា និសាមេថ សព្វេ

មេត្តំ ករោថ មានុសិយា បជាយ

ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ

តស្មា ហិ នេ រក្ខថ អប្បមត្តា។

ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់
ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្តចំពោះ
ពពួកសត្វជាមនុស្សជាតិ មនុស្សទាំងឡាយឯណា
តែងនាំមកនូវពលិកម្ម ក្នុងពេលថ្ងៃ និងពេលយប់
ព្រោះហេតុនោះ សូមអ្នកទាំងឡាយកុំមើលបំណាំ
ឡើយ សូមរក្សានូវមនុស្សទាំងឡាយនោះ ។

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា

សគ្គេសុ វា យំ រតនំ បណីតំ

ន នោ សមំ អត្ថិ តថាគតេន

ឥទម្បិ ពុទ្ធេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

ទ្រព្យឯណាមួយក្នុងលោកនេះនិងក្នុងលោកឯទៀតក្តី
រតនវត្ថុដ៏ឧត្តមឯណា ក្នុងស្ថានសួគ៌ក្តី
ទ្រព្យនិងរតនវត្ថុទាំងនោះស្មើដោយព្រះតថាគត មិនមានឡើយ
កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម
ដោយពាក្យសច្ចៈនេះសូមសិរីសួស្តីកើតមាន ។

ខយំ វិរាគំ អមតំ បណីតំ

យទជ្ឈគា សក្យមុនី សមាហិតោ

ន តេន ធម្មេន សមត្ថិ កិញ្ចិ

ឥទម្បិ ធម្មេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ*
*បានត្រាស់ដឹងហើយនូវព្រះធម៌ឯណា ជាទីក្ស័យនៃ*
*កិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់*
*ជាធម៌ដ៏ឧត្តម របស់អ្វីមួយស្មើដោយព្រះធម៌នោះ*
*មិនមានឡើយ កែវគឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម*
*ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

យំ ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ

សមាធិមានន្តរិកញ្ញមាហុ

សមាធិនា តេន សមោ ន វិជ្ជតិ

ឥទម្បិ ធម្មេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*ព្រះពុទ្ធដ៏ប្រសើរទ្រង់សរសើរនូវសមាធិឯណា ថាជាធម៌ដ៏ស្អាត*
*បណ្ឌិតទាំងឡាយពោលហើយ*
*នូវសមាធិឯណាថា ជាធម៌ឲ្យផលដោយលំដាប់*
*សមាធិឯទៀត ស្មើដោយសមាធិនោះ មិនមានឡើយ*
*កែវគឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម ដោយពាក្យសច្ចៈនេះ*
*សូមសិរីសួស្តីកើតមាន ។*

យេ បុគ្គលា អដ្ឋ សតំ បសត្ថា

ចត្តារិ ឯតានិ យុគានិ ហោន្តិ

## ១៩១

តេ ទក្ខិណេយ្យា សុគតស្ស សាវកា

ឯតេសុ ទិន្នានិ មហប្ផលានិ

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរស*
*ទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ*
*បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត*
*លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយដែលបុគ្គល*
*ឲ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ*
*ជាទានមានផលច្រើន កែវគឺព្រះសង្ឃនេះឯង*
*ជាកែវដ៏ឧត្តម ដោយពាក្យសច្ចៈនេះ*
*សូមសិរីសួស្តីកើតមាន ។*

យេ សុប្បយុត្តា មនសា ទឡ្ហេន

និក្កាមិនោ គោតមសាសនម្ហិ

តេ បត្តិបត្តា អមតំ វិគយ្ហ

លទ្ធា មុធា និព្វុតឹ ភុញ្ជមានា

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនា*
*នៃព្រះសម្ពុទ្ធទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ*

មានចិត្តខ្ជាប់ខ្ជួន ឥតមានកាមគឺសេចក្តីប្រាថ្នាឡើយ
អរិយបុគ្គលទាំងឡាយនោះដល់ហើយនូវព្រះអរហត្តផល
ហើយចូលទៅកាន់ព្រះនិព្វាន បាននូវកិរិយា រលត់កិលេសដោយទទេ
គឺឥតមានទិញដូរឡើយ ហើយសោយនូវផល កែវគឺព្រះសង្ឃនេះឯង
ជាកែវដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

យថិន្ទខីលោ បថវិស្សិតោ សិយា

ចតុព្ភិ វាតេហិ អសម្បកម្បិយោ

តថូបមំ សប្បុរិសំ វទាមិ

យោ អរិយសច្ចានិ អវេច្ច បស្សតិ

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

សសរខឿនដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិន
កម្រើកញាប់ញ័រ ដោយខ្យល់ព្យុះ ដែលបក់មកអំពី
ទិសទាំង៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញ
នូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះថា
ជាសប្បុរស(មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ)
ប្រៀបដូចជាសសរខឿនដូច្នោះឯង កែវគឺព្រះសង្ឃ
នេះឯងជាកែវដ៏ឧត្តម ដោយពាក្យសច្ចៈនេះ

សូមសិរីសួស្តីកើតមាន ។

យេ អរិយសច្ចានិ វិភាវយន្តិ

គម្ភីរបញ្ញេន សុទេសិតានិ

កិញ្ចាបិ តេ ហោន្តិ ភុសំ បមត្តា

ន តេ ភវំ អដ្ឋមមាទិយន្តិ

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*អរិយបុគ្គលទាំងឡាយឯណា ធ្វើឲ្យជាក់ច្បាស់នូវ*
*អរិយសច្ចទាំងឡាយ ដែលព្រះតថាគតព្រះអង្គមាន*
*ប្រាជ្ញាដ៏ជ្រាលជ្រៅសំដែងល្អហើយ អរិយបុគ្គលទាំងឡាយនោះ*
*ទុកជាប្រមាទដ៏លើសលប់ក៏ដោយ*
*អរិយបុគ្គលទាំងឡាយនោះគង់មិនកាន់យកនូវភព*
*ជាគម្រប់៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ*
*កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម ដោយពាក្យ*
*សច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

សហាវស្ស ទស្សនសម្បទាយ

តយស្សុ ធម្មា ជហិតា ភវន្តិ

សក្កាយទិដ្ឋី វិចិកិច្ឆិតញ្ច

សីលព្វតំ វាបិ យទត្ថិ កិញ្ចិ។

*(សំយោជនកិលេស៣យ៉ាងគឺ) សក្កាយទិដ្ឋិ វិចិកិច្ឆា*
*និងសីលព្វតបរាមាសឯណាមួយតែងមាន ធម៌ទាំងឡាយ ៣ នោះ*

*សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្ប័ទ*
*គឺសោតាបត្តិមគ្គ ។*

ចតូហាបាយេហិ ច វិប្បមុត្តោ

ឆច្ចាភិឋានានិ អភព្វ កាតុំ

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*ម្យ៉ាងទៀត សោតាបន្នបុគ្គលបានរួចស្រឡះចាក*
*អបាយទាំងឡាយ ៤ ហើយ មិនអាចធ្វើនូវស្ថានដ៏*
*អាក្រក់ទាំងឡាយ ៦ គឺអនន្តរិយកម្ម ៥ និង*
*កិរិយាងាកចិត្តទៅកាន់សាសនាដទៃឡើយ*
*កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*
*ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

កិញ្ចាបិ សោ កម្ម ករោតិ បាបកំ

កាយេន វាចា ឧទ ចេតសា វា

អភព្វ សោ តស្ស បដិច្ឆទាយ

អភព្វតា ទិដ្ឋបទស្ស វុត្តា

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*ប្រសិនណាបើ សោតាបន្នបុគ្គលនោះធ្វើនូវបាបកម្មខ្លះ*

១៩៥

ដោយកាយ វាចា ឬក៏ដោយចិត្តក្តី (ព្រោះសេចក្តីភ្លាំងភ្លាត់)
សោតាបន្នបុគ្គលនោះមិនអាចបិទបាំងនូវបាបកម្ម នោះឡើយ
ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វាន ឃើញហើយ
ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម
ព្រះពុទ្ធទាំងឡាយបានត្រាស់សំដែងហើយ
កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម
ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

វនប្បគុម្ពេ យថ ផុស្សិតគ្គេ

គិម្ហានមាសេ បឋមស្មឹ គិម្ហេ

តថូបមំ ធម្មវរំ អទេសយិ

និព្វានគាមឹ បរមំ ហិតាយ

ឥទម្បិ ពុទ្ធេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហរដូវ
គឺខែក្តៅយ៉ាងណាមិញ ព្រះសម្ពុទ្ធបាន ត្រាស់សំដែងហើយនូវធម៌
ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយឲ្យដល់នូវព្រះនិព្វាន
ដើម្បីប្រយោជន៍ដ៏ឧត្តម ប្រៀបដូចជាគុម្ពឈើក្នុងព្រៃ ដូច្នោះឯង
កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម
ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

វរោ វរញ្ញូ វរទោ វរាហរោ

អនុត្តរោ ធម្មវរំ អទេសយិ

១៩៦

ឥទម្បិ ពុទ្ធេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ*
*ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ*
*ព្រះអង្គប្រសើរឥតមានអ្នកណាមួយ ស្មើ*
*ទ្រង់ត្រាស់សំដែងហើយនូវធម៌ដ៏ប្រសើរ*
*កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម*
*ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។*

ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ

វិរត្តចិត្តាយតិកេ ភវស្មឹ

តេ ខីណពីជា អវិរូឡ្ហិឆន្ទា

និព្វន្តិ ធីរា យថាយំ បទីបោ

ឥទម្បិ សង្ឃេ រតនំ បណីតំ

ឯតេន សច្ចេន សុវត្ថិ ហោតុ។

*កម្មចាស់ (របស់អរិយបុគ្គលឯណា) អស់ហើយ*
*កម្មថ្មីរមែងមិនកើតប្រាកដ អរិយបុគ្គលទាំងឡាយ*
*ឯណា មានចិត្តនឿយណាយហើយក្នុងភពតទៅ*
*អរិយបុគ្គលទាំងឡាយនោះមានពូជអស់ហើយ*
*មានឆន្ទៈគឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ*
*ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីប*
*ដែលរលត់ទៅនេះ កែវគឺព្រះសង្ឃនេះឯង ជាកែវ*

ដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមសិរី
សួស្តីកើតមាន ។

យានីធ ភូតានិ សមាគតានិ

ភុម្មានិ វា យានិ វ អន្តលិក្ខេ

តថាគតំ ទេវមនុស្សបូជិតំ

ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ។

ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី
ពួកភូតឯណាជាទេវតា ស្ថិតនៅឰដ៏អាកាសក្តី
ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយ
សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់មក
ហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា
សូមសិរីសួស្តីកើតមាន ។

យានីធ ភូតានិ សមាគតានិ

ភុម្មានិ វា យានិ វ អន្តលិក្ខេ

តថាគតំ ទេវមនុស្សបូជិតំ

ធម្មំ នមស្សាម សុវត្ថិ ហោតុ។

ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតា
ស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយ
សូមនមស្ការនូវព្រះធម៌មានមកហើយដូចគ្នា
ដែលមនុស្សនិងទេវតាតែងបូជា សូមសិរីសួស្តីកើតមាន ។

យានីធ ភូតានិ សមាគតានិ

កុម្ភានិ វា យានិ វ អន្តលិក្ខេ

តថាគតំ ទេវមនុស្សបូជិតំ

សង្ឃំ នមស្សាម សុវត្ថិ ហោតុ ។

*ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះសង្ឃមានមកហើយដូចគ្នា ដែលទេវតានិងមនុស្សតែងបូជា សូមសិរីសួស្តីកើតមាន ។*

ធម្មស្សវនានិសំសកថា

រាជតោ វា ចោរតោ វា មនុស្សតោ វា អមនុស្សតោ វា អគ្គិតោ វា ឧទកតោ វា បិសាចតោ វា ខាណុកតោ វា កណ្តកតោ វា នក្ខត្តតោ វា ជនបទ-រោគតោ វា អសទ្ធម្មតោ វា អសន្ទិដ្ឋិតោ វា អសប្បុរិសតោ វា ចណ្ឌហត្ថិ-អស្សមិគគោណកុក្កុរអហិវិច្ឆិកមណិសប្បទីបិអច្ឆតរច្ឆសូករមហិំសយក្ខរក្ខសាទីហិ នានាភយតោ វា នានារោគតោ វា នានាឧបទ្ទវតោ វា អារក្ខំ គណ្ហន្តុ ។

*សូមសព្វសត្វ បានទទួលនូវការគ្រប់គ្រងរក្សាអំពីភ័យផ្សេងៗ អំពីរោគផ្សេងៗ អំពីឧបទ្រពផ្សេងៗ ដែលកើតអំពីព្រះរាជា ចោរ មនុស្ស អមនុស្ស ភ្លើង ទឹក បិសាច ដង្គត់ឈើ បន្លា នក្ខត្តឫក្ស រោគក្នុងជនបទ សេចក្តីប្រព្រឹត្តរបស់មនុស្សអាក្រក់ ការឃើញខុសរបស់មនុស្សអាក្រក់ ដំរី សេះ ម្រឹគ គោ ឆ្កែ ពស់ ខ្យូយ ពស់វែក ខ្លាឃ្មុំ ខ្លាដំបង ខ្លារខិន ជ្រូក ក្របី យក្ខ រក្ខសទេវតាជាដើម ដ៏កាចសាហាវ ។*

## មង្គលចក្កវាឡ

សិរីធិតិមតិតេជោជយសិទ្ធិមហិទ្ធិមហាគុណាបរិមិតបុញ្ញាធិការស្ស សព្វន្តរាយនិវារណសមត្ថស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ទ្វត្តឹស-មហាបុរិសលក្ខណានុភាវេន

*ដោយអានុភាពនៃមហាបុរិសលក្ខណៈ ៣២ ប្រការនៃព្រះដ៏មានព្រះភាគជាព្រះអរហន្ត ដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់មានបុញ្ញាធិការនឹងកំណត់មិនបានដោយឫទ្ធិដ៏ធំ និងគុណដ៏ធំ ដ៏សម្រេចដោយសិរី ដោយបញ្ញាជាគ្រឿងតម្កល់មាំ ដោយបញ្ញាជាគ្រឿងដឹង ដោយតេជះ ដោយជ័យជម្នះ ព្រះអង្គអាចក្នុងកិរិយា ឃាត់បង់នូវសេចក្ដីអន្តរាយគ្រប់យ៉ាង*

អសីត្យានុព្យញ្ជនានុភាវេន *ដោយអានុភាពនៃអនុព្យញ្ជនៈ៨០*

អដ្ឋុត្តរសតមង្គលានុភាវេន *ដោយអានុភាពនៃមង្គល១០៨*

ឆព្វណ្ណរំសិយានុភាវេន *ដោយអានុភាពនៃរស្មីមានពណ៌៦*

កេតុមាលានុភាវេន *ដោយអានុភាពនៃព្រះកេតុមាលា*

ទសបារមិតានុភាវេន *ដោយអានុភាពនៃបារមី១០*

ទសឧបបារមិតានុភាវេន *ដោយអានុភាពនៃឧបបារមី១០*

ទសបរមត្ថបារមិតានុភាវេន *ដោយអានុភាពនៃបរមត្ថបារមី១០*

សីលសមាធិបញ្ញានុភាវេន *ដោយអានុភាពនៃសីល សមាធិ បញ្ញា នៃព្រះអង្គ*

ពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធ

ធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌

សង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃ

តេជានុភាវេន ដោយអានុភាពនៃតេជះ

ឥទ្ធានុភាវេន ដោយអានុភាពនៃឫទ្ធិ

ពលានុភាវេន ដោយអានុភាពនៃកម្លាំង

ញេយ្យធម្មានុភាវេន ដោយអានុភាពនៃញេយ្យធម៌

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយអានុភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ពាន់

នវលោកុត្តរធម្មានុភាវេន ដោយអានុភាពនៃលោកុត្តរធម៌ ៩

អដ្ឋង្គិកមគ្គានុភាវេន ដោយអានុភាពនៃព្រះអរិយមគ្គមានអង្គ ៨

អដ្ឋសមាបត្តិយានុភាវេន ដោយអានុភាពនៃសមាបត្តិ ៨

ឆឡភិញ្ញានុភាវេន ដោយអានុភាពនៃអភិញ្ញា ៦

ចតុសច្ចញ្ញាណានុភាវេន ដោយអានុភាពនៃសច្ចញ្ញាណ៤

ទសពលញ្ញាណានុភាវេន ដោយអានុភាពនៃពលញ្ញាណ ១០

សព្វញ្ញុតញ្ញាណានុភាវេន ដោយអានុភាពនៃសព្វញ្ញុតញ្ញាណ

មេត្តាករុណាមុទិតាឧបេក្ខានុភាវេន ដោយអានុភាពនៃមេត្តា ករុណា មុទិតា និងឧបេក្ខា

សព្វបរិត្តានុភាវេន ដោយអានុភាពនៃព្រះបរិត្តទាំងពួង

រតនត្តយសរណានុភាវេន ដោយអានុភាពនៃកិរិយារឭកដល់ព្រះរតនត្រ័យ

តុយ្ហំ សព្វរោគសោកុបទ្ទវទុក្ខទោមនស្សុបាយាសា វិនស្សន្តុ *រោគ សោក ឧបទ្រព ទុក្ខ ទោមនស្ស និងឧបាយាសៈទាំងពួងរបស់អ្នក ចូរ វិនាសបាត់ទៅ*

សព្វអន្តរាយាបិ វិនស្សន្តុ *សេចក្តីអន្តរាយទាំងពួង (របស់អ្នក) ចូរវិនាសបាត់ទៅ*

សព្វសង្កប្បា តុយ្ហំ សមិជ្ឈន្តុ *សេចក្តីត្រិះរិះគ្រប់យ៉ាងរបស់អ្នក ចូរសម្រេចដោយល្អ*

ទីឃាយុតា តុយ្ហំ ហោតុ *ភាវៈជាអ្នកមានអាយុវែង ចូរមានដល់អ្នក*

សតវស្សជីវេន សមង្គិកោ ហោតុ សព្វទា *សូមឲ្យអ្នកជាបុគ្គល មានសេចក្តីប្រកប ដោយកិរិយារស់នៅ អស់រយនៃឆ្នាំសព្វៗកាល*

អាកាសបព្វតវនភូមិគង្គាមហាសមុទ្ទា អារក្ខកា ទេវតា *ទេវតាទាំងឡាយ ជាអ្នករក្សាដោយយកចិត្តទុកដាក់ ដែលស្ថិតនៅក្នុងអាកាស បព៌ត វនស្ថាន ភូមិស្ថាន និងទន្លេ និងមហាសមុទ្រ*

សទា តុម្ហេ អនុរក្ខន្តុ *ចូរបីបាច់រក្សានូវអ្នកទាំងឡាយសព្វៗកាល*

ភវតុ សព្វមង្គលំ　　រក្ខន្តុ សព្វទេវតា

សព្វពុទ្ធានុភាវេន　　សទា សោត្ថី ភវន្តុ តេ ។

*មង្គលទាំងពួង ចូរមាន (ដល់អ្នក) សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ដោយ អានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ សូមសិរីសួស្តី ទាំងឡាយកើតមានដល់អ្នក ឲ្យបានសព្វកាលសព្វវេលា ។*

ភវតុ សព្វមង្គលំ　　រក្ខន្តុ សព្វទេវតា

សព្វធម្មានុភាវេន　　សទា សោត្ថី ភវន្តុ តេ ។

*មង្គលទាំងពួង ចូរមាន (ដល់អ្នក) សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

*ដោយអានុភាពនៃព្រះធម៌ទាំងពួង សូមសិរីសួស្ដីទាំងឡាយ កើតមានដល់អ្នក ឲ្យបានសព្វកាល សព្វវេលា ។*

ភវតុ សព្វមង្គលំ          រក្ខន្តុ សព្វទេវតា

សព្វសង្ឃានុភាវេន          សទា សោត្ថី ភវន្តុ តេ ។

*មង្គលទាំងពួង ចូរមាន(ដល់អ្នក) សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក) ដោយអានុភាពនៃព្រះសង្ឃទាំងពួង សូមសិរីសួស្ដីទាំងឡាយ កើតមានដល់អ្នក ឲ្យបានសព្វកាលសព្វវេលា ។*

នក្ខត្តយក្ខភូតានំ          បាបគ្គហនិវារណា

បរិត្តស្សានុភាវេន          ហន្ត្វា តេសំ ឧបទ្ទវេ ។

*កិរិយាពាំងនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសម្នាក់) នៃនក្ខត្តឫក្ស និងយក្ខ និងភូតបិសាចទាំងឡាយ ដោយអានុភាពនៃព្រះបរិត្ត សូមកម្ចាត់បង់នូវឧបទ្រពទាំងឡាយ (ដែលកើតអំពីសម្នាក់) នៃនក្ខត្តឫក្ស និងយក្ខ និងភូតបិសាចទាំងឡាយនោះ ។*

## សរណាគមនគាថា

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា។

*មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនិងដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ។*

នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

*ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះមិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះទេ ។*

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។

*បុគ្គលណាមួយបានដល់នូវព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ ជាទីពឹងទីរលឹក ហើយឃើញនូវអរិយសច្ចទាំងបួន គឺសេចក្តីទុក្ខ ១ សមុទយៈជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១ និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ ១ មគ្គមានអង្គ ៨ ដ៏ប្រសើរដែលញុំាងសត្វឲ្យដល់នូវព្រះនិព្វាន ជាស្ពានរម្ងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ត្រូវ ។*

ឯតំ ខោសរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

*ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្តម (របស់នោះ) បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។*

## ធលិទ្ធសុត្តគាថា

**យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា**

*បុគ្គលឯណាមានសេចក្តីជឿតម្កល់មាំឥតកម្រើក ចំពោះព្រះតថាគត*

**សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ**

*បុគ្គលឯណាមានសីលដ៏ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលអរិយៈ ទាំងឡាយលោកសរសើរហើយ*

**សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ**

*បុគ្គលឯណាមានសេចក្តីជ្រះថ្លាចំពោះព្រះសង្ឃផង មានសេចក្តីយល់ ឃើញដ៏ត្រូវត្រង់ផង*

**អទលិទ្ទោតិ តំ អាហុ អមោឃន្តស្ស ជីវិតំ**

*បណ្ឌិតទាំងឡាយលោកហៅបុគ្គលនោះ ថាមិនមែនជាអ្នកទាល់ក្រឡើយ ជីវិតរបស់បុគ្គលនោះ មិនមែនសោះសូន្យឥតប្រយោជន៍ឡើយ*

**តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ**

**អនុយុញ្ជេថ មេធាវី សរំ ពុទ្ធាន សាសនំ ។**

*ព្រោះហេតុនោះបុគ្គលអ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ក៏គួរប្រកបរឿយ ៗ នូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវកិរិយា ឃើញនូវធម៌ផង ។*

### អត្ថន័យនៃពាក្យថា ព្រះរតនត្រ័យ

១.រមិតព្វន្តិ រមន្តិ ឯត្ថាតិ រំ *ជនទាំងឡាយ រមែងត្រេកអរនូវវត្ថុដែលអរិយបណ្ឌិតគប្បីត្រេកអរក្នុងពួក ៣ នៃបូជនីយវត្ថុនេះ ហេតុនោះ ទើបឈ្មោះថា រៈ ។*

២.អត្តានំ ភជន្តេ ឧបសេវន្តេ ទុគ្គតិតោ សំសារមហណ្ណវតោ វា តារេតីតិ តំ ។ *ពួក ៣ នៃបូជនីយវត្ថុណា រមែងញុំាងជនដែលគប់រក គឺចូលទៅសេពនូវខ្លួន ឲ្យឆ្លងផុតចាកទុគ្គតិនិងអន្លង់គឺសង្សារវដ្ដ ហេតុនោះ ពួក ៣ នៃវត្ថុនោះ ទើបឈ្មោះថា* តៈ ។

៣.អត្តានំ អនុស្សរន្តេ សុគតិនិព្វានានិ នេតីតិ នំ *ពួក ៣ នៃបូជនីយវត្ថុណា រមែងនាំជនអ្នករលឹកដល់ខ្លួនឲ្យទៅកាន់សុគតិ និងព្រះនិព្វាន ហេតុនោះ ទើបឈ្មោះថា* នៈ ។

*សរុបមក* **រតនៈ** *ចែកចេញជា ៣ អក្សរ គឺ អក្សរ* ***រ*** *មកពី* **រម** *ធាតុ ក្នុងអត្ថថា រីករាយ ។* **ត** *មកពីពាក្យថា* **តរ** *ធាតុ ក្នុងអត្ថថា ឆ្លង ។* **ន** *មកពី* **និ** *ធាតុ ក្នុងអត្ថថា ឲ្យដល់ ។* **ត្រៃ** *ជាពាក្យសំខ្យា មានន័យថា ៣ ។ រួមគ្នាជា***ព្រះរតនត្រៃយ** *ប្រែថា ជាទីរីករាយរបស់អ្នកប្រាជ្ញ ១ ជាគ្រឿងឆ្លងផុតចាកទុគ្គតិនិងសង្សារវដ្ត ១ ជាគ្រឿងនាំឲ្យដល់សុគតិនិងព្រះនិព្វាន ១ ។*

# ប្រួចទឹក ឧទ្ទិសផលបុណ្យ

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ ។
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច
ព្រហ្មា មារា ច ឥន្ទា ច លោកចាលា ច ទេវតា ។
យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច ។
សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ ខិប្បំ ចាមេជ រោមតំ ។

*ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយមានគុណដ៏ខ្ពង់ខ្ពស់ អាចារ្យទាំងឡាយមានឧបការៈ មាតាបិតាជាទីស្រឡាញ់នៃខ្ញុំ ព្រះអាទិត្យ, ព្រះចន្ទ, ព្រះរាជា, នរជនអ្នកមានគុណទាំងឡាយ, ព្រះព្រហ្ម, មារាធិរាជ, ព្រះឥន្ទទាំងឡាយ, លោកបាលមហារាជ និងទេវតាទាំងឡាយ, ព្រះយមរាជ និងមនុស្សទាំងឡាយ និងមិត្តនឹងគ្នាក្តី មានចិត្ត ជាកណ្តាលក្តី មានពៀរនឹងគ្នាក្តី ( រួបរួមសេចក្តីថា ) សូមឲ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយដែលខ្ញុំ បានកសាងសន្សំហើយ ចូរឲ្យនូវសេចក្តីសុខទាំង ៣ ប្រការ សូមឲ្យអ្នកទាំងឡាយបានដល់នូវអមតមហានិព្វាន ឲ្យបានធាប់រួសរាន់ទាន់សេចក្តីប្រាថ្នាហោង ! ។*

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេ ចេវ តណ្ហុចាទានធេទនំ
យេ សន្តានេ ហីនា ធម្មា យាវ និព្វានតោ មមំ
នស្សន្តុ សព្វទាយេវ យត្ថ ជាតោ ភវាភវេ
ឧជុចិត្តោ សតិប្បញ្ញា សល្លេខោ វីរិយោម្ហិ វា
មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ
ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ

ឆាជោ បច្ចេកពុទ្ធោ ច សង្ឃោ ឆាជោត្តមោ មមំ
តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

*ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឲ្យខ្ញុំបានដោយឆាប់ យ៉ាងរួសរាន់ទាន់ចិត្តនូវមគ្គផលជាគ្រឿងផ្តាច់បង់នូវតណ្ហានិងឧបាទាន ធម៌ទាំងឡាយណា ជាធម៌ថោកទាប គឺអកុសលធម៌ នៅក្នុងសន្តានចិត្តខ្ញុំ សូមឲ្យ ( ហីនធម៌ជាអកុសលទាំងនោះ ) វិនាសបាត់រៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន ( ក្នុងបច្ឆិមជាតិ ) បើខ្ញុំអន្ទោលទៅចាប់កំណើតក្នុងភពតូចនិងភពធំណា ៗ សូមឲ្យខ្ញុំជាបុគ្គលមានចិត្តត្រង់ មានសតិនិងបញ្ញា មានចិត្តស្អាតផូរផង់ ទាំងសូមឲ្យមានព្យាយាមផង ( ក្នុងភពនោះ ៗ ) មារទាំងឡាយចូរកុំបាននូវឱកាស ដើម្បីធ្វើឲ្យខូចព្យាយាមខ្ញុំឡើយ ព្រះពុទ្ធដូចជាប្រទីបឬកោះដ៏ប្រសើរជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធ ក៏ជាទីពឹងនៃខ្ញុំដែរ ព្រះសង្ឃក៏ជាទីពឹងដ៏ខ្ពង់ខ្ពស់នៃខ្ញុំដែរ! ដោយឧត្តមានុភាពនៃព្រះពុទ្ធ, ព្រះធម៌, ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាសចូលមកជ្រៀតជ្រែកឡើយ! ។*

## ការសូមខមាទោសចំពោះសព្វសត្វ

យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា
យេ ចាណេកេ បមាទេន កាយវាចាមនេហិ វា
បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ
វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។

*សត្វទាំងឡាយណាមួយ ទោះតូចក្តី ធំក្តី ដែលខ្ញុំបានបៀតបៀនហើយ មួយទៀតសត្វទាំងឡាយណាពួកខ្លះ ( ដែលខ្ញុំបានធ្វើទុក្ខបុកម្នេញហើយ ) ព្រោះសេចក្តីប្រមាទភ្លាំងភ្លាត់ ដោយកាយវាចាចិត្ត ( សត្វទាំងឡាយនោះ ) ចូរអនុមោទនានូវបុណ្យរបស់ខ្ញុំចុះ ចូលទទួលយកនូវផលបុណ្យដ៏ឧត្តមចុះ បើសត្វទាំងឡាយ ដែលមានពៀរនឹងគ្នា ចូររួចរំដោះ ( ចាកពៀរនោះ ) ចុះ សូមអត់ទោសទាំងពួងដល់ខ្ញុំផង ។*

## សុខាភិយាចនគាថា

បសន្នា ហោន្តុ សព្វេបិ   ចាណិនោ ពុទ្ធសាសនេ
សម្មា ធារំ បវេច្ឆន្តោ   កាលេ ទេវោ បវស្សតុ
វុឌ្ឍិភាវាយ សត្តានំ   សមិទ្ធំ នេតុ មេទនី
មាតាបិតា ច អត្រជំ   និច្ចំ រក្ខន្តិ បុត្តកំ
ឯវំ ធម្មេន រាជានោ   បជំ រក្ខន្តុ សព្វទា ។

*ប្រែថា:* បសន្នា ហោន្តុ សព្វេបិ ចាណិនោ ពុទ្ធសាសនេ *សត្វទាំងឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា* សម្មា ធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនី *សូមឲ្យភ្លៀងបង្អុរនូវធារទឹកដោយប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្តាលឲ្យផែនដីសំរិទ្ធិ គឺថាឲ្យមានដីរជាតិល្អឡើង ដើម្បីកើតសេចក្តីចម្រើនដល់សត្វទាំងឡាយ* មាតាបិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ *មាតាក្តី បិតាក្តី បីបាច់រក្សាជានិច្ចនូវកូនតូច នៃកូនបង្កើតយ៉ាងណាមិញ* ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា *សូមព្រះបរមក្សត្រទាំងឡាយ រក្សានូវប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតាបីបាច់រក្សាកូនដូច្នោះ ឲ្យបានសព្វកាលទៅហោង ។*

## សុខាភិយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ សាសនំ ។

*ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី*
*នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើង*
*ទាំងឡាយ ចូររក្សានូវព្រះពុទ្ធសាសនា ( ឲ្យបានចម្រើន ) អស់កាល*
*ជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ រាជានោ ។

*ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី*
*នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើង*

*ទាំងឡាយ ចូររក្សានូវព្រះបរមក្សត្រទាំងឡាយ ( ឲ្យបានចម្រើន ) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា  ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ  ចិរំ រក្ខន្តុ ញាតយោ ។

*ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវញាតិទាំងឡាយ( ឲ្យបានចម្រើន ) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា  ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ  ចិរំ រក្ខន្តុ ពាណិនោ ។

*ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវសត្វទាំងឡាយ ( ឲ្យបានចម្រើន ) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា  ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ  ចិរំ រក្ខន្តុ នោ សទា ។

*ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវយើងទាំងឡាយគ្រប់កាលទាំងពួង ( ឲ្យបានចម្រើន ) អស់កាលជាយូរអង្វែងទៅ ។*

**បត្តិទានគាថា**

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា

សោត្ថឹ ករោន្តុ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថវោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សង្ខយំ ។
ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោវ អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ
វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មេ អរិយប្បវេទិតេ ។

*ប្រែថា:* យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ *ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅ នៃសង្ឃព្វជ៏ខៀនព្រះស្តូប ព្វជ៏ខៀនព្រះពោធិព្រឹក្សក្នុងទីនោះ ៗ*

តា ធម្មទានេន ភវន្តុ បូជិតា *ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងទាំងឡាយបូជាហើយដោយធម្មទាន*

សោត្ថឹ ករោន្តុ វិហារមណ្ឌលេ *ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ*

ថេរា ច មជ្ឈា នវកា ច ភិក្ខវោ *ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី*

អារាមិកា ទានបតី ឧបាសកា ឧបាសក និងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី

គាមា ច ទេសា និគមា ច ឥស្សរា ជនទាំងឡាយ ដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី

សប្បាណភូតា សុខិតា ភវន្តុ តេ សត្វទាំងឡាយនោះៗ ចូរ ឲ្យបានដល់នូវសេចក្តីសុខ

ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី

និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សង្ខយំ សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ

ឋាតុ ចិរំ សតំ ធម្មោ សូមឲ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ

ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ( ចូរ ស្ថិតនៅអស់កាលយូរអង្វែងទៅ )

សង្ឃោ ហោតុ សមគ្គោ វ សូមព្រះសង្ឃព្រមព្រៀងគ្នា

អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង

អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ សូមព្រះសទ្ធម្ម រក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយ ទាំងអស់ផង

វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មេ អរិយប្បវេទិតេ សូមឲ្យយើង ទាំងឡាយបានដល់នូវសេចក្តីចម្រើន ក្នុងធម៌ដែលព្រះអរិយទាំងឡាយលោកសំដែងហើយ ។

## ត្រួចទឹកឧទ្ទិសបុណ្យ

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។ បុណ្យកុសលនេះ ឯង សូមសម្រេចដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខចុះ ។**

**សព្វបត្តិទានគាថា**

**បុញ្ញស្សិទានិ កតស្ស   យានញ្ញានិ កតានិ មេ**
**តេសញ្ច ភាគិនោ ហោន្តុ   សត្តានន្តាប្បមាណកា ។**

*សត្វទាំងឡាយ មិនមានទីបំផុត មិនមានប្រមាណ ចូរមានចំណែកនៃបុណ្យដែលខ្ញុំបានធ្វើក្នុងកាលឥឡូវនេះ និងបុណ្យដទៃដែលបានធ្វើទុកក្នុងកាលមុនហើយ ។*

**យេ បិយា គុណវន្តា ច   មយ្ហំ មាតាបិតាទយោ**
**ទិដ្ឋា មេ ចាប្យទិដ្ឋា វា   អញ្ញេ មជ្ឈត្តវេរិនោ ។**

*គឺនឹងជាសត្វពួកណា ដែលជាទីស្រឡាញ់និងមានគុណ ដូចមាតាបិតារបស់ខ្ញុំជាដើមក្តី ដែលខ្ញុំបានឃើញហើយ ឬមិនបានឃើញក្តី ពួកសត្វដទៃ ដែលជាកណ្តាលៗ ឬមានពៀរវេរក្តី ។*

**សត្តា តិដ្ឋន្តិ លោកស្មឹ   តេភុម្មា ចតុយោនិកា**
**បញ្ចេកចតុវោការា   សំសរន្តា ភវាភវេ ។**

*សត្វទាំងឡាយតាំងនៅក្នុងលោក នៅក្នុងភូមិទាំងបី នៅក្នុងកំណើតទាំង ៤ មានខន្ធ ៥ មានខន្ធ ១ មានខន្ធ ៤ កំពុងត្រាច់ទៅក្នុងភពតូចនិងភពធំក្តី ។*

**ញាតំ យេ បត្តិទានម្មេ   អនុមោទន្តុ តេ សយំ**
**យេ ចិមំ នប្បជានន្តិ   ទេវា តេសំ និវេទយុំ ។**

*សត្វពួកណា ដឹងចំណែកបុណ្យដែលខ្ញុំចែកឲ្យហើយ សត្វទាំងនោះ ចូរអនុមោទនាខ្លួនឯងចុះ ចំណែកសត្វពួកណា នៅមិនបានដឹងនូវចំណែកបុណ្យនេះ សូមទេវតាទាំងឡាយ ចូរប្រាប់ឲ្យសត្វនោះបានដឹង ។*

**មយា ទិន្នាន បុញ្ញានំ អនុមោទនហេតុនា**
**សព្វេ សត្តា សទា ហោន្តុ អវេរា សុខជីវិនោ**
**ខេមប្បទញ្ច បប្បោន្តុ តេសាសា សិជ្ឈតំ សុភា ៕**

*ព្រោះហេតុអនុមោទនាបុណ្យដែលខ្ញុំបានចែកឲ្យហើយ សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរវេរានឹងគ្នា ចូរនៅជាសុខ ចូរដល់នូវព្រះនិព្វានដ៏ក្សេម សេចក្តីប្រាថ្នាដ៏ល្អរបស់សត្វទាំងនោះ ចូរសម្រេចចុះ។*

## ច្រូចទឹក បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ
យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

*ប្រែថា:* យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម *អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ*

កាយេន វាចាមនសា *ដោយទ្វារទាំងបី គឺកាយ វាចា ចិត្ត*

តិទសេ សុគតំ កតំ *អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលដែលនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រិង្សសួគ៌ បាន*

យេ សត្តា សញ្ញិនោ អត្ថិ *សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី*

កាតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ *សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ*

យេ តំ កាតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា *បុណ្យដែលខ្ញុំ បានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ*

យេ ច តត្ថ ន ជានន្តិ *ម្យ៉ាងទៀត បណ្ដាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយ*

ទេវា គន្ត្វា និវេទយុំ *សូមទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ ៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ*

សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា *សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ*

មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា *សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។*

## ផ្សាយមេត្តាចំពោះខ្លួនឯង (សម្រាប់បុរស)

**អហំ អវេរោ ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំមានពៀរវេរានឹងគ្នា*

**អព្យាបជ្ជោ ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំបៀតបៀនគ្នានឹងគ្នា*

**អនីឃោ ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំមានសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្តឡើយ ។*

**សុខី** *ចូរមានសេចក្តីសុខកាយ និងសុខចិត្ត*

**អត្តានំ បរិហរាមិ** *ចូររក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំងអស់ ។*

## ផ្សាយមេត្តាដល់អ្នកណានីមួយ

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំមានពៀរវេរានឹងគ្នា*

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំបៀតបៀនគ្នានឹងគ្នា*

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំមានសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្តឡើយ*

*សូម (ឈ្មោះ....) ចូរមានសេចក្តីសុខកាយ និងសុខចិត្ត*

*សូម (ឈ្មោះ....) ចូររក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំងអស់ ។*

## ផ្សាយមេត្តាចំពោះខ្លួនឯង (សម្រាប់ស្ត្រី)

**អហំ អវេរា ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំមានពៀរវេរានឹងគ្នា*

**អព្យាបជ្ឈា ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំបៀតបៀនគ្នានឹងគ្នា*

**អនីឃា ហោមិ** *អាត្មាអញ ចូរនៅជាសុខ សុខចុះ កុំមានសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្តឡើយ ។*

**សុខិនី** *ចូរមានសេចក្តីសុខកាយ និងសុខចិត្ត*

**អត្តានំ បរិហរាមិ** *ចូររក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំងអស់ ។*

## ផ្សាយមេត្តាដល់អ្នកណានីមួយ

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំមានពៀរវេរានឹងគ្នា*

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំបៀតបៀនគ្នានឹងគ្នា*

*សូម (ឈ្មោះ....) ចូរនៅជាសុខ សុខចុះ កុំមានសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្តឡើយ*

*សូម (ឈ្មោះ....) ចូរមានសេចក្តីសុខកាយ និងសុខចិត្ត*

*សូម (ឈ្មោះ....) ចូររក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំងអស់ ។*

## ផ្សាយមេត្តាមិនកំណត់

**សព្វេ សត្តា អវេរា ហោន្តុ** *សត្វទាំងឡាយទាំងពួង ចូរនៅជាសុខ សុខចុះ កុំមានពៀរវេរានឹងគ្នា*

**សព្វេ សត្តា អព្យាបជ្ឈា ហោន្តុ** *សត្វទាំងឡាយទាំងពួង ចូរនៅជាសុខ សុខចុះ កុំបៀតបៀនគ្នានឹងគ្នា*

**សព្វេ សត្តា អនីឃា ហោន្តុ** *សត្វទាំងឡាយទាំងពួង ចូរនៅជាសុខ សុខចុះ កុំមានសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្តឡើយ*

**សព្វេ សត្តា សុខី ហោន្តុ** *សត្វទាំងឡាយទាំងពួង ចូរមានសេចក្តីសុខកាយ និងសុខចិត្ត*

**សព្វេ សត្តា អត្តានំ បរិហរន្តុ** *សត្វទាំងឡាយទាំងពួង ចូររក្សាខ្លួនឲ្យផុតចាកទុក្ខភ័យទាំងអស់ ។*

## ធម៌ផ្សាយមេត្តា

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសបូព៌ សូមកុំឲ្យមានពៀរនឹងគ្នាមានតែសេចក្តីសុខ*

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសអាគ្នេយ៍ សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ*

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំង ឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសទក្សិណ សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែ សេចក្តីសុខ*

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសនិរតី សូម កុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ*

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសបស្ចិម សូមកុំឲ្យ មានពៀរនឹងគ្នា មានតែសេចក្តីសុខ*

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសពាយ័ព្យ សូមកុំឲ្យ មានពៀរនឹងគ្នា មានតែ សេចក្តីសុខ*

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសឧត្តរ សូមកុំឲ្យមាន ពៀរនឹងគ្នា មានតែសេចក្តីសុខ*

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិស ឦសាន សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែសេចក្តី សុខ*

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយ ទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសខាងក្រោម សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែ សេចក្ដីសុខ*

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយ ទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដី សុខ*

សព្វេ សត្តា អវេរា ហោន្តុ *សត្វទាំងឡាយ ទាំងពួងសូមកុំឲ្យមានពៀរនឹងគ្នា*

សុខិតា ហោន្តុ *សូមឲ្យមានតែសេចក្ដីសុខ*

និទ្ទុក្ខាហោន្តុ *សូមឲ្យប្រាសចាកទុក្ខ*

អព្យាបជ្ឈា ហោន្តុ *សូមកុំព្យាបាទគ្នា*

អនីឃា ហោន្តុ *សូមកុំឲ្យមានសេចក្ដីចង្អៀតចង្អល់ចិត្ត*

ទីឃាយុកា ហោន្តុ *សូមឲ្យមានអាយុវែង*

អរោគា ហោន្តុ *សូមកុំឲ្យមានរោគ*

សម្បត្តីហិ សមិជ្ឈន្តុ *សូមឲ្យសម្រេចដោយសម្បត្តិទាំង ឡាយ*

សុខី អត្តានំ បរិហរន្តុ *សូមរក្សានូវខ្លួនឲ្យនៅជាសុខ ( តទៅ )*

ទុក្ខប្បត្តា ច និទ្ទុក្ខា
ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា
ហោន្តុ សព្វេបិ ទាណិនោ ។

*សត្វទាំង ឡាយទាំងពួង ដែលដល់ហើយនូវសេចក្ដីទុក្ខ សូមឲ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឲ្យជាសត្វបាត់សេចក្ដីសោកទៅ ។*

## សិទ្ធិយាចនគាថា

សិទ្ធមត្ថុ សិទ្ធមត្ថុ    សិទ្ធមត្ថុ ឥទំ ផលំ
ឯតស្មឹ រតនត្តយស្មឹ    សម្បសាទនចេតសោ ។

*សូមផលនៃចិត្តដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ*
*ផលនេះចូរ ជាផលសម្រេច ចូរជាផលសម្រេច*
*ចូរជាផលសម្រេច ។*

## សិទ្ធិយាចនគាថា

យទិ សន្តិកមោ មគ្គោ    មោក្ខោ ចច្ចន្តិកំ សុខំ
ឯតេន សច្ចវជ្ជេន    គមនំ មេ សមិជ្ឈតុ ។

*ផ្លូវទៅព្រះនិព្វាន    ពិតជាមានយ៉ាងប្រាកដ*
*ផ្លូវសុខយ៉ាងហ្មត់ចត់    ជាវិមុត្តិលោកុត្តរ ។*
*ដោយសច្ចកិរិយា    ការប្រាថ្នាដ៏បវរ*
*សូមឲ្យបានឃើញធម៌    គឺនិព្វានដ៏ឆាប់ហោង ។*

## បត្ថយាចនគាថា

បុញ្ញេនេតេន សោហំ និបុណមតិ សតោ សម្បរាយេ ច តិត្តោ

ទក្ខោ ទិដ្ឋុជ្ជុបញ្ញោ អវិកលវីរិយោ ភោគវា សំវិភាគី

តិក្ខោ សូរោ ធិតត្តោ សបរហិតចរោ ទីឃជីវី អរោគោ

ធញ្ញោ វណ្ណោ យសស្សី អតិពលវធរោ កិត្តិមា ខន្តុបេតោ ។

*ដោយបុណ្យដែលកើតពីការនមស្ការនោះ សូមឲ្យខ្ញុំជាអ្នកមាន*
*បញ្ញាសុខុម មានសតិ រីករាយក្នុងសម្បរាយភព ជាមនុស្ស*
*ឈ្លាស ជាមនុស្សត្រង់ មានសម្មាទិដ្ឋិ មានសេចក្ដីព្យាយាម*
*មិនរួញរា ជាមនុស្សមានភោគសម្បត្តិ ជាមនុស្សចែករំលែក*
*ជាមនុស្សមានបញ្ញាចាស់ក្លា ជាមនុស្សក្លាហាន ជាមនុស្ស*

## ២២០

មានចិត្តរឹងមាំ ប្រព្រឹត្តប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ
មានអាយុវែង មិនមានរោគ មានបុណ្យ មានសម្បុរល្អ មាន
យស មានកម្លាំងពលំ មានកិត្តិស័ព្ទ មានសេចក្តីអត់ធន់ ។

សទ្ធោ ទាតង្គុបេតោ បរមសិរិធរោ ទិដ្ឋធម្មោ វិរត្តោ

លទ្ធី កល្យាណមិត្តោ អភិរតកុសលោ បញ្ចសីលាទិរក្ខោ

អប្បិច្ឆោ អប្បកោធោ អតិវុជុហាទយោ ឥទ្ធិមា អប្បមេយ្យោ

ចាសំសោ បេមវាចោ សុជនគុណវិទូ មាមកោ សោ ភវេយ្យំ។

ជាមនុស្សមានសទ្ធា សម្បូរណ៍ដោយទ្រព្យសម្បត្តិ សម្រាប់ឲ្យ
ជាទាន មានសិរីខ្ពង់ខ្ពស់ ត្រេកអរក្នុងទិដ្ឋធម៌ ជាមនុស្សលដ្ឋី
មានកល្យាណមិត្រ ត្រេកអរក្រៃលែងក្នុងកុសលធម៌ អាចរក្សា
សីល ៥ បាន ជាមនុស្សប្រាថ្នាតិច មានសេចក្តីក្រោធតិច មាន
ចិត្តទៀងត្រង់ក្រៃលែង មានឫទ្ធិ មានគុណរកប្រមាណមិនបាន
ជាអ្នកគួរសរសើរ ពោលបិយវាចា ដឹងគុណរបស់មនុស្សល្អ
ជាអ្នកគោរពរាប់កាន់ព្រះពុទ្ធសាសនា ។

# មន្តសៃយសាស្ត្រ
## តាមបែបព្រះពុទ្ធសាសនាសុទ្ធសាធ

### *ព្យញ្ជនៈនិងលេខខ្មែរ*

**នមោ ពុទ្ធាយ សិទ្ធំ** ៚

**អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ អាំ អះ ៗ**

**ក ខ គ ឃ ង　　ច ឆ ជ ឈ ញ　　ដ ឋ ឌ ឍ ណ**

**ត ថ ទ ធ ន　　ប ផ ព ភ ម　　យ រ ល វ ស (ឝ ឞ)**

**ហ ឡ អំ ៗ**

*ស្រៈពេញតួមាន ១៤ តួគឺ*

**អអា ឥឦ ឧឩ ឫឬ ឭឮ ឯឰ ឱឳ ៗ**

*ស្រៈផ្សំ*

**អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ អោ អៅ អុំ អំ អាំ អះ ៗ**

*ស្រៈនិស្ស័យមាន ២១ តួ គឺ*

I ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ុះ ៗ

*លេខ*

**០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩**

0 Λ I M V ४ \ N / ∠

*ស្រៈក្នុងភាសាបាលី មាន ៨ តួ គឺ*

**អ អា ឥ ឦ ឧ ឩ, ឯ ឱ ៗ**

*ព្យញ្ជនៈក្នុងភាសាបាលីមាន ៣៣ តួ គឺ*

**ក ខ គ ឃ ង　　ច ឆ ជ ឈ ញ　　ដ ឋ ឌ ឍ ណ**

**ត ថ ទ ធ ន　　ប ផ ព ភ ម**

**យ រ ល វ ស[១] ហ ឡ អំ ៗ**

---

១ ក្នុងសំស្ក្រឹតមានអក្សរ "ស" នេះពីរទៀត (គ, ម) អានថា សូរសំឡេងថា "ស" ដែរ ។

## បន្ទាប់ពីបទនមស្ការព្រះរតនត្រ័យរួច ក៏គួរថ្វាយបង្គំគ្រូបាអាចារ្យ

◎ *ឱម គរុទេវំ នមាមិ  ខ្ញុំសូមលើកអញ្ជលី ហត្ថទាំងពីរផ្គងលើសិរសា គោរពបូជាគ្រូបាអាចារ្យទាំងគ្រូព្រេងព្រឹទ្ធ រហូតបច្ចុប្បន្ន គ្រូលេខ គ្រូយន្ត គ្រូវ៉ានគ្រូថ្នាំ គ្រូតម្រាប់គ្រូតម្រា គ្រូវេទមន្ត អាគមគាថា គ្រូនមោ* **ក ខ** *និង* **ក កា** *គ្រូអក្សរខមចមសព្វគ្រប់ ដែលខ្ញុំបានរៀនសូធ្យមក ខ្ញុំសូមអញ្ជើញគ្រូបាអាចារ្យទាំងនោះ មកជំនុំប្រជុំគ្នា ក្នុងស្ថានមណ្ឌលនេះ ។ ខ្ញុំសូមបូជាថ្វាយនូវគ្រឿងសក្ការៈទាំងឡាយ ដល់គ្រូបាអាចារ្យ សូមទទួលយកដោយក្ដីមេត្តា ពីខ្ញុំនេះណាតាមបំណងហោង ។*

**◎ វន្ទិត្វា សុគតំ នាថំ ពុទ្ធញ្ញូ ធម្មញ្ញូ សង្ឃញ្ញូ នមោ ពុទ្ធាយ សាធុកំ និព្វមន្តំ បវក្ខាមិ យថាពលំ បញ្ញូ អក្ខរានិ ជាតា នមោ ពុទ្ធាយ ៕**

**◎ នមស្សិត្វា ឥសិសិទ្ធិលោកនាថំ អនុត្តរំ ឥសិសិទ្ធិ ច ពន្ធនំសាត្រា អហំ វន្ទាមិ តំ ឥសិសិទ្ធិវេស្ស ៕**

**◎ វន្ទិត្វា អាចរិយំ គរុបាទំ អន្តរាយំ វិនស្សន្តិ សព្វកម្មំ ប្រសិទ្ធិ មេ ៕**

**◎ មអឧ អាទិកមូលំ ត្រីទេវានំ មហាសាត្រា ឧឧអអ មម មន្ត្រា ឧអស្វា មហាមន្តំ មអឧ លោបកេញ្ញយ្យំ អក្ខារសេវរាជិនោ ត្រីនិអក្ខរានិ ជាតានិ ឧណាលោមា បន ជាយតេ នមោ ពុទ្ធាយ សត្ថុនោ ៕**

**◎អក្ខារពិន្ទុនាថំ ឧប្បន្នានំ ព្រហ្មាសហម្បតិនាម អាទិកប្បេ សុអាគតោ បញ្ញបទុមំ និស្វា បញ្ញូ ពុទ្ធេ នមាមិហំ ៕ នមោ ពុទ្ធាយ វន្ទនំ**

**នការោ កកុសន្ធោ មោការោ កោណាគមនោ ពុទការោ កស្សបោ ពុទ្ធោ ធាការោ គោតមោ ពុទ្ធោ យការោ អរិយមេត្តេយ្យោ បញ្ញូ ពុទ្ធេ នមាមិហំ ។**

**ន ◎ នរានរហិតំ ទេវំ　　　នរទេវេហិ បូជិតំ**
**នរានំ កាមបង្កេហិ　　　នមាមិ សុគតំ ជិនំ ៕**

**មោ◎ មោហមានំ បជិច្ឆន្នំ　　　មោហមត្តំ បកាសិតំ**
**មោហសព្វញ្ញុតញ្ញាណំ　　　មោហជិតំ នមាមិហំ ៕**

**ពុទ◎ ពុទ្ធោពុទ្ធានំ ពុទ្ធតំ　　　ពុទ្ធញ្ញូ ពុទ្ធភាសិតំ**
**ពុទ្ធតំ សមនុប្បត្តោ　　　ពុទ្ធជោតំ នមាមិហំ ៕**

**ធា ◎ ធាតានំ សព្វធម្មានំ　　　ធាតុត្ថតំ បកាសិតំ**
**ធាតានំ សគ្គនិព្វានំ　　　ធាតុត្ថតំ នមាមិហំ ៕**

**យ ◎ យត្ថ វេទង្គមច្ចុប　　　យត្ថ ធម្មាសមូថសា**
**យត្ថ សង្ខ្យាអនុប្បត្តោ　　　យត្ថ តិណ្ណំ នមាមិហំ ៕**

◎ មអឧ លក្ខណជាតំ មការោ ពុទ្ធលក្ខណំ អការោ ធម្មលក្ខណំ ឧការោ សង្ឃលក្ខណំ ឥច្ចេតំ រតនត្តយំ ។

◎ ធម្មចិរោ ធម្មការោ ធម្មគរុ តថាគតោ
ធម្មទស្សី ធម្មរាជា ធម្មសាមី ច តេ នមោ ។

◎ អរហំ បូជាសក្ការំ អរហោ បាបំ អកាយេ
អរហត្តផលប្បត្តោ អរហោ នាម ច តេ នមោ ។

◎ ឧត្តមោ ចតុរោ ពុទ្ធោ ឧត្តមធម្មទេសយិ
ឧត្តមមោក្ខតទេហំ ឧត្តមំ តំ នមាមិហំ ។

◎ សិរោ[១] មេ ពុទ្ធវរោ សេដ្ឋោ នលាដេ ធម្មមុត្តមោ
តីសបារមិយោ បិដ្ឋេ ទ្វេ អំសេ អគ្គសាវកា
ព្រះពុទ្ធគុណំ ព្រះធម្មគុណំ ព្រះសង្ឃគុណំ បុមុតុយុ
សព្វេ ពុទ្ធេ នមាមិហំ ជយសោត្ថី ភវន្តុ មេ ។

◎ ឥមេសំ ទេវតានំ អានុភាវេន ឥមេសំ ឥន្ទានំ អានុភាវេន ឥមេសំ ព្រហ្មានំ អានុភាវេន ពុទ្ធានំ អានុភាវេន ធម្មានំ អានុភាវេន សង្ឃានំ អានុភាវេន ជយមង្គលំ ឥមេសុ ស្វាហាយ ។

◎ ពុទ្ធាយ ធម្មាយ សង្ឃាយ សហស្សកោដិទេវព្រហ្មទេវតា មំ រក្ខន្តុ សព្វទា ។

---

[១] *មន្តគាថានេះមានឈ្មោះថា មន្តព្រះស្រីរតនត្រ័យ មានពីរប្រភេទ គឺបាលីបែបនេះមួយ និងមួយជាបាលីលាយដោយសំស្ក្រឹត លាយសំយោគជាមួយសាសនាព្រាហ្មណ៍ ។ យើងជាពុទ្ធសាសនិក មិនគួរសូធ្យបូជាដល់មេអាទិទេព ដែលជាពាហិរសាសនានោះទេ ។ មន្តលាយគ្នានេះ គឺ*

*សិរោ មេ ពុទ្ធទេវញ្ច នលាដេ ព្រហ្មទេវតា*
*ហទយំ នារាយកញ្ចេវ ទ្វេ ហត្ថេ ច បរមេសុរា*
*បាទេ វិណ្ហុកញ្ចេវ សព្វកម្មំ ប្រសិទ្ធិ មេ ។*
*យើងខ្ញុំសូមថ្វាយបង្គំ សូមព្រះពុទ្ធមកស្ថិតនៅលើក្បាល*
*សូមព្រះព្រហ្ម មកស្ថិតឰដ៏ថ្ងាស សូមព្រះនារាយណ៍ មកស្ថិតឰដ៏ដួងហឫទ័យ*
*សូមព្រះបរមេសូរ គឺព្រះសិវៈ មកស្ថិតឰដ៏ដៃ សូមព្រះពិស្ណុការ គឺវេស្សុកម្មទេវបុត្រ មកស្ថិតឰដ៏ជើង ទើបអញស្វាធ្យាយព្រះទិព្វមន្ត ឲ្យសម្រេចសារពើទាំងពួង ។*

ពុទ្ធំ ប្រសិទ្ធិ មេ ធម្មំ ប្រសិទ្ធិ មេ សង្ឃំ ប្រសិទ្ធិ មេ សិទ្ធិវាចា មហាយសំ សិទ្ធិតេជា មហាយតំ ពុទ្ធំ សច្ចំ ធម្មំ សច្ចំ សង្ឃំ សច្ចំ សិទ្ធិវន្ទា នមាមិហំ ។

សិទ្ធិពុទ្ធោ សិទ្ធិធម្មោ      សិទ្ធិសង្ឃោ គមុត្តមោ
សិទ្ធិឥសីមុនីទេវា      សិទ្ធិមន្តំ នមាមិហំ ។
សិទ្ធិកិច្ចំ សិទ្ធិកម្មំ      សិទ្ធិការិយតថាគតោ
សិទ្ធិតេជោ ជយោ និច្ចំ      សិទ្ធិលាភោ និរន្តរំ
សព្វកម្មំ ប្រសិទ្ធិ មេ      សព្វសិទ្ធិ ភវតុ មេ ។

## រតនមាលា កម្រងព្រះពុទ្ធ ២៨ ព្រះអង្គ

| | | | |
|---|---|---|---|
| ន | ◎ | នរានរហិតំ ទេវំ | នរទេវេហិ បូជិតំ |
| | | នរានំ កាមបង្កេហិ | នមាមិ សុគតំ ជិនំ ៕ |
| មោ | ◎ | មោហមានំ បដិច្ឆន្នំ | មោហមគ្គំ បកាសិតំ |
| | | មោហសព្វញ្ញុតញ្ញាណំ | មោហជិតំ នមាមិហំ ៕ |
| ពុទ | ◎ | ពុទ្ធោ ពុទ្ធាន ពុទ្ធតំ | ពុទ្ធញ្ញូ ពុទ្ធភាសិតំ |
| | | ពុទ្ធតំ សមនុប្បត្តោ | ពុទ្ធជោតំ នមាមិហំ ៕ |
| ធា | ◎ | ធាតានំ សព្វធម្មានំ | ធាតុត្ថូតំ បកាសិតំ |
| | | ធាតានំ សគ្គនិព្វានំ | ធាតុត្ថូតំ នមាមិហំ ៕ |
| យ | ◎ | យត្ថទុទចតិសម្ពុទ្ធា | យត្ថ ធម្មា សមុទជលា |
| | | យត្ថ សង្ឃា អនុប្បត្តា | យត្ថ តិណ្ណំ នមាមិហំ៕ |
| សិទ | ◎ | សិទ្ធកិច្ចំ សិទ្ធកម្មំ | សិទ្ធិការំ តថាគតោ |
| | | សិទ្ធកព្វេវ សម្ភារំ | សិទ្ធិកិច្ចំ នមាមិហំ ៕ |
| ធំ | ◎ | ធម្មដ្ឋិតោ ធម្មគរុ | ធម្មធម្មោ តថាគតោ |
| | | ធម្មទស្សី ធម្មធរោ | ធម្មសាមិ ច តេ នមោ៕ |
| អ | ◎ | អរហំ បូជាសក្ការំ | អរហោឃាបការយេ |
| | | អរហត្តផលប្បត្តោ | អរហោ នាម ច នមោ៕ |
| អា | ◎ | អាគមោញ្ញាណសីលេន | អាគមោនេកធម្មាយវា |
| | | អាគមោមេត្តុក្ខោ ច | អាធិដ្ឋានញ្ញូ អាគមោ៕ |
| ឥ | ◎ | ឥទ្ធិវិកុព្វកត្តារោ | ឥទ្ធិការោ បកាសិតោ |
| | | ឥទ្ធីរិទ្ធិករោ ករោ | ឥទ្ធិការំ នមាមិហំ ៕ |

ឦ ◎ ឦទិសំ ពុទ្ធវចនំ ឦទិសំ ធម្មមុត្តមំ

ឦទិសំ សគ្គមោក្ខញ្ញូ ឦទិសន្តំ នមាមិហំ ៗ

ឧ ◎ ឧត្តរោ ចតុរោ ពុទ្ធោ ឧត្តរោ ធម្មទេសយិ

ឧត្តរោ សគ្គមោក្ខញ្ញូ ឧត្តមន្តំ នមាមិហំ ៗ

ឩ ◎ ឩនតោ រាគទោសញ្ញូ ឩនតោ រាគមោហកំ

ឩនតោ ទិដ្ឋិជាលញ្ញូ ឩនតន្តំ នមាមិហំ ៗ

ឯ ◎ ឯសតិ សព្វពុទ្ធានំ ឯសតិ ធម្មមុត្តមំ

ឯសតិ សគ្គមោក្ខញ្ញូ ឯសសន្តំ នមាមិហំ ៗ

ឰ ◎ ឰយោគេ នាគសុបណ្ណានំ ឰយោគេនឧរក្ខិតំ

ឰយោគេន ជិតមារំ ឰយទិដ្ឋី នមាមិហំ ៗ

ឱ ◎ ឱហិតោ សព្វកិលេសំ ឱហិតោ ច សព្វមលំ

ឱហិតោ សព្វទិដ្ឋិញ្ញូ ឱហិចិត្តំ នមាមិហំ ៗ

ឳ ◎ ឳវហយោ លោកសម្ពុតោ ឳវហយោ ជេដ្ឋកាជិនោ

ឳវហយោ ពុទ្ធសេដ្ឋោ ច ឳវហយោតំ នមាមិហំៗ

អំ ◎ អគ្គសម្បន្នោ ពុទ្ធោ ច អគ្គយុកោសុទេសិតោ

អគ្គសេដ្ឋោ ច បវរោ អគ្គកតំ នមាមិហំ ៗ

អ ◎ អតីតានាគតជោតិ អធិកំ ធម្មមុត្តមំ

អទិដ្ឋធម្មរសញ្ញូ អតុទ្ធានញ្ញូ គោចរំ

ក ◎ ករោ ករធិរោ ករោ ករាកំ ហិតង្ករោ

ករាកំ ករោករោ តណ្ហង្ករំ នមាមិហំ ៗ

ខ ◎ ខរាខរខីរខណោ ខរាខំ ខណោ បត្តោ

ខរាខំ ករេ មេធំ មេធង្ករំ នមាមិហំ ៗ

គ ◎ គកាគរគីមគ្គ គរិគរគុគរូ
គរិគរគាគំ នមាមិ សរណំ គរំ ៗ
ឃ ◎ ឃរឃរឃនឃដិ ឃរឃុរឃដីឃដិ
ឃរាឃរឃេទីបំ បទីបង្កំ នមាមិហំ ៗ
ខ ◎ ខរាខំ ខុត្តង្ករោ ខរខរនិពិន្ទកោ
ខរាខរនិពកោណ្ឌំ កោណ្ឌញ្ញំ បនាមិហំ ៗ
ឆ ◎ ឆន្នាឆន្នំ ឆិរាឆេរំ ឆន្នាឆន្ទវរាវរា
ឆន្នាឆន្ទវរំវរំ នមាមិ សុមនំ ពុទ្ធំ ៗ
ជ ◎ ជរាជរជិនោជិនោ ជរាជរជិនុត្តមោ
ជរាជរជិនោមោចំ នមាមិ ពុទ្ធរេវតំ ៗ
ឈ ◎ ឈណាឈានរតោ ជិនោ ឈណាឈានករោករោ
ឈណាឈានករំ សុតំ នមាមិ ពុទ្ធសោភិតំ ៗ
ញ ◎ ញាណាញាណេសុ កុសលោ ញាណាញាណេសុឃាកតោ
ញាណាញាណេសុ សុតំ កម្ពុំ នមាមិ អនោមទស្សិំ
ដ ◎ ដដាដដេសុ វិនយោ ដដាដដេសុ កោវិទោ
ដដាដដេសុតំ កម្ពុំ នមាមិ បទុមំ ជិនំ ៗ
ឋ ◎ ឋឋាគតេ ឋឋាឋិតោ ឋឋាមគ្គោឋឋាវរោ
ឋប្បដ្ឋានឋីរំវរំ នមាមិ នារទំ ជិនំ ៗ
ឌ ◎ ឌរាឌរធិរោធិរោ ឌរាឌរហិតោហិតោ
ឌរាឌរំករត្តំ នមាមិ បទុមុត្តរំ ៗ
ឍ ◎ ឍធាឍធំអគ្គោនគ្គោ ឍធាឍធរនោរនោ
ឍធាឍធធរជ នមាមិ សុមេធំ ជិនំ ៗ

| | | | |
|---|---|---|---|
| ណ | ◎ | ណាមមាណោបិតោធីរោ | ណាមជេយ្យោ សុមេធសោ |
| | | ណាមមោចេតិសំសារំ | ណាមាមិ សុជាតំ ជិនំ២ |
| ត | ◎ | តរតរតរន្តោសោ | តរមានោតរោតរោ |
| | | តរន្តរតរប្បាយំ | បិយទស្សី នមាមិហំ២ |
| ថ | ◎ | ថប្បមានោ ថិតោ ឥន្ទោ | ថប្បមានោ ថិតោថិតោ |
| | | ថប្បមានំ ករំ សុតំ | អត្ថទស្សី នមាមិហំ ២ |
| ទ | ◎ | ទទមានោ ថិតោ ឥន្ទោ | ទទមាទា អសេសតោ |
| | | ទទមានំ សុតំ បុញ្ញំ | ធម្មទស្សី នមាមិហំ ២ |
| ធ | ◎ | ធរាធរធរាធរោ | ធរធរំ ធិរោធិរោ |
| | | ធរាធរំធុរំធីរំ | សិទ្ធត្ថញ្ច នមាមិហំ ២ |
| ន | ◎ | នរានរត្ថញ្ញាណំ | នរានរត្ថហិតំ |
| | | នរានរត្ថខេមំ | តិស្សជិនន្នមាមិហំ ២ |
| ប | ◎ | បទាបទេសុ បជន្តោ | បទាបទេសុ ឃាកតោ |
| | | បទាបទេសុ ជេតុម្បិ | បុស្សជិនន្នមាមិហំ ២ |
| ផ | ◎ | ផលាផលេសុ កម្មេសុ | ផលាផលេសុ ពោធីសុ |
| | | ផលាផលកត្តំការំ | វិបស្សិញ្ច នមាមិហំ ២ |
| ព | ◎ | ពណ្ណាពណ្ណេសុ ពន្ធន្តោ | ពណ្ណាពណ្ណេសុ ពន្ធកោ |
| | | ពណ្ណាពណ្ណេ សុតំ បុញ្ញំ | ពុទ្ធសិខិន្នមាមិហំ ២ |
| ភ | ◎ | ភវាភវេសុ លភន្តោ | ភវាភវេសុ កុសលោ |
| | | ភវាភវេសុ ឆេកម្បិ | វេស្សភុញ្ច នមាមិហំ២ |
| ម | ◎ | មន្តាមន្តេ សុទ្ធោមទ្ធោ | មន្ទមានោ មនោមនោ |
| | | មនុញ្ញកាសមានម្បិ | កកុសន្ធន្នមាមិហំ ២ |

| | | | |
|---|---|---|---|
| យ | ◎ | យត្ថយត្ថគតោធិរោ | យត្ថយត្ថគតោសុភោ |
| | | យត្ថយត្ថគតោញាណំ | កោណាគមនន្ទមាមិហំៗ |
| រ | ◎ | រត្នារត្នំ ករោករោ | រត្នារត្នំ ករោជិនោ |
| | | រត្នារត្នំករវំ | នមាមិ កស្សបជិនំ ៗ |
| ល | ◎ | លក្ខាលក្ខំលិតោលិនោ | លក្ខាលក្ខំលយាលយោ |
| | | លក្ខាលក្ខំតរំវរំ | នមាមិ គោតមំ ជិនំ ៗ |
| វ | ◎ | វជ្ជាវជ្ជំ គតោ ធីរោ | វទ្ធាវទ្ធវិរោវិនោ |
| | | វនវនំ តុវតុវំ | នមាមិ វនត្តំ ជិនំ ៗ |
| ស | ◎ | សន្តាសន្តោកោសការោ | សន្តោសន្តធិរោសន្តោ |
| | | សន្តោសការណធីរំ | នមាមិ សុគតំ ជិនំ ៗ |
| ហ | ◎ | ហរាហរំហរោហរោ | ហរាហរីហិរោហិរោ |
| | | ហរាហរហរំហរំ | នមាមិ ហរន្តំ ជិនំ ៗ |
| ឡ | ◎ | ឡនាឡនិឡនំឡនំ | ឡនាឡនំ ករោញាណំ |
| | | ឡនាឡនិឡនំឡនំ | នមាមិ ឡនន្តំ ជិនំ ៗ |
| អំ | ◎ | អម្ពាកំ ពុទ្ធវចនំ | អម្ពាកំ ធម្មមុត្តមំ |
| | | អម្ពាកំ សត្ថមោក្ខញូ | នមាមិ អរហំ ជិនំ ៗ |

# មន្តការពារភយន្តរាយ

**សិរស្មឹ មេ ពុទ្ធសេដ្ឋោ សារិបុត្តោ ច ទក្ខិណោ**

**វាមអំសេ មោគ្គល្លានោ បុរតោ បិដកត្តយំ ។**

*សូមអាពធនាព្រះពុទ្ធដ៏ប្រសើរតាំងលើសិរសានៃខ្ញុំ*
*ព្រះសារីបុត្រស្ថិតនៅខាងស្តាំ ព្រះមោគ្គល្លានស្ថិតនៅ*
*ខាងឆ្វេង ព្រះត្រៃបិដកស្ថិតនៅខាងមុខ ។*

**បច្ឆិមេ មម អានន្ទោ ចតុទិសា ខីណាសវា**

**សមន្តា លោកបាលា ច ឥន្ទា ទេវា សព្រហ្មកា ។**

*ព្រះអានន្ទស្ថិតនៅខាងក្រោយ ព្រះខីណាស្រពក្នុងទិស ទាំងបួន*
*លោកបាលមហារាជ ព្រះឥន្ទ ពួកទេវតា និងព្រះព្រហ្ម ស្ថិតនៅជុំវិញ ។*

**ឯតេសំ អានុភាវេន សព្វេ ភយា ឧបទ្ទវា**

**អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។**

*ដោយគុណានុភាពទាំងនុ៎ះ សូមភ័យនិងឧបទ្រពទាំងឡាយ ទាំងពួង*
*ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសបាត់ទៅ*
*កុំបីមានសេសសល់ឡើយ ។*

## ចុទ្ទសមគាថា (បជោតា ១៤ បជ)

### ១.អទ្ធរាម បបមគាថា

បជោតា ជម្មភា ហោតុ　ជោតិវហេ សតាវហោ
តាវិយោ សុវតាភា-　ជហេ　យោគោ ច សុសម្មា ។

តតោ សង្ឃរតនំ អនុស្សរិត្វា អត្តាយ ហិតាយ សុខាយ ទេវមនុស្សានំ, សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ, ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ, ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ, សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា, ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។ ឯតេន សច្ចវជ្ជេន ហោតុ មេ សោត្ថិមង្គលំ។

ភេសជ្ជំ ទេវមនុស្សានំ    កដុកំ តិត្តិការសំ
អម្ពិលំ លវណាញ្ចេវ    សព្វព្យាធី វិនស្សតិ ។
ឯកទ្វិតិទិនំ វាបិ    បញ្ចសត្តទិនំ តថា

យាវ ទុក្ខា ន សមេន្តិ ជីវទានំ ករោតុ តេ ។
ជីវទានំ ទទន្តស្ស អាយុំ វណ្ណំ សុខំ ពលំ
ជីវទានានុភាវេន ហោតុ ទេវោ សុខី សទា ។
ជីវទានំបិ ទត្វាន ឱសថំ ឧត្តមំ វរំ
សរីរទុក្ខំ នាសេតិ ភេសជ្ជំ ទានមុត្តមំ ។
តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។
ឥមិនា ជីវទានេន តុម្ហាកំ កឹ ភវិស្សតិ
ទីឃាយុកា សទា ហោន្តិ សុខិតា ហោន្តិ សព្វទា ។
ជីវទានំ ទទន្តស្ស អាយុំ វណ្ណំ សុខំ ពលំ
ទីឃាយុកា សទា ហោន្តុ ជីវទានំ មហប្ផលំ ។
យោ សោ ទទាតិ សក្កច្ចំ សីលវន្តេសុ តាទិសុ
បាណទានំ វរំ ទត្វា ជីវទានំ មហប្ផលំ ។
ឯវំ មហត្ថិកា ឯសា យទិទំ បុញ្ញសម្បទា
តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ។

២៨៨

តេន ពុទ្ធានុភាវេន　　តេន ធម្មានុភាវេន
តេន សង្ឃានុភាវេន　　សព្វទាទា វិនស្សន្តុ។
តេន ទានានុភាវេន　　តេន សីលានុភាវេន
តេន សច្ចានុភាវេន　　សព្វទាទា វិនស្សន្តុ។
ជីវទានានុភាវេន　　សព្វេ ឧប្បាតុបទ្ទវា
ទុក្ខរោគភយា ចាតិ　　វិនស្សន្តុ អសេសតោ។

# មហាមេត្តាចាប

មេត្តាសុត្តំ រតនញ្ច ខន្ធាដានាដិយំ តថា ធជគ្គំ អង្គុលិមាលញ្ច ទិសាបាលញ្ច សត្តមំ អដ្ឋវីសតិពុទ្ធបរិត្តញ្ច អដ្ឋមង្គលំ ។

*មេត្តាសូត្រ រតនបរិត្ត ខន្ធបរិត្ត អាដានាដិយបរិត្ត ធជគ្គបរិត្ត អង្គុលិមាលបរិត្ត ទិសាបាលបរិត្ត[1] បរិត្តនៃព្រះពុទ្ធម្ភៃប្រាំបីព្រះអង្គ[2] និងពុទ្ធជយមង្គល ៨ ប្រការ[3] ។* សេយ្យជីធំ ។ *តើមានប្រការដូចម្ដេចខ្លះ ។* ឯកាទសមាតិ

វុត្តំ មារវិជយញ្ច សាខញ្ច ធារណី គិរិមានន្ទំ មោគ្គល្លានញ្ច ចុន្ទញ្ច កស្សបំ មារាខុតថាយ ។ សុរិយំ ចន្ទញ្ចេវ ធន្ទគ្គំ វដ្ដជាតកំ រាហុលញ្ច បរិត្តានិ សិរសានិ ច លោកានញ្ច ហិតត្ថាយ អត្តនោ សាវកា ច មាតាបិតុស្ស *ព្រះបរិត្តទាំង ១១ គឺ*

*មារវិជយបរិត្ត សាខបរិត្ត ធារណបរិត្ត គិរិមានន្ទបរិត្ត មោគ្គល្លានបរិត្ត ចុន្ទបរិត្ត កស្សបបរិត្ត មារាខុបរិត្ត[4] សុរិយបរិត្ត ចន្ទិមបរិត្ត ធទ្ធគ្គបរិត្ត វដ្ដកបរិត្ត រាហុលបរិត្ត ព្រះបរិត្តដ៏កំពូល ដើម្បីសេចក្ដីចម្រើនដល់សត្វលោកផង ដល់សាវ័ករបស់ខ្លួនផង ដល់មាតាបិតាផង សព្វានិ*

---

*១មន្តឥតិបិសោ ៨ ទិស ។ ២ ធម៌ នមោ សព្វពុទ្ធានំ ។ ៣ ធម៌ពាហុំ ។ ៤ ប្រ័ហែលមន្តចំណាងព្រះឧបគុត្ត ។*

ចតុវីសានិ ពុទ្ធនេវ បកាសិតា អត្ថាយ ហិតាយ សុខាយ សព្វលោកស្សាតិ *ព្រះបរិត្តទាំង ២៤ នេះ ដែលព្រះពុទ្ធទ្រង់សម្តែងហើយ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់សត្វលោក។*

ឥមេ មាតាបិតរោ បរលោកំ គន្ត្វា ឥធ សាសនេ ឥមស្ស មាតាបិតុរស្ស អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ។

*មាតាបិតាទាំងឡាយ ដែលទៅកាន់បរលោកហើយក្តី ដែលមានជីវិតរស់នៅ ក្នុងសាសនានេះក្តី សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទទួលសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ ភគនិយា ញាតកា ពន្ធុកុលុបកសហាយកា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*ញាតិ ដែលជាបងប្អូន ផៅពង្សសន្តាន ជីតុន និងសម្លាញ់ទាំងឡាយ សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ រាជានោ ទេវាធិបតិទេវា សហ បុត្តទារា សហ អមច្ចា សហ បរិវារា ជនា សហ សេនាបតិ សហ ពលពាហនា សហ ទាសាទាសី ហត្ថីអស្សគោឈាមហឹសាទយោ អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ។

*ព្រះរាជាទាំងឡាយ ទេវាធិបតីទាំងឡាយ មួយអន្លើដោយបុត្រនិងភរិយា មួយអន្លើដោយអាមាត្យ មួយអន្លើដោយជនដែលជាបរិវារ មួយអន្លើដោយសេនាបតី មួយអន្លើដោយពលពាហនៈ មួយអន្លើដោយទាសាទាសី និងដំរី សេះ គោ ក្របីជាដើម សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមស្មឹ គាមេ វា រាជធានិយោ វា អរញ្ញេសុ វា សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*សត្វទាំងឡាយទាំងពួង ដែលនៅក្នុងស្រុកក្តី រាជធានីក្តី ព្រៃក្តី សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ មនុស្សា ច រត្តិន្ទិវញ្ច ឥត្ថី វា បុរិសោ វា កុមារោ វា កុមារី វា យេ ច ទហរា, យេ ច មជ្ឈិមបុរិសា, យេ ច វុឌ្ឍា, យេ ច ទលិទ្ទា, យេ ច សមិទ្ធា, យេ ច ពាលា, យេ ច បណ្ឌិតា, យេ ច សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ,សម្បត្តីហិ សមិជ្ឈន្តុ,សុខី អត្តានំ បរិហរន្តុ ។

*មនុស្សទាំងឡាយនេះ ទោះជាស្ត្រីក្តី បុរសក្តី កុមារក្តី កុមារីក្តី កម្លោះក្តី អ្នកកណ្តាលក្តី អ្នកមានក្តី អ្នកក្រក្តី អ្នកសម្រេចក្តី ពាលក្តី បណ្ឌិតក្តី*

*ម្យ៉ាងទៀត សត្វទាំងឡាយទាំងពួងឯណា សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅទាំងយប់ទាំងថ្ងៃ ។*

អយំ សុរិយោ ច, អយំ ចន្ទោ ច, ពរណោ ច, នាគោ ច, ភារទ្វាជោ ច, សុមនោ ច, សហាទេវា មហិទ្ធិកា មហានុភាវា ច, អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ។

*សុរិយទេពនេះ ចន្ទទេពនេះ ពរណទេពនេះ នាគទេពនេះ ភារទ្វាជទេពនេះ សុមនទេពនេះ សហទេពនេះ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តី ព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ ចាតុម្មហារាជិកាទេវា តាវត្តឹសាទេវា យាមាទេវា តុសិតាទេវា និម្មានរតិទេវា បរនិម្មិតវសវតិទេវា យាវ

ព្រហ្មលោកា ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភាកិណ្ហកា វេហប្ផលា អសញ្ញីសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋកា អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ មហាព្រហ្មសង្ខាតា បឋវិតលតោ យាវ ភវគ្គសមន្តតោ ច អវិជ្ជហិត្វា យាវ ចក្កវាឡបរិយន្តា ឥតរា សព្វេ សត្តា ឥមេ សត្តា អបាទា វា ទ្វិបាទា វា ចតុប្បាទា វា ពហុប្បាទា បក្ខិមេហិ វា ជលេហិ វា ថលេហិ វា អន្តលិក្ខេហិ វា តេ ច សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ,សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*ចាតុម្មហារាជិកាទេវតាទាំងឡាយ តាវត្តឹសទេវតាទាំងឡាយ យាមា ទេវតាទាំងឡាយ តុសិតទេវតាទាំងឡាយ និម្មានរតិទេវតាទាំងឡាយ បរិនិម្មិតវសវតិទេវតាទាំងឡាយ រហូតដល់ព្រហ្មលោក គឺព្រហ្មបារិសជ្ជា*

ទាំងឡាយ ព្រហ្មបុរោហិតាទាំងឡាយ មហាព្រហ្មាទាំងឡាយ ព្រហ្មបរិត្តាភាទាំងឡាយ ព្រហ្មអប្បមាណាភាទាំងឡាយ ព្រហ្មអាភស្សរាទាំងឡាយ ព្រហ្មបរិត្តសុភាទាំងឡាយ ព្រហ្មអប្បមាណសុភាទាំងឡាយ ព្រហ្មសុភាកិណ្ហកាទាំងឡាយ ព្រហ្មវេហប្ផលាទាំងឡាយ ព្រហ្មអសញ្ញីសត្វទាំងឡាយ ព្រហ្មអវិហាទាំងឡាយ ព្រហ្មអតប្បាទាំងឡាយ ព្រហ្មសុទស្សាទាំងឡាយ ព្រហ្មសុទស្សីទាំងឡាយ ព្រហ្មអកនិដ្ឋកៈទាំងឡាយ ព្រហ្មអាកាសានញ្ចាយតនៈទាំងឡាយ ព្រហ្មវិញ្ញាណញ្ចាយតនៈទាំងឡាយ ព្រហ្មអាកិញ្ចញ្ញាយនតៈទាំងឡាយ ព្រហ្មនេវសញ្ញានាសញ្ញាយតនៈទាំងឡាយ តាំងពីមហាព្រហ្មរហូតមកផ្ទៃផែនដី មិនលះបង់ដោយជុំវិញនៃភព រហូតទីបំផុតនៃចក្កវាឡ សត្វទាំងឡាយដែលនៅក្នុងភពដទៃក្តី សត្វទាំងឡាយទាំងពួង ដែលមិនមានជើងក្តី ជើងពីរក្តី ជើងបួនក្តី ជើងច្រើនក្តី សត្វស្ងាបក្តី សត្វគោកក្តី សត្វទឹកក្តី សត្វអាកាសក្តី សត្វទាំងឡាយទាំងពួងនោះ សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តី ព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។

ឥមេ និរយេ អដ្ឋ និរយេសុ សញ្ជីវេសុ កាលសុត្តេសុ សឹឃាដេសុ រោរុវេសុ មហារោរុវេសុ តាបនេសុ មហាតាបនេសុ អវីចីសុ មហាអវីចីសុ លោហកុម្ភីសុ មហាលោហកុម្ភីសុ

សិម្ពលិវុក្ខេ វា ខារនទិយំ វា អង្គារបព្វតេ វា អយកុម្ភេ វា ថុសេ វា សុក្ខេ វា យន្តបាសាណេ វា អយំ មហាបថវី យាវ សោឡសនិរយេសុ អដ្ឋ មហានិរយេសុ សព្វេ តេ និរយេសុ សត្តា លោកន្តរនិរយេសុ សត្តា កាយកម្មេន វា វចីកម្មេន វា មនោកម្មេន វា អមាតាបិតោ អលេណតោ អសរណតោ *សត្វទាំងឡាយទាំងពួង ដែលស្ថិត នៅក្នុងនរក ១៦ រណ្តៅ ក្នុងនរក ៨ រណ្តៅ និងក្នុងលោកន្តរនរក មាន សញ្ជីវនរក កាលសុត្តនរក សង្ឃាដនរក រោរុវនរក មហារោរុវនរក តាបន នរក មហាតាបននរក អវិចីនរក មហាអវិចីនរក លោហកុម្ភីនរក មហាលោហកុម្ភីនរក ដែលស្ថិតនៅដើមរកាក្តី ស្ទឹងដីប្រៃក្តី ភ្នំភ្លើងក្តី ដុំដែកក្តី អង្កាមក្តី ទីស្ងួតក្តី គ្រឿងយន្តថ្មក្តី ជាអ្នកមិនមានមាតាបិតា មិនមានទីពូន មិនមានទីពឹង ព្រោះកាយកម្ម វចីកម្ម និងមនោកម្មរបស់ខ្លួន* (*ដែលជាទុច្ចរិត*)

មម បុញ្ញានុភាវេន មម មេត្តានុភាវេន មម ករុណានុ–ភាវេន មម មុទិតានុភាវេន មម ឧបេក្ខានុភាវេន *ដោយអានុភាពនៃបុណ្យរបស់ខ្ញុំ ដោយអានុភាពនៃមេត្តារបស់ខ្ញុំ ដោយអានុភាពនៃករុណារបស់ខ្ញុំ ដោយអានុភាពនៃមុទិតារបស់ខ្ញុំ ដោយអានុភាពនៃឧបេក្ខារបស់ខ្ញុំ* សព្វេ តេ និរយកសត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា

ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*សត្វនរកទាំងឡាយទាំងពួងនោះ សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

**មហាមេត្តាចារោ និដ្ឋិតោ ។**

# មហាសមយសូត្រ

ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ; ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ អថ ខោ ចតុន្នំ សុទ្ធាវាសកាយិកានំ ទេវតានំ ឯតទហោសិ "អយំ ខោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ; ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ យន្នូន មយម្បិ យេន ភគវា តេនុបសង្កមេយ្យាម; ឧបសង្កមិត្វា ភគវតោ សន្តិកេ បច្ចេកំ គាថំ ភាសេយ្យាមា"តិ។

អថ ខោ តា ទេវតា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ, ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា ភគវតោ បុរតោ បាតុរហេសុំ។ អថ ខោ តា ទេវតា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ។ ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ :

មហាសមយោ បវនស្មឹ
ទេវកាយា សមាគតា
អាគតម្ហ ឥមំ ធម្មសមយំ
ទក្ខិតាយេ អបរាជិតសង្ឃ"ន្តិ។

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ :

២៩៩

“តត្រ ភិក្ខវោ សមាទហំសុ
ចិត្តមត្តនោ ឧជុកំ អកំសុ
សារថីវ នេត្តានិ គហេត្វា
ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតា”តិ។

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ :

“ឆេត្វា ខីលំ ឆេត្វា បលិឃំ
ឥន្ទខីលំ ឱហច្ច មនេជា
តេ ចរន្តិ សុទ្ធា វិមលា
ចក្ខុមតា សុទន្តា សុសុនាគា”តិ។

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ :

“យេកេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមិំ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តី”តិ។

## ទេវតាសន្និថាតា

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ “យេភុយ្យេន ភិក្ខវេ ទសសុ លោកធាតូសុ ទេវតា សន្និបតិតា ហោន្តិ, តថាគតំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ យេបិ តេ, ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា, តេសម្បិ ភគវន្តានំ ឯតំបរមាយេវ ទេវតា សន្និបតិតា អហេសុំ សេយ្យថាបិ មយ្ហំ ឯតរហិ។ យេបិ តេ, ភិក្ខវេ ភវិស្សន្តិ

អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា, តេសម្បិ ភគវន្តានំ ឯតំបរមាយេវ ទេវតា សន្និបតិតា ភវិស្សន្តិ សេយ្យថាបិ មយ្ហំ ឯតរហិ។ អាចិក្ខិស្សាមិ, ភិក្ខវេ ទេវកាយានំ នាមានិ; កិត្តយិស្សាមិ, ភិក្ខវេ ទេវកាយានំ នាមានិ; ទេសេស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ។ តំ សុណាថ, សាធុកំ មនសិករោថ, ភាសិស្សាមី”តិ។ “ឯវំ ភន្តេ”តិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ។

ភគវា ឯតទវោច :

“សិលោកមនុកស្សាមិ យត្ថ ភុម្មា តទស្សិតា
យេ សិតា គិរិគព្ភរំ បហិតត្តា សមាហិតា។
បុថូសីហាវ សល្លីនា លោមហំសាភិសម្ភុនោ
ឱទាតមនសា សុទ្ធា វិប្បសន្នមនាវិលា ។
ភិយ្យោ បញ្ចសតេ ញត្វា វនេ កាបិលវត្ថវេ
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ។
ទេវកាយា អភិក្កន្តា តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមករុំ សុត្វា ពុទ្ធស្ស សាសនំ។
តេសំ បាតុរហុ ញាណំ អមនុស្សានទស្សនំ
អប្បេកេ សតមទ្ទក្ខុំ សហស្សំ អថ សត្តរឹ។
សតំ ឯកេ សហស្សានំ អមនុស្សានមទ្ទសុំ
អប្បេកេនន្តមទ្ទក្ខុំ ទិសា សព្វា ផុដា អហុំ។
តញ្ច សព្វំ អភិញ្ញាយ វវត្ថិត្វាន ចក្ខុមា
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ។

“ទេវកាយា អភិក្កន្តា    តេ វិជានាថ ភិក្ខវោ
យេ វោហំ កិត្តយិស្សាមិ    គិរាហិ អនុបុព្វសោ។
“សត្តសហស្សា តេ យក្ខា    ភុម្មា កាបិលវត្ថវា
ឥទ្ធិមន្តោ ជុតិមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។
“ឆសហស្សា ហេមវតា    យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតីមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។
“សាតាគិរា តិសហស្សា    យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។
“ឥច្ចេតេ សោឡសសហស្សា    យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។
“វេស្សាមិត្តា បញ្ចសតា    យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។
“កុម្ភីរោ រាជគហិកោ    វេបុល្លស្ស និវេសនំ
ភិយ្យោ នំ សតសហស្សំ    យក្ខានំ បយិរុបាសតិ
កុម្ភីរោ រាជគហិកោ    សោបាគា សមិតឹ វនំ។

“បុរិមញ្ច ទិសំ រាជា ធតរដ្ឋោ បសាសតិ។
គន្ធព្វានំ អធិបតិ មហារាជា យសស្សិសោ។
“បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។
“ទក្ខិណញ្ច ទិសំ រាជា វិរូឡ្ហោ តំ បសាសតិ
កុម្ភណ្ឌានំ អធិបតិ មហារាជា យសស្សិសោ។
“បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។
“បច្ឆិមញ្ច ទិសំ រាជា វិរូបក្ខោ បសាសតិ
នាគានញ្ច អធិបតិ មហារាជា យសស្សិសោ។
“បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។
“ឧត្តរញ្ច ទិសំ រាជា កុវេរោ តំ បសាសតិ
យក្ខានញ្ច អធិបតិ មហារាជា យសស្សិសោ។
“បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។

"បុរិមំ ទិសំ ធតរដ្ឋោ ទក្ខិណេន វិរូឡ្ហកោ
បច្ឆិមេន វិរូបក្ខោ កុវេរោ ឧត្តរំ ទិសំ។
'ចត្តារោ តេ មហារាជា សមន្តា ចតុរោ ទិសា
ទទ្ទល្លមានា អដ្ឋំសុ វនេ កាបិលវត្ថវេ។
"តេសំ មាយាវិនោ ទាសា អាគុំ វញ្ចនិកា សឋា
មាយា កុដេណ្ឌុ វិដេណ្ឌុ វិដុច្ច វិដុដោ សហ។
"ចន្ទនោ កាមសេដ្ឋោ ច កិន្និឃណ្ឌុ និឃណ្ឌុ ច
បនាទោ ឱបមញ្ញោ ច ទេវសូតោ ច មាតលិ។
"ចិត្តសេនោ ច គន្ធព្វោ នឡោរាជា ជនេសភោ
អាគា បញ្ចសិខោ ចេវ តិម្ពរូ សូរិយវច្ចសា ។
"ឯតេ ចញ្ញេ ច រាជានោ គន្ធព្វា សហ រាជុភិ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។
"អថាគុំ នាភសា នាគា វេសាលា សហតច្ឆកា
កម្ពលស្សតរា អាគុំ បាយាគា សហ ញាតិភិ។
"យាមុនា ធតរដ្ឋា ច អាគូ នាគា យសស្សិនោ
ឯរាវណោ មហានាគោ សោបាគា សមិតឹ វនំ។

"យេ នាគរាជេ សហសា ហរន្តិ
ទិព្វា ទិជា បក្ខិ វិសុទ្ធចក្ខូ
វេហាយសា តេ វនមជ្ឈបត្តា
ចិត្រា សុបណ្ណា ឥតិ តេស នាមំ។

"អភយំ តទា នាគានមកាសិ
សុបណ្ណតោ ខេមមកាសិ ពុទ្ធោ
សណ្ហាហិ វាចាហិ ឧបវ្ហយន្តា
នាគា សុបណ្ណា សរណមកំសុ ពុទ្ធំ។

"ជិតា វជិរហត្ថេន  សមុទ្ទំ អសុរាសិតា។
ភាតរោ វាសវស្សេតេ  ឥទ្ធិមន្តោ យសស្សិនោ។
កាលកញ្ចា មហាភិស្មា  អសុរា ទានវេឃសា
វេបចិត្តិ សុចិត្តិ ច  បហារាទោ នមុចី សហ។
"សតញ្ច ពលិបុត្តានំ  សព្វេ វេរោចនាមកា
សន្នយ្ហិត្វា ពលិសេនំ  រាហុភទ្ទមុបាគមុំ
សមយោទានិ ភទ្ទន្តេ  ភិក្ខូនំ សមិតិំ វនំ។
"អាបោ ច ទេវា បថវី  តេជោ វាយោ តទាគមុំ
វរុណា វារណា ទេវា  សោមោ ច យសសា សហ។
មេត្តា ករុណា កាយិកា  អាគុំ ទេវា យសស្សិនោ
ទសេតេ ទសធា កាយា  សព្វេ នានត្តវណ្ណិនោ។
ឥទ្ធិមន្តោ ជុតិមន្តោ  វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ  ភិក្ខូនំ សមិតិំ វនំ។
"វេណ្ឌុទេវា សហលិ ច  អសមា ច ទុវេ យមា
ចន្ទស្សូបនិសា ទេវា  ចន្ទមាគុំ បុរក្ខត្វា។
"សូរិយស្សូបនិសា ទេវា  សូរិយមាគុំ បុរក្ខត្វា
នក្ខត្តានិ បុរក្ខត្វា  អាគុំ មន្ទវលាហកា។

‟វសូនំ វាសវោ សេដ្ឋោ សក្កោបាគា បុរិន្ទទោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ។
‟ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។
‟អថាគុំ សហភូ ទេវា ជលមគ្គិសិខារិវ
អរិដ្ឋកា ច រោជា ច ឧមាបុប្ផនិភាសិនោ។
‟វរុណា សហធម្មា ច អច្ចុតា ច អនេជកា
សូលេយ្យរុចិរា អាគុំ អាគុំ វាសវនេសិនោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ។
‟ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។
‟សមានា មហាសមនា មានុសា មានុសុត្តមា
ខិឌ្ឌាបទោសិកា អាគុំ អាគុំ មនោបទោសិកា។
‟អថាគុំ ហរយោ ទេវា យេ ច លោហិតវាសិនោ
បារគា មហាបារគា អាគុំ ទេវា យសស្សិនោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ។
‟ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។
‟សុក្កា ករម្ភា អរុណា អាគុំ វេឃនសា សហ
ឱទាតគយ្ហា បាមោក្ខា អាគុំ ទេវា វិចក្ខណា។

‘‘សទាមត្តា ហារគជា　　មិស្សកា ច យសស្សិនោ
ថនយំ អាគ បជ្ជុន្នោ　　យោ ទិសា អភិវស្សតិ។
‘‘ទសេតេ ទសធា កាយា　　សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ　　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　　ភិក្ខូនំ សមិតឹ វនំ។
‘‘ខេមិយា តុសិតា យាមា　　កដ្ឋកា ច យសស្សិនោ
លម្ពីតកា លាមសេដ្ឋា　　ជោតិនាមា ច អាសវា
និម្មានរតិនោ អាគុំ　　អថាគុំ បរនិម្មិតា។
‘‘ទសេតេ ទសធា កាយា　　សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ　　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　　ភិក្ខូនំ សមិតឹ វនំ។
‘‘សដ្ឋេតេ ទេវនិកាយា　　សព្វេ នានត្តវណ្ណិនោ
នាមន្វយេន អាគច្ឆុំ　　យេ ចញ្ញេ សទិសា សហ។
‘‘‘បវុដ្ឋជាតិមខិលំ　　ឱឃតិណ្ណមនាសវំ
ទក្ខេមោឃតរំ នាគំ　　ចន្ទំវ អសិតាតិគំ’។
‘‘សុព្រហ្មា បរមត្តោ ច　　បុត្តា ឥទ្ធិមតោ សហ
សនង្កុមារោ តិស្សោ ច　　សោធាគ សមិតឹ វនំ។
‘‘សហស្សំ ព្រហ្មលោកានំ　　មហាព្រហ្មាភិតិដ្ឋតិ
ឧបបន្នោ ជុតិមន្តោ　　ភិស្មាកាយោ យសស្សិសោ។
‘‘ទសេត្ថ ឥស្សរា អាគុំ　　បច្ចេកវសវត្តិនោ
តេសញ្ច មជ្ឈតោ អាគ　　ហារិតោ បរិវារិតោ។

“តេ ច សព្វេ អភិក្កន្តេ    សឥន្ទេ ទេវេ សព្រហ្មកេ
មារសេនា អភិក្កាមិ    បស្ស កណ្ហាស្ស មន្ទិយំ ។
“‘ឯថ គណ្ហថ ពន្ធថ    រាគេន ពទ្ធមត្ថុ វោ
សមន្តា បរិវារេថ    មា វោ មុញ្ចិត្ថ កោចិ នំ៍ ។
“ឥតិ តត្ថ មហាសេនោ    កណ្ហោ សេនំ អបេសយិ;
ចាណិនា តលមាហច្ច    សរំ កត្វាន ភេរវំ ។
“យថា ចាវុស្សកោ មេឃោ    ថនយន្តោ សវិជ្ជុកោ
តទា សោ បច្ចុទាវត្តិ    សង្កុទ្ធោ អសយំវសេ ។
តញ្ច សព្វំ អភិញ្ញាយ    វត្ថិត្វាន ចក្ខុមា
តតោ អាមន្តយី សត្ថា    សាវកេ សាសនេ រតេ ។
“មារសេនា អភិក្កន្តា    តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមករុំ    សុត្វា ពុទ្ធស្ស សាសនំ
វីតរាគេហិ បក្កាមុំ    នេសំ លោមាបិ ឥញ្ជយុំ ។
“‘សព្វេ វិជិតសង្គាមា    ភយាតីតា យសស្សិនោ
មោទន្តិ សហ ភូតេហិ    សាវកា តេ ជនេសុតា”តិ ។

មហាសមយសុត្តំ និដ្ឋិតំ សត្តមំ ។

# ឧប្បាតសន្តិ

*បទសូធ្យរម្ងាប់ឧត្បាត ឬរម្ងាប់ហេតុអន្តរាយ*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

គន្ថារម្ភ

[ក] សុទុទ្ទសោ អយំ ធម្មោ លោកត្ថំ ជិនទេសិតោ

មហាសន្តិករោ លោកេ សព្វសម្បត្តិទាយកោ ។

*ព្រះធម៌នេះ សត្វលោកឃើញបានដោយកម្រក្រៃលែង*
*ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដើម្បីប្រយោជន៍ដល់សត្វលោក*
*ជាធម៌ធ្វើនូវមហាសន្តិ គឺសេចក្ដីស្ងប់ដ៏ធំក្នុងលោក*
*ជាធម៌ឲ្យនូវសម្បត្តិទាំងពួង ។*

[១] សព្វុប្បាតូបសមណោ ភូតយក្ខនិវារណោ

អកាលមច្ចុសមណោ សោករោគវិនាសនោ ។

*ជាគ្រឿងរម្ងាប់ហេតុអន្តរាយទាំងពួង ជាគ្រឿងការពារ*
*ពីអមនុស្ស និងយក្ស ជាគ្រឿងផុតពីសេចក្ដីស្លាប់*
*មុនកាលវេលា ជាគ្រឿងកម្ចាត់នូវសោកនិងរោគភ័យ ។*

[គ] បរចក្កបមទ្ទនោ រញ្ញោ វិជយវឌ្ឍនោ

សព្វានិដ្ឋហរោ សន្តោ ធម្មំ វក្ខាមិ ភូតតោ ។

ជាគ្រឿងញាំញីនូវកម្លាំងរបស់សត្រូវ ជាគ្រឿងចម្រើននូវជ័យជម្នះដល់ព្រះរាជា ជាគ្រឿងនាំវត្ថុមិនជាទីប្រាថ្នាចេញ ជាធម៌ដ៏ប្រសើរ ខ្ញុំនឹងពោលនូវព្រះធម៌តាមសេចក្តីពិត ។

[ឃ] វត្ថុត្តយស្ស យោ យត្ថ  សំវណ្ណោតិ គុណាត្តមេ

តស្ស តត្ថ សុខារោគ្យ- សោត្ថិយោ ហោន្តិ សព្វទា ។

ខ្ញុំនឹងពណ៌នាព្រះរតនត្រ័យណា ព្រោះគុណដ៏កំពូលណា សេចក្តីសុខ ការមិនមានរោគ និងសេចក្តីសួស្តី រមែងមានគ្រប់កាល ព្រោះគុណដ៏កំពូលនោះ របស់ព្រះរតនត្រ័យអង្គនោះ ។

# ព្រះរតនត្រ័យ

*ព្រះពុទ្ធក្នុងអតីតៈ ២៧ ព្រះអង្គ*

## ក្នុងសារមណ្ឌកប្ប ៤ ព្រះអង្គ

[១] តណ្ហង្ករោ មហាវីរោ សព្វលោកានុកម្បកោ
វដ្ដសំសារគមនោ សព្វកាមទនោ សទា ។

*ព្រះតណ្ហង្ករសម្មាសម្ពុទ្ធ ព្រះអង្គជាមហាវីរៈ ទ្រង់អនុគ្រោះសត្វលោកទាំងពួង ទ្រង់លះនូវការត្រាច់ទៅក្នុងសង្សារវដ្ដបានហើយ សូមប្រទាននូវវត្ថុដែលគួរប្រាថ្នាទាំងពួងឲ្យ សព្វៗកាល ។*

[២] សព្វាភិភូ សព្វវិទូ សព្វទេវគរុត្តមោ
សព្វាសវបរិក្ខីណោ សទា សោត្ថិំ ករោតុ នោ ។

*ទ្រង់គ្របសង្កត់នូវធម៌ទាំងពួង ទ្រង់ដឹងច្បាស់នូវធម៌ទាំងពួង ទ្រង់ជាគ្រូដ៏កំពូលរបស់ទេវតាទាំងពួង ទ្រង់អស់អាសវៈទាំងពួងហើយ សូមប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៣] វរលក្ខណសម្បន្នោ មេធង្ករោ មហាមុនិ
ជុតិន្ធរោ មហាសិរី សុវណ្ណាភិរសន្និភោ ។

ព្រះមេធង្ករសម្មាសម្ពុទ្ធ ទ្រង់ដល់ព្រមហើយដោយ
លក្ខណៈដ៏ប្រសើរ ជាព្រះមហាមុនី ទ្រង់ទ្រទ្រង់នូវ
កាពរុងរឿង ទ្រង់មាននូវមហាសិរី ប្រៀបដូចជាក្តី
នៃមាស ។

[៤] ទិព្វរូបោ មហាកាយោ មហានាទោ មហព្ពលោ

មហាការុណិកោ សត្ថា មហាសន្តិ ករោតុ នោ ។

ទ្រង់ជាព្រះសាស្តាមានព្រះរូបដូចជាទិព្វ មានព្រះមហាកាយ
ដ៏ធំ ជាទីពឹងដ៏ធំក្រៃលែង មានកម្លាំងខ្លាំងក្លា និងទ្រង់
ប្រកបដោយមហាករុណា សូមធ្វើនូវមហាសន្តិ គឺសេចក្តី
ស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[៥] មហាមោហតមំ ហន្ត្វា យោ នាថោ សរណង្ករោ

ទេវាទេវមនុស្សានំ លោកានញ្ច ហិតង្ករោ ។

ព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះនាមសរណង្ករ ទ្រង់កម្ចាត់
នូវងងឹត គឺមោហៈដ៏ធំបានហើយ ជាទីពឹង ធ្វើនូវប្រយោជន៍
ដល់ទេវតា និងមិនមែនជាទេវតា ដល់មនុស្សនិងសត្វលោក
ទាំងឡាយ ។

[៦] ព្យាមប្បភាភិរុចិតោ និគ្រោធបរិមណ្ឌលោ

និគ្រោធបក្កពិម្ពោដ្ឋោ សទា សោត្ថឹ ករោតុ នោ ។

*ទ្រង់មានរស្មីមួយព្យាមដ៏រុងរឿង មានបរិមណ្ឌលដូចដើមនិគ្រោធ មានរីមព្រះឱស្ឋ ដូចផ្លែបាសទុំត្រង់ដើមនិគ្រោធ សូមព្រះសម្មាសម្ពុទ្ធអង្គនោះ ប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧] អសីតិរតនុព្វេធោ ទីបង្ករោ មហាមុនិ

បភា និទ្ធាវតេ តស្ស ឋានេ ទ្វាទស យោជនេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករ មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់ជាព្រះមហាមុនី មានរស្មីផ្សាយចេញទៅក្នុងទី ១២ យោជន៍ ។*

[៨] វស្សសតសហស្សានិ ឋត្វា លោកេ វិនាយកោ

លោកាលោកករោ សត្ថាសទា សោត្ថឹ ករោតុ នោ ។

*ទ្រង់មានព្រះជន្មនៅក្នុងលោក ១ សែនឆ្នាំ ទ្រង់ណែនាំសត្វលោក ទ្រង់ជាអ្នកធ្វើនូវពន្លឺដល់សត្វលោក ទ្រង់ជាព្រះសាស្តា សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារកប្ប ១ អង្គ

[៩] អដ្ឋាសីតិហត្ថុព្វេធោ កោណ្ឌញ្ញោ នាម នាយកោ

សព្វធម្មេហិ អសមោ សព្វចារមិតាគមោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមកោណ្ឌញ្ញៈ ទ្រង់កម្ពស់*

*៨៨ ហត្ថ ទ្រង់ជានាយក ទ្រង់ជាអ្នកមិនមានបុគ្គលណា*
*នីមួយស្មើដោយធម៌ទាំងពួង ទ្រង់ដល់ភាពជាអ្នកមាន*
*បារមីទាំងពួង ។*

[១០] វស្សសតសហស្សានិ អាយុ តស្ស មហេសិនោ
មោចេតុ សោ សព្វភយា សទា សោត្ថិំ ករោតុ នោ ។

*ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ*
*សូមព្រះអង្គញុំាងខ្ញុំទាំងឡាយ ឲ្យរួចផុតចាកភ័យទាំងពួង*
*សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងសារមណ្ឌកប្ប ៤ ព្រះអង្គ

[១១] អដ្ឋាសីតិរតនានិ អច្ចុគ្គតោ ជុតិន្ធរោ
មង្គលោ នាម សម្ពុទ្ធោ នវុតិសហស្សាយុកោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមមង្គលៈ ទ្រង់*
*កម្ពស់ ៨០ ហត្ថ ទ្រង់មានអានុភាពច្រើន មានព្រះជន្ម*
*៩ ម៉ឺនឆ្នាំ ។*

[១២] ចព្វណ្ណរំសិយោ ឧស សហស្សលោកធាតុយោ
ផរន្តា តស្ស ធាវន្តិ ឯស សោត្ថិំ ករោតុ នោ ។

*ឆព្វណ្ណរង្សីរបស់ព្រះអង្គ ផ្សាយទៅកាន់មួយម៉ឺនលោកធាតុ*
*សូមព្រះដ៏មានព្រះភាគអង្គនោះ ប្រទាននូវសួស្តីដល់ខ្ញុំ*
*ទាំងឡាយ សព្វៗកាល ។*

[១៣] នវុតិរតនុព្ពេធោ សុមនោ នាម នាយកោ

កញ្ចនាចលសង្កាសោ នវុតិសហស្សាយុកោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមសុមនៈ ទ្រង់កម្ពស់ ៩០ ហត្ថ ទ្រង់ជានាយក ទ្រង់ប្រៀបដូចជាភ្នំនៃមាស មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។*

[១៤] ឧបេតោ ពុទ្ធគុណេហិ សព្វសត្តហិតេសកោ

ករោតុ នោ មហាសន្តឹ អារោគ្យញ្ច សុខំ សទា ។

*ទ្រង់ប្រកបដោយព្រះពុទ្ធគុណទាំងឡាយ ទ្រង់ស្វែងរកនូវប្រយោជន៍ដល់សត្វលោកទាំងពួង សូមប្រទាននូវមហាសន្តិ គឺសេចក្តីស្ងប់ដ៏ធំក្រៃលែង ការមិនមានរោគ និងសេចក្តីសុខដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៥] អសីតិរតនុព្ពេធោ សដ្ឋីសហស្សអាយុកោ

រេវតោ នាម សម្ពុទ្ធោ សព្វលោកុត្តរោ មុនិ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គឯណា ព្រះនាមរេវតៈ ទ្រង់កម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះជន្ម ៦ ម៉ឺនឆ្នាំ ត្រាស់ដឹងដោយព្រះអង្គឯង ប្រសើរជាងសត្វលោកទាំងពួង ជាព្រះមហាមុនី ។*

[១៦] តស្ស សរីរេ និព្វត្តា បភាមាលា អនុត្តរា

ជរន្តា យោជនេ និច្ចំ សទា សោត្ថឹ ករោតុ នោ ។

*កម្រងរស្មីដ៏ប្រសើរខ្ពង់ខ្ពស់ ផ្សាយទៅក្នុង ១ យោជន៍ អស់កាលជានិច្ច ដែលកើតហើយក្នុងសរីរៈរបស់ព្រះអង្គ សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៧] សោភិតោ នាម សម្ពុទ្ធោ នវុតិសហស្សាយុកោ
សំសារសាគរេ សត្តេ ពហូ មោចេតិ ទុក្ខតោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមសោភិតៈ ទ្រង់មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ទ្រង់ញុំាងសត្វលោកជាច្រើន ឲ្យរួចចាកទុក្ខក្នុងសាគរ គឺសង្សារវដ្ត ។*

[១៨] អដ្ឋបញ្ញាសរតនំ អច្ចុគ្គតោ មហាមុនិ
ឱភាសេតិ ទិសា សព្វា សទា សោត្ថី ករោតុ នោ ។

*ទ្រង់កម្ពស់ ៥៨ ហត្ថ ជាព្រះមហាមុនី ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងវរកប្ប ៣ ព្រះអង្គ

[១៩] អនោមទស្សី សម្ពុទ្ធោ តេជសី ទុរតិក្កមោ
អដ្ឋបញ្ញាសរតនោ ឱភាសេន្តោ សទេវកេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមអនោមទស្សី ទ្រង់*

មានតេជះ ដែលអ្នកណានីមួយ មិនអាចកន្លងបាន ទ្រង់កម្ពស់ ៥៨ ហត្ថ ទ្រង់ញ៉ាំងមនុស្ស ព្រមទាំងទេវតា ឲ្យភ្ញាក់ស្វាង ។

[២០] និព្វានទាយកោ លោកេ  វស្សសតសហស្សាយុ
ករោតុ នោ មហាសន្តឹ  សុខិតា ច មយំ សទា ។

ទ្រង់រំលត់នូវបាបធម៌ហើយក្នុងលោក ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ សូមប្រទាននូវមហាសន្តិ គឺសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ និងខ្ញុំទាំងឡាយ ចូរជាអ្នកបាននូវសេចក្តីសុខ សព្វៗកាល ។

[២១] បទុមោ នាម សម្ពុទ្ធោ  លោកជេដ្ឋោ នរាសភោ
អដ្ឋបញ្ញាសរតនោ  អាទិច្ចោវ វិរោចតិ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមបទុមៈ ទ្រង់ជាចម្បងក្នុងលោក ជានរៈដ៏ប្រសើរ ទ្រង់កម្ពស់ ៥៨ ហត្ថ រុងរឿងដូចជាព្រះអាទិត្យ ។

[២២] វស្សសតសហស្សានិ  អាយុ តស្ស មហេសិនោ
សោបិ ពុទ្ធោ ការុណិកោ សទា សោត្ថឹ ករោតុ នោ ។

ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ ព្រះពុទ្ធជាម្ចាស់ សូម្បីអង្គនោះ ទ្រង់ប្រកបដោយករុណា សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៣] អដ្ឋាសីតិរតនុព្ពេធោ　　នារទោ សព្វកាមទោ
និរន្តរំ ទិវារត្តឹ　　យោជនំ ផរតេ បភា ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមនារទៈ ទ្រង់កម្ពស់ ៨៨ ហត្ថ ទ្រង់ប្រទាននូវវត្ថុដែលគួរពេញចិត្តទាំងពួង រស្មីរបស់ព្រះអង្គ ផ្សាយចេញទៅ ១ យោជន៍ទាំងថ្ងៃ ទាំងយប់ អស់កាលជានិច្ច ។*

[២៤] នវុតិវស្សសហស្សានិ　　ឋត្វា លោកេ វិនាយកោ
មោចេតិ ទុក្ខតោ សត្តេ　　សោបិ សោត្ថឹ ករោតុ នោ ។

*ទ្រង់ណែនាំសត្វលោក ទ្រទ្រង់ព្រះជន្មក្នុងលោក រហូត ៩ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងសត្វលោកទាំងឡាយឲ្យរួចផុតចាក ទុក្ខ សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ សូមប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ក្នុងសារកប្ប ១ ព្រះអង្គ**

[២៥] អដ្ឋបញ្ញាសរតនោ　　បទុមុត្តរោ មហាមុនិ
តស្ស ចាកតិនា រំសី　　ផរន្តិ ទ្វាទសយោជនេ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមបទុមុត្តរៈ ទ្រង់កម្ពស់ ៥៨ ហត្ថ ទ្រង់ជាមហាមុនី រស្មីមានដោយប្រក្រតីរបស់ ព្រះអង្គ ផ្សាយទៅក្នុងទី ១២ យោជន៍ ។*

[២៦] វស្សសតសហស្សានិ ឋត្វា លោកេមតន្ទទោ

មោចេតិ ពន្ធនា សត្តេ សោបិ ចាលេតុ នោ សទា។

*ទ្រង់ប្រទានអមតៈ គឺព្រះនិព្វាន ទ្រង់ទ្រទ្រង់ព្រះជន្មក្នុងលោក រហូត ១ សែនឆ្នាំ ទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យរួចផុតចាក កិលេសជាគ្រឿងចង សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ សូមប្រទាននូវការរក្សាដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

## ក្នុងមណ្ឌកប្ប ២ ព្រះអង្គ

[២៧] អដ្ឋាសីតិរតនានិ អច្ចុគ្គតោ មហាមុនិ

សុមេធោ នាម សម្ពុទ្ធោ នវុតិសហស្សាយុកោ ។

*ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមសុមេធៈ មានព្រះកាយ កម្ពស់៨៨ ហត្ថ ទ្រង់ជាមុនីដ៏ប្រសើរ មានព្រះជន្ម ៩ ម៉ឺនឆ្នាំ។*

[២៨] តស្ស ចាកតិកា រំសី ផរន្តិ យោជនំ សទា

ចាលេតុ នោ សទា ពុទ្ធោ ភយេហិ វិវិធេហិ ច ។

*ព្រះរស្មីមានតាមប្រក្រតីរបស់ព្រះអង្គ ផ្សាយទៅរហូត មួយម៉ឺនយោជន៍ សូមព្រះពុទ្ធជាម្ចាស់អង្គនោះ ធ្វើ នូវការរក្សាដល់ខ្ញុំទាំងឡាយ ឲ្យរួចផុតចាកភ័យវិបត្តិ មានប្រការផ្សេងៗ ។*

[២៩] បញ្ញាសរតនុព្វេធោ សុជាតោ នាម នាយកោ

ហេមវណ្ណោ មហាវីរោ មហាតមវិនោទនោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម សុជាតៈ មានព្រះកាយកម្ពស់ ៥០ ហត្ថ ទ្រង់មានព្រះឆវីវណ្ណដូចជាមាស ទ្រង់ក្លៀវក្លា យ៉ាងក្រៃលែង ទ្រង់បន្ទោបង់នូវងងឹតដ៏ធំ គឺមោហៈ ។*

[៣០] នវុតិវស្សសហស្សានិ អាយុ តស្ស មហេសិនោ
សោបិ ពុទ្ធោ ការុណិកោ សទា សោត្ថី ករោតុ នោ ។

*ទ្រង់មានព្រះជន្ម ៩ ម៉ឺនឆ្នាំ សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់មាននូវករុណា សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ក្នុងវរកប្ប ៣ ព្រះអង្គ

[៣១] អសីតិរតនុព្វេធោ បិយទស្សី មហាមុនិ
នវុតិវស្សសហស្សានិ ឋត្វា លោកគ្គនាយកោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម បិយទស្សី មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់ជាមុនីដ៏ប្រសើរ ទ្រង់ជានាយកដ៏កំពូលក្នុងលោក ទ្រង់មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។*

[៣២] សោបិ សព្វគុណូបេតោ សព្វលោកសុខប្បទោ
សព្វទោសំ វិនាសេន្តោ សព្វំ សោត្ថី ករោតុ នោ ។

*សូម្បីព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់ប្រកបដោយគុណទាំងពួង ប្រទាននូវសេចក្តីសុខដល់សត្វលោកទាំងមូល*

*ទ្រង់កម្ចាត់ទោសទាំងអស់ សូមប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៣៣] អសីតិរតនុព្វេធោ អត្ថទស្សី នរាសភោ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ នាយកោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម អត្ថទស្សី មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់ជានរៈដ៏ប្រសើរ ទ្រង់មានព្រះជន្មក្នុងលោក ១ សែនឆ្នាំ ។*

[៣៤] តស្ស ចាកតិកា រំសី ផរន្តិ យោជនំ សទា
និរន្តរំ ទិវារត្តឹ នាថោ សោត្ថឹ ករោតុ នោ ។

*ព្រះរស្មីតាមប្រក្រតីរបស់ព្រះអង្គ ផ្សាយទៅអស់មួយយោជន៍ ទាំងយប់ទាំងថ្ងៃអស់កាលជានិច្ច ព្រះអង្គជាទីពឹងនៃសត្វលោក សូមប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៣៥] ធម្មទស្សី ច សម្ពុទ្ធោ អសីតិហត្ថមុគ្គតោ
អតិរោចតិ តេជេន សទេវាសុរមានុសេ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម ធម្មទស្សី មានព្រះកាយកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿងលើសព្រហ្ម ទេវតា អសុរ និង មនុស្សទាំងឡាយ ដោយតេជានុភាព ។*

[៣៦] វស្សសតសហស្សានិ     ឋត្វា លោកេ មហាយសោ

សព្វសត្តេ បមោចេតិ     ភយា រក្ខតុ នោ សទា ។

*ទ្រង់មានយសដ៏ធំ មានព្រះជន្មក្នុងលោក ១ សែនឆ្នាំ*
*ទ្រង់ញុំាងសត្វឲ្យរួចចាកភ័យ សូមរក្សានូវខ្ញុំទាំងឡាយ*
*ឲ្យរួចផុតចាកភ័យ សព្វៗកាល ។*

## ក្នុងសារកប្ប ១ ព្រះអង្គ

[៣៧] សិទ្ធត្ថោ នាម សម្ពុទ្ធោ   សដ្ឋិរតនមុគ្គតោ

តិភវេ សោត្ថិជនកោ     សតសហស្សអាយុកោ ។

*ព្រះសម្ពុទ្ធជាម្ចាស់ ព្រះនាម សិទ្ធត្ថៈ មានព្រះកាយកម្ពស់*
*៦០ ហត្ថ ទ្រង់ញុំាងសួស្តីឲ្យកើតឡើងក្នុងភពទាំងបី មាន*
*ព្រះជន្ម ១ សែនឆ្នាំ ។*

[៣៨] សំសារសាគរា លោកេ   សន្តារេត្វា សទេវកេ

និព្វាបេសិ ច សោ សត្ថា  សទា សោត្ថឹ ករោតុ នោ ។

*ទ្រង់ញុំាងមនុស្សនិងទេវតា ឲ្យឆ្លងចាកសាគរនៃសំសារវដ្ត*
*និងឲ្យរំលត់កិលេស សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ*
*សព្វៗកាល ។*

## ក្នុងមណ្ឌកប្ប ២ ព្រះអង្គ

[៣៩] សដ្ឋិរតនមុព្វេធោ តិស្សោ លោកគ្គនាយកោ
អនូបមោ អសទិសោ អតុលោ ឧត្តមោ ជិនោ ។

*ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសើរក្នុងលោក ព្រះនាម តិស្សៈ មានព្រះកាយកម្ពស់ ៦០ ហត្ថ ទ្រង់ជាព្រះជិនស្រី ដ៏ឧត្តម មិនមានបុគ្គលដទៃប្រៀបប្រដូចបាន មិនមានអ្នកស្មើ មានព្រះគុណមិនអាចថ្លឹងថ្លែងបាន ។*

[៤០] វស្សសតសហស្សានិ អាយុ តស្ស មហេសិនោ
អារោគ្យញ្ច មហាសុខំ ហោតុ នោ តស្ស តេជសា ។

*ទ្រង់មានព្រះជន្ម ១ សែនឆ្នាំ ដោយតេជះរបស់ព្រះអង្គ សូមសុខភាពល្អនិងសេចក្តីសុខដ៏ធំក្រៃលែង ចូរមានដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៤១] អដ្ឋបញ្ញាសរតនោ បុស្សោ លោកគ្គនាយកោ
ជនម្ពុជំ វិពោធេន្តោ និព្វាបេន្តោ សទេវកេ ។

*ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រសើរក្នុងលោក ព្រះនាម បុស្សៈ មានព្រះកាយកម្ពស់ ៥៨ ហត្ថ ទ្រង់ញុំាងបទុមជាតិគឺវេនេយ្យសត្វឲ្យរីក ទ្រង់ញុំាងមនុស្សនិងទេវតាឲ្យរំលត់ទុក្ខ។*

[៤២] នវុតិវស្សសហស្សានិ ឋត្វា លោកេ មហាយសោ
ឧទ្ធរន្តោ ពហូ សត្តេ សទា សោត្ថឹ ករោតុ នោ ។

*ទ្រង់មានយសដ៏ធំ ទ្រង់ព្រះជន្មក្នុងលោក ៩ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងសត្វដ៏ច្រើន ឲ្យចេញចាកវដ្ដៈ សូមប្រទាននូវសួស្ដី ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ក្នុងសារកប្ប ១ ព្រះអង្គ**

[៤៣] អសីតិរតនុព្វេធោ វិបស្សី លោកនាយកោ
បភា និច្ឆរតេ តស្ស សមន្តា សត្តយោជនេ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម វិបស្សី មានព្រះកាយកម្ពស់ ៨០ ហត្ថ ព្រះរស្មីរបស់ព្រះអង្គ ផ្សាយទៅ ៧ យោជន៍ ដោយជុំវិញអស់កាលជានិច្ច ។*

[៤៤] សោបិ ទេវមនុស្សានំ ពន្ធនា បរិមោចយិ
អសីតិសហស្សាយុកោ នាថោ សោត្ថឹ ករោតុ នោ ។

*ទ្រង់មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ទ្រង់ញ៉ាំងទេវតានិងមនុស្ស ទាំងឡាយ ឲ្យរួចចាកគ្រឿងចំណង គឺកិលេស សូមប្រទាន នូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ក្នុងមណ្ឌកប្ប ២ ព្រះអង្គ**

[៤៥] សត្តតិហត្ថមុព្វេធោ សិខី នាមេស នាយកោ
បភា និច្ឆរតេ តស្ស សមន្តា យោជនត្តយេ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម សិខី មានព្រះកាយកម្ពស់*
*៧០ ហត្ថ ព្រះរស្មីរបស់ព្រះអង្គ ផ្សាយទៅ ៣ យោជន៍*
*ដោយជុំវិញអស់កាលជានិច្ច ។*

[៤៦] សោបិ អតុល្យោ សម្ពុទ្ធោ សត្តតិសហស្សាយុកោ
ករោតុ នោ មហាសន្តឹ សុខិតា ច មយំ សទា ។

*ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ មានព្រះគុណមិនអាចថ្លឹងថ្លែង*
*បាន មានព្រះជន្ម ៧ ម៉ឺនឆ្នាំ សូមប្រទាននូវសេចក្តីស្ងប់ដ៏ធំ*
*ក្រៃលែងដល់ខ្ញុំទាំងឡាយ និងខ្ញុំទាំងឡាយ ចូរជាអ្នកមាន*
*សេចក្តីសុខ សព្វៗកាល ។*

[៤៧] វេស្សភូ នាម សម្ពុទ្ធោ ហេមរូបសមូបមោ
សដ្ឋិរតនមុព្វេធោ សដ្ឋិ ច សហស្សាយុកោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម វេស្សភូ ទ្រង់ឆវីវណ្ណដូចជាមាស*
*មានព្រះកាយកម្ពស់ ៦០ ហត្ថ មានព្រះជន្ម ៩ ម៉ឺនឆ្នាំ ។*

[៤៨] ព្រហ្មទេវមនុស្សេហិ នាគាសុរគិជេហិ វា
បូជិតោបិ សទា នាថោ សទា សោត្ថឹ ករោតុ នោ ។

*ព្រះអង្គជាទីពឹង ដែលព្រហ្ម ទេវតា មនុស្ស នាគ អសុរ*
*និងគ្រុឌបូជាហើយ សូមព្រះអង្គប្រទាននូវសួស្តីដល់ខ្ញុំទាំង*
*ឡាយ សព្វៗកាល ។*

## ក្នុងភទ្ទកប្ប ៥ ព្រះអង្គ
## កន្លងទៅហើយ ៣ ព្រះអង្គ

[៤៩] តាឡីសរតនមុព្វេធោ កកុសន្ធោ មហាមុនិ
តស្ស កាយា និច្ឆរន្តិ បភា ទ្វាទសយោជនេ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម កកុសន្ធៈ ទ្រង់ជាមុនី មានព្រះកាយកម្ពស់ ៤០ ហត្ថ ព្រះរស្មីរបស់ព្រះអង្គផ្សាយទៅ ១២ យោជន៍អស់កាលជានិច្ច ។*

[៥០] ចត្តាឡីសសហស្សានិ តស្ស អាយុ អនុត្តរោ
ករោតុ សោ សទា នាថោ អាយុំ សុខំ ពលញ្ច នោ ។

*ទ្រង់មានព្រះជន្ម ៤ ម៉ឺនឆ្នាំ ទ្រង់ជាទីពឹងដ៏ប្រសើរ សូមប្រទាននូវអាយុ សេចក្តីសុខ និងកម្លាំងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៥១] កោណាគមនសម្ពុទ្ធោ តឹសហត្ថសមុគ្គតោ
តឹសវស្សសហស្សានិ អាយុ តស្ស មហេសិនោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម កោណាគមនៈ មានព្រះកាយកម្ពស់ ៣០ ហត្ថ ទ្រង់មានព្រះជន្ម ៣ ម៉ឺនឆ្នាំ ។*

[៥២] ធម្មាមតេន តប្បេតា ទេវសង្ឃំ សុរាលយេ
មហីតលេ ច ជនតំ សទា សោត្ថឹ ករោតុ នោ ។

*ព្រះអង្គទ្រង់ញុំាងទេពក្នុងសុរាល័យ និងពួកជនក្នុងប្រឹថពី*

*ឲ្យឆ្អែតដោយអមតធម៌ សូមព្រះអង្គប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយអស់កាលជានិច្ច ។*

[៨៣] កស្សបោ នាម សម្ពុទ្ធោ ធម្មរាជា បភង្ករោ
វីសតិហត្ថមុព្វេធោ វីសសហស្សអាយុកោ ។

*ព្រះសម្ពុទ្ធជាម្ចាស់ ព្រះនាម កស្សបៈ ទ្រង់ជាធម្មរាជា ទ្រង់មានរស្មី មានព្រះកាយកម្ពស់ ២០ ហត្ថ មានព្រះជន្ម ២ ម៉ឺនឆ្នាំ ។*

[៨៤] អនូបមោសមសមោ ទេវសត្ថា អនុត្តរោ
ករោតុ នោ មហាសន្តិំ អារោគ្យញ្ច ជយំ សទា ។

*ទ្រង់មិនមានអ្នកស្មើ ទ្រង់ស្មើនឹងព្រះពុទ្ធអង្គមុនដ៏ប្រសើរ ទ្រង់ជាសាស្តារបស់ពួកទេពទាំងឡាយ សូមព្រះអង្គប្រទាននូវសេចក្តីស្ងប់ដ៏ធំ សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ព្រះពុទ្ធក្នុងបច្ចុប្បន្ន ១ ព្រះអង្គ

[៨៥] អដ្ឋារសហត្ថុព្វេធោ គោតមោ សក្យវឌ្ឍនោ
សព្វញ្ញូ សព្វតិលកោ សព្វលោកសុខប្បទោ ។

*ព្រះពុទ្ធជាម្ចាស់ ព្រះនាម គោតម មានព្រះកាយកម្ពស់ ១៨ ហត្ថ ទ្រង់ជាអ្នកចម្រើនក្នុងសក្យវង្ស ទ្រង់ជា*

សព្វញ្ញូ ទ្រង់ប្រៀបដូចតិលកនៃត្រៃលោកទាំងពួង
ទ្រង់ជាអ្នកប្រទាននូវសេចក្តីសុខដល់សត្វលោកទាំងពួង ។

[៨៦] សម្ពុទ្ធោ សព្វធម្មានំ ភគេហិ ភាគ្យវាយុកោ
វិជ្ជាចរណសម្បន្នោ សោត្ថ្យាភោគ្យំ ទទាតុ នោ ។

ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ទ្រង់បរិបូណ៌
ដោយបុញ្ញាភិនិហារ មានព្រះបារមីដ៏ខ្ពង់ខ្ពស់ ទ្រង់បរិបូណ៌
ដោយវិជ្ជានិងចរណៈ សូមព្រះអង្គប្រទាននូវសួស្តីនិង
សុខភាពល្អដល់ខ្ញុំទាំងឡាយ ។

[៨៧] អត្ថាតីតា ច សម្ពុទ្ធា អនេកសតកោដិយោ
សព្វលោកមភិញ្ញាយ សព្វសត្តានុកម្បិនោ ។

ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយច្រើនរយកោដិ ដែលកន្លង
ទៅហើយ ទ្រង់ដឹងប្រចក្សនូវលោកទាំងពួងហើយ ទ្រង់
អនុគ្រោះសត្វលោកទាំងពួង ។

[៨៨] សព្វវេរភយាតីតា សព្វលោកសុខប្បទា
សព្វទោសំ វិនាសេន្តា សព្វសោត្ថឹ ករោតុ នោ ។

ទ្រង់កន្លងផុតចាកពៀរនិងភ័យ ទ្រង់ប្រទាននូវសេចក្តីសុខ
ដល់សត្វលោកទាំងពួង ទ្រង់កម្ចាត់ទោសទាំងអស់
សូមព្រះអង្គប្រទាននូវសួស្តីគ្រប់ប្រការដល់ខ្ញុំទាំងឡាយ។

## ព្រះពុទ្ធក្នុងអនាគត ១ ព្រះអង្គ

[៥៩] អនាគតេ ច សម្ពុទ្ធោ មេត្តេយ្យោ ទេវបូជិតោ
មហិទ្ធិកោ មហាទេវោ មហាសន្តឹ ករោតុ នោ ។

*ម្យ៉ាងទៀត ក្នុងអនាគត ព្រះសម្ពុទ្ធ ព្រះនាម មេត្រី ដែលពួកទេពបូជាហើយ ទ្រង់មានឫទ្ធិច្រើន ទ្រង់ជាមហាទេព សូមព្រះអង្គប្រទាននូវសេចក្តីស្ងប់ដ៏ធំដល់ខ្ញុំទាំងឡាយ។*

## ព្រះបច្ចេកពុទ្ធ

[៦០] សព្វេ បច្ចេកសម្ពុទ្ធា និរោធឈានគោចរា
និរាលយា និរាសង្កា អប្បមេយ្យា មហោសយោ ។

*ព្រះបច្ចេកពុទ្ធទាំងឡាយទាំងពួង ទ្រង់ជំនាញក្នុងនិរោធ និងឈាន ទ្រង់ប្រាសចាកតណ្ហា និងសេចក្តីញាប់ញ័រ ទ្រទ្រង់គុណរកប្រមាណមិនបាន ស្វែងរកនូវគុណដ៏ធំ ។*

[៦១] ទូរេបិ វិនេយ្យេ ទិស្វា សម្បត្តា តង្ខណេន តេ
សន្ទិដ្ឋិកជលេ កត្វា សទា សន្តឹ ករោតុ នោ ។

*ទ្រង់សំឡឹងឃើញវេនេយ្យជន សូម្បីក្នុងទីឆ្ងាយ ក៏និមន្តទៅប្រោសជនទាំងនោះ ឲ្យបានទទួលនូវប្រយោជន៍ក្នុងបច្ចុប្បន្ន ដោយរហ័សក្លាម សូមព្រះអង្គប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ។*

## ព្រះធម៌

[៦២] ស្វាក្ខាតាទិសម្បន្នោ ធម្មោ សបរិយត្តិកោ
សំសារសាគរា លោកេ តារេតិ ជិនគោចរោ ។

*ព្រះធម៌ ព្រមទាំងព្រះបរិយត្តិ ដែលបរិបូណ៌ដោយគុណ មានភាពជាធម៌ដែលព្រះពុទ្ធទ្រង់ត្រាស់សម្តែងល្អហើយ ដែលជាអារម្មណ៍របស់ព្រះពុទ្ធ រមែងញុំាងសត្វលោក ឲ្យឆ្លងចាកសាគរនៃសំសារវដ្ត ។*

[៦៣] កិលេសជាលវិទ្ធំសី វិសុទ្ធោ ពុទ្ធសេវិតោ
និព្វានគមនោ សន្តោ សទា សោត្ថិំ ករោតុ នោ ។

*សូមព្រះធម៌ដ៏បរិសុទ្ធក្រៃលែង ដែលទម្លាយសំណាញ់គឺកិលេស ជាធម៌ដែលព្រះពុទ្ធជាម្ចាស់ចម្រើនហើយ ជាធម៌ដ៏ស្ងប់ឲ្យទម្លុះព្រះនិព្វាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ព្រះសង្ឃ

[៦៤] សីលាទិគុណសម្បន្នោ សង្ឃោ មគ្គផលេ ឋិតោ
ជិតិន្ទ្រិយោ ជិតចាចោ ទក្ខិណេយ្យោ អនុត្តរោ។

*ព្រះសង្ឃអ្នកបរិបូណ៌ដោយគុណមានសីលជាដើម ទ្រទ្រង់នូវមគ្គផល ជាអ្នកឈ្នះឥន្ទ្រិយ និងបាបបាន ជាអ្នកគួរទទួលនូវទក្ខិណាដ៏ប្រសើរ ។*

[៦៥] អនាសវោ បរិសុទ្ធោ　　និរាសាសោ ភវាភវេ

និព្វានគោចរោ សន្តោ　　សទា សោត្ថឹ ករោតុ នោ ។

*ជាអ្នកប្រាសចាកអាសវៈ ជាអ្នកបរិសុទ្ធ ផុតចាកសេចក្តីប្រាថ្នាក្នុងភពតូចនិងភពធំ ជាអ្នកស្ងប់ មានព្រះនិព្វានជាអារម្មណ៍ សូមប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

**ព្រះមហាថេរៈ ១៨២ អង្គ**

[៦៦] អញ្ញាតកោណ្ឌញ្ញត្ថេរោ　　រត្តញ្ញូនំ អគ្គោ អហុ

ធម្មចក្កាភិសមយោ　　សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអញ្ញាកោណ្ឌញ្ញៈ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានរាត្រីយូរ ជាអ្នកទម្លុះសោតាបន្ន ដោយ (ការស្តាប់) ធម្មចក្កប្បវត្តនសូត្រ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៦៧] វប្បត្ថេរោ មហាបញ្ញោ　　មហាតមវិនោទនោ

មហាសន្តិករោ លោកេ　　មហាសន្តឹ ករោតុ នោ ។

*សូមព្រះវប្បត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកកម្ចាត់នូវងងឹតដ៏ធំ គឺមោហៈ ជាអ្នកប្រទាននូវស្ងប់ដ៏ធំក្នុងលោក ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ។*

[៦៨] ភទ្ទិយោ ភទ្ទសីលោ ច　　ទក្ខិណេយ្យោ អនុត្តរោ

លោកត្ថចរិតោ ថេរោ　　សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះភទ្ទិយត្ថេរ អ្នកមានសីលដ៏ល្អ គួរទទួលនូវទក្ខិណា ដ៏ប្រសើរ ជាអ្នកបំពេញនូវប្រយោជន៍ដល់សត្វលោក ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៦៩] មហានាមោ មហាបញ្ញោ មហាធម្មវិទូ សុតោ
មហាខីណាសវោ ថេរោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះមហានាមត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកត្រាស់ដឹងនូវធម៌ដ៏ប្រសើរ មានព្រះនាមរន្ទឺ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧០] អស្សជិតថេរោ មហាបញ្ញោ ជិតមារោ ជិតិន្ទ្រិយោ
ជិតបច្ចត្ថិកោ លោកេ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអស្សជិតត្ថេរ ជាអ្នកមានបញ្ញាច្រើន ជាអ្នកឈ្នះមារ ជាអ្នកឈ្នះឥន្ទ្រិយ ជាអ្នកឈ្នះសត្រូវក្នុងលោក ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧១] អនុបុព្វិកថំ សុត្វា យសោ ឯកគ្គមានសោ
អគ្គធម្មមនុប្បត្តោ សោត្ថារោគ្យំ ទទាតុ នោ ។

*សូមព្រះយសត្ថេរ ជាអ្នកស្តាប់អនុបុព្វីកថាហើយ មានចិត្តមាំ បានទម្លុះនូវធម៌ប្រសើរ (គឺអរហត្តផល) ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ ។*

[៧២] ចត្វាធិកា ច បញ្ញាស ថេរា គិហិសហាយកា
បត្វាន បរមំ សន្តឹ សទា សោត្ថឹ ករោន្តុ នោ ។

*និងព្រះមហាថេរៈជាព្រះអរហន្ត ៥៤ អង្គ ធ្លាប់ជាសម្លាញ់របស់ព្រះយសត្ថេរ កាលនៅជាគ្រហស្ថ បានទម្លុះព្រះនិព្វានដ៏ប្រសើរហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៣] យេ តឹស ភទ្ទវគ្គិយា រូបេនាតុលវណ្ណិនោ
ខីណាសវា វសីភូតា តេ ករោន្តុ អនាមយំ ។

*ព្រះភទ្ទវគ្គិយៈ ៣០ អង្គណា ជាអ្នកមានរូបសម្បុរមិនមានអ្នកស្មើ អស់អាសវៈហើយ ជាអ្នកឈ្នះខ្លួន ជំនាញក្នុងសមាបត្តិ (គឺឈានសមាបត្តិ ផលសមាបត្តិ និងនិរោធសមាបត្តិ) សូមប្រទាននូវសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៤] ឧរុវេលកស្សបោចាបិ មហាបរិសានមុត្តមោ
ឋបិតោ អគ្គឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះឧរុវេលកស្សបត្ថេរ ជាអ្នកទ្រទ្រង់តំណែងកំពូលជាងភិក្ខុទាំងឡាយ អ្នកមានបរិស័ទច្រើន ចូរប្រទាននូវនូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៥] យោ នទីកស្សបត្ថេរោ    បុញ្ញក្ខេត្តោ អនុត្តរោ

សសង្ឃោ សីលសម្បន្នោ សទា សោត្ថឹ ករោតុ នោ។

*សូមព្រះនទីកស្សបត្ថេរ ជាអ្នកមានបុណ្យដ៏ប្រសើរ ជាអ្នក*
*មានសង្ឃជាបរិវារ សម្បូរដោយសីល ចូរប្រទាននូវសួស្តី*
*ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៦] ធម្មបជ្ជលិតោ សន្តោ    យោ ថេរោ គយាកស្សបោ

សំយុត្តោ ភវនិស្នេហោ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគយាកស្សបត្ថេរ ជាអ្នករុងរឿងដោយធម៌ ជាអ្នក*
*ស្ងប់ដ៏កំពូលក្នុងត្រៃភព ចូរប្រទាននូវសួស្តីដល់ខ្ញុំ*
*ទាំងឡាយ សព្វៗកាល ។*

[៧៧] លោកនាថំ ឋបេត្វាន    បញ្ញវន្តាន ចាណិនំ

បញ្ញាយ សារិបុត្តស្ស    កលំ នាគ្ឃតិ សោឡសឹ ។

*បណ្តាអ្នកមានបញ្ញាទាំងឡាយ វៀរលែងតែព្រះជាពុទ្ធជា*
*ម្ចាស់ ដែលជាទីពឹងនៃសត្វលោកហើយ បុគ្គលណាៗ*
*រមែងមិនដល់ចំណែកទី ១៦ នៃបញ្ញារបស់ព្រះសារីបុត្រ ។*

[៧៨] សារិបុត្តោ មហាបញ្ញោ    បឋមោអគ្គសាវកោ

ធម្មសេនាបតី សេដ្ឋោ    សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសារីបុត្រអ្នកមានបញ្ញាច្រើន ជាអគ្គសាវកទីមួយ ជាព្រះធម្មសេនាបតីដ៏ប្រសើរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៧៩] ចាតុទ្ទិលិកមត្តេន　　វេជយន្តបកម្បនោ

បឋវឹ មហាតឹ សព្វំ　　សមត្ថោ បរិវត្តិតុំ ។

*ព្រះមហាថេរៈអង្គណា អាចញុំាងប្រាសាទវេជយន្តឲ្យកម្រើកញាប់ញ័រ ដោយត្រឹមមេជើង អាចត្រឡប់នូវមហាប្រឹថពីបានទាំងអស់ ។*

[៨០] មោគ្គល្លានោ មហាថេរោ ទុតិយោ អគ្គសាវកោ

ឥទ្ធិមន្តានំ សោ អគ្គោ　សទា សោត្ថឹ ករោតុ នោ ។

*ព្រះមហាថេរៈអង្គនោះ មានព្រះនាមថា មោគ្គល្លាន ជាអគ្គសាវកទីពីរ កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានឫទ្ធិ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨១] មហាកស្សបត្ថេរោបិ　　ឧត្តត្តកនកន្និភោ

ធុតគុណាគ្គនិក្ខិត្តោ　　តតិយោ សត្ថុសាវកោ ។

*សូមព្រះមហាកស្សបត្ថេរ ជាអ្នកមានពណ៌សម្បុរដូចជាដុំមាស ទ្រទ្រង់នូវតំណែងកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ធុតង្គ ជាសាវកអង្គទីបីរបស់ព្រះសាស្តា ។*

[៨២] អរញ្ញវាសាភិរតោ　　បំសុកូលធរោ មុនិ

សុគតសាសនធរោ　　សទា សោត្ថឹ ករោតុ នោ ។

*ជាអ្នកត្រេកអរនៅក្នុងព្រៃ ទ្រទ្រង់សំពត់បង្សុកូល ជាព្រះមុនីដែលទ្រទ្រង់ពាក្យបង្រៀនរបស់ព្រះសុគត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៣] អាបត្តិអនាបត្តិយា　　សតេកិច្ឆាយ កោវិទោ

វិនយេ អគ្គនិក្ខិត្តោ　　ឧបាលិ សត្ថុវណ្ណិតោ ។

*សូមព្រះឧបាលិត្ថេរ ជាអ្នកឈ្លាសក្នុងអាបត្តិនិងអនាបត្តិ ឈ្លាសក្នុងអាបត្តិដែលកែខៃបាន និងកែខៃមិនបាន ព្រះសាស្តាទ្រង់សរសើរហើយ បានទទួលតំណែងថា ជាអ្នកកំពូលក្នុងព្រះវិន័យ ។*

[៨៤] វិនយេ ធារមិប្បត្តោ　　វិនយគោចរោ មុនិ

ករោតុ នោ មហាសន្តិំ　សោត្ថារោគ្យំ ទទាតុ នោ។

*ជាអ្នកដល់នូវត្រើយក្នុងព្រះវិន័យ ជាព្រះមុនីមានព្រះវិន័យជាទីគោចរ (គឺទឹកដល់រឿងព្រះវិន័យស្មើ) ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៥] អនុរុទ្ធមហាថេរោ ទិព្វចក្ខុនមុត្តមោ

ញាតិសេដ្ឋោ ភគវតោ សោត្ថ្យាភាគ្យំ ទទាតុ នោ ។

*សូមព្រះអនុរុទ្ធត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានទិព្វចក្ខុ ជាញាតិដ៏ប្រសើររបស់ព្រះដ៏មានព្រះភាគ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

[៨៦] ឧច្ចាកុសិកានំ អគ្គោ ភទ្ទិយោ សុសមាហិតោ

កាឡិគោធាយ បុត្តោ ច សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះភទ្ទិយត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានត្រកូលខ្ពង់ខ្ពស់ ជាអ្នកមានចិត្តមាំ ជាបុត្ររបស់នាងកាឡិគោធា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៧] អានន្ទោ ពុទ្ធុបដ្ឋាកោ សង្គីតិសាធុសម្មតោ

ពហុស្សុតោ ធម្មធរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអានន្ទត្ថេរ ជាពុទ្ធុបដ្ឋាក បានទទួលតំណែងកំពូលថា ជាអ្នកដំណើរការល្អក្នុងសង្គាយនា ជាពហុស្សុត ទ្រទ្រង់ធម៌ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៨] កិមិលោ សិរិសម្បន្នោ មហាសុខសមប្បិតោ

មហាខីណាសវោ ជាតោ មហាសត្ថឹ ករោតុ នោ ។

*សូមព្រះកិមិលត្ថេរ ជាអ្នកបរិបូណ៌ដោយសិរី ប្រកបដោយមហាសុខ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៨៩] គរុវាសំ វសិត្វាន        បសន្នោ ពុទ្ធសាសនេ
ភគុ ចារហាតំ បត្តោ        សទា សោត្ថី ករោតុ នោ ។

*សូមព្រះភគុត្ថេរ ជាអ្នកជ្រះថ្លាក្នុងពាក្យបង្រៀនរបស់ព្រះពុទ្ធជាម្ចាស់ បានទម្មុះជាព្រះអរហន្ត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៩០] កុលប្បសាទជនកោ        កាឡុទាយី មហិទ្ធិកោ
ឯតទគ្គដ្ឋិតោ ថេរោ        សទា សោត្ថី ករោតុ នោ ។

*សូមព្រះកាឡុទាយិត្ថេរ ជាអ្នកមានឫទ្ធិច្រើន ញុំាងសេចក្តីជ្រះថ្លារបស់ត្រកូលឲ្យកើតឡើង ទ្រទ្រង់នៅក្នុងតំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[៩១] សេដ្ឋោ ធម្មកថិកានំ        តិណ្ណំ វេទាន ចារគូ
បុណ្ណោ មន្តានិយា បុត្តោ ថេរោ សោត្ថី ករោតុ នោ។

*សូមព្រះបុណ្ណត្ថេរ ជាបុត្ររបស់នាងមន្តានី ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកជាធម្មកថិក ជាអ្នកដល់នូវត្រៃវេទ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

[៩២] ភារទ្វាជោ មហាថេរោ សីហនាទានមុត្តមោ

ឋបិតោ អគ្គឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះបិណ្ឌោលភារទ្វាជមហាថេរ ជាអ្នកទ្រទ្រង់តំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកបន្លឺសីហនាទ ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៣] សង្ខិត្តភាសិតមត្ថំ វិត្ថារេន វិជានកោ

កច្ចានោ ភវវិស្នេហោ ថេរោ សោត្ថឹ ករោតុ នោ ។

*សូមព្រះកច្ចាយនត្ថេរ ជាអ្នកយល់សេចក្តីដែលព្រះពុទ្ធជាម្ចាស់ ត្រាស់ទុកដោយសង្ខេប ឲ្យពិស្តារបាន ជាអ្នក ប្រាសចាកសេចក្តីជំពាក់ក្នុងលោក ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៤] លកុណ្ឌកភទ្ទិយោ ថេរោ មញ្ជុស្សរានមុត្តមោ

ឋបិតោ អគ្គឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះលកុណ្ឌកភទ្ទិយត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុ ទាំងឡាយ អ្នកមានសំឡេងពីរោះ ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៥] អរណវិហារិនំ អគ្គោ ទក្ខិណេយ្យោ អនុត្តរោ

សុភូតិ ភូតឧមនោ ថេរោ សោត្ថឹ ករោតុ នោ ។

សូមព្រះសុភូតិត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកនៅដោយធម៌មិនមានកិលេស ជាអ្នកគួរទទួលនូវទក្ខិណាដ៏ប្រសើរ ជាអ្នកណែនាំវេនេយ្យជន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៦] អរញ្ញវាសិនំ អគ្គោ   រេវតោ ខទិរវនិយោ

ឈានាភិរតោ ថេរោ   សទា សោត្ថឹ ករោតុ នោ ។

សូមព្រះរេវតត្ថេរ ជាអ្នកអាស្រ័យនៅក្នុងព្រៃ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកនៅក្នុងព្រៃជាវត្ត ជាអ្នកត្រេកអរដ៏ក្រៃលែងក្នុងវិវេក ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៧] ឈាយីនំ ឧត្តមោ ថេរោ   កង្ខារេវតនាមកោ

សមាធិឈានកុសលោ   សទា សោត្ថឹ ករោតុ នោ ។

សូមព្រះកង្ខារេវតត្ថេរ ជាអ្នកកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទម្លុះឈាន អ្នកជំនាញក្នុងសមាធិនិងឈាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[៩៨] សោណោ ច កោឡិវិសោបិ អារទ្ធវីរិយានមុត្តមោ

បហិតត្តោ សទា ថេរោ   សោត្ថឹ ជាសុំ ករោតុ នោ ។

សូមព្រះសោណកោឡិវិសត្ថេរ ជាអ្នកមានចិត្តមាំ ជាអ្នក

*កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកប្រារព្ធសេចក្តីព្យាយាម ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[៩៩] កល្យាណវាក្ករណានំ សោណោ កុដិកណ្ណោបិ ច

អគ្គោតិ វណ្ណិតោ ថេរោ សោត្ថឹ ជាសុំ ករោតុ នោ ។

*សូមព្រះសោណកុដិកណ្ណត្ថេរ ជាអ្នកដែលព្រះសាស្តាទ្រង់សរសើរថា ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកពោលវាចាពីរោះ ចូរប្រទានទូវផាសុកគឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០០] លាភីនមុត្តមោ ថេរោ សីវលី ឥតិ វិស្សុតោ

សោ រតោ បច្ចយាធិដ្ឋិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈប្រាកដនាមថា សីវលី ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានលាភ តែប្រាថ្នាតិចក្នុងបច្ច័យជាដើម ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០១] សទ្ធាធិមុត្តានំ អគ្គោ វក្កលិ ឥតិ នាមកោ

ចាមោជ្ជពហុលោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈព្រះនាមថា វក្កលិ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកបង្អោនទៅដោយសទ្ធា អ្នកច្រើនដោយប្រាមោទ្យ ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០២] រាហុលោ ពុទ្ធបុត្តោបិ     សិក្ខាកាមានមុត្តមោ

ទាយាទោ សព្វធម្មេសុ     មហាសន្តឹ ករោតុ នោ ។

*សូមព្រះរាហុលត្ថេរ ជាព្រះពុទ្ធបុត្រ ជាកំពូលលើសជាង ភិក្ខុទាំងឡាយ អ្នកប្រាថ្នាសិក្សា ជាទាយាទក្នុងធម៌ទាំង ពួង ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៣] សទ្ធាយ បព្វជិត្វាន     រដ្ឋបាលោ បរក្កមី

ឯតទគ្គេ ឋិតោយេវ     សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះរដ្ឋបាលត្ថេរ អ្នកបួសហើយដោយសទ្ធា មាន សេចក្តីព្យាយាម ទ្រទ្រង់ក្នុងតំណែងឯតទគ្គៈដោយពិត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៤] កុណ្ឌធានោ មហាថេរោ  សលាកំ បឋមំ គតោ

ឋបិតោយេវ ឋានម្ហិ     សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកុណ្ឌធានមហាថេរ អ្នកបានទទួលនូវសលាកជាទី មួយ អ្នកទ្រទ្រង់នូវតំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីដល់ ខ្ញុំទាំងឡាយ សព្វៗកាល។*

[១០៥] បដិភាណវន្តានម្បិ     អគ្គោតិ ពុទ្ធវណ្ណិតោ

វង្គីសោ អរហា សេដ្ឋោ   សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវង្គីសត្ថេរ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរ ថា ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបដិភាណ ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១០៦] សមន្តចាសាទិកានំ  អគ្គដ្ឋានម្ហិ ឋបិតោ

ឧបសេនោ វង្គន្តបុត្តោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះឧបសេនវង្គន្តបុត្តត្ថេរ អ្នកទ្រទ្រង់ក្នុងតំណែងជា កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបរិស័ទគួរជ្រះថ្លា ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១០៧] ទព្វោ មល្លបុត្តោ ថេរោ  សេនាសនាបញ្ញាបកោ

ឋបិតោ អគ្គដ្ឋានម្ហិ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះទព្វត្ថេរ ជាមល្លបុត្រ អ្នកទ្រទ្រង់តំណែងឯតទគ្គៈ អ្នកចាត់ចែងសេនាសនៈ ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំង ឡាយ សព្វៗកាល ។*

[១០៨] បិលិន្ទវច្ឆសមណោ  ទេវតានំ បិយោ អហុ

ឋបិតោ អគ្គដ្ឋានម្ហិ  សោត្ថារោគ្យំ ទទាតុ នោ ។

*សូមព្រះបិលិន្ទវច្ឆត្ថេរ ដែលជាទីស្រឡាញ់របស់ពួកទេវតា អ្នកទ្រទ្រង់តំណែងឯតទគ្គៈ ចូរប្រទានទូវសួស្តីនិងសុខភាព ល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១០៩] ពាហិយោ ទារុចីរិយោ ខិប្បាភិញ្ញានមុត្តមោ

ករោតុ នោ មហាសន្តឹ អារោគ្យញ្ច ជយំ សទា ។

*សូមព្រះពាហិយទារុចីរិយត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកត្រាស់ដឹងរហ័ស ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១០] កុមារកស្សបត្ថេរោ ចិត្តកថីនមុត្តមោ

មិច្ឆាវិតក្កុបច្ឆេទោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកុមារកស្សបត្ថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានវាចាដ៏វិចិត្រ កម្ចាត់មិច្ឆាវិតក្កៈបាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១១] បដិសម្ភិទាបត្តានំ អគ្គដ្ឋានម្បិ ឋបិតោ

កោដ្ឋិតោ អរហា សេដ្ឋោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកោដ្ឋិតត្ថេរ ជាអ្នកទ្រទ្រង់តំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទម្លុះបដិសម្ភិទា ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១២] អប្បាពាធោ មហាថេរោ អប្បាពាធានមុត្តមោ

ពាក្កុលោ អរហា ជាតោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះពាកុលមហាថេរ អ្នកមានអាពាធតិច ជាកំពូល*
*លើសជាងភិក្ខុទាំងឡាយ អ្នកមានអាពាធតិច ជាព្រះអរហន្ត*
*ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១៣] បុព្វេនិវាសវេទីនំ អគ្គោតិ ពុទ្ធវណ្ណិតោ

សោភិតោ នាម សោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសោភិតត្ថេរ ដែលព្រះពុទ្ធទ្រង់ត្រាស់សរសើរថា*
*ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នករលឹកជាតិបាន*
*ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១៤] មហាកប្បិនត្ថេរោបិ ភិក្ខុ ឱវាទកោ អហុ

កុសលោ ឱវាទទានេ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីព្រះមហាកប្បិនត្ថេរ ជាអ្នកឲ្យឱវាទដល់ភិក្ខុ ជាកំពូល*
*លើសក្នុងការបង្រៀន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ*
*សព្វៗកាល ។*

[១១៥] ភិក្ខុនោវាទកានគ្គោ នន្ទកោ ឥតិ វិស្សុតោ

បាលេតុ នោ សទា ថេរោ សោត្ថឹ ផាសុំ ករោតុ នោ ។

*សូមព្រះថេរៈប្រាកដនាមថា នន្ទកៈ ជាកំពូលលើសជាង*
*ភិក្ខុទាំងឡាយ អ្នកឲ្យឱវាទដល់នាងភិក្ខុនី ចូរគ្រប់គ្រងនូវ*
*ខ្ញុំទាំងឡាយ សព្វៗកាល ចូរប្រទាននូវផាសុកគឺសួស្តី*
*ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១៦] ឥន្ទ្រិយេសុ គុត្តទ្វារោ អគ្គដ្ឋានេ ឋិតោ អហុ
នន្ទត្ថេរោ វសិប្បត្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះនន្ទត្ថេរ ជាអ្នកគ្រប់គ្រងនូវទ្វារក្នុងឥន្ទ្រិយហើយ ទ្រទ្រង់ក្នុងតំណែងឯតទគ្គៈ ដល់ភាពជំនាញហើយ (ក្នុងសមាបត្តិ) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

[១១៧] តេជោធាតុកុសលានំ អគ្គដ្ឋានម្ហិ ឋបិតោ
សាគតោ នាម សោ ថេរោ សោត្ថឹ ផាសុំ ករោតុ នោ។

*សូមព្រះថេរៈព្រះនាម សាគតៈ អ្នកទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកឈ្លាសក្នុងតេជោកសិណ ចូរប្រទាននូវផាសុកគឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១១៨] សញ្ញាវិវដ្ដកុសលោ បធានោ ភាវនារតោ
ពុទ្ធសិស្សោ មហាបន្ថោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះមហាបន្ថកត្ថេរ អ្នកឈ្លាសក្នុងវិបស្សនាដែលចេញចាកសញ្ញា (មាននិច្ចសញ្ញាជាដើម) មានសេចក្តីព្យាយាមត្រេកអរក្នុងការអប់រំចិត្ត ជាសិស្សរបស់ព្រះសាស្តា ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយសព្វៗកាល។*

[១១៩] ចូឡបន្ថកត្ថេរោបិ មនោមយាភិនិម្មិតោ

ឋបិតោ អគ្គដ្ឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះចូឡបន្ថកត្ថេរ អ្នកនិម្មិតកាយដែលសម្រេចដោយ (ឈាន) ចិត្ត អ្នកទ្រទ្រង់នូវតំណែងឯតទគ្គៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២០] បដិភាណេយ្យកានំ តុ អគ្គដ្ឋានម្ហិ ឋបិតោ

រាធោ ថេរោ មហាសោត្ថឹ ករោតុ នោ អនាមយំ ។

*សូមព្រះរាធត្ថេរ អ្នកទ្រទ្រង់នូវតំណែង កំពូលលើសជាងភិក្ខុទាំងឡាយ អ្នកមានបដិភាណ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែងនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២១] លូខចីវរធរានំ ភិក្ខូនំ ឧត្តមោ អហុ

មោឃរាជមហាថេរោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះមោឃរាជមហាថេរ ជាកំពូលលើសជាងភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ចីវរសៅហ្មង ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១២២] វិមលោ វិមលប្បញ្ញោ សុវចោ សុសមាហិតោ

រជោ ន លិម្បតិ ខន្ធេ មហាសន្តឹ ករោតុ នោ ។

សូមព្រះវិមលត្ថេរ អ្នកមានបញ្ញា ប្រាសចាកមន្ទិល មាន
រូបស្អាត មានចិត្តតាំងមាំល្អ ធុលីគឺកិលេស មិនមានជាប់
ក្នុងខន្ធ ៥ របស់លោក ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំ
ក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១២៣] ធម្មធរោ មហាធរោ មហាធម្មធរោ យតិ

មហាខីណាសវោ លោកេ មហាសន្តិំ ករោតុ នោ ។

សូមព្រះមហាបាលត្ថេរ អ្នករក្សាធម៌ដ៏ប្រសើរ ទ្រទ្រង់ធម៌
ដ៏ប្រសើរ ជាព្រះមហាខីណាស្រព ចូរប្រទាននូវសេចក្តី
ស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[១២៤] ចក្ខុធរោ មហាថេរោ បធានោ សីលសំវុតោ

បហិតត្តោ មហាកាយោ មហាសន្តិំ ករោតុ នោ ។

សូមព្រះចក្ខុបាលមហាថេរ អ្នកមានសេចក្តីព្យាយាម
សង្រួមក្នុងសីល អ្នកមានចិត្តតាំងមាំ មានពួកធម៌ដ៏ប្រសើរ
ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។

[១២៥] សព្វវេរភយាតីតោ នារទោ អាសវក្ខយោ

មហាសន្តិករោ លោកេ សទា សោត្ថិំ ករោតុ នោ ។

សូមព្រះនារទត្ថេរ អ្នកកន្លងផុតចាកពៀរនិងភ័យទាំងពួង

*អស់អាសវៈហើយ អ្នកសាងសេចក្ដីស្ងប់ដ៏ធំក្រៃលែង ក្នុងលោក ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៦] ពុទ្ធបូជាយ និរតោ ជិនភត្តិបរាយនោ

សទ្ធម្មសវនោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសទ្ធម្មសវនត្ថេរ អ្នកត្រេកអរក្នុងការបូជានូវព្រះពុទ្ធជាម្ចាស់ មានភក្ដីក្នុងព្រះជិនស្រី ជាទីតាំង ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៧] បច្ឆិមភវសម្បត្តោ គោតមោ ភាវនារតោ

រាគក្ខយមនុប្បត្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគោតមត្ថេរ ជាអ្នកដល់ទីបំផុតនៃភពហើយ ត្រេកអរក្នុងសេចក្ដីព្យាយាម បានដល់នូវកិរិយាអស់ទៅនៃរាគៈ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៨] សេនាសនេសុ សប្បាយំ លទ្ធា ឈានំ សមារភិ

គោធិកោ ពុទ្ធឈាយន្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគោធិកត្ថេរ បានទទួលនូវសេនាសនៈ ជាទីសប្បាយ ហើយ ប្រារព្ធឈាន សំឡឹងមើលព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១២៩] ពុទ្ធេ បសន្នមានសោ សុពាហុ បញ្ជលីកតោ
ខីណាសវោ វសីភូតោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះសុពាហុត្ថេរ ជាអ្នកមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ បានធ្វើអញ្ជលី (កាល ៩៤ កប្បកន្លងមកហើយ) ជាព្រះខីណាស្រព មានជំនាញ (ក្នុងសមាបត្តិ) ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៣០] វិបស្សនាយ បសុតោ វល្លិយោ សុសមាហិតោ
សតោ ឈាយី វនេវាសី សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវល្លិយត្ថេរ ជាអ្នកខ្វល់ខ្វាយក្នុងវិបស្សនាភាវនា មានចិត្តតាំងមាំល្អហើយ មានសតិ សំឡឹងឈាន នៅក្នុងព្រៃជានិច្ច ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣១] ឧត្តិយោ វិនយធរោ អតិក្កន្តោ នរាមរេ
ធារេន្តោ អន្តិមំ ទេហំ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះឧត្តិយត្ថេរ អ្នកទ្រទ្រង់ព្រះវិន័យ កន្លងផុតមនុស្ស និងទេវតា អ្នកទ្រទ្រង់កាយដែលមានក្នុងភពជាទីបំផុត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣២] វិមលោ វិរជោជល្លោ ជាតោ បណ្ឌរកេតុនា
ពិម្ពិសារធ្វជោ ថេរោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវិមលកោណ្ឌញ្ញត្ថេរ ជាអ្នកប្រាសចាកនូវធុលីគឺកិលេស បង្កើតជាព្រះភិក្ខុនិងព្រះមុនី ជាអ្នកមានបញ្ញាបរិសុទ្ធ ដូចជាទង់ព្រះបាទពិម្ពិសារ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៣] រម្មារញ្ញេ វសិត្វាន ភាវេន្តោ កុសលំ ពហុំ

យោគក្ខេមមនុប្បត្តោ សភិយោ សន្តឹ ករោតុ នោ ។

*សូមព្រះសភិយត្ថេរ ជាអ្នកនៅក្នុងព្រៃដែលគួររីករាយ ចម្រើនកុសលជាអនេក ទម្ពុះព្រះនិព្វាន ជាទីក្សេមចាកកិលេស ចូរប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៤] បុព្វេនិវាសំ ជានន្តោ ទិព្វចក្ខុវិសោធនោ

នាគិរហាតំ បត្តោ សោត្ថ្យាភោគ្យំ ទទាតុ នោ ។

*សូមព្រះនាគិតត្ថេរ ជាអ្នករលឹកជាតិក្នុងកាលមុនបាន ជាអ្នកជម្រះនូវទិព្វចក្ខុឲ្យបរិសុទ្ធ បានដល់នូវភាពជាព្រះអរហន្តហើយ ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៥] ចាតិមោក្ខមនុប្បត្តោ វិជយោ វញ្ញគោចរោ

លាភាលាភី តថាសំសី សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវិជយត្ថេរ ជាអ្នកដល់ព្រមដោយបាតិមោក្ខ-សំវរសីល ជាអ្នកមានព្រៃជាទីគោចរ មានលាភទាំងតូចទាំងធំ បានពោលសរសើរតាមសភាពពិត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៣៦] តណ្ហាជដំ វិជដេត្វា វឌ្ឍេត្វាន វិបស្សនំ

សង្ឃរក្ខិតោ មហាថេរោ មហាសន្តិំ ករោតុ នោ ។

*សូមព្រះសង្ឃរក្ខិតមហាថេរ ជាអ្នកកាប់ឆ្ការនូវជដៈគឺតណ្ហា ចម្រើនវិបស្សនាហើយ ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៣៧] អរញ្ញវាសាភិរតោ ភវនេត្តិសមូហតោ

ធម្មានំ ចារមិប្បត្តោ ឧត្តរោ ចាតុ នោ ភយា ។

*សូមព្រះឧត្តរត្ថេរ ជាអ្នកត្រេកអរក្នុងការនៅព្រៃ ជាអ្នកដកនូវតណ្ហា ដែលនាំទៅកាន់ភពបាន ជាអ្នកដល់នូវត្រើយនៃធម៌ទាំងឡាយ ចូរគ្រប់គ្រងរក្សានូវខ្ញុំទាំងឡាយ ឲ្យផុតចាកភ័យវិបត្តិ ។*

[១៣៨] បុព្វេ បុញ្ញានិ កត្វាន បុព្វយោគំ សមារភិ

ឧសភោរហតំ បត្តោ សទា សោត្ថិំ ករោតុ នោ ។

*សូមព្រះឧសភត្ថេរ ជាអ្នកធ្វើបុណ្យក្នុងកាលមុនហើយ*

ប្រារព្ធកម្មដ្ឋាន ដែលជាចំណែកខាងដើម (នៃមគ្គ) បាន ទម្លុះភាពជាព្រះអរហន្ត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៧៩] សមាបត្តិសមាបន្នោ ឆឡភិញ្ញោ មហិទ្ធិកោ
សិវកោ ពុទ្ធឈាយន្តោ សទា សោត្ថី ករោតុ នោ ។

សូមព្រះសិវកត្ថេរ ជាអ្នកដល់ព្រមដោយសមាបត្តិ មាន អភិញ្ញា ៦ មានឫទ្ធិច្រើន ជាអ្នកសំឡឹងមើលព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៨០] សត្តារិយធនោ ថេរោ ធនិយោ ធម្មសាគរោ
វដ្តសំសារគមនោ សទា សោត្ថី ករោតុ នោ ។

សូមព្រះធនិយត្ថេរ ជាអ្នកមានអរិយទ្រព្យ ៧ ប្រការ ជា សាគរនៃធម៌ លះការប្រព្រឹត្តទៅក្នុងសង្សារវដ្តហើយ ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៨១] បញ្ចក្ខន្ធេ បរិញ្ញាយ ភាវយិត្វាន និព្វុតឹ
បត្វាន បរមំ សន្តឹ ចោសិយោ ចាតុ នោ ភយា។

សូមព្រះបោសិយត្ថេរ ជាអ្នកកំណត់ដឹងនូវបញ្ចក្ខន្ធហើយ ចម្រើននូវការរំលត់កិលេស បានដល់នូវសេចក្តីស្ងប់ ដ៏ក្រៃលែង ចូរគ្រប់គ្រងរក្សានូវខ្ញុំទាំងឡាយ ឲ្យផុត ចាកភ័យវិបត្តិ ។

[១៤២] ឧបនិស្សយសម្បន្នោ ឧជ្ជយោ ពុទ្ធមាមកោ
លោកត្ថុបសុតោ ថេរោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧជ្ជយត្ថេរ ជាអ្នកសម្បូរដោយធម៌ដែលជាហេតុចេញចាកវដ្តៈ ជាអ្នកគោរពក្នុងព្រះពុទ្ធ ជាអ្នកខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់សត្វលោក ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៤៣] ពុទ្ធប្បសាទសម្បន្នោ បព្វជិ ជិនសាសនេ
សញ្ជយោ នាម សោ ថេរោ សទា សោត្ថី ករោតុ នោ។

*សូមព្រះថេរៈព្រះនាមថា សញ្ជយៈ ជាអ្នកដល់ព្រមដោយសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ បួសហើយក្នុងសាសនារបស់ព្រះជិនស្រី ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល។*

[១៤៤] មារញ្ជយោ មហាថេរោ រាមណេយ្យោ មហិទ្ធិកោ
និព្វាននិន្នចិត្តោ សោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះមហាថេរៈនាមថា រាមណេយ្យៈ ជាអ្នកមានឫទ្ធិច្រើន មានចិត្តបង្អោនទៅព្រះនិព្វាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៥] ឩភោ ចាបញ្ច បុញ្ញញ្ច  វីតិវត្តោ អនាសវោ

វីរត្ថេរោ រហប្បត្តោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះវីរត្ថេរ ជាអ្នកចូងផុតចាកបាប និងបុណ្យទាំងពីរប្រការ អស់អាសវៈហើយ ដល់ភាពជាព្រះអរហន្ត ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៦] បុណ្ណមាសមហាថេរោ  បំសុកូលធរោ យតិ

បុព្វកិច្ចវិធឹ កត្វា  មហាសន្តឹ ករោតុ នោ ។

*សូមព្រះបុណ្ណមាសមហាថេរ ជាអ្នកទ្រទ្រង់សំពត់បង្សុកូល ធ្វើនូវវិធីដែលជាបុព្វកិច្ចខាងដើមហើយ ចូរប្រទាននូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៧] បញ្ចជិន្នោ បញ្ចជហោ  បញ្ច ចុត្តរិភាវនោ

បញ្ចសង្គាតិគោ ថេរោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះបញ្ចសង្គាតិគត្ថេរ ជាអ្នកកាត់សំយោជនៈខាងក្រោម ៥ ជាអ្នកលះសំយោជនៈខាងលើ ៥ ជាអ្នកអប់រំឥន្ទ្រិយ ៥ ឲ្យក្រៃលែងៗទៅ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៨] បុព្វយោគំ វិចារេន្តោ  ជិនភត្តិបរាយនោ

ពេលដ្ឋសីសោ វសធរោ  សទា សោត្ថឹ ករោតុ នោ ។

សូមព្រះពេលដ្ឋសីសត្ថេរ ជាអ្នកពិចារណាសេចក្ដីខ្វល់ខ្វាយ ក្នុងជាតិមុន មានភក្ដីក្នុងព្រះជិនស្រីជាទីតាំង ជាអ្នកទ្រទ្រង់ វង្សត្រកូល ចូរប្រទាននូវសួស្ដីដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៨៩] បញ្ចុប្បន្នេហិ អភយោ និកន្តិ នត្ថិ ជីវិតេ

អជិតោ សោ មហាថេរោ មហាសន្តឹ ករោតុ នោ ។

សូមព្រះមហាថេរៈនាម អជិតៈ ជាអ្នករួចភ័យចាកខន្ធ ៥ ដែលកើតឡើងហើយ មិនមានសេចក្ដីត្រេកអរក្នុងជីវិត ចូរប្រទាននូវសេចក្ដីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។

[១៩០] វិវដ្ដនិស្សយេ បុញ្ញំ កត្វា សម្ពុទ្ធភត្តិមា

កុល្លត្ថេរោ រហប្បត្តោ មហាសន្តឹ ករោតុ នោ ។

សូមព្រះកុល្លត្ថេរ ជាអ្នកមានភក្ដីក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់ បំពេញបុណ្យអាស្រ័យព្រះនិព្វាន បានដល់នូវភាពជាព្រះ អរហន្តហើយ ចូរប្រទាននូវសេចក្ដីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។

[១៩១] វិបស្សី ធម្មទាយាទោ ថេរោ និគ្រោធនាមកោ

និព្វានគមនសន្និដ្ឋោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈនាមថា និគ្រោធៈ ជាអ្នកសំឡឹងត្រៃលក្ខណ៍ (ដោយវិបស្សនាបញ្ញា) ជាធម្មទាយាទ ឃើញច្បាស់នូវធម៌ដែលធ្វើឲ្យដល់នូវព្រះនិព្វាន ចូរប្រទាននូវសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥២] តិស្សោ វិជ្ជា អនុបត្តោ　សុគន្ធោ នាម សោ រហា
សព្វបាបបរិក្ខីណោ　　សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះអរហន្តនាមថា សុគន្ធៈ ជាអ្នកបានដល់នូវវិជ្ជា ៣ មានបាបទាំងពួងអស់រលីងហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៣] នន្ទិយោ សទ្ធាសម្បន្នោ　ជិតក្លេសោ មហាថេរោ
អភិញ្ញាចារមិប្បត្តោ　　សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះនន្ទិយមហាថេរ ជាអ្នកដល់ព្រមដោយសទ្ធា ឈ្នះកិលេសហើយ ជាអ្នកដល់នូវត្រើយនៃអភិញ្ញា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៤] កិលេសា ឈាបិតា យេន ជិតធម្មរតេន សោ
កម្មារបុត្តវិមលោ　　　សទា សោត្ថឹ ករោតុ នោ ។

*ព្រះថេរៈអង្គណា ជាអ្នកត្រេកអរក្នុងធម៌ដែលជាគ្រឿងវិជិតមារ ដុតកិលេសបានហើយ ព្រះថេរៈមាននាមថា វិមលៈ*

*ជាបុត្ររបស់ជាងមាស ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៥] ទេវលោកមនុស្សេសុ អនុភុត្វា វិភូតិយោ
តិស្សត្ថេរោ មហាភូតោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះតិស្សត្ថេរ ជាអ្នកសោយសម្បត្តិក្នុងទេវលោក និង មនុស្សលោកហើយ ជាព្រះអរហន្តដ៏ប្រសើរ ចូរប្រទានទូវ នូវសេចក្តីស្ងប់ដ៏ធំក្រៃលែងដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៦] សុវិមុត្តោ មហានាគោ តីហិ វង្កេហិ មុត្តកោ
សុមង្គលោ មហាថេរោ មហាសន្តឹ ករោតុ នោ ។

*សូមព្រះសុមង្គលមហាថេរ ជាអ្នករួចផុតល្អហើយ ជាព្រះ អរហន្តដ៏ធំ ផុតហើយចាកកោងទាំង ៣ (គឺកោងផ្លូវកាយ វាចា ចិត្ត) ចូរប្រទានទូវសេចក្តីស្ងប់ដ៏ធំក្រៃលែដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៥៧] និរគ្គឡោ និរាសាសោ មលជីលវិសោធនោ
វិវេកាភិរតោ គុត្តោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះមហាថេរៈនាមថា គុត្តៈ ជាអ្នកមិនមានអវិជ្ជា ប្រាសចាកតណ្ហា ជម្រះមន្ទិលឲ្យបរិសុទ្ធ ត្រេកអរក្រៃលែង ក្នុងវិវេក អ្នកសង្រួមខ្ទនហើយ ចូរប្រទានទូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៥៨] បវិវេកមនុប្បត្តោ  គិរិមានន្ទនាមកោ

ភាវេន្តោ កុសលេ ធម្មេ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរៈនាមថា គិរិមានន្ទ ជាអ្នកចម្រើននូវកុសលធម៌ បានដល់ហើយនូវវិវេក ៣ (គឺកាយវិវេក ចិត្តវិវេក និង ឧបធិវិវេក) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៥៩] ពុទ្ធសាសនមារទ្ធោ  សមិទ្ធិ ភាវនារតោ

សមិទ្ធិគុណសម្បន្នោ  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសមិទ្ធិត្ថេរ ជាអ្នកព្យាយាមបដិបត្តិតាមពាក្យបង្រៀន របស់ព្រះពុទ្ធជាម្ចាស់ ជាអ្នកត្រេកអរក្នុងភាវនា ដល់ព្រម ដោយគុណនៃសេចក្តីសម្រេច ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦០] អារាធិតជិនោ សន្តោ  ជោតិត្ថេរោ មហារហា

វិមុត្តោ សព្វសំសារា  សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះជោតិត្ថេរ ជាអ្នកញុំាងព្រះជិនស្រីឲ្យមានព្រះទ័យរីក រាយហើយ ជាអ្នកស្ងប់ ជាព្រះអរហន្តដ៏ធំក្រៃលែង រួចផុត ហើយចាកសង្សារវដ្តទាំងពួង ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦១] សេនាសនានិ បន្តានិ សេវន្តោ ឈានមារតិ

ឆឡភិញ្ញោ មហាចុន្ទោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះមហាចុន្ទត្ថេរ ជាអ្នកអាស្រ័យក្នុងសេនាសនៈដ៏ស្ងាត់ ចូលឈានហើយ ទ្រទ្រង់អភិញ្ញា ៦ ចូរប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦២] ឆន្នត្ថេរោ សហជាតោ សុណន្តោ ជិនសាសនំ

យោគក្ខេមមនុប្បត្តោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះឆន្នត្ថេរ ជាសហជាតនឹងព្រះពុទ្ធជាម្ចាស់ កាលជឿ ស្តាប់ពាក្យបង្រៀនរបស់ព្រះជិនស្រីហើយ បានដល់ហើយ នូវព្រះនិព្វាន ដែលជាទីក្សេមចាកកិលេស ចូរប្រទាននូវ សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៣] មេឃិយោ ពុទ្ធុបដ្ឋាកោ ជិនភត្តិបរាយនោ

មិច្ឆាវិតក្កុបច្ឆេទោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះមេឃិយត្ថេរ ជាពុទ្ធុបដ្ឋាក មានភក្តីក្នុងព្រះជិនស្រី ជាទីតាំង កាត់មិច្ឆាវិតក្កៈហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល។*

[១៦៤] ឧបវាណោ មហាថេរោ មហាកាយោ មហាវហោ

មហិទ្ធិកោ មហាតេជោ សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧបវាណមហាថេរ ជាអ្នកមានរាងកាយខ្ពស់ធំ ជាព្រះអរហន្តដ៏ធំក្រៃលែង មានឫទ្ធិដ៏ច្រើន មានអានុភាពច្រើន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៥] សន្តិច្ចោ ចោរទមនោ សព្វសំយោជនក្ខយោ

ចាលេតុ នោ សព្វភយា សោត្ថ្យាភាវំ ទទាតុ នោ ។

*សូមព្រះសន្តិច្ចត្ថេរ ជាអ្នកទូន្មាននូវចោរ អស់សំយោជនៈទាំងពួង ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយឲ្យផុតចាកភ័យទាំងពួង ចូរប្រទាននូវសួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៦] បញ្ញាព្យាករណោ ធេកោ មេត្តាឈានរតោ យតិ

សោចាកោ ចាយសម្បន្នោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសោបាកត្ថេរ ជាអ្នកឈ្លាសក្នុងការតបបញ្ហារបស់ព្រះពុទ្ធជាម្ចាស់ ត្រេកអរក្នុងឈាន ដែលប្រកបដោយមេត្តាបរិបូណ៌ដោយហេតុ (ក្នុងការទម្លុះមគ្គផល) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៧] ខេត្តសម្បត្តិសម្បត្តោ វឌ្ឍមានោវ សោត្ថិនា

សុមនោ អរហា ជាតោ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះសុមនត្ថេរ ជាអ្នកដល់ព្រមដោយកាលដ៏សមគួរ*

*(ក្នុងការទម្មះធម៌) ជាអ្នកចម្រើនដោយសេចក្តីសុខដ៏ពិត ជាព្រះអរហន្តហើយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៨] បិយោ ទេវមនុស្សានំ     សានុត្តេរោ ពហុស្សុតោ

មេត្តាឈាយី តមោឃាតីសទា សោត្ថី ករោតុ នោ ។

*សូមព្រះសានុត្ថេរ ជាទីស្រឡាញ់នៃមនុស្សនិងទេវតាទាំងឡាយ ជាពហុស្សុត មានឈានប្រកបដោយមេត្តា ជាអ្នកទម្លាយនូវងងឹត គឺមោហៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៦៩] យោ ច បុព្វេ កតំ ចាបំ  កុសលេន បិធីយតិ

អង្គុលិមាលោ សោ ថេរោ សទា សោត្ថី ករោតុ នោ ។

*ព្រះថេរៈអង្គណា បិទរាំងនូវបាបដែលខ្លួនធ្វើទុកក្នុងកាលមុនដោយកុសល ព្រះថេរៈមាននាមថា អង្គុលិមាល ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧០] វិបស្សនាធុរា យេបិ      ថេរា សមថយានិកា

ខីណាសវា មហាតេជា   មហាតមវិនោទនា ។

*សូម្បីព្រះថេរៈអង្គណា ជាវិបស្សនាយានិក ឬសមថយានិក ជាអ្នកអស់អាសវៈហើយ មានតេជៈច្រើន ជាអ្នកកម្ចាត់នូវងងឹតដ៏ធំ គឺមោហៈ ។*

[១៧១] ឈានិកាឈានិកា យេបិ ធម្មាភិសមយានយោ

សព្វេ សោត្ថឹ សទា ទេន្តុ ជយមារោគ្យមាយុនោ ។

*និងព្រះថេរៈទាំងឡាយអង្គឯណា បានទម្លុះធម៌ជាដើម ទាំងបានឈាន និងមិនបានឈាន សូមព្រះថេរៈទាំងឡាយអង្គនោះ ចូរប្រទាននូវសួស្តី ជ័យជម្នះ សុខភាពល្អ និងអាយុ ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

## ព្រះមហាថេរី ១៣ អង្គ

[១៧២] រត្តញ្ញូនំ ភិក្ខុនីនំ គោតមី ជិនមាតុច្ឆា

ឋបិតា អគ្គឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះគោតមីថេរី ជាព្រះមាតុច្ឆារបស់ព្រះពុទ្ធជាម្ចាស់ ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានរាត្រីយូរ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៣] មហាបញ្ញានមគ្គដ្ឋា ខេមាថេរីតិ ចាកដា

សាវិកា ពុទ្ធសេដ្ឋស្ស សទា សោត្ថឹ ករោតុ នោ ។

*សូមសាវិការបស់ព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ ប្រាកដនាមថាព្រះខេមាថេរី ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានបញ្ញាច្រើន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៤] ថេរី ឧប្បលវណ្ណា ច ឥទ្ធិមន្តីនមុត្តមា
សាវិកា ពុទ្ធសេដ្ឋស្ស សទា សោត្ថី ករោតុ នោ ។

*សូមព្រះឧប្បលវណ្ណាថេរី សាវិការបស់ព្រះពុទ្ធជាម្ចាស់ ដ៏ប្រសើរ ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានឫទ្ធិច្រើន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៥] វិនយធ្វីនំ អគ្គា បដាចារាតិ វិស្សុតា
ឋបិតា អគ្គដ្ឋានម្ហិ សទា សោត្ថី ករោតុ នោ ។

*សូមព្រះថេរីប្រាកដនាមថា បដាចារា ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់ព្រះវិន័យ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៦] ធម្មកថិកបវរា ធម្មទិន្នាតិ នាមិកា
ឋបិតា អគ្គដ្ឋានម្ហិ សទា សោត្ថី ករោតុ នោ ។

*សូមព្រះថេរីមាននាមថា ធម្មទិន្នា ទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកជាធម្មកថិកា ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៧] ឈាយិកានំ ភិក្ខុនីនំ នន្ទាថេរីតិ នាមេសា
អគ្គឋានេ ឋិតា អហុ សទា សោត្ថី ករោតុ នោ ។

*សូមសាវិកានាមថា នន្ទាថេរី ទ្រទ្រង់តំណែងកំពូលលើស ជាងភិក្ខុនីទាំងឡាយ អ្នកមានឈាន ចូរប្រទាននូវសួស្តី ដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៨] អារទ្ធវីរិយានំ អគ្គា សោណាថេរីតិ នាមិកា
ថបិតា តត្ថ ឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរីនាមថា សោណា ទ្រទ្រង់តំណែងកំពូលលើស ជាងភិក្ខុនីទាំងឡាយ អ្នកប្រារព្ធសេចក្ដីព្យាយាម ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៧៩] ទិព្វចក្ខុកានំ អគ្គា ពកុលា ឥតិ វិស្សុតា
វិសុទ្ធនយនា សាបិ សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះថេរីប្រាកដនាមថា ពកុលា អ្នកមានចក្ខុដ៏ប្រសើរ ជាកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានទិព្វចក្ខុ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨០] កុណ្ឌលកេសា ភិក្ខុនី ខិប្បាភិញ្ញានមុត្តមា
ថបិតាយេវ ឋានម្ហិ សទា សោត្ថឹ ករោតុ នោ ។

*សូមភិក្ខុនីឈ្មោះថា កុណ្ឌលកេសា អ្នកទ្រទ្រង់តំណែងកំពូល លើសជាងភិក្ខុនីទាំងឡាយ អ្នកត្រាស់ដឹងរហ័ស ចូរប្រទាន នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨១] ថេរី ភទ្ទកាបិលានី      បុព្វជាតិមនុស្សរី
តាសំយេវ ភិក្ខុនីនំ      អគ្គា សោត្ថឹ ករោតុ នោ ។

*សូមព្រះភទ្ទាកាបិលានីថេរី អ្នករលឹកជាតិមុនបាន ជាកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នករលឹកជាតិបាន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨២] ថេរី តុ ភទ្ទកច្ចានា      មហាភិញ្ញានមុត្តមា
ជិនេន សុខទុក្ខំ សា      សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះភទ្ទាកច្ចានាថេរី (គឺព្រះនាងយសោធរា) អ្នករួមទុក្ខរួមសុខរបស់ព្រះជិនស្រី ជាកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកមានអភិញ្ញាធំ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៣] លូខចីវរធារីនំ      អគ្គា កិសាបិ គោតមី
ថបិតា អគ្គឋានម្ហិ      សទា សោត្ថឹ ករោតុ នោ ។

*សូមព្រះកិសាគោតមី អ្នកទ្រទ្រង់តំណែងកំពូលលើសជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់ចីវរសៅហ្មង ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល។*

[១៨៤] សិង្គាលមាតា ភិក្ខុនី      សទ្ធាធិមុត្តានមុត្តមា
ករោតុ នោ មហាសន្តឹ      អារោគ្យញ្ច សុខំ សទា ។

*សូមព្រះសិង្គាលមាតាភិក្ខុនី ជាកំពូលលើសជាងភិក្ខុនីទាំង
ឡាយ អ្នកបង្អោនទៅដោយសទ្ធា ចូរប្រទាននូវសេចក្តី
ស្ងប់ដ៏ធំក្រៃលែង សុខកាលល្អ និងសេចក្តីសុខដល់ខ្ញុំ
ទាំងឡាយ សព្វៗកាល ។*

[១៨៥] អញ្ញា ភិក្ខុនិយោ សព្វា   នានាគុណាធរា ពហូ
ចាលេន្តុ នោ សព្វភយា   សោករោគាទិសម្ភវា ។

*សូមភិក្ខុនីដទៃច្រើនព្រះអង្គ អ្នកទ្រទ្រង់គុណធម៌ផ្សេងៗ
ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយឲ្យផុតចាកភ័យទាំងពួង ដែល
កើតអំពីសេចក្តីសោក និងរោគភ័យជាដើម ។*

[១៨៦] សោតាបន្នាទយោ សេក្ខា សទ្ធាបញ្ញាសីលាធិកា
ភាគសោ ក្លេសទហនា   សទា សោត្ថឹ ករោន្តុ នោ។

*សូមព្រះភិក្ខុនីជាសេក្ខបុគ្គល មានសោតាបន្នជាដើម អ្នក
ក្រៃលែងដោយសទ្ធា បញ្ញា និងសីល ជាអ្នកដុតកិលេស
បានចំណែកខ្លះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ
សព្វៗកាល ។*

## ស្តេចនាគ

[១៨៧] សុមនោ សុមនចលោ   អរវាឡេរបត្តកោ
ចម្បេយ្យោ មុចលិន្ទោ ច កម្ពលោ ភុជគិស្សរោ ។

*សុមននាគរាជ សុមនចលនាគរាជ អរវាឡនាគរាជ ឯរបត្តកនាគរាជ ចម្បេយ្យនាគរាជ មុចលិន្ទនាគរាជ និងកម្ពលនាគរាជ ជាស្តេចនាគ ។*

[១៨៨] កាលនាគោ មហាកាឡោ សង្ខបាលោ មហោទរោ
មណិកណ្ឋោ មណិអក្ខិ នន្ទនាគោបនន្ទកោ។

*កាលនាគរាជ មហាកាឡនាគរាជ សង្ខបាលនាគរាជ មហោទរនាគរាជ មណិកណ្ឋនាគរាជ មណិអក្ខិនាគរាជ នន្ទនាគរាជ និងឧបនន្ទនាគរាជ ។*

[១៨៩] វរុណោ ធតរដ្ឋោ ច កុឌ្គិវិលោបលាសកោ
ចិត្រនាគោ មហាវីរោ ធព្យាបុត្តោ ច វាសុកី ។

*វរុណនាគរាជ ធតរដ្ឋនាគរាជ កុឌ្គិវិលនាគរាជ អបលាលនាគរាជ ចិត្រនាគរាជ មហាវីរនាគរាជ ធព្យាបុត្តនាគរាជ និងវាសុកីនាគរាជ ។*

[១៩០] កណ្ហាគោតមោ ភុជគិន្ទោ អគ្គិធូមសិខោ តថា
ចូឡោទរោ អហិច្ឆត្តោ នាគា ឯរាបថាទយោ។

*កណ្ហាគោតមនាគរាជ ដែលជាស្តេចនាគ អគ្គិសិខនាគរាជ ធូមសិខនាគរាជ ចូឡោទរនាគរាជ អហិច្ឆត្តនាគរាជ និងនាគទាំងឡាយ មានឯរាបថនាគរាជជាដើម ។*

[១៩១] អាសីវិសា ឃោរវិសា  យេ សព្វេ នយនាវុធា

ជលដ្ឋា វា ថលដ្ឋា វា  បព្វតេយ្យា នទីចរា

ករោន្តុ នោ មហាសោត្ថឹ អាយុមារោគិយំ សទា ។

*នាគរាជពួកណាមានពិសដ៏ខ្លាំងក្លា មានពិសគួរឲ្យភ័យខ្លាច មានភ្នែកជាអាវុធ ទោះនៅក្នុងទឹក នៅលើគោក នៅក្នុងភ្នំ ឬនៅក្នុងស្ទឹង សូមនាគទាំងឡាយនោះ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង អាយុ និងសុខភាពល្អ ដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

## ប្រេត

[១៩២] និជ្ឈាមតណ្ហិកា បេតា  ឧសុសត្តិ ច លោមកា

មំសបិណ្ឌាទយោ បេតា  បេតា វេមានិកាទយោ

ចាលេន្តុ នោ សព្វភយា  សទា តេ សុខិនោ សទា ។

*និជ្ឈាមតណ្ហិកប្រេត ឧសុលោមកប្រេត សត្តិលោមកប្រេត មំសបិណ្ឌប្រេត និងវេមានិកប្រេតជាដើម សូមប្រេតទាំងនោះ ចូរមានសេចក្តីសុខគ្រប់កាល ចូរគ្រប់គ្រងនូវខ្ញុំទាំងឡាយ ឲ្យផុតចាកភ័យទាំងពួង សព្វៗកាល ។*

## អសុរ

[១៩៣] យេ បហារាទសម្ពរ-  ពល្យាសុរគណា ច យេ

វេបចិត្តាសុរគណា  ចន្ទាសុរគណាទយោ ។

*ពួកអសុរណា គឺពួកបហារាទអសុរ ពួកសម្ពរអសុរ ពួកពលិអសុរ ពួកវេបចិត្តអសុរ និងពួកចន្ទអសុរជាដើម ។*

[១៩៤] សព្វេ តេបិ មហាតេជា ភូតយក្ខនិវារណា
ករោន្តុ នោ មហាសោត្ថឹ អារោគ្យញ្ច ជយំ សទា ។

*សូមឲ្យពួកអសុរទាំងអស់នោះ ជាអ្នកមានតេជះច្រើន ជាទីរារាំងភូតនិងយក្ខ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ទេវតា**

[១៩៥] យេ យក្ខា សត្តសហស្សា ភុម្មា កាបិលវត្ថុកា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ ។

*យក្ខជាភុម្មទេវតាប្រាំពីរពាន់ណា នៅក្នុងក្រុងកបិលពស្តុ ទ្រទ្រង់ឥទ្ធិឫទ្ធិ មានរស្មីរុងរឿង មានសម្បុរល្អ បរិបូណ៌ដោយបរិវារ ។*

[១៩៦] សព្វេ តិសរណា យក្ខា មហេសក្ខា ជុតិន្ធរា
ករោន្តុ នោ មហាសោត្ថឹ អារោគ្យញ្ច ជយំ សទា ។

*យក្ខទាំងឡាយទាំងពួង ដែលមានព្រះរតនត្រ័យជាទីពឹង មានស័ក្តិធំ ទ្រទ្រង់នូវពន្លឺ សូមយក្ខទាំងនោះ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង សុខភាពល្អ និងជ័យជម្នះដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៩៧] ឆសហស្សា ហេមវតា យក្ខា នានត្តវណ្ណិនោ

ពុទ្ធបូជាយ និរតា សទា សោត្ថឹ ករោតុ នោ ។

*សូមយក្ខប្រាំមួយពាន់ ដែលនៅក្នុងព្រៃហិមពាន្ត មាន សម្បុរផ្សេងៗគ្នា ត្រេកអរក្នុងការបូជានូវព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[១៩៨] សាតាគិរា តិសហស្សា យក្ខា នីលាទិវណ្ណិនោ

នានាបភាយ សម្បន្នា សទា សោត្ថឹ ករោតុ នោ ។

*សូមយក្ខបីពាន់ ដែលនៅលើភ្នំសាតាគិរី មានសម្បុរខៀវ ជាដើម បរិបូណ៌ដោយពន្លឺផ្សេងៗ ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល ។*

[១៩៩] វេស្សាមិត្តា បញ្ចសតា យក្ខា នានត្តវណ្ណិនោ

ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ

មោទមានា អភិក្កាមុំ សទា សោត្ថឹ ករោន្តុ នោ ។

*សូមយក្ខប្រាំរយ ដែលនៅលើភ្នំវេស្សាមិត្ត មានសម្បុរ ផ្សេងៗគ្នា ទ្រទ្រង់នូវឫទ្ធិ មានរស្មី មានសម្បុរល្អ បរិបូណ៌ ដោយបរិវារ រីករាយមកប្រជុំគ្នា ចូរប្រទាននូវសួស្តីដល់ខ្ញុំ ទាំងឡាយ សព្វៗកាល ។*

[២០០] កុម្ភីរោ រាជគហិកោ វេបុល្លស្ស និវេសនំ

ភិយ្យោ នំ សតសហស្សំ យក្ខានំ បយិរុបាសតិ

យោ យក្ខេហិ បរិវារោ សទា សោត្ថឹ ករោតុ នោ ។

*យក្ខឈ្មោះកុម្ភីរៈ ដែលនៅជិតក្រុងរាជគ្រឹះ មានភ្នំវេបុល្ល ជាវិមាន មានពួកយក្ខច្រើនសែនមកចូលមកប្រណិប័តន៍ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០១] បុរិមញ្ច ទិសំ រាជា ធតរដ្ឋោ បសាសតិ

គន្ធព្វានំ អធិបតិ មហារាជា យសស្សិ សោ ។

*ស្តេចមហារាជព្រះនាមថា ធតរដ្ឋ គ្រប់គ្រងក្នុងទិសបូព៌ ជាអធិបតីរបស់ពួកគន្ធព្វ មានបរិវារច្រើន ។*

[២០២] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា

សោ រាជា សហ បុត្តេហិ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចធតរដ្ឋនិងបុត្រទាំងឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៣] ទក្ខិណាញ្ច ទិសំ រាជា វិរុឡ្ហោ តំ បសាសតិ

កុម្ភណ្ឌានំ អធិបតិ មហារាជា យសស្សិ សោ ។

*ស្ដេចមហារាជព្រះនាមថា វិរុឡ្ហកៈ គ្រប់គ្រងក្នុងទិសទក្សិណ ជាអធិបតីរបស់ពួកកុម្ភណ្ឌ មានបរិវារច្រើន ។*

[២០៤] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា

វិរុឡ្ហា សហ បុត្តេហិ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្ដេចវិរុឡ្ហកៈនិងបុត្រទាំងឡាយ ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៥] បច្ឆិមញ្ច ទិសំ រាជា វិរូបក្ខោ បសាសតិ

នាគានញ្ច អធិបតិ មហារាជា យសស្សិ សោ ។

*ស្ដេចមហារាជព្រះនាមថា វិរូបក្ខៈ គ្រប់គ្រងក្នុងទិសបស្ចិម ជាអធិបតីរបស់ពួកនាគ មានបរិវារច្រើន ។*

[២០៦] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា

វិរូបក្ខោ សហ បុត្តេហិ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្ដេចវិរូបក្ខៈនិងបុត្រទាំងឡាយ ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៧] ឧត្តរញ្ច ទិសំ រាជា កុវេរោ តំ បសាសតិ
យក្ខានញ្ច អធិបតិ មហារាជា យសស្សិ សោ ។

*ស្តេចមហារាជព្រះនាមថា កុវេរៈ គ្រប់គ្រងក្នុងទិសឧត្តរ ជាអធិបតីរបស់ពួកយក្ខ មានបរិវារច្រើន ។*

[២០៨] បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
កុវេរោ សហ បុត្តេហិ សទា សោត្ថឹ ករោតុ នោ ។

*សូម្បីបុត្ររបស់មហារាជក៏មានច្រើន មាននាមថា ឥន្ទៈដូចគ្នា សុទ្ធតែមានកម្លាំងច្រើន សូមស្តេចកុវេរៈនិងបុត្រទាំងឡាយ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២០៩] បុរិមំ ទិសំ ធតរដ្ឋោ ទក្ខិណេន វិរុឡ្ហកោ
បច្ឆិមេន វិរូបក្ខោ កុវេរោ ឧត្តរំ ទិសំ ។

*ស្តេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមទិស ស្តេចវិរុឡ្ហកៈ (នៅរក្សា)ខាងទក្ខិណទិស ស្តេចវិរូបក្ខៈ (នៅរក្សា)ខាងបច្ឆិមទិស ស្តេចកុវេរៈ (នៅរក្សា)ខាងឧត្តរទិស ។*

[២១០] ចត្តារោ តេ មហារាជា សមន្តា ចតុរោ ទិសា
ទទ្ទល្លមានា អដ្ឋំសុ សទា សោត្ថឹ ករោន្តុ នោ ។

*មហារាជទាំងឡាយ៤នោះ ជាអ្នកញុំាងទិសទាំងបួនដោយ*

*ជុំវិញ ឲ្យរុងរឿង ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយសព្វៗកាល ។*

[២១១] តេសំ មាយាវិនោ ទាសា អាគុំ វញ្ចនិកា សឋា
មាយា កុដេណ្ឌុ វិដេណ្ឌុ វិតុច្ច វិដុដោ សហ ។

*អ្នកបម្រើស្តេចមហារាជទាំងបួននោះ ជាអ្នកមានមាយាបោកបញ្ឆោត មានលេស មកកាន់ទីប្រជុំ គឺអ្នកបម្រើឈ្មោះកុដេណ្ឌុ វិដេណ្ឌុ វិតុច្ច និងវិដុដៈ ។*

[២១២] ចន្ទនោ កាមសេដ្ឋោ ច កិន្នុឃណ្ឌុ និឃណ្ឌុ ច
បនាទោ ឱបមញ្ញោ ច ទេវសូតោ ច មាតលិ ។

*ឈ្មោះចន្ទនៈ កាមសេដ្ឋៈ កិន្នុឃណ្ឌុ និឃណ្ឌុ បនាទៈ ឱបមញ្ញៈ និងសារថីមាតលី ។*

[២១៣] ចិត្តសេនោ ច គន្ធព្វោ នឡោ រាជា ជនេសភោ
វាគោ បញ្ចសិខោ ចេវ តិម្ពរូ សុរិយវច្ចសា ។

*គន្ធព្វឈ្មោះចិត្តៈ សេនៈ និងចិត្តសេនៈ ទេវបុត្រឈ្មោះនឡៈ ទេវបុត្រឈ្មោះជនេសភៈ ទេវបុត្រឈ្មោះបញ្ចសិខៈ ទេពគន្ធព្វឈ្មោះតិម្ពរូ ទេពធីតាឈ្មោះសុរិយវច្ចសា ។*

[២១៤] ឯតេ ចញ្ញេ ច រាជានោ គន្ធព្វា ច មហាព្វលា
មោទមានា សទា សោត្ថិ កករាន្ទុ នោ អនាមយំ ។

*សូមទេព យក្ខ និងគន្ធព្វទាំងនោះ ព្រមទាំងទេវតាដទៃៗ*
*ជាអ្នកមានកម្លាំងច្រើន មានចិត្តរីករាយ ចូរប្រទាននូវ*
*សួស្តីនិងសុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## **នាគ**

[២១៥] មហន្តា នាគសា នាគា វេសាលា សហ តច្ឆកា

កម្ពលស្សតរា ចាបិ មេរុបាទសិតា ពលា ។

*ពួកនាគទាំងឡាយដ៏ច្រើន អាស្រ័យនៅក្នុងស្រះឈ្មោះថា*
*នាគសៈ នាគអាស្រ័យនៅក្នុងនគរវេសាលី ព្រមទាំងបរិវារ*
*របស់នាគតច្ឆកៈ កម្ពលនាគរាជ និងអស្សតរនាគរាជ ជា*
*អ្នកមានកម្លាំងខ្លាំងក្លា ស្ថិតនៅក្នុងភ្នំសុមេរុរាជ ។*

[២១៦] យាមុនា ធតរដ្ឋា ច សព្វេ នាគា យសស្សិនោ

ឯរាវណោ មហានាគោ ករោន្តុ នោ អនាមយំ ។

*នាគនៅក្នុងស្ទឹងយមុនា និងនាគធតរដ្ឋៈ នាគទាំងពួងនោះ*
*ព្រមទាំងបរិវារ និងស្តេចដំរីឯរាវ័ណ ចូរប្រទាននូវ*
*សុខភាពល្អដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## **គ្រុឌ**

[២១៧] មហិទ្ធិកា សុបណ្ណា យេ នាគរាជេ មហព្វលេ

គហេត្វា ជិនខេត្តេវ បក្ខន្ទឹសុ នភេ ពលា

តេ ពុទ្ធសរណា សព្វេ សោត្ថឹ ករោន្តុ នោ សទា ។

*គ្រុឌទាំងឡាយឯណា មានឫទ្ធិច្រើន កាលចាប់នាគរាជដែលមានកម្លាំងខ្លាំង ហើយហើរទៅកាន់អាកាសដែលជាខេត្តដែនឈ្មោះនាគដោយកម្លាំង គ្រុឌទាំងឡាយនោះ មានព្រះពុទ្ធជាសរណៈ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

**ទេវតា**

[២១៨] បថព្យាបោ ច តេជោ ច វាយោ ទេវា មហិទ្ធិកា

ឧបចារេន និព្វត្តា សទា សោត្ថី ករោន្តុ នោ ។

*ទេវតាឈ្មោះបឋវី ឈ្មោះអាបោ ឈ្មោះតេជោ និងឈ្មោះវាយោ មានឫទ្ធិច្រើន កើតដោយឧបចារឈាន (ក្នុងបឋវីកសិណជាដើម) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២១៩] វរុណា វារណា ទេវា សោមោ ច យសសា សហ

មេត្តាការុណិកា សព្វេ សទា សោត្ថី ករោន្តុ នោ ។

*ទេវតាឈ្មោះវរុណៈ ឈ្មោះវារណា ឈ្មោះសោមៈ ព្រមទាំងទេវតាឈ្មោះយសៈ ម្យ៉ាងទៀត ទេវតាឈ្មោះមេត្តា គឺអ្នកកើតដោយការចម្រើនមេត្តា) និងឈ្មោះករុណា គឺអ្នកកើតដោយការចម្រើនករុណា) ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២០] បណ្ណាសយោជនាយាមេ វិមានេ រតនាមយេ

ឋិតោ តមេ វិហន្ត្វាន     សុរិយោ សោត្ថី ករោតុ នោ ។

*សូមសុរិយទេព ដែលស្ថិតនៅក្នុងវិមាន ៥០យោជន៍ ដែលសម្រេចហើយដោយរតនៈ ចូរកម្ចាត់នូវងងឹតហើយ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២១] ចន្ទោ សីតករោ លោកេ បភាយុជ្ជលិតោទយោ

មហាន្ធការវិទ្ធំសី     សទា សោត្ថី ករោតុ នោ ។

*សូមចន្ទទេពមានរស្មីរុងរឿង កម្ចាត់នូវងងឹតដ៏ធំ ឧទ័យឡើងភ្លឺស្វាងក្នុងលោក ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២២] វេណ្ហុ ច សហាសីទេវា     អសមា ច ទុវេ យមា

ចន្ទស្សូបនិសា ទេវា     ទេវា សុរិយនិស្សិតា

ពុទ្ធស្ស មាមកា សព្វេ     សទា សោត្ថី ករោន្តុ នោ ។

*ទេវតាឈ្មោះវេណ្ហុ ឈ្មោះសហសី ឈ្មោះអសមៈ ព្រះយមទាំងពីរ ទេវតាដែលអាស្រ័យព្រះចន្ទ និងទេវតាដែលអាស្រ័យព្រះអាទិត្យ សូមទេវតាទាំងពួង ដែលរាប់កាន់ព្រះពុទ្ធជាម្ចាស់ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៣] នក្ខត្តានិ បុរក្ខត្វា    ទេវា មន្ទវលាហកា
សក្កោ បុរិន្ទទោ សេដ្ឋោ    សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឡោមព័ទ្ធនក្ខត្តឫក្ស ទេវតាខ្យល់ ទេវតាភ្លៀង ទេវតាមេឃ និងសក្កទេវរាជដ៏ប្រសើរដែលបានឲ្យទានក្នុងកាលមុន ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៤] មហាន្តា សហភូ ទេវា    ជលមគ្គិសិខារិវ
អរិដ្ឋកា ច រោជា ច    ឧមាបុប្ផនិភាសិនោ ។

*ទេវតាឈ្មោះសហភូ ដ៏ធំរុងរឿងដូចភ្លើង អរិដ្ឋកទេព និងរោជទេព អ្នកមានរស្មីដូចផ្កាត្រកៀត ។*

[២២៥] វរុណា សហធម្មា ច    អច្ចុតា ច អនេជកា
សូលេយ្យរុចិរា ទេវា    ទេវា វាសវនេសិនោ
ទសេតេ ទសធា កាយា    សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឈ្មោះវរុណៈ ឈ្មោះសហធម្មៈ ឈ្មោះអច្ចុតៈ ឈ្មោះអនេជកៈ ឈ្មោះសូលេយ្យៈ ឈ្មោះរុចិរៈ និងឈ្មោះវាសវនេសី សូមទេពដប់ពួកៗ និងដប់ពួកទាំងនោះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៦] សមានា មហាសមានា    មានុសា មានុសុត្តមា
ខិឌ្ឌាបទោសិកា ទេវា    ទេវា មនោបទោសិកា ។

*ទេវតាឈ្មោះសមានៈ ឈ្មោះមហាសមានៈ ឈ្មោះមានុសៈ ឈ្មោះមានុសុត្តមៈ ឈ្មោះខិឌ្ឌាបទោសិកៈ និងឈ្មោះ មនោបទោសិកៈ ។*

[២២៧] អថាបិ ហរយោ ទេវា ទេវា លោហិតវាសិនោ

ចារគា មហាចារគា សព្វេ ទេវា យសស្សិនោ

ឧសេតេ ឧសធា កាយា សធា សោត្ថឹ ករោន្តុ នោ ។

*ម្យ៉ាងទៀត ទេវតាឈ្មោះហរិ ឈ្មោះលោហិតវាសី ឈ្មោះ ចារគៈ ឈ្មោះមហាចារគៈ ទេវតាទាំងពួងនោះ បរិបូណ៌ ដោយបរិវារ សូមទេពដប់ពួកៗ និងដប់ពួកទាំងនោះ ចូរ ប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២២៨] សុក្កា ករុម្ហា អរុណា អាគុំ វេឃនសា សហ

ឱទាតគយ្ហា ចាមោក្ខា អាគុំ ទេវា វិចក្ខណា ។

*ទេវតាឈ្មោះសុក្កៈ ឈ្មោះករុម្ហៈ ឈ្មោះអរុណៈ មកហើយ ព្រមទាំងវេឃនសទេព ទេវតាឈ្មោះឱទាតគយ្ហៈ ជាប្រធាន ទេវតាឈ្មោះវិចក្ខណៈ ក៏មកព្រមគ្នា ។*

[២២៩] សទាមត្តា ហារគជា មិស្សកា ច យសស្សិនោ

ថនយំ អាគ បជ្ជុន្នោ យោ ទិសា អភិវស្សតិ ។

*ទេវតាឈ្មោះសទាមត្តៈ ឈ្មោះហារគជៈ ឈ្មោះមិស្សកៈ បរិបូណ៌ដោយបរិវារ និងបជ្ជុន្នទេព ដែលផ្គរឲ្យភ្លៀងធ្លាក់គ្រប់ទិស ក៏មកព្រមគ្នា ។*

[២៣០] ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ

ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ

មោទមានា ជិនទានា សទា សោត្ថឹ ករោន្តុ នោ ។

*ពួកទេពជប់ពួកៗ និងជប់ពួកទាំងនោះ មានសម្បុរផ្សេងៗគ្នា មានឫទ្ធិច្រើន មានអានុភាពច្រើន មានសម្បុរល្អ បរិបូណ៌ដោយបរិវារ រីករាយចិត្ត ដែលឲ្យនូវជ័យជម្នះ ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣១] លោកធាតុសហស្សេសុ ទសស្វេវ សមន្តតោ

ទេវាទយោ ចាណាគណា សទា សោត្ថឹ ករោន្តុ នោ ។

*សូមពួកសត្វមានទេវតាជាដើម ក្នុងម៉ឺនលោកធាតុដោយជុំវិញនោះឯង ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣២] ខេមិយា កដ្ឋកាយា ច ជោតិនាមា មហិទ្ធិកា

លម្ពីតកា លាមសេដ្ឋា សទា សោត្ថឹ ករោន្តុ នោ ។

*ទេវតាឈ្មោះខេមិយៈ ឈ្មោះកដ្ឋកាយៈ ឈ្មោះជោតិ មាន*

*ឫទ្ធិច្រើន ទេវតាឈ្មោះលម្ពីតកា និងឈ្មោះលាមសេដ្ឋៈ*
*ចូរប្រទាននូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៣] ជលដ្ឋា ច ថលដ្ឋញ្ច ទេវាកាសដ្ឋកាទយោ
យក្ខគន្ធព្វកុម្ភណ្ឌា បិសាចា យេ មហោរគា
មេត្តចិត្តា ច សព្វេ តេ សោត្ថី ជាសុំ ករោន្តុ នោ ។

*ទេវតាដែលនៅក្នុងទឹក ទេវតានៅលើគោក និងទេវតាដែល*
*នៅក្នុងអាកាស ជាដើមពួកដទៃ យក្ខ គន្ធព្វ កុម្ភណ្ឌ បិសាច*
*និងនាគរាជទាំងអស់ ចូរមានមេត្តាចិត្ត សូមប្រទាននូវផាសុក*
*គឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៤] តាវតឹសា ច យេ ទេវា យាមា ទេវា មហិទ្ធិកា
តុសិតា ច មហាទេវា និម្មានរតិនោ មរា ។

*ទេវតាឯណានៅជាន់តាវត្តិង្ស ជាន់យាមា មានឫទ្ធិច្រើន*
*ទេវតាដ៏ធំជាន់តុសិត ជាន់និម្មានរតី ។*

[២៣៥] វសវត្តិស រតិនោ សព្វេ ទេវា សវាសវា
ពុទ្ធបូជាយ និរតា សទា សោត្ថី ករោន្តុ នោ ។

*ម្យ៉ាងទៀត ទេវតាជាន់បរិនិម្មិតវសវតី សូមទេវតាទាំងពួង*
*ព្រមទាំងស្តេចវាសវៈ អ្នកត្រេកអរក្នុងពុទ្ធបូជា ចូរប្រទាន*
*នូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## **ព្រហ្ម**

[២៣៦] ព្រហ្មានោ បារិសជ្ជា ច   យេ ច ព្រហ្មបុរោហិតា
មហាព្រហ្មា ច សព្វេ តេ   បឋមជ្ឈានសណ្ឋិនោ ។

*ព្រហ្មទាំងឡាយឯណា ជាន់បារិសជ្ជា ជាន់បុរោហិតា និង ព្រហ្មជាន់មហាព្រហ្ម ព្រហ្មទាំងអស់នោះ ទ្រទ្រង់ក្នុង បឋមជ្ឈាន ។*

[២៣៧] មេត្តាវិហារិនោ សន្តា   សម្ពុទ្ធស្ស បរាយនា
ការោន្តុ នោ មហាសោត្ថឹ   សេក្ខាសេក្ខបុថុជ្ជនា ។

*ព្រហ្មទាំងនោះ នៅដោយមេត្តាជាប្រក្រតី ជាអ្នកស្ងប់ មានមុខឆ្ពោះទៅរកព្រះសម្ពុទ្ធ ទោះជាបុថុជ្ជន សេក្ខៈ និង អសេក្ខៈ ចូរប្រទាននូវសួស្តីដ៏ធំក្រៃលែង ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៣៨] បរិត្តាភាប្បមាណាភា   ព្រហ្មា ចាភស្សរា តថា
ពុទ្ធបូជាយ និរតា   ទុតិយជ្ឈានសណ្ឋិនោ ។

*ព្រហ្មជាន់បរិត្តាភា ព្រហ្មជាន់អប្បមាណាភា និងព្រហ្មជាន់ អាភស្សរា ជាអ្នកត្រេកអរក្នុងពុទ្ធបូជា ទ្រទ្រង់នៅក្នុង ទុតិយជ្ឈាន ។*

[២៣៩] មេត្តាការុណិកា សព្វេ   សព្វសត្តហិតេសិនោ
ការោន្តុ នោ មហាសន្តឹ   សោត្ថិមារោគ្យមាយុវំ ។

*ព្រហ្មទាំងអស់នោះ ប្រកបដោយមេត្តា និងករុណា ស្វែងរកប្រយោជន៍ផ្ទង់ផ្ដើមដល់ជនទាំងពួង ចូរប្រទាននូវការស្ងប់ដ៏ធំក្រៃលែង សួស្ដី សុខភាពល្អ និងអាយុវែងដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៨០] បរិត្តសុភាព្រហ្មានោ អប្បមាណសុភា ច យេ
សុភាកិណ្ហា ច ព្រហ្មានោ តតិយជ្ឈានសណ្ឋិនោ ។

*ព្រហ្មទាំងឡាយឯណា ឈ្មោះព្រហ្មជាន់បរិត្តសុភា ព្រហ្មជាន់អប្បមាណសុភា និងព្រហ្មជាន់សុភាកិណ្ហា ព្រហ្មទាំងអស់នោះ ទ្រទ្រង់នៅក្នុងតតិយជ្ឈាន ។*

[២៨១] បភាយ ជរណា លោកេ ពុទ្ធជ្ឈានរតា សទា
អហឹសា សព្វសត្តេសុ សទា សន្តឹ ករោន្តុ នោ ។

*ព្រហ្មទាំងនោះផ្សាយរស្មីទៅក្នុងលោក ត្រេកអរក្នុងការរលឹកដល់ព្រះពុទ្ធ ជាអ្នកមិនបៀតបៀនសត្វលោកទាំងមូល ចូរប្រទាននូវសេចក្ដីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៨២] វេហប្ផលាបិ ព្រហ្មានោ ចតុត្ថជ្ឈានសណ្ឋិនោ
សេក្ខបុថុជ្ជនាសេក្ខា សទា សន្តឹ ករោន្តុ នោ ។

*សូម្បីព្រហ្មជាន់វេហប្ផលា ទ្រទ្រង់នៅក្នុងចតុត្ថជ្ឈាន ទោះជាបុថុជ្ជន សេក្ខៈ និងអសេក្ខៈ ចូរ ប្រទាននូវសេចក្ដីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៣] សម្បត្តិយា ន ហាយន្តិ   ព្រហ្មានោ ជិនសាវកា

អវិហានាមកា សព្វេ   សទា សន្តិ ករោន្តុ នោ ។

*ពួកព្រហ្មទាំងអស់ ជាសាវករបស់ព្រះជិនស្រី រមែងមិន វិនាសចាកសម្បត្តិ ទើបបានឈ្មោះថា អវិហា ចូរប្រទាននូវ សេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៤] អតប្បា នាម ព្រហ្មានោ ចតុត្ថជ្ឈានសណ្ឋិនោ

ព្រហ្មវិហារិកា សព្វេ   សោត្ថិ ផាសុំ ករោន្តុ នោ ។

*ពួកព្រហ្មទាំងអស់ ទ្រទ្រង់នៅក្នុងចតុត្ថជ្ឈាន បរិបូណ៌ដោយ ព្រហ្មវិហារ ចូរប្រទាននូវផាសុក គឺសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៥] សុទស្សា នាម ព្រហ្មានោ-ភិរូបា ឈានភោគិនោ

អបុនាគមនា កាមេ   សន្តិ ផាសុំ ករោតុ នោ ។

*ពួកព្រហ្មឈ្មោះថា សុទស្សា មានរូបស្អាត សោយឈាន ជាអ្នកមិនត្រឡប់មកកាន់កាមភូមិទៀត ចូរប្រទាននូវផាសុក គឺសេចក្តីស្ងប់ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៤៦] ព្រហ្មវិហារសម្បន្នា   ជិនភត្តិបរាយនា

ព្រហ្មានោ សុទស្សី នាម   សទា សោត្ថិ ករោន្តុ នោ ។

ពួកព្រហ្មឈ្មោះថា សុទស្សី ដល់ព្រមហើយដោយព្រហ្ម-
វិហារ មានភក្តីក្នុងព្រះជិនស្រី ជាទីតាំង ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៤៧] អកនិដ្ឋា ច ព្រហ្មានោ   ជេដ្ឋា សព្វគុណោហិ ច

បហីនភាវនិស្នេហា   សទា សោត្ថឹ ករោន្តុ នោ ។

ពួកព្រហ្មឈ្មោះថា អកនិដ្ឋ ដ៏ប្រសើរដោយគុណទាំងពួង
កម្ចាត់សេចក្តីស្រឡាញ់ក្នុងភពបានហើយ ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៤៨] បឋមារូបព្រហ្មានោ   សព្វរូបវិរាគិនោ

ជិនភត្តិរតា សព្វេ   សទា សោត្ថឹ ករោន្តុ នោ ។

អរូបព្រហ្មជាន់ទី ១ ទាំងពួង ជាអ្នកមិនជាប់ជំពាក់ក្នុងរូប
ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវសួស្តី
ដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៤៩] ទុតិយារូបព្រហ្មានោ   ហេដ្ឋាឈានវិរាគិនោ

ជិនភត្តិរតា សព្វេ   សទា សោត្ថឹ ករោន្តុ នោ ។

អរូបព្រហ្មជាន់ទី ២ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន
ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ
សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

[២៨០] តតិយារូបព្រហ្មានោ ហេដ្ឋាឈានវិភាគិនោ

ជិនភត្តិរតា សព្វេ សទា សោត្ថី ករោន្តុ នោ ។

*អរូបព្រហ្មជាន់ទី ៣ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

[២៨១] ចតុត្ថារូបព្រហ្មានោ ហេដ្ឋាឈានវិភាគិនោ

ជិនភត្តិរតា សព្វេ សទា សោត្ថី ករោន្តុ នោ ។

*អរូបព្រហ្មជាន់ទី ៤ ទាំងពួង ជាអ្នកមិនពេញចិត្តក្នុងឈាន ជាន់ទាប ត្រេកអរក្នុងភក្តីចំពោះព្រះជិនស្រី ចូរប្រទាននូវ សួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។*

## ប្រភេទរួមបុគ្គល

[២៨២] វេទេហាបរគោយានេ ជម្ពុទីបេ កុរុម្ហិ ច

ទេវយក្ខបិសាចេហិ សទ្ធឹ វិជ្ជាធរាទយោ ។

*ពួកវិជ្ជាធរជាដើម ព្រមទាំងទេវតា យក្ខ និងបិសាច ក្នុងវេទេហទ្វីប អបរគោយានទ្វីប ជម្ពូទ្វីប និងឧត្តរកុរុទ្វីប។*

[២៨៣] អាកាសដ្ឋា ច ព្រហ្មានោ ជលដ្ឋា ចន្តលិក្ខជា

ទ្វិបទាទយោ យេ សត្តា សទា សោត្ថី ករោន្តុ នោ ។

ពួកព្រហ្មស្ថិតនៅក្នុងអាកាស និងសត្វជើងពីរជាដើម ដែលស្ថិតនៅក្នុងទឹក ឬអាកាស ចូរប្រទានទូវសួស្តីដល់ខ្ញុំទាំងឡាយ សព្វៗកាល ។

## អានុភាពព្រះរតនត្រ័យ

[២៩៨] មារសេនប្បភញ្ជនំ ជិនស្ស សុខឈាយនោ
តេជោពលេន មហតា សទា មង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះជិនស្រី ព្រះអង្គទ្រង់មានសេចក្តីសុខក្នុងឈាន ព្រោះបានកម្ចាត់បង់នូវមារាធិរាជព្រមទាំងសេនា សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៩៩] នានាគុណវិចិត្តស្ស រូបកាយស្ស សត្ថុនោ
សព្វទេវមនុស្សានំ មារពន្ធវិមោចិនោ
មេត្តាពលេន មហតា សទា មង្គលមត្ថុ នោ ។

ដោយតេជានុភាពនៃព្រះមេត្តាដ៏ធំក្រៃលែងនៃព្រះរូបកាយដ៏វិចិត្រផ្សេងៗរបស់ព្រះសាស្តា ព្រះអង្គទ្រង់ញ៉ាំងទេវតានិងមនុស្សទាំងពួង ឲ្យរួចផុតចាកគ្រឿងចំណងរបស់មារ សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៩៦]សព្វញ្ញុតាទិកាយស្ស ធម្មកាយស្ស សត្ថុនោ
ចក្ខាទ្យគោចរស្សាបិ គោចរស្សេវ ភ្វិយា
តេជោពលេន មហាតា សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះធម្មកាយ ដែលមានព្រះសព្វញ្ញុតញ្ញាណជាដើមរបស់ព្រះសាស្តា សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

[២៩៧]រូបកាយសទិសស្ស និម្មិតស្ស មហេសិនោ
ធម្មស្ស វត្ថុនោ សត្ថេ ទេវានំ សុគតា បតិ
តេជោពលេន មហាតា សទា មង្គលមត្ថុ នោ ។

*ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះពុទ្ធនិម្មិត ដែលព្រះពុទ្ធជាម្ចាស់ទ្រង់និម្មិតហើយ ដូចជាព្រះរូបកាយរបស់ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ សម្តែងធម៌ដល់ទេវតាទាំងឡាយក្នុងស្ថានតាវត្តិង្ស សូមមង្គលចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

[២៩៨]សិក្ខិត្វា មានុសេ ទេវេ មោចយិត្វា សទេវកេ
សង្ខារេ បជហន្តស្ស និព្វុតស្ស មហេសិនោ
មហាន្តេនានុភាវេន សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងរបស់ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជាអ្នកស្វែងរកនូវគុណធំ ព្រះអង្គទ្រង់បង្រៀននូវទេវតានិងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ញ៉ាំងទេវតានិងមនុស្សទាំងឡាយ ឲ្យរួចផុតចាកអន្ទាក់របស់មារ លះសង្ខារទាំងឡាយបរិនិព្វានហើយ សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៥៩]ចតុរាសីតិសហស្ស　　ធម្មក្ខន្ធស្ស តេជសា

នវង្គសាសនស្សាបិ　　នវលោកុត្តរស្ស ច

សព្វបាបបវាហេន　　សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពនៃព្រះធម៌ ៨៤,០០០ ព្រះធម្មក្ខន្ធ នវង្គសត្ថុសាសន៍ និងនវលោកុត្តរធម៌ ដែលនាំបាបទាំងពួងចេញហើយ សូមមង្គលទាំងពួង ចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

[២៦០]មហាគោរិយសង្ឃស្ស　　បុញ្ញក្ខេត្តស្ស តាទិនោ

បហីនសព្វបាបស្ស　　សីលាទិគុណធារិនោ

មហាតេជានុភាវេន　　សព្វមង្គលមត្ថុ នោ ។

ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះអរិយសង្ឃ ជាស្រែបុណ្យ ដែលមិនកម្រើកញាប់ញ័រ ជាអ្នកលះបាបទាំងពួងហើយ ទ្រទ្រង់នូវគុណមានសីលជាដើម សូមមង្គលទាំងពួងចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។

## អានុភាពទេវតា

[២៦១]ទាតាលេ ភូតលាកាសេ ទេវយក្ខបិសាចកា

វិជ្ជាធរា ច គន្ធព្វា        នាគកុម្ភណ្ឌរក្ខសា

សព្វេសមានុភាវេន        សព្វមង្គលមត្ថុ នោ ។

*ដោយតេជានុភាពនៃសត្វទាំងពួង គឺទេវតា យក្ខ បិសាច វិជ្ជាធរ គន្ធព្វ នាគ កុម្ភណ្ឌ និងរក្ខសទេវតាទាំងឡាយ ដែលស្ថិតនៅក្រោមផែនដី លើផែនដី និងក្នុងអាកាស សូមមង្គលទាំងពួង ចូរកើតមានដល់យើងទាំងឡាយគ្រប់កាលទាំងពួង ។*

## អានុភាពនៃឧប្បាតសន្តិ

[២៦២]ឥច្ចេវមុប្បាតសន្តឹ        យោ វទេយ្យ សុណេយ្យ វា

វិជេយ្យ សព្វទាទានិ        វុឌ្ឍត្តញ្ច ភវិស្សតិ ។

*បុគ្គលណាស្វាធ្យាយ ឬស្តាប់ឧប្បាតសន្តិ ដែលខ្ញុំពោលមកហើយយ៉ាងនេះ បុគ្គលនោះ គប្បីឈ្នះបាបទាំងពួង នឹងមានសេចក្តីចម្រើនរុងរឿង ។*

[២៦៣] សោត្ថិកាមោ លភេ សោត្ថឹ    សុខកាមោ សុខំ លភេ

អាយុកាមោ លភេយ្យាយុំ    បុត្តកាមោ លភេ បុត្តេ។

*អ្នកប្រាថ្នានូវសួស្តី រមែងបាននូវសួស្តី អ្នកប្រាថ្នាសុខ រមែង*

*បានសុខ អ្នកប្រាថ្នាអាយុ រមែងបានអាយុ អ្នកប្រាថ្នាបុត្រ រមែងបានបុត្រ ។*

[២៦៤] ន តស្ស រោគា ជាយន្តិ វាតបិត្តាទិសម្ភវា
អកាលមរណំ នត្ថិ ន ទេវា វិសមោសរេ ។

*រោគកើតពីខ្យល់និងប្រមាត់ជាដើម រមែងមិនបៀតបៀនបុគ្គលនោះ សេចក្តីស្លាប់មុនកាល រមែងមិនមាន ទេវតាមិនបៀតបៀនឲ្យធ្លាក់ចុះ ។*

[២៦៥] ន ចុប្បាតភយំ តស្ស នោបិ បត្តភយំ តថា
នស្សន្តិ ទុន្និមិត្តានិ ចាបកម្មជ្ជិតានិ ច
ទីឃមាយុ មហាសោត្ថិ អារោគ្យញ្ច សទា ភវេ ។

*ភ័យគឺហេតុអាក្រក់ រមែងមិនមាន ភ័យចំពោះមុខ នឹងមិនកើតឡើង និមិត្តអាក្រក់និងបាបគ្រោះ រមែងវិនាសទៅ ការមានអាយុវែង សិរីសួស្តីដ៏ធំ ការមិនមានរោគ នឹងគប្បីមាន (ដល់បុគ្គលអ្នកស្វាធ្យាយ ឬអ្នកស្តាប់) ។*

[២៦៦] យោ សុត្វាបិ មហាសន្តឹ សង្គាមំ បវិសេ នរោ
វិជយេ វេរិនោ សព្វេ ន សត្ថេហ្យភិភុយ្យតេ។

*បុគ្គលណាស្តាប់ឧប្បាតសន្តិដ៏ប្រសើរហើយ គប្បីចូលទៅកាន់សង្គ្រាម នឹងឈ្នះសឹកសត្រូវ សាស្ត្រាវុធមិនអាចមុតបានឡើយ ។*

[២៦៧] សព្វទា លភតេ បីតឹ    វិបត្តឹ នាវគាហតិ

រោគេហិ នាភិភូយតេ    សវត្ថុហិ វិវឌ្ឍតេ ។

*រមែងបានទទួលនូវបីតិសព្វៗកាល មិនមានវិបត្តិ មិនមាន*
*រោគបៀតបៀន រមែងចម្រើនដោយទ្រព្យ ។*

[២៦៨] យត្រ ទេសេ មហោរគា    ពាឡ្ហកា រក្ខសាទយោ

ឧប្បាតសន្តិឃោសេន    សព្វេ តត្ថ សមន្តិ តេ ។

*ពស់ធំនិងអារក្សទឹកជាដើមដែលអាក្រក់ នៅក្នុងទីណា*
*ទាំងអស់នោះ រមែងស្ងប់ទៅក្នុងស្ថានទីនោះ ដោយ*
*សំឡេងស្វាធ្យាយឧប្បាតសន្តិ ។*

[២៦៩] យមុទ្ទិស្សវេ សន្តឹ    សជីវញ្ចាប្យជីវិតំ

សោ មុច្ចតេ មហាទុក្ខា    បប្បោតិ សុគតឹ សទា ។

*បុគ្គលស្វាធ្យាយឧប្បាតសន្តិ ដោយឧទ្ទិសឲ្យអ្នកណា ដែល*
*មានជីវិតរស់នៅ ឬមិនមានជីវិត រមែងរួចផុតចាកទុក្ខដ៏ធំ*
*រមែងដល់នូវសុគតិភព ។*

[២៧០] ទេវដ្ឋានេ នគរេ វា    និច្ចមុប្បាតសន្តិយា

ចាលកា ទេវរាជានោ    តេជសិរីវិវឌ្ឍនា ។

*ទេវតារក្សាទេវដ្ឋាន ឬក្នុងព្រះនគរ ជាអ្នកចម្រើនដោយតេជះ*
*និងសិរីមង្គល ដោយឧប្បាតសន្តិ ដែលស្វាធ្យាយឧទ្ទិសឲ្យ។*

[២៧១] បថព្យាទាទិសញ្ជាតា ឧប្បាតា ចន្ទលិក្ខជា
ឥន្ទាទិជនិតុប្បាតា ចាបកម្មសមុដ្ឋិតា
សព្វុប្បាតា វិនស្សន្តិ តេជសុប្បាតសន្តិយាតិ ។

*ហេតុអាក្រក់ដែលកើតពីផែនដី និងទឹកជាដើម ដែលកើតពីអាកាស ដែលកើតពីចន្ទគ្រាសជាដើម ឬដែលកើតពីបាបកម្ម ហេតុអាក្រក់ទាំងអស់នោះ នឹងវិនាសទៅដោយតេជៈនៃឧប្បាតសន្តិ ។*

**ឧប្បាតសន្តិ និដ្ឋិតា ។**

**ចប់ឧប្បាតសន្តិ**

# ឥតិបិសោរតនមាលា

## ព្រះពុទ្ធគុណ ៥៦

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

*ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសព្រមទាំងវាសនាគឺ កាយប្បយោគនិងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិទ្រង់*

ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គ ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

ឥ. ឥដ្ឋោ សព្វញ្ញុតញ្ញាណំ ឥច្ឆន្តោ អាសវក្ខយំ
ឥដ្ឋំ ធម្មំ អនុប្បត្តោ ឥទ្ធិមន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រាថ្នាសព្វញ្ញុតញ្ញាណ
គ្មានធុញថប់ត្រឡប់ថយក្រោយ ពុំមានធ្វោយទាល់ក្ស័យ
អាសវៈ ទ្រង់ទម្លុះនូវធម៌ដែលព្រះអង្គប្រាថ្នាហើយ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន
សេចក្តីប្រាថ្នាសម្រេចហើយ ។

តិ. តិណ្ណោ យោ វដ្តទុក្ខម្ហា តិណ្ណំ លោកានមុត្តមោ
តិស្សោ ភូមី អតិក្កន្តោ តិណ្ណាឱឃំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ឆ្លងចាកទុក្ខក្នុងវដ្តៈទាំង ៣
ភូមិទាំង ៣ ហើយព្រះអង្គប្រសើរឧត្តម ខ្ញុំសូមនមស្ការ

*នូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលបានធ្វើឱយ:ហើយ ។*

បិ. បិយោ ទេវមនុស្សានំ បិយោ ព្រហ្មានមុត្តមោ

បិយោ នាគសុបណ្ណានំ បិណិន្ទ្រិយំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ជាទីស្រឡាញ់នៃទេវតានិង មនុស្សទាំងឡាយ ជាទីស្រឡាញ់ដ៏ខ្ពង់ខ្ពស់នៃព្រហ្ម ទាំងឡាយ ជាទីស្រឡាញ់នៃនាគនិងគ្រុឌទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន ឥន្ទ្រិយស្មើត្រឹម ។*

សោ. សោកា វិរត្តចិត្តោ យោ សោភមានោ សទេវកេ

សោកបត្តេ បមោទេន្តោ សោភវណ្ណំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជៀសវាងផុតចាកសោក ហើយ ទ្រង់ល្អក្នុងលោក ព្រមទាំងទេវលោក ហើយ ញុំាងសត្វដែលមានសោកឲ្យរីករាយ ខ្ញុំសូមនមស្ការនូវ ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានឆវីវណ្ណដ៏ស្អាត ។*

ភ. ភជិតា យេន សទ្ធម្មា ភគ្គចាបេន តាទិនា

ភយសត្តេ បហាសេន្តោ ភយសន្តំ នមាមិហំ ។

*ព្រះសទ្ធម្មទាំងឡាយ ដែលព្រះពុទ្ធជាម្ចាស់អង្គឯណា មានបាបធម្មាយបំបាក់ចោលហើយ មានព្រះហឫទ័យមាំ*

ទ្រង់ចែកហើយ ព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់ញុំាងសត្វ
ដែលភ័យខ្លាច ឲ្យបាត់ភ័យខ្លាច ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានភ័យស្ងប់ហើយ ។

គ. គមិតោ យេន សទ្ធម្មោ គមាបិតោ សទេវកំ
គច្ឆមានោ សិវំ រម្មំ គតធម្មំ នមាមិហំ ។

ព្រះសទ្ធម្មទាំងឡាយ ដែលព្រះពុទ្ធជាម្ចាស់អង្គឯណា
ទ្រង់ទម្លុះហើយ ទ្រង់ញុំាងមនុស្ស ព្រមទាំងទេវតា
ឲ្យទម្លុះហើយ ទ្រង់ទម្លុះដល់ព្រះនិព្វាន ជាទីរីករាយ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន
ធម៌ទម្លុះហើយ ។

វា. វានា និក្ខមិ យោ តណ្ហា វាចំ ភាសតិ ឧត្តមំ
វាននិព្វាបនត្ថាយ វាយមន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចេញចាកវានៈគឺតណ្ហា
ទ្រង់ពោលព្រះវាចាដ៏ឧត្តម ប្រយោជន៍ដល់ការរលត់
នូវតណ្ហា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ
ដែលជាអ្នកមាននូវសេចក្តីព្យាយាម ។

អ. អនស្សា សកសត្តានំ អស្សាសំ ទេតិ យោ ជិនោ
អនន្តគុណសម្បន្នោ អន្តគាមឹ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវភាពកក់ក្តៅ

ដល់សត្វទាំងឡាយ ដែលមិនមានភាពកក់ក្តៅ ទ្រង់
ដល់ព្រមដោយគុណទាំងឡាយ រកប្រមាណមិនបាន
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់
នូវទីបំផុត (នៃទុក្ខ) ។

រ. រតោ និព្វានសម្បត្តេ    រតោ យោ សត្តមោចនេ

រម្មាបេតីធ សត្តេ យោ    រណាចាគំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរហើយក្នុង
និព្វានសម្បត្តិ ទ្រង់ត្រេកអរក្នុងការញ៉ាំងសត្វឲ្យរួចចាកទុក្ខ
ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ញ៉ាំងសត្វទាំងឡាយក្នុង
លោកនេះ ឲ្យត្រេកអរ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
អង្គនោះ ដែលជាអ្នកលះបង់នូវសត្រូវគឺកិលេស ។

ហំ. ហញ្ញតិ បាបកោ ធម្មេ    ហំសាបេតិ បរំ ជនំ

ហំសមានំ មហាវីរំ    ហន្តុបាបំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្លាប់បាបធម៌ជាខាង
ក្នុង ហើយញ៉ាំងជនដទៃឲ្យសម្លាប់បាបធម៌ដែរ ខ្ញុំសូម
នមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកសម្លាប់
នូវបាប ជាមហាវីរៈ កម្ចាត់បាបបាន ។

ស. សង្ខតាសង្ខតេ ធម្មេ    សម្មា ទេសេសិ បាណិនំ

សំសារំ សំវិយាជេតិ    សមុទ្ធត្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្តែងនូវធម៌ដែលជា
សង្ខត: និងអសង្ខត: ដល់សត្វទាំងឡាយដ៏ប្រពៃ
ទ្រង់ពិឃាតនូវសង្សារវដ្តបានហើយ ខ្ញុំសូមនមស្ការ
នូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាព្រះសម្ពុទ្ធ ។

ម្ចា. មាតាវ ចាលិតោ សត្តេ មានជទ្ធេ បមទ្ទិនោ
មានិតោ ទេវសង្ឃេហិ មានឃាដំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់រក្សានូវសត្វទាំងឡាយ
ដូចមាតារក្សានូវកូន ទ្រង់ញាំញីនូវមានះដ៏រឹងត្អឹង ទ្រង់ជា
អ្នក ដែលពួកទេវតាតែងបូជាហើយ ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកសម្លាប់នូវមានះ ។

ស. សព្វាយំ ចារមី សម្មា សព្វិត្វា សុខមត្តនោ
សង្ខារានំ ខយំ ទិស្វា សន្តគាមី នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សន្សំនូវបារមីទាំងឡាយ
ដ៏ប្រពៃ ទ្រង់សុខក្នុងអង្គជាសុខុមល្អិត ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកដល់នូវធម៌ដ៏ស្ងប់
ព្រោះឃើញនូវការអស់ទៅនៃសង្ខារទាំងឡាយ ។

ម្ពុ. ពុជ្ឈិត្វា ចតុសច្ចានិ ពុជ្ឈាបេតិ មហាជនំ
ពុជ្ឈាបេន្តំ សិវំ មគ្គំ ពុទ្ធសេដ្ឋំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រាស់ដឹងច្បាស់នូវ

សច្ចៈទាំង ៤ ទ្រង់ញ៉ាំងមហាជនឲ្យត្រាស់ដឹងផង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធដ៏ប្រសើរអង្គនោះ ដែលជាអ្នកបង្ហាញសត្វឲ្យដឹងផ្លូវព្រះនិព្វាន ។

ធោ. ធោតិ រាគេ ច ទោសេ ច ធោតិ មោហេ ច ចាណិនំ

ធោតក្លេសំ មហាបុញ្ញំ ធោតាសវំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់លាងនូវរាគៈ ទោសៈ និងមោហៈជ្រះហើយ ញ៉ាំងសត្វទាំងឡាយឲ្យលាងកិលេសអស់ហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកមានបុណ្យច្រើន មានអាសវៈលាងហើយ ។

វិ. វិវេចេតិ អសទ្ធម្មា វិចិត្វា ធម្មទេសនំ

វិវេកេ ឋិតចិត្តោ យោ វិទិតន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ឆ្ងាយស្ងាត់ចាកអសទ្ធម្ម ហើយទ្រង់វិចិត្រនូវធម្មទេសនា តម្កល់ព្រះទ័យក្នុងវិវេក ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកប្រាជ្ញ ។

ជា. ជាតិធម្មោ ជរាធម្មោ ជាតិអន្តោ បកាសិតោ

ជាតិសេដ្ឋេន ពុទ្ធេន ជាតិមុត្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា មានជាតិជាព្រះពុទ្ធដ៏ប្រសើរ ហើយទ្រង់ប្រកាសសម្ដែងនូវព្រះនិព្វានជាទីបំផុតនៃជាតិ

គឺជាតិធម៌ និងជរាធម៌ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលរួចផុតចាកជាតិ ។

ច. ចយេតិ បុញ្ញសម្ភារេ ចយេតិ សុខសម្បទំ

ចជន្តំ ចាបកម្មានិ ចជាបេន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រកបនូវបុណ្យសម្ភារ ទើបសន្សំបាននូវសុខសម្ប័ទ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលលះបង់នូវបាបកម្មទាំងឡាយដោយខ្លួនឯង ហើយញុំាងសត្វឲ្យលះបង់ផង ។

រ. រមិតំ យេន និព្វានំ រក្ខិតា លោកសម្បទា

រជទោសាទិក្លេសេហិ រហិតំ តំ នមាមិហំ ។

ព្រះនិព្វានដែលព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរហើយ លោកសម្បទាដែលព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់រក្សាទុកហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលវៀរចាកកិលេសទាំងឡាយមានទោសៈជាដើម ។

ណ. នមិតោយេវ ព្រហ្មេហិ នរទេវេហិ សព្វទា

នទន្តោ សីហនាទំ យោ នទន្តំ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បន្លឺសីហនាទ ជាទីត្រេកអរនៃមនុស្ស ទេវតា និងព្រហ្មទាំងឡាយ តែងថ្វាយបង្គំ

សព្វកាល ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកបន្លឺសីហនាទ ។

ស. សង្ខារេ តិវិធេ លោកេ សញ្ញានាតិ អនិច្ចតោ

សម្មា និព្វានសម្បត្តិ សម្បន្នោ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់កំណត់ដឹងនូវសង្ខារទាំងឡាយក្នុងលោកទាំង ៣ ដោយភាពជារបស់មិនទៀង ទ្រង់ដល់ព្រមដោយនិព្វានសម្បត្តិដ៏ប្រពៃ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ។

ប្ប. បករតោ ពោធិសម្ភារេ បសដ្ឋោ យោ សទេវកេ

បញ្ញាយ ន សមោ ហោតិ បសន្នំ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សាងសន្សំពោធិសម្ភារ ទើបបានជាអ្នកប្រសើរបំផុតក្នុងមនុស្ស ព្រមទាំងទេវតា មិនមានអ្នកស្មើដោយបញ្ញារបស់ព្រះអង្គ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកថ្លៃថ្នូរ ។

ន្នោ. នោ ទេតិ និរយំ គន្តុំ នោ ច ចាបំ អការយិ

នោ សមោ អត្ថិ បញ្ញាយ នោនធម្មំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ការពារសត្វមិនឲ្យធ្លាក់ទៅនរក និងមិនឲ្យធ្វើអំពើបាប អ្នកណាមួយស្មើដោយបញ្ញារបស់ព្រះអង្គមិនមាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធ

ជាម្ចាស់អង្គនោះ ជាអ្នកមិនធ្វេសប្រហែស ។

សុ. សុន្ទរោ វររូបេន សុសរោ ធម្មភាសនេ

សុទុទ្ទសំ ទិសាបេតិ សុគតំ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា មានព្រះរូបដ៏ស្អាត ទ្រង់សម្ដែងព្រះធម៌ មានសូរសៀងពីរោះក្រៃ ប្រោសវេនេយ្យសត្វឲ្យឃើញធម៌ ដែលឃើញបានដោយលំបាក ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់មានដំណើរយាងទៅល្អហើយ ។

គ. គច្ឆន្តោ លោកិយា ធម្មា គច្ឆន្តោ អមតំ បទំ

គតោ សោ សត្តមោចេតុំ គតញ្ញាណំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចេញចាកលោកិយធម៌ ដល់នូវបទគឺអមតធម៌ ទ្រង់យាងទៅទីណាៗ ក៏ដើម្បីរំដោះសត្វចាកទុក្ខ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់ហើយនូវសព្វញ្ញុតញ្ញាណ ។

តោ. តោសេន្តោ វរធម្មេន តោសជ្ឈានេ សិវេ វរេ

តោសំ អកាសិ ជន្តូនំ តោសចិត្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ញុំាងសត្វឲ្យរីករាយ ដោយធម៌ដ៏ប្រសើរ ទ្រង់ធ្វើនូវសេចក្ដីត្រេកអរក្នុងព្រះនិព្វាន ដែលជាទីត្រេកអរដល់សត្វទាំងឡាយ

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះទ័យរីករាយ ។*

លោ. លោកេ ជហាតិ សម្ពុទ្ធោ   លោកសេដ្ឋោ គុណាករោ

លោកេ សត្តេ ជហាបេតិ លោកសន្តំ នមាមិហំ ។

*ព្រះសម្ពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជាអ្នកធ្វើនូវគុណដ៏ប្រសើរក្នុងលោក ទ្រង់លះបង់នូវលោកៈបាន ហើយញុំាងសត្វឲ្យលះបង់នូវលោកៈដែរ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានលោកៈស្ងប់ហើយ ។*

ក. កន្តោ យោ សព្វសត្តានំ   កត្វា ទុក្ខក្ខយំ ជិនោ

កថេន្តោ មធុរំ ធម្មំ   កថាសណ្ហំ នមាមិហំ ។

*ព្រះពុទ្ធជិនស្រីជាម្ចាស់អង្គឯណា ទ្រង់ជាទីស្រឡាញ់នៃសព្វសត្វទាំងឡាយ ទ្រង់សម្ដែងនូវធម៌ដែលមានសំឡេងពីរោះផ្អែម ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះវាចាដ៏ល្អិតសុខុម ។*

វិ. វិនយំ យោ បកាសេតិ   វិទ្ធំសេត្វា តយោ ភវេ

វិសេសញ្ញាណសម្បន្នោ   វិប្បសន្នំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្ដែងនូវព្រះវិន័យ ទ្រង់ទម្លាយនូវត្រៃភពហើយ ទ្រង់ដល់ព្រមដោយព្រះញាណដ៏វិសេស ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*

*អង្គនោះ ដែលមានព្រះទ័យថ្លាស្អាតបរិសុទ្ធ ។*

ទូ. ទូរេ សតេ្ត បហាសេន្តោ ទូរដ្ឋានេ បកាសតិ

ទូរំ និព្វានមាគម្ម ទូរសហន្តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ញ៉ាំងសត្វអ្នកប្រទូស្តរ៉ាយ ឲ្យរីករាយបាត់ក្រោធខឹង ដោយព្រះធម៌ ទ្រង់មានកិត្តិគុណប្រាកដទៅឆ្ងាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់ដល់ដែនដ៏ឆ្ងាយគឺព្រះនិព្វាន ហើយកម្ចាត់បង់នូវសេចក្តីអាក្រក់ ។*

អ. អន្តំ ជាតិជរាទីនំ អកាសិ ទិបទុត្តមោ

អនេកស្សាហចិត្តេន អស្សាសេន្តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រសើរជាងសត្វអ្នកមានជើងពីរ ទ្រង់ធ្វើទីបំផុតនៃទុក្ខ មានជាតិ និងជរាជាដើមហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលប្រោសសត្វឲ្យរីករាយ ដោយទឹកព្រះទ័យគឺឧស្សាហៈដ៏ច្រើន ។*

នុ. នុទេតិ រាគចិត្តានិ នុទាបេតិ បរំ ជនំ

នុន អត្តំ មនុស្សានំ នុសាសន្តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បន្ទោបង់នូវរាគចិត្តបានហើយ ទ្រង់ញ៉ាំងជនដទៃឲ្យបន្ទោបង់ដែរ ខ្ញុំ*

សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់បង្រៀនធម៌ជាប្រយោជន៍ដល់មនុស្សទាំងឡាយដ៏ពិតប្រាកដ ។

ត្ត. តនោតិ កុសលំ កម្មំ តនោតិ ធម្មទេសនំ

តណ្ហាយ វិចរន្តានំ តណ្ហាឃាដំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ផ្សព្វផ្សាយនូវធម៌ដែលជាកុសល ទ្រង់ពង្រីកការសម្ដែងព្រះធម៌ឲ្យទូលាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជួយកម្ចាត់នូវតណ្ហារបស់សត្វទាំងឡាយ ដែលត្រាច់ទៅដោយតណ្ហា ។

រោ. រោសេន្តោ នេវ កោបេតិ រោសេហេវ ន កុជ្ឈតិ

រោគានំ រាគអាទីនំ រោគហន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់មិនក្រោធអ្នកដែលក្រោធ ទ្រង់មិនមានក្រោធសោះ ចំពោះមនុស្សដែលក្រោធ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់កម្ចាត់រោគនៃរោគទាំងឡាយ មានរាគៈជាដើម ។

បុ. បុណ្ណន្តំ អត្តនោ ចាបំ បូរេន្តំ ទសបារមី

បុញ្ញវន្តស្ស រាជស្ស បុត្តភូតំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់កម្ចាត់បាប

របស់ព្រះអង្គ ទ្រង់បំពេញហើយនូវបារមី ១០ ជាឱរសរបស់ព្រះរាជាអ្នកមានបុណ្យ ។

វិ. វិបុរាគាទិភូតំ វ  វិទ្ធិយា បដិហញ្ញតិ
វិត្តំ កម្មំ ន ការេតា-  វិយវំសំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់កម្ចាត់នូវវត្ថុដែលជាសត្រូវ មានរាគៈជាដើម ដោយបុញ្ញឫទ្ធិ ទ្រង់មិនញុំាងសត្វឲ្យធ្វើនូវកម្ម ដែលឥតប្រយោជន៍ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាវង្សព្រះអរិយៈ ។

ស. សម្បន្នោ វរសីលេន  សមាធិបវរោ ជិនោ
សយម្ភូញាណសម្បន្នោ  សណ្ហវាចំ នមាមិហំ ។

ព្រះពុទ្ធជិនស្រីជាម្ចាស់អង្គឯណា ទ្រង់ដល់ព្រមដោយសីលដ៏ប្រសើរ មានសមាធិដ៏ខ្ពង់ខ្ពស់ ប្រកបដោយសយម្ភូញាណ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះវាចាដ៏ពីរោះ ។

ទ. ទន្តោ យោ សកចិត្តានិ  ទមិត្វាបិ សទេវកំ
ទទន្តោ អមតំ ខេមំ  ទន្តិន្ទ្រិយំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ទូន្មាននូវចិត្តរបស់អង្គឯងហើយ ទ្រង់ទូន្មានសូម្បីនូវមនុស្ស និងទេវតា ហើយ

ប្រទាននូវអមតធម៌ដ៏ក្សេម ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានឥន្ទ្រិយទូន្មានហើយ ។

ម្ម. មហុស្សាហេន សម្ពុទ្ធោ មហន្តំ ញាណមាគមិ
មហិតំ នរទេវេហិ មនោសុទ្ធំ នមាមិហំ ។

ព្រះសម្ពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បាក់ដុះនូវញាណដ៏ធំ ដោយសេចក្ដីព្យាយាមដ៏ក្រៃលែង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានមនោដ៏បរិសុទ្ធ ដែលមនុស្ស ព្រមទាំងទេវតាតែងគោរពបូជា ។

សា. សារំ ទេតីធ សត្តានំ សារេតិ អមតំ បទំ
សារថី វិយ សារេតិ សារធម្មំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវធម៌ដ៏ខ្លឹមដល់សត្វទាំងឡាយ ហើយញ៉ាំងសត្វទាំងឡាយឲ្យដល់នូវបទគឺអមតៈ ដូចសារថីញ៉ាំងសេះឲ្យស្ទុះទៅកាន់ទីដែលខ្លួនប្រាថ្នា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានធម៌ជាសារៈ ។

រ. រម្មតារិយសទ្ធម្មេ រម្មាបេតិ សសាវកំ
រម្មេ ឋានេ វសាបេន្តំ រណាហន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរក្នុងអរិយសទ្ធម្ម ទ្រង់ញ៉ាំងសាវករបស់ព្រះអង្គ ឲ្យត្រេកអរផង ខ្ញុំសូម

*នមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលញុំាងសាវ័កឲ្យតាំងនៅក្នុងឋានៈដែលគួរត្រេកអរ កម្ចាត់សត្រូវគឺកិលេស ។*

ឋិ. ឋិតោ យោ វរនិព្វានេ ឋិរេ ឋានេ សសាវកោ

ឋិរំ ឋានំ បកាសេតិ ឋិតំ ធម្មេ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ព្រមទាំងសាវ័ករបស់ព្រះអង្គតាំងនៅក្នុងឋានៈដ៏មាំទាំគឺព្រះនិព្វាន ទ្រង់ប្រកាសនូវឋានៈដ៏មាំទាំគឺព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលតាំងនៅក្នុងធម៌ ។*

ស. សទ្ធម្មំ ទេសយិត្វាន សន្តនិព្វានចាបកំ

សសាវកំ សមាហិតំ សន្តចិត្តំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ព្រមទាំងសាវ័ករបស់ព្រះអង្គ ដែលសម្ដែងនូវព្រះសទ្ធម្មឲ្យដល់នូវព្រះនិព្វានដ៏ស្ងប់ ជាអ្នកតាំងមាំ មានចិត្តដ៏ស្ងប់ ។*

ឋា. ឋានំ និព្វានសង្ខាតំ ឋាមេនាធិគតោ មុនិ

ឋានេ សគ្គសិវេ សត្តេ ឋាបេន្តំ តំ នមាមិហំ ។

*ព្រះមុនីជាម្ចាស់អង្គឯណា បានចាក់ចុះនូវឋានៈពោលគឺព្រះនិព្វាន ដោយកម្លាំងគឺសេចក្ដីព្យាយាម ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលញុំាងសត្វ*

*ឲ្យតាំងនៅក្នុងឋានៈគឺសួគ៌និងនិព្វាន ។*

ទេ. ទេន្តោ យោ សគ្គនិព្វានំ ទេវមនុស្សទាណិកំ

ទេន្តំ ធម្មវរំ ទានំ ទេវសេដ្ឋំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវសម្បត្តិគឺ*
*សួគ៌និងនិព្វាន ដល់ពួកសត្វគឺមនុស្សនិងទេវតា*
*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ជាទេវៈ*
*ប្រសើរប្រទាននូវធម៌ដ៏ប្រសើរ ។*

វ. វន្តរាគំ វន្តទោសំ វន្តមោហំ អនាសវំ

វន្ទិតំ ទេវព្រហ្មេហិ វរំ ពុទ្ធំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ ទ្រង់ខ្ជាក់*
*ចេញនូវរាគៈ ខ្ជាក់ចេញនូវទោសៈ ខ្ជាក់ចេញនូវមោហៈ*
*ជាអ្នកមិនមានអាសវៈ ដែលទេវតានិងព្រហ្មទាំងឡាយ*
*ក្រាបថ្វាយបង្គំហើយ ។*

ម. មហាតា វីរិយេនាបិ មហន្តំ ចារមី អកា

មនុស្សទេវព្រហ្មេហិ មហិតន្តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សាងបារមីដ៏ធំធេង*
*ដោយសេចក្ដីព្យាយាមដ៏ធំ ខ្ញុំសូមនមស្ការនូវព្រះ*
*ពុទ្ធជាម្ចាស់អង្គនោះ ដែលមនុស្ស ទេវតា និង*
*ព្រហ្មទាំងឡាយបូជាហើយ ។*

៤១១

នុ. នុនធម្មំ បកាសេន្តោ នុទនត្ថាយ ចាបកំ

នុន ទុក្ខាធិបន្នានំ នុទាបិតំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្តែងធម៌ដ៏ពិត ដើម្បីដកចេញនូវបាបរបស់សត្វទាំងឡាយ ដែលជាប់នៅក្នុងទុក្ខ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលប្រោសសត្វឲ្យចេញចាកបាបបាន ។*

ស្បា. សាវកានំនុសាសេតិ សារធម្មេ ច ចាណិនំ

សារធម្មំ មនុស្សានំ សាសិតំ តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បង្រៀនសារធម៌ដល់សាវកទាំងឡាយ និងសត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលបង្រៀនធម៌ជាសារៈដល់មនុស្សទាំងឡាយ ។*

នំ. នន្ទន្តោ វរសទ្ធម្មេ នន្ទាបេតិ មហាមុនិ

នន្ទភូតេហិ ទេវេហិ នន្ទនីយំ នមាមិហំ ។

*ព្រះមហាមុនីជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរក្នុងព្រះសទ្ធម្ម ទ្រង់ញ៉ាំងសត្វទាំឡាយឲ្យត្រេកអរផង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទេវតាទាំងឡាយជាអ្នកត្រេកអរ គប្បីត្រេកអរក្នុងព្រះអង្គ ។*

ពុ. ពុជ្ឈិត្វារិយសច្ចានិ ពុជ្ឈាបេតិ សទេវកំ

ពុទ្ធញ្ញាណេហិ សម្បន្នំ ពុទ្ធំ សម្មា នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រាស់ដឹងអរិយសច្ច ហើយ ញ៉ាំងមនុស្សនិងទេវតាទាំងឡាយ ឲ្យត្រាស់ដឹងផង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់ព្រមដោយពុទ្ធញ្ញាណទាំងឡាយ ត្រាស់ដឹងដោយប្រពៃហើយ ។*

ធោ. ធោវិតព្វំ មហាវីរោ ធោវន្តោ ជលមត្តនោ

ធោវិតោ ចាណភិនំ ចាបំ ធោតក្លេសំ នមាមិហំ ។

*ព្រះមហាវីរៈជាម្ចាស់អង្គឯណា ទ្រង់លាងមន្ទិលដែលគប្បីលាងរបស់ព្រះអង្គ ហើយទ្រង់លាងនូវមន្ទិលរបស់សត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះមហាវីរៈជាម្ចាស់អង្គនោះ ដែលមានគ្រឿងសៅហ្មងលាងជ្រះហើយ ។*

ភ. ភយមាបន្នសត្តានំ ភយំ ហាបេតិ នាយកោ

ភវេ សព្វេ អតិក្កន្តោ ភយសន្តំ នមាមិហំ ។

*ព្រះនាយកជាម្ចាស់អង្គឯណា ទ្រង់ញ៉ាំងសេចក្តីខ្លាចរបស់សត្វទាំងឡាយ ដែលមានខ្លាច ឲ្យវិនាសបាត់ទៅ ទ្រង់ឆ្លងចាកភពទាំងពួង ខ្ញុំសូមនមស្ការនូវព្រះនាយកជាម្ចាស់អង្គនោះ ដែលមានភ័យស្ងប់ហើយ ។*

គ. គហិតោ យេន សទ្ធម្មោ គតញ្ញាណេន ចាណិនំ

គហាណិយំ វរំ ធម្មំ គណ្ហាបេតុំ នមាមិហំ។

*ព្រះសទ្ធម្មដែលព្រះពុទ្ធជាម្ចាស់អង្គឯណា មានព្រះញាណដល់ព្រមត្រាស់ទុកហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់ញុំាងសត្វទាំងឡាយឲ្យទទួលយកនូវធម៌ ដែលគួរទទួលយកដ៏ប្រសើរ ។*

ឃ. ឃាបិតំ បវរំ ធម្មំ ឃានមោក្ខាយ ភិក្ខុនំ

ឃាសិតំ បវរេ ធម្មេ ឃានហន្តុំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់បណ្តុះនូវធម៌ដ៏ប្រសើរដល់ភិក្ខុទាំងឡាយ ដើម្បីរួចផុតចាកឃានៈគឺតណ្ហា អប់រំហើយក្នុងធម៌ដ៏ប្រសើរ កម្ចាត់ឃានៈគឺតណ្ហា ។*

តិ. តិណ្ណោ យោ សព្វចាបេហិ តិណ្ណោ សគ្គា បតិដ្ឋិតោ

តិរេ និព្វានសង្ខាតេ តិក្ខញ្ញាណំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ឆ្លងចាកបាបទាំងពួង ហើយឆ្លងចាកស្ថានសួគ៌ ទ្រង់តាំងនៅស៊ប់ក្នុងត្រើយពោលគឺព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះញាណចាស់ក្លាហើយ ។*

**ចប់ព្រះពុទ្ធគុណ ៥៦ តែប៉ុណ្ណោះ ។**

## ៤១៤

ឆប្បញ្ញាស ពុទ្ធគាថា ពុទ្ធគុណា សុគម្ភិរា
ឯតេសមានុភាវេន សោត្ថិ មេ ហោតុ សព្វទា។

*បទពុទ្ធគាថា មានអត្ថាដ៏ជ្រាលជ្រៅ*
*៥៦ នោះឯងត្រូវ ជាបទគុណនៃព្រះពុទ្ធ។*
*ដោយគុណានុភាព លោកនាថដ៏បរិសុទ្ធ*
*សូមឲ្យបានរួចផុត ចាកទុក្ខទោសគ្រោះចេញឆ្ងាយ។*
*សោត្ថិសុខសួស្តី សុខសិរីជោគទាំងឡាយ*
*រោគភ័យសូមខ្ចាត់ខ្ចាយ សូមមង្គលកើតមានហោង ។*

## ព្រះធម្មគុណ ៣៨

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ-
បស្សិកោ ឱបនេយ្យិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ស្វាក្ខាតោ ភគវតា ធម្មោ *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១ )* សន្ទិដ្ឋិកោ *ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង* អកាលិកោ *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ* ឯហិបស្សិកោ *ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើ ព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន* ឱបនយិកោ *ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា* បច្ចត្តំ វេទិតព្វោ វិញ្ញូហិ *ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។*

ស្វា. ស្វាគតន្តំ សិវំ រម្មំ    ស្វាឆយំ ធម្មទេសិតំ

ស្វាហុនេយ្យំ បុញ្ញក្ខេត្តំ   ស្វាសភន្តំ  ឆមាមិហំ ។

*ព្រះនិព្វាននោះ ជាគុណជាតគួរត្រេកអរ ដែលព្រះពុទ្ធ ជាម្ចាស់ទ្រង់បានដល់ល្អហើយ ខ្ញុំសូមនមស្ការនូវព្រះ ធម៌ជាម្ចាស់នោះ ជាធម៌ដែលព្រះពុទ្ធទ្រង់សម្តែងទុកល្អ ហើយ ព្រះសង្ឃនាំបន្តមកល្អហើយ គួរបូជាយ៉ាង ល្អ ជាបុញ្ញក្ខេត្តដ៏ប្រសើរពិត ។*

ក្ខា. ខាឧន្តោ យោ សព្វទាបំ    ខាយិតោ យោ ច មាធុរោ

ខាយន្តំ តិវិធំ លោកំ    ខាយិតន្តំ  ឆមាមិហំ ។

*ព្រះធម៌ឯណា ទំពាស៊ីគឺទម្លាយនូវបាបទាំងពួង ព្រះធម៌ដ៏ផ្អែមឯណា ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុក ហើយ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែល ទំពាស៊ីគឺគ្របសង្កត់នូវលោកទាំងបី ប្រាកដច្បាស់ ។*

តោ. តោសេន្តោ សព្វសត្តានំ    តោសេតិ ធម្មទេសនំ

តោសចិត្តំ សមិជ្ឈន្តំ    តោសិតំ  តំ ឆមាមិហំ ។

*ព្រះធម៌ឯណា ញុំាងសត្វឲ្យត្រេកអរ ហើយស្តាប់នូវ ធម្មទេសនា ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលញុំាងសត្វមានចិត្តត្រេកអរក្នុងព្រះធម៌ឲ្យចម្រើន ឲ្យរីករាយ ។*

៤១៧

ភ. ភគ្គរាគោ ភគ្គទោសោ    ភគ្គមោហោ អនុត្តរោ
ភគ្គកិលេសសត្តានំ    ភគវន្តំ នមាមិហំ។

*ព្រះធម៌ឯណា បំបាក់រាគៈ បំបាក់ទោសៈ បំបាក់ មោហៈ រកធម៌ដទៃក្រៃលែងជាងគ្មាន ខ្ញុំសូមនមស្ការ នូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីគោរពសក្ការៈរបស់ សត្វអ្នកមានកិលេសបាក់ហើយ ។*

គ. គច្ឆន្តោ រម្មកេ សិវេ    គមាបិតោ សទេវកេ
គច្ឆន្តោ ព្រហ្មចរិយេ    គច្ឆន្តំ តំ នមាមិហំ ។

*ព្រះធម៌ឯណា មានដំណើរទៅកាន់ព្រះនិព្វានដ៏គួរ រីករាយ ញ៉ាំងមនុស្ស ព្រមទាំងទេវតាឲ្យប្រព្រឹត្ត នូវព្រហ្មចរិយៈ ដំណើរទៅដល់ព្រះនិព្វាននោះ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលមាន ដំណើរទៅយ៉ាងនោះ ។*

វ. វន្តរាគំ វន្តទោសំ    វន្តមោហំ វន្តចាបកំ
វន្តំ ពាលមិច្ឆាទីនំ    វន្តគន្ថំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់ ដែលខ្ជាក់ចេញ នូវរាគៈ ទោសៈ មោហៈ បាប ល្ងង់ មិច្ឆាទិដ្ឋិ និង កិលេសជាគ្រឿងចងរឹត ។*

តា. តារេតិ សព្វសត្តានំ    តារេសិ ឱឃមំតិរំ

តារេន្តំ ឱឃសំសារំ    តារេន្តំ តំ នមាមិហំ។

*ព្រះធម៌ឯណា ញុំាងសត្វឲ្យឆ្លងចាកសង្សារវដ្ត ឆ្ពោះ
ទៅកាន់ព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ដែលញុំាងសត្វឲ្យឆ្លងចាកឱឃៈបាន ។*

ធ. ធរមានេបិ សម្ពុទ្ធេ    ធម្មំ ទេសិ និរន្តរំ

ធរេតិ អមតំ បទំ    ធរេន្តំ តំ នមាមិហំ ។

*ក៏កាលព្រះសម្ពុទ្ធគង់ធរមាននៅ បានសម្ដែងនូវ
ព្រះធម៌អស់កាលជានិច្ច ព្រះធម៌ឯណាទ្រទ្រង់ទុក
នូវបទគឺអមតៈ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ដែលទ្រទ្រង់ទុកនូវបទគឺអមតៈ ។*

ម្មោ. មោហាញ្ញោ នមន្តោ សត្តេ មោហជិតេ អការយិ

មោហជាតេ ធម្មចារី    មោហជិតំ នមាមិហំ ។

*ព្រះធម៌ឯណា ទូន្មានសត្វទាំងឡាយដែលវង្វេង
ធ្វើឲ្យជាអ្នកឈ្នះនូវភាពវង្វេងបាន ញុំាងសត្វ
អ្នកកើតមកដោយភាពវង្វេង ឲ្យប្រព្រឹត្តនូវធម៌
ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលគ្រប
សង្កត់នូវភាពវង្វេងគឺមោហៈបាន ។*

ស. សព្វសត្តតមោនុទោ    សព្វសោកវិនាសកោ

សព្វសត្តហិតក្ករោ    សព្វសន្តំ នមាមិហំ។

*ព្រះធម៌ឯណា បន្ទោបង់នូវភាពងងឹតរបស់សត្វទាំងពួង ញាំងសេចក្តីសោកទាំងពួង ឲ្យវិនាស ធ្វើនូវប្រយោជន៍ ដល់សត្វទាំងពួង ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលមានសភាពស្ងប់ត្រជាក់ដោយប្រការទាំងពួង ។*

ទិ្ឋ. ទិដ្ឋេ ធម្មេ អនុប្បត្តោ   ទិដ្ឋិកន្តារយោ លុតោ

ទិដ្ឋី ទ្វាសដ្ឋិ ជិន្នត្តោ   ទិដ្ឋិសន្តំ ឆមាមិហំ ។

*ព្រះធម៌ឯណា អ្នកមានបញ្ញាដល់ហើយតាមលំដាប់ ក្នុងទិដ្ឋធម៌ កាត់នូវទិដ្ឋិ ៦២ បាន ខ្ញុំសូមនមស្ការនូវ ព្រះធម៌ជាម្ចាស់នោះ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ឃើញ ហើយ ។*

ឋិ្ឋ. ឋិតិសីលសមាចារេ   ឋិតិតេរសធុតង្គេ

ឋិតិធម្មេ បតិដ្ឋិតំ   ឋិតធម្មំ ឆមាមិហំ ។

*ព្រះអរិយៈរមែងតាំងនៅក្នុងឋិតិធម៌គឺធម៌មាំទាំ គឺសីល សមាចារ ដែលជាឋិតិ ក្នុងធុតង្គៈ ១៣ ដែលជាឋិតិ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាគ្រឿង ដល់ឋិតិ ។*

កោ. កោកានំ រាគំ បីឡេតិ   កោធោបិ បជិហាញ្ញតិ

កោកានំ បូជិតោ លោកេ កោកានន្តំ ឆមាមិហំ ។

*ព្រះធម៌ឯណា ដែលបៀតបៀននូវរាគៈរបស់សត្វ*

ទាំងឡាយ ដែលប្រកាន់យក សូម្បីសេចក្តីក្រោធ
ក៏កម្ចាត់ចេញបាន ជាធម៌ដែលសត្វប្រកាន់យក
បូជាក្នុងលោកនេះ ខ្ញុំសូមនមស្ការនូវព្រះធម៌ជា
ម្ចាស់នោះ ដែលជាទីបំផុតនៃការប្រកាន់យក ។

អ. អគ្គោ សេដ្ឋោ វរធម្មោ   អគ្គបញ្ញោ បតុជ្ឈតិ
អគ្គំ ធម្មំ សុនិបុណំ   អគ្គធ្លំ វ នមាមិហំ។

ព្រះធម៌ជាគុណជាតលើសប្រសើរបំផុត អ្នកមាន
បញ្ញាដ៏ប្រសើរ រមែងត្រាស់ដឹងនូវធម៌ដ៏ប្រសើរ
ល្អិតសុខុមបាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ដែលជាធម៌ដ៏ប្រសើរ ។

កា. ការេន្តោ យោ សិវំ រដ្ឋំ   ការេតិ ធម្មចារិយេ
កាតព្វសុសិក្ខាកាមេ   ការេន្តធ្លំ នមាមិហំ។

ព្រះធម៌ឯណា កាលញុំាងសត្វឲ្យធ្វើសិវរាជ្យគឺព្រះនិព្វាន
រមែងញុំាងអ្នកប្រព្រឹត្តធម្មចរិយា ឲ្យធ្វើ ខ្ញុំសូមនមស្ការ
នូវព្រះធម៌ជាម្ចាស់នោះ ដែលញុំាងសត្វអ្នកប្រាថ្នាក្នុង
ការសិក្សាដ៏ល្អ ដែលខ្ជួនគប្បីធ្វើ ឲ្យធ្វើនូវសិវរាជ្យនោះ។

លិ. លិតោ យោ សព្វទុក្ខានិ   លិខិតោ បិដកត្តយេ
លិម្បិតេបិ សុវណ្ណេន   លិតធ្លំបិ នមាមិហំ។

ព្រះធម៌ឯណា បំបាត់នូវទុក្ខទាំងពួង ជាធម៌ចារទុក

*ក្នុងព្រះត្រៃបិដក បិទហើយដោយទឹកមាសដ៏ស្អាត ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលបានបំបាត់នូវទុក្ខពិត ។*

កោ. កោ សទិសោវ ធម្មេន  កោ ធម្មំ អភិបូជយិ

កោ វិន្ទតិ ធម្មរសំ  កោសលន្តំ នមាមិហំ។

*អ្វីស្មើដោយព្រះធម៌ (មានឬ) អ្នកណាបូជាព្រះធម៌ដ៏ក្រៃលែង អ្នកណាបានជួបនូវធម្មរស ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលធ្វើបុគ្គលឲ្យឈ្លាស ។*

ឃ. ឃសតិ ពុទ្ធវចនំ  ឃសតិ ធម្មមុត្តមំ

ឃសតិ សគ្គមោក្ខញ្ច  ឃសតន្តំ នមាមិហំ។

*បណ្ឌិតរមែងស្វែងរកព្រះពុទ្ធវចនៈ រមែងស្វែងរកព្រះធម៌ដ៏ខ្ពង់ខ្ពស់ និងរមែងស្វែងរកនូវសួគ៌និងព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីស្វែងរកនៃបណ្ឌិត ។*

ហិ. ហិនេ ឋានេ ន ជាយន្តេ  ហិនេ ជោមេតិ សុគតី

ហិនេ មោហាសមំ ជាលំ  ហិនន្តំបិ នមាមិហំ។

*ព្រះធម៌ឯណា មិនញ៉ាំងសត្វឲ្យកើតក្នុងទីដ៏ថោកទាប ញ៉ាំងមនុស្សទាប (ដែលធ្វើល្អ) ឲ្យរីករាយក្នុងសុគតិ លះសំណាញ់គឺកិលេស ស្មើដោយមោហៈបាន ខ្ញុំសូម*

*នមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីបំផុតនៃ
ហីនធម៌ ។*

ប.	បកតោ ពោធិសម្ភារេ	បសដ្ឋោ យោ សទេវកេ

បញ្ញាយ ន សមោ ហោតិ បសដ្ឋោ តំ នមាមិហំ។

*ព្រះធម៌ឯណា ទ្រង់សាងសន្សំពោធិសម្ភារទើបបានជាអ្នក
ប្រសើរបំផុតក្នុងមនុស្ស ព្រមទាំងទេវតា វត្ថុដូចផង់ស្មើ
ដោយបញ្ញាមិនមាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ។*

ស្សិ.	សីលេន សុគតឹ យន្តិ	សីលេន ភោគសម្បទា

សីលេន និព្វុតឹ យន្តិ	សីលធម្មំ នមាមិហំ ។

*សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល
សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល
សត្វទាំងឡាយទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានបាន
ក៏ព្រោះសីល ខ្ញុំសូមនមស្ការនូវព្រះធម៌គឺសីលជា
ម្ចាស់នោះ ។*

កោ.កោ យោ អគ្គបុញ្ញោ ពុទ្ធោ	កោធជហំ អធិគច្ឆតិ

កោ ធម្មញ្ញូ វិជានាតិ	កោធវន្តំ នមាមិហំ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ជាអ្នកមានបុណ្យដ៏ប្រសើរ
ទ្រង់ត្រាស់ដឹងនូវធម៌ ដែលលះសេចក្តីក្រោធបាន*

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ដឹងច្បាស់នូវធម៌ ខ្ញុំ
សូមនមស្ការនូវព្រះធម៌នោះ ដែលខ្ជាក់ចោលនូវ
សេចក្តីក្រោធបាន ។

ឱ. ឱភតោ សព្វកិលេសំ    ឱភញ្ចិតោ សព្វាសវំ

ឱភតោ ទិដ្ឋិជាលញ្ច    ឱភតំ តំ ឆមាមិហំ។

ព្រះធម៌ឯណា ទម្លាយកិលេសទាំងពួងបាន បំបាក់
អាសវៈទាំងពួងហើយ និងរើនូវបណ្តាញគឺទិដ្ឋិចេញ
បានហើយ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលជា
គុណជាតរើកិលេសចេញ ។

ប. បញ្ញា បសដ្ឋា លោកស្មឹ  បញ្ញា និព្វេធគាមិនី

បញ្ញាយ ឆ សមោ ហោតិ បសន្ថោ តំ ឆមាមិហំ ។

បញ្ញា ជាគុណជាតិប្រសើរក្នុងលោក បញ្ញាធ្វើឲ្យដឹង
ច្បាស់ គុណជាតិដូចផង់ស្មើដោយបញ្ញា រមែងមិនមាន
ខ្ញុំសូមនមស្ការនូវព្រះធម៌គឺបញ្ញានោះ ។

ឆ. ឆរាឆរហិតំ ធម្មំ    ឆរទេវេហិ បូជិតំ

ឆរាធំ កាមបង្កេហិ    ឆមិតន្តំ ឆមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះធម៌ ដែលជាប្រយោជន៍ដល់
មនុស្ស និងអមនុស្ស ដែលមនុស្ស និងទេវតាទាំង
ឡាយ តែងបូជា ញ៉ាំងមនុស្សទាំងឡាយ ឲ្យផុត
ចាករណ្តៅគឺកាមនោះ ។

យិ. យិដ្ឋគេ សព្វសត្តានំ យិដ្ឋគេ ទេវព្រហ្មុនា
យិដ្ឋិស្សតេ ច ចាណភីហិ យិដ្ឋន្តម្បិ នមាមិហំ ។

*ព្រះធម៌ឯណា ដែលសត្វទាំងពួងទាំងឡាយ តែងបូជា ទេវតានិងព្រហ្មក៏បូជា សត្វទាំងឡាយនឹងបូជាតៗទៅ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលសត្វទាំងឡាយ តែងបូជា ។*

កោ. កោធំ ជហាតិ ចាបកំ កោធកោធញ្ញ នាស្សតិ
កោធំ ជហោតិ ធម្មេន កោធន្ទុំ នមាមិហំ ។

*ព្រះធម៌ឯណា លះសេចក្តីក្រោធដ៏លាមកបាន និងធ្វើ មនុស្សមានសេចក្តីក្រោធ ឲ្យបាត់ក្រោធ សត្វលះ សេចក្តីក្រោធបានដោយធម៌ ខ្ញុំសូមនមស្ការនូវ ព្រះធម៌ ដែលបន្ទោបង់នូវសេចក្តីក្រោធបាន ។*

ប. បបញ្ចាភិរតា បជា បជហិតា ចាបកា ចយោ
បប្បោតិ សោតិវិបុលោ បជ្ជោតន្តំ នមាមិហំ ។

*ពួកសត្វត្រេកអរក្រៃលែងក្នុងបបញ្ចធម៌ (គឺតណ្ហា មានះ និងទិដ្ឋិ) បាបធម៌ទាំងឡាយនោះ ដែលធម៌ ណាលះបានហើយ អ្នកណាបានដល់ធម៌នោះ អ្នក នោះ ជាវិបុលដ៏ធំទូលាយ ខ្ញុំសូមនមស្ការនូវ ព្រះធម៌នោះ ដែលមានរស្មីពន្លឺច្បាស់ ។*

ចុ. ចរិត្វា ព្រហ្មចរិយំ ចត្តាសវោ វិសុជ្ឈតិ

ចជាបេន្តំ វ ទានេន ចជន្តន្តំ នមាមិហំ ។

*បុគ្គលលះអាសវៈបាន ព្រោះប្រព្រឹត្តព្រហ្មចរិយៈ រមែងបរិសុទ្ធ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលជាសភាពលះ ញុំាងសត្វឲ្យលះដោយការឲ្យទាន ។*

តំ. តនោតិ កុសលំ កម្មំ តនោតិ សព្វីរិយំ

តនោតិ សីលសមាធឹ តនន្តំ វ នមាមិហំ ។

*ព្រះធម៌ឯណា ផ្សាយនូវកុសលកម្ម ពង្រីកនូវសេចក្តីព្យាយាម ដើម្បីលះបាប ផ្សាយសីល សមាធិ (និងបញ្ញា) ឲ្យចេញទៅ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលផ្សាយចេញទៅ មិនមានការបិទបាំង ។*

វេ. វេរានិបិ ន ពន្ធន្តិ វេរំ តេសូបសម្មតិ

វេរំ វេរេន វេរានិ វេរសន្តំ នមាមិហំ ។

*នរជនណាមិនចងពៀរទុក ពៀររមែងស្ងប់រម្ងាប់ទៅ ពៀររមែងប្រព្រឹត្តទៅ ព្រោះការចងពៀរ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលស្ងប់នូវពៀរ ។*

ទិ. ទីឃាយុកោ ពហុបុញ្ញោ ទីឃរត្តំ មហព្វលោ

ទីឃសុខេន បុញ្ញេន ទីឃរត្តំ នមាមិហំ ។

*ព្រះធម៌ជាសភាពមានអាយុវែង មានបុណ្យច្រើន មាន*

*កម្លាំងខ្លាំង អស់កាលជាអង្វែង ខ្ញុំសូមនមស្ការនូវ ព្រះធម៌នោះ ដែលអស់កាលជាអង្វែង ដោយបុណ្យ ឲ្យកើតសុខជាយូរអង្វែង ។*

ត. តតោ ទុក្ខា បមុញ្ចន្តោ   តតោ មោចេតិ បាណិនោ

តតោ រាគាទិក្លេសេហិ   តតោ មោក្ខំ នមាមិហំ ។

*ព្រះធម៌ឯណា ជាធម៌នាំឲ្យរួចផុតចាកទុក្ខ ញ៉ាំងសត្វឲ្យ រួចផុតចាកទុក្ខនោះ ចាកកិលេសទាំងឡាយ មានរាគៈ ជាដើម ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលរួចផុត ចាកកិលេស និងទុក្ខនោះ ។*

ពោ. ពោធិ វិជ្ជា ឧបាគមិ   ពោធេតិ មគ្គផលានិ ច

ពោធិយា សព្វធម្មានំ   ពោធិយន្តំ នមាមិហំ ។

*វិជ្ជា ចូលដល់នូវការត្រាស់ដឹង ញ៉ាំងសត្វឲ្យត្រាស់ដឹង នូវមគ្គផលផង ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែល ជាគ្រឿងត្រាស់ដឹង ដោយត្រាស់ដឹងនូវញេយ្យធម៌ ទាំងពួង ។*

វិ. វិរតិ សព្វទុក្ខស្មា   វិរិយេនេវ ទុល្លភា

វិរិយាតាបសម្បន្នា   វិរតន្តំ នមាមិហំ ។

*ការវៀរចាកទុក្ខទាំងពួង នឹងមានបានដោយសេចក្ដី ព្យាយាមប៉ុណ្ណោះ បុគ្គលអ្នកដល់ព្រមដោយសេចក្ដី*

*ព្យាយាមដុតកម្ដៅកិលេស រកបានដោយកម្រ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលវៀរចាកទុក្ខ ។*

ញា. ញាតញ្ញាណេហិ សម្បន្នំ ញាតយោគសមប្បិតំ
ញាតញ្ញាណាឧស្សនញ្ញុ ញាតយោគំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះធម៌ ដែលដល់ព្រមដោយសព្វញ្ញុតញ្ញាណ ដែលបរិបូណ៌ដោយយោគៈគឺសេចក្ដីព្យាយាមប្រកប ដើម្បីញាណនោះ ខ្ញុំសូមនមស្ការនូវព្រះធម៌គឺសេចក្ដីដឹងច្បាស់ និងសេចក្ដីព្យាយាមនោះ ។*

ហី. ហីសន្តិ សព្វទោសានិ ហីសន្តិ សព្វភយានិ ច
ហីសមោហា បដិស្សតា ហីសន្តន្តំ នមាមិហំ ។

*អ្នកមានសតិ បៀតបៀននូវទោសៈទាំងពួងបាន បៀតបៀនភ័យទាំងពួង ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលបៀតបៀននូវទោសៈ និងភ័យ ។*

តិ. តិណ្ណោ យោ វដ្ដទុក្ខម្ហា តិណ្ណំ លោកានមុត្តមោ
តិស្សោ ភូមី អតិក្កន្តោ តិណ្ណោឱឃំ នមាមិហំ ។

*ព្រះធម៌ឯណា ឆ្លងចាកទុក្ខក្នុងវដ្ដៈទាំង ៣ ភូមិទាំង ៣ ហើយប្រសើរឧត្ដម ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលបានឆ្លងឱឃៈហើយ ។*

**ចប់ព្រះធម្មគុណ ៣៨ តែប៉ុណ្ណោះ ៕**

## ៤២៨

| | |
|---|---|
| អដ្ឋត្តឹស ធម្មគាថា | ធម្មគុណា សុគម្ភិរា |
| ឯតេសមានុភាវេន | សោត្ថិ មេ ហោតុ សព្វទា។ |
| *បទធម្មគាថា* | *មានអត្ថាដ៏ជ្រាលជ្រៅ* |
| *៣៨ នោះឯងត្រូវ* | *ធម្មគុណនៃព្រះពុទ្ធ។* |
| *ដោយគុណានុភាព* | *ធម្មធាតុដ៏បរិសុទ្ធ* |
| *សូមឲ្យបានរួចផុត* | *ចាកទុក្ខទោសគ្រោះចេញឆ្ងាយ។* |
| *សោត្ថិសុខសួស្តី* | *សុខសិរីជោគទាំងឡាយ* |
| *រោគភ័យសូមខ្ចាត់ខ្ចាយ* | *សូមមង្គលកើតមានហោង។* |

# ព្រះសង្ឃគុណ ១៤

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃ ជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។*

សុ. សុទ្ធសីលេន សម្បន្នោ សុជុ យោ បដិបន្នកោ
សុន្ទរោ សាសនករោ សុន្ទរន្តំ នមាមិហំ ។
*ព្រះសង្ឃឯណា ដល់ព្រមដោយសីលដ៏បរិសុទ្ធ ជាអ្នកបដិបត្តិដ៏ល្អ ជាអ្នកធ្វើតាមពាក្យបង្រៀនដ៏ល្អ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកដ៏ល្អ ។*

ប. បដិសម្ភិទប្បត្តោ យោ បសដ្ឋោ វ អនុត្តរោ
បញ្ញាយ ឧត្តរោ លោកេ បសដ្ឋន្តំ នមាមិហំ ។
*ព្រះសង្ឃឯណា ជាអ្នកសម្រេចនូវបដិសម្ភិទា ដែលបណ្ឌិតសរសើរហើយដោយពិត ជាអ្នកប្រសើរដោយបញ្ញា ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលប្រសើរក្នុងលោក ។*

ដិ. តិត្ថការជិតោ សង្ឃោ តិត្ថោ ធីរោ វ សាសនេ
តិត្ថិយា ពុទ្ធវចនេ តិត្ថន្តំបិ នមាមិហំ ។

*ព្រះសង្ឃឯណា ឈ្មោះលទ្ធិផ្សេងៗ ជាគ្រូអ្នកមានបញ្ញា ក្នុងសាសនាពិត ជាកំពង់ក្នុងព្រះពុទ្ធវចនៈ ខ្ញុំសូម នមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ទុកដូចជាកំពង់ ។*

ប. បសដ្ឋោ ធម្មគម្ភីរោ បញ្ញាវា ច អវង្កតោ

បស្សន្តោ អត្ថធម្មញ្ច បសដ្ឋំបិ នមាមិហំ ។

*ព្រះសង្ឃឯណា ទ្រទ្រង់នូវធម៌ដ៏ជ្រៅ គួរឲ្យសរសើរ មានប្រាជ្ញានិងស្មោះត្រង់ ឃើញអត្ថ ឃើញធម៌ ខ្ញុំ សូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលគួរ សរសើរដោយពិត ។*

ន្នោ. នោ ចេតិ កុសលំ កម្មំ នោ ច បាបំ អការយិ

នោនតំ ពុជ្ឈតិ ធម្មំ នោឌិសន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា មិនធ្វើនូវអំពើជាកុសល និងមិនធ្វើ នូវបាប គឺលះទាំងបុណ្យទាំងបាប ដឹងនូវធម៌ដែល មិនគ្រោតគ្រាត ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់ នោះ ដែលមិនមានសត្រូវជាមួយអ្នកណា ។*

ភ. ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ ច បាណិនំ

ភញ្ជកោ សព្វក្លេសានំ ភញ្ជន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា ជាអ្នកបំបាក់រាគៈ បំបាក់ទោសៈ បំបាក់មោហៈ និងជួយបំបាក់កិលេសទាំងពួងរបស់*

*សត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់
នោះ ដែលមានកិលេសបំបាក់ហើយ ។*

គ. គច្ឆន្តោ លោកិយំ ធម្មំ គច្ឆន្តោ លោកុត្តរម្បិ
គតោយេវ កិលេសេហិ គមិតន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា កាលដល់លោកិយធម៌ និងលោកុត្តរធម៌
ជាអ្នកចេញចាកគ្រឿងសៅហ្មងទាំងឡាយ ហើយទៅ
ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលចេញចាក
គ្រឿងសៅហ្មងហើយ ។*

វ. វណ្ណេតិ កុសលំ ធម្មំ វណ្ណេតិ សីលសម្បទំ
វណ្ណេតិ សីលរក្ខិតំ វណ្ណិតន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា សរសើរកុសលធម៌ សរសើរការដល់
ព្រមនៃសីល សរសើរអ្នករក្សាសីល ខ្ញុំសូមនមស្ការនូវ
ព្រះសង្ឃជាម្ចាស់នោះ ដែលសរសើរនូវធម៌គួរសរសើរ។*

តោ. តោសេន្តោ ទេវមនុស្សេ តោសេន្តោ ធម្មទេសយិ
តោសេតិ ទុដ្ឋចិត្តេបិ តោសេន្តន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា ញុំាងទេវតានិងមនុស្សទាំងឡាយ ឲ្យ
ត្រេកអរក្នុងធម៌ សំដែងធម៌គួរពេញចិត្តដល់អ្នកស្តាប់
ញុំាងមនុស្សសូម្បីមានចិត្តប្រទូស្ត ឲ្យត្រឡប់ត្រេកអរ
ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលញុំាង
ទេវតានិងមនុស្សឲ្យត្រេកអរ ។*

សា. សាសនំ សម្បជិច្ចន្នោ   សាសន្តោ សិវគាមិនី

សាសនមនុសាសន្តោ   សាសនន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា ទទួលនូវព្រះសាសនាទុក ណែនាំ*
*នូវផ្លូវទៅព្រះនិព្វាន បង្រៀននូវព្រះសាសនា (ដល់*
*មនុស្ស និងទេវតា) ខ្ញុំសូមនមស្ការនូវព្រះសង្ឃជា*
*ម្ចាស់នោះ ដែលណែនាំបង្រៀន ។*

វ. វន្តរាគំ វន្តទោសំ   វន្តមោហំ សុទិដ្ឋិកំ

វន្តញ្ញុ សព្វថាថានិ   វន្តក្លេសំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់ ដែលមានសេចក្តី*
*ឃើញដោយប្រពៃ ខ្ជាក់ចោលនូវរាគះ ទោសះ មោហះ*
*និងកិលេសបាបធម៌ទាំងពួង ។*

ក. ការោន្តោ សីលសមាធឹ   ការោន្តោ សារមត្តនោ

ការោន្តោ កម្មដ្ឋានានិ   ការោន្តន្តំ នមាមិហំ ។

*ព្រះសង្ឃឯណា បំពេញនូវសីល សមាធិ ធ្វើសារះ*
*ដល់ខ្លួន ធ្វើនូវកម្មដ្ឋានផ្សេងៗ ខ្ញុំសូមនមស្ការនូវ*
*ព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកធ្វើ ។*

សំ. សំសារេ សំសរន្តានំ   សំសារតោ វិមុត្តិ សោ

សំសារទុក្ខា មោចេសិ   សំសុទ្ធន្តំ នមាមិហំ ។

*កាលសត្វទាំងឡាយ កំពុងត្រាច់ចរក្នុងសង្សារវដ្ត*
*ព្រះសង្ឃរួចផុតចាកសង្សារវដ្តហើយ ហើយជួយ*

*សត្វទាំងឡាយ ឲ្យរួចផុតចាកសង្សារវដ្តផងដែរ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកបរិសុទ្ធព្រម ។*

យោ. យោរទុក្ខក្ខយំ កត្វា　　យោសាបេតិ សុរំ នរំ
យោសយិ បិដកត្តយំ　　យោសកន្តំ ឆមាមិហំ ។

*ព្រះសង្ឃឯណា ធ្វើនូវការអស់ទៅនៃទុក្ខដែលគួរឲ្យខ្លាច ហើយញុំាំងមនុស្ស និងទេវតាឲ្យប្រកាសព្រះត្រៃបិដក ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកប្រកាស (នូវព្រះត្រៃបិដក) ។*

**ចប់ព្រះសង្ឃគុណ ១៤ តែប៉ុណ្ណោះ ៚**

ចតុទ្ទស សង្ឃគាថា　　សង្ឃគុណា សុគម្ភិរា
ឯតេសមានុភាវេន　　សោត្ថិ មេ ហោតុ សព្វទា។

*បទសង្ឃគាថា　　មានអត្ថាដ៏ជ្រាលជ្រៅ*
*១៤ នោះឯងត្រូវ　　សង្ឃគុណដ៏ហ្មត់ចត់។*
*ដោយគុណានុភាព　　សង្ឃទាយាទដ៏បរិសុទ្ធ*
*សូមឲ្យបានរួចផុត　　ចាកទុក្ខទោសគ្រោះចេញឆ្ងាយ។*
*សោត្ថិសុខសួស្តី　　សុខសិរីជោគទាំងឡាយ*
*រោគភ័យសូមខ្ចាត់ខ្ចាយ　　សូមមង្គលកើតមានហោង។*

ឥតិបិសោរតនមាលា និដ្ឋិតា។

# នមក្ការបាលី-ប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

*វិកិរិយានមស្ការថ្វាយបង្គំ (នៃខ្ញុំព្រះករុណា) ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

[១] សុគតំ សុគតំ សេដ្ឋំ     កុសលំកុសលំ ជហំ

អមតំ អមតំ សន្តំ     អសមំ អសមំ ទទំ។

[២] សរណំ សរណំ លោកំ     អរណំ អរណំ ករំ

អភយំ អភយំ ឋានំ     នាយកំ នាយកំ នមេ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់ស្ដេចយាងទៅដ៏ល្អ ទ្រង់ត្រាស់ដ៏ល្អ ទ្រង់ជាអ្នកដ៏ប្រសើរ ទ្រង់លះនូវកុសល និងអកុសល ទ្រង់វៀរចាកសេចក្ដីស្លាប់ ទ្រង់ទម្លុះដល់អមតនិព្វាន ទ្រង់ជាអ្នកស្ងប់ មិនមានអ្នកណាមួយ ស្មើដោយព្រះអង្គ ទ្រង់ប្រទាននូវវត្ថុដែលគ្មានអ្វីដូច ទ្រង់ជាទីពឹង ទ្រង់ជាទីរឭករបស់សត្វលោក ទ្រង់មិនមានកិលេស ទ្រង់ធ្វើភាពមិនមានកិលេស ទ្រង់មិនមានភ័យ ទ្រង់នាំទៅកាន់ឋានៈមិនមានភ័យ ទ្រង់នាំសត្វទៅកាន់ព្រះនិព្វាន ។*

[៣] នយនសុភគកាយង្គំ

មធុរវរសរោបេតំ

អមិតគុណគណាធារំ

ទសពលមតុលំ វន្ទេ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ទ្រង់មានអង្គនៃព្រះវរកាយដ៏ស្រស់*
*ស្អាត មានព្រះសូរសៀងដ៏ពីរោះ*
*គួរស្តាប់ ទ្រទ្រង់ទុកនូវគុណរាប់*
*ប្រមាណមិនបាន មានកម្លាំង ១០*
*ប្រការ មិនមានអ្នកណាដូច ។*

[៤] យោ ពុទ្ធោ ធិតិមាញ្ញធារកោ

សំសារេ អនុភោសិ កាយិកំ

ទុក្ខំ ចេតសិកញ្ច លោកតោ

តំ វន្ទេ នរទេវមង្គលំ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់*
*មានសមាធិ ទ្រទ្រង់នូវអរហត្តផល*
*ទ្រង់ប្រសព្វទុក្ខក្នុងសង្សារវដ្ត ព្រោះ*

៤៣៦

តែសត្វលោក ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់ជាមង្គល
របស់មនុស្សនិងទេវតា ។

[៥] ពាត្តឹសតិលក្ខណាចិត្រទេហំ
ទេហជ្ជុតិនិគ្គតបជ្ជលគ្គំ
បញ្ញាធិតិសីលគុណោឃវិន្ធុំ
វន្ទេ មុនិមន្តិមជាតិយុត្តំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ដែលមានព្រះវរកាយដ៏ស្រស់ស្អាត
ដោយព្រះលក្ខណៈ ៣២ ប្រការ
មានព្រះរស្មីដ៏រុងរឿង ផ្សាយចេញ
ពីព្រះវរកាយ ទ្រង់បាននូវពួកនៃ
គុណ គឺបញ្ញា សមាធិ សីល
ទ្រង់ជាព្រះមុនី មានព្រះជាតិចុង
ក្រោយបំផុត។

[៦] ចាគោទយំ ពាលទិវាករំវ
មជ្ឈេ យតីនំ លលិតំ សិរីហិ

៤៣៧

បុណ្ណិន្ទុសង្កាសមុខំ អនេជំ

វន្ទាមិ សព្វញ្ញុមហំ មុនិន្ទំ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ប្រៀបដូចដួងអាទិត្យមានរស្មីឧទ័យ*
*រះពេលព្រលឹម ទ្រង់វិលាសដោយ*
*ព្រះសិរីទាំងឡាយ ក្នុងកណ្តាលនៃ*
*ពួកភិក្ខុ មានព្រះភក្ត្រដូចព្រះចន្ទពេញ*
*វង់ ទ្រង់ប្រាសចាកតណ្ហា ទ្រង់ដឹងសព្វ*
*គ្មានសល់ចន្លោះ ជាព្រះមុនិន្ទ ។*

[៧] ឧបេតបុញ្ញោ វរពោធិមូលេ

សសេនមារំ សុគតោ ជិនិត្វា

អពោជ្ឈិ ពោធឹ អរុណោទយម្ហិ

នមាមិ តំ មារជិនំ អភង្គំ។

*ព្រះសុគតជាម្ចាស់អង្គឯណា*
*ទ្រង់សម្បូរណ៍ដោយបុញ្ញាធិការ*
*ទ្រង់ឈ្នះមារាធិរាជ ព្រមទាំងសេនា*
*ក្នុងគល់ពោធិព្រឹក្ស បានត្រាស់*
*ដឹងនូវពោធិញ្ញាណ ក្នុងពេល*

*អរុណារះ ខ្ញុំសូមនមស្ការនូវព្រះ*
*សុគតជាម្ចាស់អង្គនោះ ទ្រង់*
*ឈ្នះមារហើយ ដែលមារបំបាក់*
*មិនបាន ។*

[៨] រាគាទិឆេទាមលញាណខគ្គំ

សតីសមញ្ញាផលកាភិគាហំ

សីលោឃលង្ការវិភូសិតំ តំ

នមាមិភិញ្ញាវរមិទ្ធុបេតំ៕

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ទ្រង់កាន់នូវព្រះខ័ន គឺព្រះញាណ*
*កាត់នូវមន្ទិលគឺកិលេស មានរាគៈ*
*ជាដើម ទ្រង់កាន់នូវខែល ឈ្មោះ*
*ថា សតិយ៉ាងមាំ ទ្រង់ប្រដាប់ដោយ*
*គ្រឿងប្រដាប់ គឺសីល ។*

[៩] ទយាលយំ សព្វធិ ទុក្ករំ ករំ

ភវណ្ណវាតិក្កមមគ្គតំ គតំ

តិលោកនាថំ សុសមាហិតំ ហិតំ

សមន្តចក្ខុំ បណមាមិ តំមិតំ៕

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ទ្រង់មហាករុណាគុណ ទ្រង់ធ្វើ
នូវវត្តដែលធ្វើដោយកម្រ គ្រប់ៗ
អត្តភាព កន្ទង់ផុតមហោស្រព គឺ
ភព ទ្រង់ដល់នូវភាវៈដ៏ប្រសើរ
ទ្រង់ជាទីពឹងរបស់លោកទាំង ៣
ទ្រង់មានសមាធិល្អ ទ្រទ្រង់សមាធិ
ដ៏ល្អ ទ្រទ្រង់នូវប្រយោជន៍ ទ្រង់
មានសមន្តចក្ខុ មានព្រះគុណ មិន
អាចកំណត់បាន ។

[១០] តហឹ តហឹ ចារមិសញ្ចយំ ចយំ
គតំ គតំ សត្ថិ សុខប្បទំ បទំ
ឆរានរានំ សុខសម្ភវំ ភវំ
ឆមានមានំ ជិនបុង្គវំ គវំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ទ្រង់ជាទីប្រជុំនៃបារមី ទ្រង់កសាង
បារមីក្នុងអត្តភាពនោះៗ ទ្រង់ជា
អ្នកដែលសប្បុរសចូលមករក

ទ្រង់ដល់នូវព្រះនិព្វាន ដែលជាទី
តាំងនៃសេចក្តីសុខ ញុំាងហេតុនៃ
សុខឲ្យកើតដល់មនុស្ស និងទេវតា
ទ្រង់ជាព្រះជិនស្រីដ៏ប្រសើរខ្ពង់ខ្ពស់
ជាងសត្វទាំងឡាយ ។

[១១] មគ្គង្គនាវំ មុនិន្ទនាវិកោ
ឦហាធិយំ ញាណករេន គាហកោ
អារុយ្ហ យោ តារយ ពហូ ភវណ្ណវា
តារេសិ តំ ពុទ្ធមយប្បហំ នមេ។

នាយទូកដ៏ឈ្លាស គឺព្រះពុទ្ធជាម្ចាស់
អង្គឯណា ទ្រង់ឡើងកាន់នាវា គឺ
អរិយមគ្គប្រកបដោយអង្គ ៨ ទ្រង់
ប្រើព្រះហស្ត គឺញាណចាប់ច្រវា គឺ
វិរិយៈ នាំវេនេយ្យសត្វដ៏ច្រើន ឆ្លង
ចាកមហោស្រព គឺភព ដោយទូក
គឺមគ្គមានអង្គ ៨ នោះ ទ្រង់ជួយ
កម្ចាត់ទុក្ខឲ្យសព្វសត្វ ។

[១២] សមតឹសតិបារមិសម្ភរណំ

វរពោធិទុមេ ចតុសច្ចទសំ

វរមិទ្ធិគតំ នរទេវហិតំ

តិភវូបសមំ បណមាមិ ជិនំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ទ្រង់បំពេញបុណ្យបារមី ៣០ យ៉ាង
បរិបូណ៌ ទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង
៤ ទៀបគល់ពោធិព្រឹក្សដ៏ប្រសើរ
ទ្រង់បានសម្រេចនូវឫទ្ធិដ៏ប្រសើរ
ទ្រទ្រង់ទុកនូវប្រយោជន៍របស់
មនុស្សនិងទេវតា ទ្រង់ស្ងប់នូវ
ភពទាំង ៣ ទ្រង់ឈ្នះមារ ។

[១៣]សតបុញ្ញជលក្ខណិកំ វិរជំ

គគនូបមធឹ ធិតិមេរុសមំ

ជលជូបមសីតលសីលយុតំ

បថវីសហនំ បណមាមិ ជិនំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ដែលសម្បូរណ៍ដោយព្រះលក្ខណៈ

ដែលកើតដោយតេជះនៃបុណ្យបារមី
មួយរយ ទ្រង់ប្រាសចាកធូលី គឺ
កិលេស ទ្រង់មានព្រះសព្វញ្ញុតញ្ញាណ
ដូចផ្ទៃអាកាស មានសមាធិមិនញាប់
ញ័រ ដូចភ្នំសិនេរុ ប្រកបដោយសីល
ដ៏ត្រជាក់ ដូចផ្កាបទុម ដែលកើតក្នុង
ទឹក មានព្រះខន្តិគុណដូចផែនដី ទ្រង់
ឈ្នះមារហើយ ។

[១៤] យោ ពុទ្ធោ សុមតិ ទិវេ ទិវាករោវ

សោភន្តោ រតិជននេ សិលាសនម្ហិ

អាសីនោ សិវសុខទំ អទេសិ ធម្មំ

ទេវានំ តមសទិសំ នមាមិ និច្ចំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់មាន
សព្វញ្ញុតញ្ញាណដ៏ល្អ រុងរឿងដូច
ទិវាករក្នុងកណ្ដាលថ្ងៃ គង់លើ
សិលាសនៈ ញ៉ាំងសេចក្ដីត្រេកអរ
ឲ្យកើត សម្ដែងធម៌ប្រទាននិព្វានសុខ
ដល់ពួកទេវតាទាំងឡាយ (ក្នុងស្ថាន

តាវត្តិង្ស) ខ្ញុំសូមនមស្ការនូវព្រះពុទ្ធ
ជាម្ចាស់នោះ គ្មានបុគ្គលណាប្រៀប
ផ្ទឹមពុំបាន ។

[១៥]យោ ចារុបង្កជមុទុត្តលរាជិកេហិ
លោកេហិ តីហិវិកលេហិ និរាកុលេហិ
សម្បាបុណេ និរុបមេយ្យតមេវ នាថោ
តំ សព្វលោកមហិតំ អសមំ នមាមិ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជាទីពឹង
របស់សព្វសត្វ ទ្រង់ដល់ព្រមដោយភាព
ដែលលោកទាំង ៣ ប្រៀបផ្ទឹមពុំបាន មាន
ព្រះបាទទាំងគូរាបស្មើល្អ មិនវិកល មិន
វិការ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ដែលសត្វលោកទាំងពួងបូជា គ្មានបុគ្គល
ណាប្រៀបបាន ។

[១៦]ពុទ្ធំ នរានរសមោសរណំ ធិតត្តំ
បញ្ញាបទីបជុតិយា វិហតន្ធការំ
អត្ថាទិកាមនរទេវហិតាវហំ តំ
វន្ទាមិ ការុណិកមគ្គមនន្តញាណំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់ជាទីដែលមនុស្សនិងទេវតាមកប្រជុំ មានព្រះទ័យមាំទាំ ទ្រង់កម្ចាត់នូវងងឹត ដោយពន្លឺ គឺអរហត្តមគ្គញ្ញាណ ប្រាថ្នាប្រយោជន៍ដល់សត្វលោក ទ្រទ្រង់ទុកនូវប្រយោជន៍ដល់មនុស្សនិងទេវតា ទ្រង់មហាករុណាដ៏លើស មានព្រះញាណកំណត់មិនបាន។

[១៧] អខិលគុណនិធានោ យោ មុនិន្ទោបគន្ត្វា

វនមិសិបតន្ហំ សញ្ញតានំ និកេតំ

តហិមកុសលជេនំ ធម្មចក្កំ បវត្តោ

តមតុលមភិកន្តំ វន្ទេយ្យំ នមាមិ។

ព្រះមុនីជាម្ចាស់អង្គឯណា ទ្រង់មានព្រះគុណទាំងពួង ទ្រង់យាងទៅព្រៃឥសិបតនៈដែលជាទីនៅរបស់ពួកឥសីដែលសង្រួមហើយ ទ្រង់ប្រកាសធម្មចក្កដែលជាធម៌កាត់អកុសល ក្នុងព្រៃនោះ ខ្ញុំសូមនមស្ការនូវព្រះមុនិន្ទជាម្ចាស់នោះ ដែលមិនមានបុគ្គលណាដូច ដែលមនុស្សនិងទេវតាគប្បីចូលរកដែលគួរដល់ការថ្វាយបង្គំ ។

[១៨]សុចិបរិវារិតំ សុរុចិរប្បភាហិ រត្តំ

សិរីវិសាលយំ គុបិតមិន្ទ្រិយេហុបេតំ

រវិសសិមណ្ឌលប្បភុតិលក្ខណោបចិត្តំ

សុរនរប្បូជិតំ សុគតមាទរំ នមាមិ។

*ខ្ញុំសូមនមស្ការនូវព្រះសុគតជាម្ចាស់*
*ដែលមានសាវកចោមរោមហើយ មាន*
*ព្រះវរកាយរុងរឿងដោយរស្មីដ៏ស្រស់*
*ស្អាត ជាទីរងទទួលពួកនៃព្រះសិរី គឺ*
*បញ្ញានិងបុញ្ញាធិការ ទ្រង់គ្រប់គ្រងឥន្ទ្រិយ*
*មានព្រះបាទប្រដាប់ដោយកងចក្រ ដូចដួង*
*ព្រះអាទិត្យ ដូចដួងព្រះចន្ទ ដែលមនុស្សនិង*
*ទេវតាគប្បីបូជាដោយគោរព ៗ*

[១៩] មគ្គោឡុម្បេន មុហាបដិយាសាទិឧល្លោលវីចឹ

សំសារោឃំ តរិ តមភយំ ចារបត្តំ បជានំ

តាណំ លេណំ អសមសរណំ ឯកតិត្ថំ បតិដ្ឋំ

បុញ្ញក្ខេត្តំ បរមសុខទំ ធម្មរាជំ នមាមិ។

*ព្រះធម្មរាជាអង្គឯណា ទ្រង់ឆ្លងអន្លង់ទឹក គឺ*

*សង្សារវដ្ដ ដែលមានរលកតូចធំ គឺទោសៈ
មោហៈ និងតណ្ហា ដោយផែ គឺអរិយមគ្គ
ខ្ញុំសូមនមស្ការព្រះធម្មរាជាអង្គនោះ ដែល
មិនមានភ័យ ទ្រង់យាងដល់ច្រាំងហើយ
ទ្រង់ជាអ្នកគ្រប់គ្រងរក្សាពួកប្រជា ទ្រង់
ជាទីពួនចាកភ័យ ទ្រង់ជាទីពឹងមិនមាន
អ្នកណាដូច ទ្រង់ជាកំពង់នាំទៅព្រះនិព្វាន
ទ្រង់ជាទីពួកសត្វតាំងនៅ ទ្រង់ជាបុញ្ញក្ខេត្ត
ទ្រង់ប្រទានបរមសុខ ។*

[២០] កណ្ឌម្ពំមូលេ បរហិតករោ យោ មុនិន្ទោ និសិន្នោ
អច្ឆេរំ សីឃំ នយនសុភគំ អាកុលណ្ណគ្គិជាលំ
ទុដ្ឋាលទ្ធំសំ មុនិភិជហិតំ ចាដិហេរំ អកាសិ
វន្ទេ តំ សេដ្ឋំ បរមរតិជំ ឥទ្ធិធម្មេហុបេតំ។

*ព្រះមុនិន្ទអង្គណា ទ្រង់បំពេញប្រយោជន៍ដល់អ្នក
ដទៃ គង់ក្នុងបរិវេណដើមកណ្ឌម្ពព្រឹក្ស បានធ្វើ
បាដិហារ្យ ដែលព្រះមុនីទាំងឡាយមិនទ្រង់លះបង់
មានភ្លើងនិងក្រសែទឹកលាយគ្នា គួរអស្ចារ្យ រហ័ស
គួរគយគន់ កម្ចាត់សំណាញ់នៃទិដ្ឋិ ខ្ញុំសូមនមស្ការ*

*ព្រះមុនីជាម្ចាស់អង្គនោះ ដែលជាបុគ្គលដ៏ប្រសើរ ញ៉ាំងសេចក្តីត្រេកអរឲ្យកើតយ៉ាងក្រៃលែង មានឥទ្ធិគុណ ។*

[២១] មុនិន្ទក្កោ យ្វេកោ ឧទយុទយរុណោ ញាណវិត្ថិណ្ណពិម្ពោ

វិនេយ្យប្បាណោឃំ កមលកជិតំ ធម្មរំសីវរេហិ

សុពោធេសិ សុទ្ធេ តិភវកុហរេ ព្យាបិតក្កិត្តិនញ្ច

តិលោកេកចក្ខុំ ធុវមសហាធំ តំ មហេសឹ នមាមិ។

*ព្រះអាទិត្យ គឺព្រះមុនិន្ទ មួយដួង មានពន្លឺអរុណ គឺមហាករុណាឧទ័យឡើងមក មានបរិមណ្ឌល គឺសព្វញ្ញុតញ្ញាណដ៏ធំទូលាយ ញ៉ាំងផ្កាកមលៈ គឺពួកវេនេយ្យសត្វ ក្នុងស្រះ គឺភពទាំង ៣ ដ៏ថ្លាស្អាតឲ្យត្រជាក់រីករាយ គឺត្រាស់ដឹង ដោយរស្មី គឺព្រះសទ្ធម្មដ៏ប្រសើរ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យ គឺព្រះមុនិន្ទអង្គនោះ ដែលមានកិត្តិស័ព្ទផ្សាយទៅហើយ ជាដួងភ្នែកមួយដួងក្នុងលោកទាំង ៣ ដែលអត់សង្កត់នូវវត្ថុដែលលំបាក ជាអ្នកស្វែងរកបុណ្យ ។*

[២២] យោ ជិនោ អនេកជាតិយំ សបុត្តទារមង្គជីវិតម្បិ

ពោធិបេមតោ អលគ្គមានសោ អទាសិយេវ អត្ថិកស្ស

ទានបារមី តតោ បរំ អប្បិ សីលបារមាទិកម្បិ

តាសមិទ្ធិយោបយាតមគ្គតំ តមេកទីបកំ នមាមិ ។

*ព្រះជិនស្រីជាម្ចាស់អង្គឯណា ទ្រង់មានព្រះហឫទ័យ មិនជាប់ជំពាក់ ព្រោះសេចក្តីស្រឡាញ់ក្នុងពោធិញ្ញាណ ទើបបានលះនូវភរិយា ព្រមទាំងបុត្រ អវយវៈនិង ជីវិត ឲ្យដល់អ្នកត្រូវការច្រើនភពជាតិហើយ ក្រៅពីនោះនៅបំពេញទានបារមី សីលបារមីជាដើម ខ្ញុំសូម នមស្ការនូវព្រះជិនស្រីជាម្ចាស់អង្គនោះ ជាដួងប្រទីប មួយដួង ជាអ្នកដល់ភាពដ៏ប្រសើរ ព្រោះផលនៃ បារមីនោះ ។*

[២៣] ទេវាទេវាតិទេវំ និធនវបុធរំ មារភគ្គំ អភគ្គំ

ទីបំ ទីបំ បជានំ ជយវរសយនេ ពោធិបត្តំធិបត្តំ

ព្រហ្មាព្រហ្មាគតានំ វរគិរកថិកំ ចាបហីនំ បហីនំ

លោកាលោកាភិរាមំ សតតមភិនមេ តំ មុនិន្ទំ មុនិន្ទំ ។

*ខ្ញុំសូមនមស្ការនូវព្រះមុនិន្ទជាម្ចាស់ ជាទេពកំពូលលើទេព និងមិនមែនទេព ទ្រទ្រង់ទុកនូវអត្តភាពចុងបំផុត កម្ចាត់នូវ មារ ដែលគ្មានអ្នកណាកម្ចាត់បាន ទ្រង់ទ្រោលប្រទីបឲ្យពពួក សត្វ ទ្រង់សម្រេចនូវពោធិញ្ញាណលើពោធិបល្ល័ង្ក ដែលជា*

ស្ថានទីឈ្នះមារ និងជាស្ថានទីគួរត្រេកអរ ទ្រង់សម្តែងធម៌ដ៏ប្រសើរដល់ព្រហ្ម ទេវតា និងមនុស្សចូលមករក ទ្រង់លះបាបបានហើយ ទ្រង់កាត់អកុសលដាច់ហើយ ជាទីត្រេកអររបស់មនុស្សលោកនិងទេវលោក ដែលជាព្រះមុនិន្ទ ។

[២៤] ពុទ្ធោ និគ្រោធពិម្ពោ មុទុករចរណោ ព្រហ្មឃោសេណិជង្ឃោ
កោសច្ឆាទង្គជាតោ បុនរបិ សុគតោ សុប្បតិដ្ឋិតបាទោ
មូទោទាតុណ្ណលោមោ អថមបិ សុគតោ ព្រហ្មុជុគ្គត្តភាវោ
នីលក្ខី ទីឃបណ្ហី សុខុមមលឆវី ថោម្យរសគ្គសគ្គី ។

ព្រះពុទ្ធជាម្ចាស់ មានព្រះវរកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ មានព្រះជង្ឃា គឺស្នងរៀវមូលត្រសូល ដូចជង្ឃានៃព្រហ្ម មានព្រះអង្គាវយវៈ ដែលត្រូវលាក់កំបាំងដោយសំពត់ស្ថិតនៅក្នុងស្រោម ទ្រង់យាងទៅល្អ មានផ្ទៃព្រះបាទទាំងគូរាបស្មើល្អ មានព្រះលោមាដ៏ទន់ពណ៌មាស មានព្រះសួរស័ព្ទដ៏ពីរោះ មានព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម មានព្រះនេត្រខៀវស្រស់ មានកែងព្រះបាទវែង មានព្រះឆវីល្អិតផូរផង់រលីងស្រិល មានព្រះប្រសាទ គឺសរសៃល្អិតធ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ។

[២៥] ចត្តាលីសគ្គទន្តោ សមកលបទជោ អន្តរំសប្បបីនោ

ចក្កេនង្កិតចាទោ អវិរឡទសនោ មារជុស្សង្ខចាទោ

តិដ្ឋន្តោ នោនមន្តោភយការមុទុនា ជណ្ណុកានាមសន្តោ

វដ្តក្ខន្ធោ ជិនោ គោតុណោបខុមកោ សីហបុព្វឌ្ឍកាយោ។

*មានព្រះទន្ត ៤០ គត់ មានព្រះទន្តស្មើគ្នា មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ មានផ្ទៃព្រះបាទប្រដាប់ដោយចក្រ មានព្រះទន្តជិតស្និទ្ធល្អ ទ្រង់ឈ្នះមារ មានព្រះបាទដូចជាអណ្តែតឡើងខាងលើដូចជាស័ង្ខ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជានុបាន មានព្រះស្មូរងមូលសម មានដួងព្រះនេត្រដូចជាភ្នែកនៃកូនគោ មានព្រះកាយពាក់កណ្តាលខាងលើ ដូចជាកាយនៃរាជសីហ៍។*

[២៦] សត្តប្បីនោ ច ធីយង្គុលិ មជ សុគតោ លោមក្វបេកលោមោ

សម្បន្នោធាតធាឋោ កនកសមតចោ ធីលមុទ្វគ្គលោមោ

សម្តុន្ធោ ចូលជិហ្វោ អជ សីហហនុកោ ជាលិកប្បាទហត្តោ

ឆាថោ ឧណ្ហីសសីសោ ឥតិគុណសហិតំ តំ មហេសឹ ឆមាមិ។

*ព្រះសុគតជាម្ចាស់ មានព្រះមំសៈគឺសាច់ ៧ អន្លើដោយបរិបូណ៌ (គឺខ្នងព្រះហស្ត ២, ខ្នងព្រះបាទ ២, ព្រះអង្សា ២, ព្រះស្មូរង ១) មានព្រះអង្គុលិវែងស្មើគ្នា មានព្រះលោមាតែ ១ សរសៃ ៗ គឺក្នុងរណ្តៅរោម ១ មានរោម ១ មានព្រះទាឋា គឺចង្កូមកែវទាំង ៤*

*សស្អាត មានស្បែកសម្បុរថ្ងៃ (លឿងភ្លឺអន្ទង់) ដូចជាសម្បុរនៃ មាស មានព្រះលោមាពណ៌ខៀវមានចុង-ងឡើងលើ ព្រះសម្ពុទ្ធ មានព្រះជិវ្ហាដ៏ធំវែងទន់ មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទ មានប្រទាក់ក្រឡាដូចជាសំណាញ់ ព្រះលោកនាថ ទ្រង់មានទលាដ៍និងព្រះសិរីរូបបរិបូណ៌ ខ្ញុំសូម នមស្ការនូវព្រះសុគត ដែលសម្បូរណ៍ដោយព្រះគុណ ដូច ពោលមកនេះ ទ្រង់ស្វែងរកនូវព្រះគុណដ៏ធំក្រៃលែង ។*

[២៧] ពុទ្ធោពុទ្ធោតិឃោសោ អតិទុលភតរោ កា កថា ពុទ្ធភាវោ

លោកេ តស្មា វិភាវី វិវិធហិតសុខំ សាធវោ បត្ថយន្តា

ឥដ្ឋំ អត្ថំ វហន្តំ សុរនរមហិតំ និព្ភយំ ទក្ខិណេយ្យំ

លោកានំ នន្ទិវឌ្ឍំ ទសពលមសមំ តំ នមស្សន្តុ និច្ចំ។

*សំឡេងប្រកាសថា ពុទ្ធោ ពុទ្ធោ ឮបានដោយកម្រក្រៃពេក នឹង បាច់ពោលទៅថ្វី ភាពជាព្រះពុទ្ធ ដូច្នោះ សាធុជនអ្នកមានបញ្ញា ប្រាថ្នាប្រយោជន៍សុខ មានប្រការផ្សេងៗក្នុងលោក ចូរនមស្ការ នូវព្រះពុទ្ធជាម្ចាស់ ដែលគួរចូលគាល់ ទ្រង់ទ្រទ្រង់ទុកនូវ ប្រយោជន៍ ដែលទេវតានិងមនុស្សនាំគ្នាបូជា ទ្រង់មិនមាន ភ័យ ជាទក្ខិណេយ្យ អ្នកញ៉ាំងសេចក្តីត្រេកអរឲ្យចម្រើន ដល់សត្វលោក អ្នកមានកម្លាំង ១០ គ្មានបុគ្គលណាស្មើ ដូចព្រះអង្គ អស់កាលជានិច្ច ។*

[២៨]បុញ្ញេនេតេន សោហំ និបុណមតិ សតោ សម្បរាយេ ច តិត្តោ
ទក្ខោ ទិដ្ឋុជ្ជុបញ្ញោ អវិកលវីរិយោ ភោគវា សំវិភាគី
តិក្ខោ សូរោ ធិតត្តោ សបរហិតចរោ ទីឃជីវី អរោគោ
ធញ្ញោ វណ្ណោ យសស្សី អតិពលវធរោ កិត្តិមា ខន្តុបេតោ។

*ដោយបុណ្យដែលកើតពីការនមស្ការនោះ សូមឲ្យខ្ញុំជាអ្នកមាន បញ្ញាសុខុម មានសតិ រីករាយក្នុងសម្បរាយភព ជាមនុស្ស ឈ្លាស ជាមនុស្សត្រង់ មានសម្មាទិដ្ឋិ មានសេចក្តីព្យាយាម មិនរួញរា ជាមនុស្សមានភោគសម្បត្តិ ជាមនុស្សចែករំលែក ជាមនុស្សមានបញ្ញាចាស់ក្លា ជាមនុស្សក្លាហាន ជាមនុស្ស មានចិត្តរឹងមាំ ប្រព្រឹត្តប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ មានអាយុវែង មិនមានរោគ មានបុណ្យ មានសម្បុរល្អ មាន យស មានកម្លាំងពលំ មានកិត្តិស័ព្ទ មានសេចក្តីអត់ធន់ ។*

[២៩]សទ្ធោ ទាតង្គុបេតោ បរមសិរិធរោ ទិដ្ឋធម្មេ វិរត្តោ
លទ្ធី កល្យាណមិត្តោ អភិរតកុសលោ បញ្ចសីលាធិរក្ខោ
អប្បិច្ឆោ អប្បកោធោ អតិវុឌ្ឍុហានយោ ឥទ្ធិមា អប្បមេយ្យោ
ចាសំសោ បេមវាចោ សុជនគុណវិទូ មាមកោ សោ ភវេយ្យំ។

*ជាមនុស្សមានសទ្ធា សម្បូរណ៍ដោយទ្រព្យសម្បត្តិ សម្រាប់ឲ្យ*

ជាទាន មានសីរីខ្ពង់ខ្ពស់ ត្រេកអរក្នុងទិដ្ឋធម៌ ជាមនុស្សល្អ មានកល្យាណមិត្រ ត្រេកអរក្រៃលែងក្នុងកុសលធម៌ អាចរក្សាសីល ៥ បាន ជាមនុស្សប្រាថ្នាតិច មានសេចក្តីក្រោធតិច មានចិត្តទៀងត្រង់ក្រៃលែង មានឫទ្ធិ មានគុណរកប្រមាណមិនបាន ជាអ្នកគួរសរសើរ ពោលបិយវាចា ដឹងគុណរបស់មនុស្សល្អ ជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនា ។

[៣០] ឥត្ថំ អសង្ខេយ្យេ ឆាជ- គុណោ លក្ខណាទីបិតេ
គាថាសុ សូចកាស្វេក- គាថម្បិ សរតេ ពុធោ។

បណ្ឌិតណា កាលបានឮគេប្រកាសគុណលក្ខណៈរបស់ព្រះលោកនាថ ដែលប្រមាណមិនបាន ដោយប្រការដូច្នេះហើយ ទ្រទ្រង់ចាំគាថា ១ គាថា ក្នុងបណ្តាគាថាទាំងឡាយបាន ។

[៣១] ចតុរាចាយមុត្តោ សោ សាធកត្ថទ្វយស្ស ច
ហាត្វុបទ្ទវជាលោ ច លាភី ហិតសុខស្ស ច។

បណ្ឌិតនោះ នឹងរួចផុតចាកអបាយភូមិទាំង ៤ នឹងជាអ្នកញុំាងប្រយោជន៍ទាំងពីរឲ្យសម្រេច នឹងជាអ្នកកម្ចាត់សំណាញ់ គឺឧបទ្រពបាន នឹងបានទទួលប្រយោជន៍ជាសុខ ។

[៣២] អធិបោ នរទេវានំ  ចតុទីបិស្សរោបិ វា

ភវេយ្យ អន្តិមេ ទេហោ  តមញ្ញំ សេតជត្តកំ។

[៣៣] ភាវនាយានមារុយ្ហ  សមមេស្សតិ សុព្វតោ

ឥមស្មឹ អត្តភាវេបិ  អរោគោ ទីឃជីវិកោ។

*នឹងជាធំក្នុងទេវតានិងមនុស្ស នឹងកើតជាស្តេចចក្រពត្តិ ជាធំក្នុងទ្វីបទាំង ៤ ក្នុងអត្តភាពចុងបំផុត នឹងជាអ្នកមានសេចក្តីប្រព្រឹត្តល្អ ឡើងកាន់យាន គឺភាវនា ដែលទ្រទ្រង់ទុកនូវស្វេតច្ឆត្រ គឺអរហត្តផលនោះ ទៅដល់ព្រះនិព្វាន សូម្បីក្នុងអត្តភាពនេះ ក៏នឹងជាមនុស្សមានអាយុវែង មិនមានរោគ ។*

[៣៤] បូជិតោ សព្វលោកេហិ  ភាវនាភិរតីមនោ

ជនប្បិយោ មនាបោ ច  កា កថាវិលធារណោ។

*ជាអ្នកមានចិត្តត្រេកអរក្នុងភាវនា ជាអ្នកដែលមនុស្សលោកទាំងពួង គោរពបូជាហើយ ជាទីស្រឡាញ់ ជាទីពេញចិត្តនៃមហាជន នឹងចាំបាច់ពោលទៅថ្វី ក្នុងការការទ្រទ្រង់ចាំគាថាបានទាំងអស់ ។*

**ចប់នមក្ការបាលី-ប្រែ ត្រឹមតែប៉ុណ្ណេះ ។**

## ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ

ឧកាសខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ
សូមយាងបារមី ម្ចាស់ថ្លៃមកគង់ នៅនាកំឡុង
ទីស្ថាននេះណា ។

ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ
ព្រះសមណគោតម បរមពុទ្ធោ ព្រះមេត្តេយ្យោ
ព្រះពោធិសត្វថ្លៃ ។

ព្រមទាំងព្រះធម៌ ជ្រាលជ្រៅបវរ ប្រសើរពេកក្រៃ
ប្រាំបីម៉ឺនបួនពាន់ ព្រះធម្មក្ខន្ធនេះនៃ របស់ព្រះជិនស្រី
ទីទៃរាល់អង្គ ។

ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្តព្រះពុទ្ធ
លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត
កាយវាចាចិត្ត ។

ដោយតេជៈខ្ញុំ លើកហត្ថបង្គំ ត្រៃរតនា
សូមកំចាត់បង់ សត្រូវនានា ទុក្ខសោកពោគា
វិនាសទៅហោង ៕

## បទថ្វាយផ្កា

យើងខ្ញុំមានចិត្តត្រេក អរពន់ពេកកើតជ្រះថ្លា
នាំគ្នាបូជាផ្កា ថ្វាយសាស្តាដោយគោរព ។
ដើម្បីយកផល្លា និងលោះលាខ្លួនចាកភព
ចាកភ័យចាកឧបទ្រព្យ ដោយសារម្ទប់បុណ្យសាសនា ។
ទើបនាំយកផ្កាឈើ មកក្រងធ្វើភួងមាលា
មានពណ៌ក្លិនផ្សេងគ្នា សូមបូជាថ្វាយព្រះពុទ្ធ ។
ព្រះធម៌និងព្រះសង្ឃ ប្រសើរអង្គសីលបរិសុទ្ធ
ត្រ័យរតន៍នេះខ្ពស់ផុត ដែលជាបុណ្យលោកទាំងបី ។
ខ្ញុំម្ចាស់ទាំងអស់គ្នា តែងកំព្រាទាំងប្រុសស្រី
ព្រាត់ប្រាស់ក្នុងលោកិយ ព្រាត់ស្វាមីព្រាត់ភរិយា ។

តែងជួបនិងឈឺចាប់ និងក្តីស្លាប់ជាធម្មតា
មានក្តីទុក្ខក្តៅផ្សា រកអ្នកណាជួយពុំបាន ។
ដោយតេជៈបូជា ភួងមាលាល្អកល្យាណ
ត្រ័យរតន៍ទាំងបីឋាន សូមឲ្យបានផុតទោសទុក្ខ ។
ផុតចាស់ ផុតឈឺចាប់ ផុតក្តីស្លាប់តទៅមុខ
សូមឲ្យខ្ញុំបានសុខ ក្នុងសម្បត្តិព្រះនិព្វាន ។
ពាក្យពោលប៉ងប្រាថ្នា ធ្វើសច្ចាប្រណិធាន
សូមមគ្គផលនិព្វាន ឲ្យខ្ញុំបានប្រាកដហោង៕

 នមោ ៨ បទ

**១-នមោ អរហតោ សម្មា- សម្ពុទ្ធស្ស មហេសិនោ**
ខ្ញុំសូមបង្គំឆ្ពោះព្រះអរហន្ត សម្ពុទ្ធកតវន្តកាលស្វែងរកធម៌
គឺពោធិញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ
**២-នមោ ឧត្តមធម្មស្ស ស្វាក្ខាតស្សេវ តេនិធ**
សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសម្តែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកជាសាសនា
**៣-នមោ មហាសង្ឃស្សាបិ វិសុទ្ធិសីលទិដ្ឋិនោ**
សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទដ្ឋិនិងសីល
ឲ្យបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ
**៤-នមោ ឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ**
សូមថ្វាយបង្គំប្រជុំត្រ័យរតន៍ ប្រារព្ធដោយបទមាន៣ប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃនេះណា ប្រសើរអស្ចារ្យថ្វីងថ្លែងពុំបាន
**៥-នមោ ឱមកាតី តស្ស តស្ស វត្ថុត្តយស្សាបិ**
សូមថ្វាយបង្គំភ្ជុំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វស្ថាន តេជះកល្យាណដោយគុណគួរគាប់
**៦-នមោ ការប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា**
សូមថ្វាយបង្គំត្រ័យរតន៍សោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកម្ចាត់ ធ្វើក្តីវិបត្តិឲ្យស្ងាត់សូន្យទៅ

៧-នមោ កាភណុភាវេន សុវត្ថិ ហោតុ សព្វទា
*សូមថ្វាយបង្គំត្រ័យរតន៍ទាំងបី សូមសុខសួស្តីកើតសព្វវេលា*
*ដោយអានុភាពធ្វើការវន្ទា គោរពបូជាព្រះត្រៃរតន៍*
៨-នមោ ការស្ស តេជេន វិជិម្ហិ ហោមិ តេជវា
*សូមថ្វាយបង្គំត្រ័យរតន៍សោភា តេជះចេស្តាចូរមានដល់ខ្ញុំ*
*ក្នុងពិធីធ្វើការថ្វាយបង្គំ តេជះបុណ្យធំចូរកើតឡើងហោង ។*

## នមោ ៣ មេ

**នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ**

**សម្មាសាមំវ ពុទ្ធស្ស ធម្មេ វិភជ្ជវាទិនោ** ។
*សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត ទ្រង់នាមភគវន្តប្រសើរបវរ*
*ព្រះអង្គមិនមានព្រះទ័យញាប់ញ័រ ដោយលោកធម៌ទាំង ៨ ឡើយ*
*ទ្រង់ត្រាស់ដឹងធម៌ដោយប្រពៃហើយ ចែកធម៌នោះឲ្យដល់សត្វទាំងពួង ។*
**នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្តតោ**
**បភេទា នវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ ។**
*សូមថ្វាយបង្គំឆ្ពោះគុណព្រះធម៌ ស្រង់សត្វនិករចេញចាកសង្សារ*
*ពោលជាធម៌មានភេទ ៩ ប្រការ ដែលសាស្តាចារ្យពោលទុកទូន្មាន*
*ព្រះសោតានោះជាប្រធាន មានព្រះនិព្វាន ជាបរិយោសាន ។*
**នមោ អរិយសង្ឃស្ស សញ្ញិត្វតស្ស សត្ថុនោ**
**កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា។**
*សូមថ្វាយបង្គំឆ្ពោះគុណព្រះសង្ឃ ប្រសើរគ្រប់អង្គជាសិស្សសាស្តា*
*ជាសង្ឃប្រតិបត្តិលះកាត់តណ្ហា ព្រះទ័យល្អថ្លាគ្មានសៅហ្មងឡើយ*
*អនុស័យកិលេសលោកលះអស់ហើយនឹងឆ្លងដល់ត្រើយគឺព្រះនិព្វាន ។*

## នមោ ៣ បញ្ចូលរួមជាមួយបទ

**នមោ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបារគុំ**
**ភវគវករំ ធម្មំ គណាញ្ញ គុណាសាគរំ។**
*សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ ប្រសើរខ្ពស់ផុតជាងសត្វក្នុងលោក*
*ព្រះអង្គមានញាណជ្រាលជ្រៅប្រាជ្ញព្រោក ហើយព្រះទ្រង់ជោគដល់ត្រើយសាគរ។*
*សូមថ្វាយបង្គំព្រះធម៌បវរ ញុំាងសត្វនិករឲ្យឆ្លងចាកភព*

សូមថ្វាយបង្គំព្រះសង្ឃជាម្ចប់ គុណាគួរគោរពដូចសាគរធំ ។
តេជានុភាពផលថ្វាយបង្គំ សូមឲ្យយើងខ្ញុំបានសុខសព្វកាល ៕

## នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

**វន្ទេ តណ្ហង្ករំ ពុទ្ធំ វន្ទេ មេធង្ករំ មុនឹ**
**សរណង្ករំ មុនឹ ទីបង្ករំ ជិនំ នមេ**
**វន្ទេ កោណ្ឌញ្ញសត្ថារំ វន្ទេ មង្គលនាយកំ**
**វន្ទេ សុមនសម្ពុទ្ធំ វន្ទេ រេវតនាយកំ**
**វន្ទេ សោភិតសម្ពុទ្ធំ អនោមទស្សឹ មុនឹ នមេ**
**វន្ទេ បទុមសម្ពុទ្ធំ វន្ទេ នារទនាយកំ**
**បទុមុត្តរំ មុនឹ នមេ វន្ទេ សុមេធនាយកំ**
**វន្ទេ សុជាតសម្ពុទ្ធំ បិយទស្សឹ មុនឹ នមេ**
**អត្ថទស្សឹ មុនឹ វន្ទេ ធម្មទស្សឹ ជិនំ នមេ**
**វន្ទេ សិទ្ធត្ថសត្ថារំ វន្ទេ តិស្សមហាមុនឹ**
**វន្ទេ ផុស្សមហាវរំ វន្ទេ វិបស្សិនាយកំ**
**សិខឹ មហាមុនឹ វន្ទេ វន្ទេ វេស្សភុនាយកំ**
**កកុសន្ធំ មុនឹ វន្ទេ វន្ទេ កោណាគមនំ ជិនំ**
**កស្សបំ សុគតំ វន្ទេ វន្ទេ គោតមនាយកំ**
**អដ្ឋវីសតិមេ ពុទ្ធា និព្វានគមនាយកំ**
**នមោ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ។**

ខ្ញុំសូមបង្គំព្រះបរមសម្ពុទ្ធ មាននាមប្រាកដព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំព្រះបរមបវរ ព្រះមេធង្ករជាសម្ពុទ្ធា ។
សូមក្រាបបង្គំប្រណម្យវន្ទា នូវព្រះភគវាព្រះសរណង្ករ
សូមថ្វាយបង្គំព្រះទីបង្ករ មានញាណបវរបារមីពោរពេញ។
សូមថ្វាយបង្គំនូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញធម៌ជាកុសល
ខ្ញុំសូមបង្គំនូវព្រះទសពល ព្រះនាមមង្គលជាសម្ពុទ្ធៈ។
ខ្ញុំសូមបង្គំប្រណម្យគារវៈ ព្រះនាមសុមនៈសម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំព្រះបរមសុគត ព្រះនាមប្រាកដព្រះរេវតៈ ។
ខ្ញុំសូមបង្គំព្រះបរមពុទ្ធៈ មានញាណសោភៈព្រះនាមសោភិត
ខ្ញុំសូមបង្គំប្រណម្យប្រណីត ឈ្មោះព្រះវិជិតអនោមទស្សី។

ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសី ចំពោះព្រះមុនីព្រះនាមបទុម
ខ្ញុំសូមឱនកាយថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទៈ។
សូមថ្វាយបង្គំព្រះបទុមុត្តរៈ មានញាណសោភៈវរពុទ្ធា
ខ្ញុំសូមបង្គំព្រះភគវា នាមសុមេធាជាព្រះសម្ពុទ្ធ ។
ខ្ញុំសូមបង្គំប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធព្រះនាមសុជាត
ខ្ញុំសូមបង្គំប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថបិយទស្សី
ខ្ញុំសូមបង្គំឆ្ពោះព្រះជិនស្រី អត្ថទស្សីបារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះធម្មទស្សី ។
ខ្ញុំសូមបង្អោនលំទោនសិរសី បង្គំជិនស្រីព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំនូវព្រះមុនីរតន៍ ព្រះនាមប្រាកដតិស្សសាស្តា ។
ខ្ញុំសូមបង្គំនូវព្រះសម្មា- សម្ពុទ្ធនាមថាផុស្សៈមុនី
ខ្ញុំសូមបង្គំប្រណម្យអញ្ជលី ឆ្ពោះព្រះមុនីព្រះនាមវិបស្សី។
សូមថ្វាយបង្គំបរមជិនស្រី ព្រះនាមសិខីសារពេជ្ជពុទ្ធា
ខ្ញុំសូមឱនកាយក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំលើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូនាមកកុសន្ធៈ
ខ្ញុំសូមបង្គំប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈកោណាគមនោ ។
ខ្ញុំសូមឱនកាយវាចាទន់ទោរ បង្គំពុទ្ធោព្រះនាមកស្សបៈ
ខ្ញុំសូមលំទោនបង្អោនសិរៈ ជាទីគារវៈព្រះនាមគោតម ។
គម្រប់ម្ភៃប្រាំបីព្រះបរម- សម្ពុទ្ធជាធំកំពូលលោកា
ទាំងត្រៃភពជាម្លប់សាខា មនុស្សសត្វទេវតាមារព្រហ្មទាំងឡាយ។
ដែលបានចូលជ្រកក្រោមម្លប់ព្រះឆាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខក្នុងឋានសួគ៌ា ឬឋានព្រហ្មានិងព្រះនិព្វាន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធានជាយាននាំសត្វ
តេជៈយើងខ្ញុំប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរតន៍គ្រប់ៗព្រះអង្គ។
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គម្ភៃប្រាំបី
ខ្ញុំសូមអានុភាពពីព្រះជិនស្រី ម្ភៃប្រាំបីព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ព្រះអង្គសម្តែង ទាំងព្រះគម្តែងសង្ឃជាសាវ័ក

សូមសុខចម្រើនកើតឡើងតាមថ្នាក់ កុំឲ្យមានអាក់រៀងរាល់ជាតា។
សូមឲ្យខ្ញុំបានដល់ឋានទេវតា ដូចក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត
មានព្រះនិព្វានជាអវសានជាតិ កុំឲ្យខ្ញុំឃ្លាតពីនិព្វានហោង។

## ពាក្យវេរសម្រាប់កឋិនចីវរ

**ឥមំ ភន្តេ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម,**

**ទុតិយម្បិ ឥមំ ភន្តេ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម,**

**តតិយម្បិ ឥមំ ភន្តេ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម ។**

**សាធុ នោ ភន្តេ សង្ឃោ, ឥមំ កឋិនចីវរំ សានិសំសំ បដិគ្គណ្ហាតុ បដិគ្គហេត្វា ច ឥមិនា ទុស្សេន កឋិនំ អត្ថរតុ, មាតាបិតូនំ គុណវន្តានំ ញាតកានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

*បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន! យើងខ្ញុំព្រះករុណាទាំងឡាយសូមវេរប្រគេននូវសំពត់កឋិនព្រមទាំងអានិសង្សលោកនេះ ចំពោះព្រះសង្ឃ សូមព្រះសង្ឃទទួលយកនូវសំពត់កឋិនព្រមទាំងអានិសង្សលោកនេះ របស់យើងខ្ញុំព្រះករុណាទាំងឡាយ លុះទទួលយកហើយ សូមក្រាលគ្រងកឋិនដោយសំពត់នេះដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម ដល់ញាតិទាំងឡាយផង ដល់យើងខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង ។*

*ជាគម្រប់ពីរដងផង ។ ជាគម្រប់បីដងផង ។*



